# មេដឹកនាំ




## ភាគ ១

## ឯកសារសម្ងាត់

# សេចក្តីថ្លែងអំណរគុណ
## (Acknowledgment)


ជាបឋមខ្ញុំសូមលើកហត្ថថ្វាយបង្គំ និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកឪពុក អ្នកម្តាយ និងជាតិខ្មែរ ជាអ្នកមានគុណដ៏លើសលុប ដែលបានផ្តល់ជីវិត ផ្តល់កំណើតអោយកូន និងខិតខំចិញ្ចឹមបីបាច់ថែរក្សាកូន។ សូមគោរពថ្លែងអំណរគុណលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ ដែលបានផ្តល់ចំណេះដឹងដល់ខ្ញុំ និងកុលបុត្រ កុលធីតាខ្មែរគ្រប់រូប។ សូមគោរពថ្លែងអំណរគុណ ព្រះតេជគុណគ្រប់ព្រះអង្គ ព្រមទាំងភរិយា និងប្អូនៗរបស់ខ្ញុំ ដែលបានជួយសម្រួលកិច្ចការ ក្នុងការចងក្រងសៀវភៅនេះ។ សូមគោរពថ្លែងអំណរគុណ អស់លោក លោកស្រី ដែលបានជួយឧបត្ថម្ភគាំទ្រ។ សៀវភៅនេះ ចងក្រងឡើង ដើម្បីឧទ្ទិសដល់អ្នកដឹកនាំ អ្នកស្នេហាជាតិ និងអ្នកជាតិខ្មែរនិយម ដែលសុខចិត្តលះបង់កំលាំងកាយ ចិត្ត រហូតដល់បូជាជីវិត ដើម្បីបុព្វហេតុការពារជាតិមាតុភូមិខ្មែរគ្រប់ជំនាន់ អោយបានគង់វង្សរហូតមកដល់បច្ចុប្បន្ននេះ។

សៀវភៅដែលខ្ញុំខិតខំចងក្រងឡើងនេះ គឺក្នុងគោលបំណងរួមចំណែកក្នុងការបណ្តុះស្មារតីជាតិនិយម និងបណ្តុះឆន្ទៈប្រជាជាតិខ្មែរអោយមានការយល់ដឹងបន្ថែមអំពី **មេដឹកនាំជាតិខ្មែរ** និងយុទ្ធសាស្ត្រដឹកនាំរបស់បណ្តាប្រទេសអភិវឌ្ឍន៍មួយចំនួន ដើម្បីទាញយកបទពិសោធន៍និងគំនិត មកអភិវឌ្ឍប្រទេសខ្មែរ អោយមានការរីកចំរើនដូចបណ្តាប្រទេសទាំងឡាយនៅលោកខាងលិច។

ខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងជួយបំភ្លឺដល់ ព្រះតេជគុណ សិស្ស និស្សិត ជំនាន់ក្រោយ និងអស់លោក លោកស្រីដែលមានបំណងចង់ក្លាយជាមេដឹកនាំដ៏ល្អ សំរាប់សង្គមជាតិខ្មែរ ឬតាមបណ្តាស្ថាប័នផ្សេងៗ។ ហើយខ្ញុំយល់ថា តាមរយៈសៀវភៅនេះ គឺជាកញ្ចក់ឆ្លុះបញ្ចាំងពីគំនិត និងបទពិសោធន៍ផ្ទាល់របស់ខ្ញុំ ដ៏តិចតួចស្តួចស្តើង មិនទាន់បានគ្រប់ជ្រុងជ្រោយនៅឡើយទេ។ ខ្ញុំរីករាយនិងទទួលយកនូវការរិះគន់ កែលម្អ គ្រប់បែបយ៉ាងអំពីលោកអ្នកអាន។

ជាចុងបញ្ចប់នេះ ខ្ញុំសង្ឃឹមថា អស់លោកអ្នកអានពិតជានិងទទួលបាននូវគំនិតយុទ្ធសាស្ត្រដឹកនាំ ដើម្បីអភិវឌ្ឍសង្គមជាតិយើងអោយមានការរីកចំរើនរុងរឿង និងធ្វើអោយខ្លួនយើងក្លាយជា **កំពូលអ្នកដឹកនាំគំរូល្អក្នុងសង្គមជាតិខ្មែរ** នាពេលអនាគត។ **“ ឱកាសកើតឡើងដោយការប្រឹងប្រែងរៀបចំ មិនមែនកើតដោយសារការចៃដន្យនោះទេ ”**

ធ្វើនៅទីក្រុងវ៉ាស៊ីនតោន

ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៧

**បណ្ឌិត ស ធម្មរង្សី**

# អារម្ភកថា

មេដឹកនាំ មានតួនាទីសំខាន់ណាស់ ក្នុងការដឹកនាំប្រទេសជាតិ សហគ្រាស ក្រុមហ៊ុន អង្គការ ឬស្ថាប័នផ្សេងៗ ដើម្បីឱយមានការរីកវិវឌ្ឍន៍ លូតលាស់ជឿនលឿនទៅមុខ។ ដូច្នេះ ដើម្បីឱយស្របទៅនឹងកាលៈទេសៈ នៃការវិវឌ្ឍន៍របស់តំបន់ និងសាកលលោក សៀវភៅមេដឹកនាំជាតិខ្មែរនេះ នឹងឆ្លុះបញ្ចាំងទាំងទ្រឹស្តី និងការអនុវត្តន៍ ដែលជាការពិសោធន៍ របស់មេដឹកនាំកំពូលៗ នៅលើលោកនេះ ។ យើងបានដកស្រង់មកចងក្រងផងដែរ នូវគំរូវីរភាព របស់វីរបុរស មហាបុរសខ្មែរ យើងយកមកគួបផ្សំ នឹងស្ថានការណ៍ ប្រវត្តិសាស្ត្រពិតនានា ដែលប្រទេសជាតិ និងខ្មែរយើងគ្រប់រូបបានហែលឆ្លងកាត់ សំរាប់ជាគំនិត ដល់ការត្រិះរិះពិចារណាប្រៀបធៀប ក្នុងការដឹកនាំប្រទេសខ្មែរ អោយរស់រានគង់វង្សជាខ្មែរ ដូចអារ្យប្រទេសនានាលើលោកនេះ។

ដើម្បីព្យាបាលជំងឺ វេជ្ជបណ្ឌិត ចាំបាច់ត្រូវស្គាល់រោគសញ្ញាពិត។ យ៉ាងណាមិញ ដើម្បីរកវិធីកែបញ្ហាសង្គមខ្មែរ យើងរាល់គ្នា ជាអ្នកដឹកនាំ មានការខ្វាយខ្វល់ ចំពោះអាយុជីវិតរបស់ប្រទេសជាតិ ត្រូវតែស្គាល់ដល់ ឬសគល់ នៃបញ្ហា សិក្សាគាស់កកាយ រកអោយឃើញការពិត ជាដើមចម។ អ្នកនិពន្ធព្យាយាមតាំងចិត្ត ជាកណ្តាល តែថា ការសិក្សារកនូវអ្វីដែលពិត រមែងប៉ះដល់តួរអង្គណាមួយ ដោយចៀសមិនរួច ដូចភាសិតខ្មែរពោលថា" *ពាក្យពិតវែងរឹង ស្រាវែងស្រើង មិនសូវជា* "។ ការសិក្សារកការពិត មិនគ្រាន់តែជាមធ្យោបាយអោយយើងអាចរកវិធីកែខៃបញ្ហាជាតិ ប៉ុណ្ណោះទេ តែនឹងជួយ អោយយើងអាចនាំមកនូវយុត្តិធម៌ ដល់អ្នកដែលបានបាត់បង់ជីវិតទៅ និងដល់សង្គមជាតិទៀតផង។ ព្រោះថា នៅក្នុងសង្គមខ្មែរយើង អ្នកចាញ់ហើយស្លាប់តែងតែខុស ឯអ្នករស់ហើយឈ្នះ ទោះមានកំហុសធ្ងន់ធ្ងរក៏វិតណា រមែងកែខ្លួនលាក់កំហុស យកត្រូវជានិច្ច។ បញ្ហាបែបនេះ កើតមានក្នុងសង្គមខ្មែរយើង ជារៀងដ៏រាបមក ដែលជាហេតុធ្វើឱយពូជសាសន៍ខ្មែរ ចុះអន់ខ្សោយស្ទើផុតពូជដូចសព្វថ្ងៃ។

ម្យ៉ាងទៀត ការចងក្រងសៀវភៅនេះ ជាឯកសារ ដើម្បីបណ្តុះគំនិត សិស្ស និស្សិត ប្រជាជាតិខ្មែរ ឱយក្លាយទៅជាមេដឹកនាំមួយដ៏ល្អមួយដោយខ្លួនឯង សំរាប់សង្គមជាតិខ្មែរ នាពេលអនាគត ក្នុងបំណងចង់អោយ មាតុភូមិយើង សម្បូរដោយមេដឹកនាំល្អៗ មានប្រសិទ្ធិភាព មានគំនិតស្នេហាជាតិពិតៗ គ្រប់ស្រទាប់នៃសង្គម។ សង្គមជាតិមួយ សម្បូរដោយមេដឹកនាំល្អគ្រប់ស្ថាប័នជាតិ នឹងធ្វើឱយសង្គមនោះ មានការរីកចំរើន ជឿនលឿនយ៉ាងប្រាកដ។ សម័យអង្គរ ជាឧទាហរណ៍ សំរាប់យើងជាខ្មែរ យកមកធ្វើការសិក្សា។ ព្រះពុទ្ធអង្គបានទូន្មាន ទុកថា " *ម្នាលភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាទាំងឡាយ សម័យកាលណាមានព្រះរាជា(មេដឹកនាំ)ល្អ សម័យនោះ នាម៉ឺនមន្ត្រីក៏ប្រកបដោយធម៌ មេឃដីខ្យល់ អាកាសធាតុក៏ល្អ ការបង្កបង្កើនផល ក៏បានផលល្អ ប្រជានិករ ក៏រស់បានសុខក្សេមក្សាន្ត ទៅតាមនោះដែរ។ ផ្ទុយទៅវិញ សម័យកាលណា មានព្រះរាជាមិនល្អ សម័យកាលនោះ នាម៉ឺនមន្ត្រីក៏មិនប្រកបដោយធម៌ មេឃដីខ្យល់អាកាសធាតុ ក៏ប្រែប្រួលមិនទៀងទាត់ នាំឱយមានទឹកជំនន់រាំងស្ងួតហួតហែងខុសប្រក្រតី ការបង្កបង្កើនផល ក៏មិនបានផលល្អ ម្ហូបអាហារសំបូរដោយជាតិពិសពុល ប្រជានិករ ក៏មានរោគាជំងឺឈឺថ្កាត់ប្លែកពីប្រកតី និងរស់ដោយការលំបាកក្រីក្រ អត់ឃ្លាន ភ័យខ្លាច ល្ងង់ខ្លៅ ថោកទាប យ៉ាប់យ៉ឺន ទៅតាមនោះដែរ* "។ ផ្អែកតាមព្រះសូត្រនេះ យើងអាចប្រៀបធៀបបានយ៉ាងងាយ ចំពោះសង្គមខ្មែរសព្វថ្ងៃនេះ ថាយ៉ាងណា? ។

អ្នកនិពន្ធ មិនហ៊ានអះអាងថាឯកសារវិភាគទានដ៏ស្តួចស្តើងនេះ ជាតំរាដ៏មានប្រសិទ្ធភាពមួយ ញុំាងអោយយើងគ្រប់គ្នាពិតជាក្លាយទៅជាអ្នកដឹកនាំខ្មែរ ដ៏ល្អនោះទាំងស្រុងបានឡើយ។ តែវាអាស្រ័យលើ ឆន្ទះរបស់យើងគ្រប់រូបក្នុងការប្រតិបត្តិ និងការដាក់ធុរៈចិត្តកាយបំរើជាតិ នោះមានក៏រិតមុតមាំប៉ុណ្ណា។ អ្នកនិពន្ធ មិនបានអធិប្បាយអោយបានក្បោះក្បាយលំអិតពីរបៀបដឹកនាំទេ គ្រាន់តែផ្តល់គំនិតគោល១ ពីរបៀបដឹកនាំ និងគ្រឹះសំខាន់១ខ្លះជាគំនិត ដល់លោកអ្នកអានយកទៅសិក្សាស្រាវជ្រាវបន្ថែម អោយបានដល់ជំរៅពុទ្ធិទៀតចុះ។ អ្វីជាគោលដៅ ក្នុងភាគទី ១ នៃសៀវភៅនេះ អ្នកនិពន្ធចង់ផ្តោតលើការបណ្តុះឆន្ទៈ ជាតិនិយម ដល់កុលបុត្រ កុលធីតាខ្មែរ អោយភ្ញាក់រលឹក គិតគូរសង្រ្គោះ ប្រទេសជាតិយើងដោយខ្លួនឯង មិនចាំបាច់ដេកចាំសង្ឃឹមបុគ្គលអស្ចារ្យ ឬរង់ចាំអ្នកមានបុណ្យណាឡើយ។ ព្រោះថាអ្នកមានបុណ្យ ដែលខ្មែរភាគច្រើន កំពុងដេកសង្ឃឹមនោះ ជាការសង្ឃឹមមេឃ សង្ឃឹមខ្យល់តែប៉ុណ្ណោះ។ នៅប្រទេសខ្មែរ ពួកមេត្រួតត្រា មិនដែលបានបណ្តុះឆន្ទះខ្មែរឱយនឹកចង់ក្លាយខ្លួនជា មេដឹកនាំ សោះឡើយ។ លើសពីនេះ គេតែងពង្វក់ខ្មែរ ឱយរស់លុះលង់ ក្នុងឧបាយកលបោកប្រាស ភូតភរ គ្មានការពិត។ ផ្ទុយទៅវិញ នៅបស្ចឹមប្រទេស គេតែងបណ្តុះលើកទឹកចិត្តពលរដ្ឋគេទាំងអស់ អោយមានចំណេះដឹង អោយមានឆន្ទៈ ធ្វើជាមេដឹកនាំ គ្រប់១គ្នា។ ប្រទេសអាមេរិក ជាឧទាហរណ៍ស្រាប់ ទើបចាប់កំណើតត្រឹមជាង ២០០ ឆ្នាំ សោះប្រទេសនេះអាចសាងខ្លួនជាមហាអំណាចត្រួតពិភពលោកនេះបាន ក៏ព្រោះតែ គេដឹកនាំប្រជាជាតិគេ តាមមាគ៌ាដែល**ប្រកាន់ការពិត(សច្ចៈ)** នេះ **និងផ្អែកលើប្រយោជន៏ជាតិ ជនរួមជាតិជាគោលធំចំបងខ្ពង់ខ្ពស់ ជាងប្រយោជន៏បុគ្គល** តាមគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ **សេរីភាព សមភាពពិត របស់ពលរដ្ឋនេះឯង គ្មានបុគ្គលណា មានបុព្វសិទ្ធនៅក្រៅច្បាប់អង្គុយលើច្បាប់ឡើយ គ្រប់១គ្នា ត្រូវតែស្ថិតនៅក្រោមច្បាប់រដ្ឋតែមួយ** ដែលខុសស្រឡះ រដ្ឋធម្មនុញ្ញខ្មែរបែរជាមាន ៥ មាត្រា ចែងថាបុគ្គលពូជពង្ស ស្ថាបន័នេះ មិនអាចប៉ះពាល់រិះគន់បានដាច់ខាត (សូមអានរដ្ឋធម្មនុញ្ញរាជាណាចក្រកម្ពុជា ជំពូកទី ២ មាត្រា ទី ៧ វគ្គខណ្ឌទី ៣)។ តើ បុគ្គលនៃ ក្រុមគ្រួសារនោះ ធ្វើអ្វីមិនខុសរហូតឬ?។ នេះជាទង្វើបង្ហៃងដាន ខ្វះការទទួលខុសត្រូវក្នុងភាពជាមនុស្ស និងរិតតែមិនសក្តិសម ជាអ្នកដឹកនាំមានទសពិតរាជធម៌នោះទៅទៀត។

ព្រះពុទ្ធបានទូន្មានប្រដៅយើងអោយរស់នៅក្នុងភាព ភ្លឺស្វាងនៃ **ពុទ្ធិ** និង**បញ្ញា** ដោយផ្អែកតាមគោលការណ៏ "**កម្មផល**" វៀរចាក **អវិជ្ជា**។ បានន័យថា មិនជឿជាតិដ៏ទៃងាយដោយខ្វះការពិចារណាតាម ហេតុ ផល ។ បើយើងធ្វើអំពើយ៉ាងណា នឹងទទួលមកវិញនូវ ផលបែបនោះ ឬអាចថា" បើយើងដាំ ពោត **ផល** បានមកវិញជាផ្លែពោត។ បើយើងមានមេត្តាដោយ ភាពល្ងង់ខ្លៅ នឹងបានផលមកវិញដូចរឿង អ្នកបរទេះនិងក្រពើដាច់ទឹក ក្នុងល្បើកខ្មែរបានប្រដៅទុកមកដូច្នោះដែរ។ ចុះបើ ស្តេច សីហនុ ដែលចិញ្ចឹមក្រពើ យួន លទ្ធផល បានមកវិញ វាដូច ខ្មែរយើងសព្វថ្ងៃនេះ។ គឺពេលយួនមានកំលាំងហក់មកខាំ ត្របាក់ក្បាលខ្មែរយ៉ាងហ្នឹង។ ម្លឹងហើយ ស្តេចនេះ នៅតែពោលទាំង ងងើលបែបឡប់១សតិ ដោយគ្មានអៀនខ្មាស់ គ្មានវិចារណញ្ញាណជាមនុស្សបន្តិចសោះ នៅចំពោះមុខហ្វូងនិស្សិត នាឆ្នាំ ១៩៩១ ឯសាលាភូមិន្ទរដ្ឋបាលក្នុងទីក្រុងភ្នំពេញថា "*ពួកសាធារណរដ្ឋចេះតែចោទថា យួន១ ខ្ញុំគ្រាន់តែជួយយួន រំដោះទឹកដីគេសោះ (រំដោះខ្មែរកម្ពុជាក្រោមពី យួនខាងត្បូង ទៅជារបស់យួនទាំងស្រុង ) ពួកសាធារណរដ្ឋចោទខ្ញុំថា ក្បត់ជាតិដែរ*"។ នេះជាសំដីលីលាបែបមនុស្សក្បត់ជាតិ ដែលសម្បជញ្ញៈជាមនុស្ស។ "(សូមចុចស្តាប់សំដី សីហនុ. ចុចស្តាប់នៅក្នុង ស៊ីឌីដែលភ្ជាប់មកជាមួយ)

D:\Kh Hist\coup-1970-a.mp3 D:\Kh Hist\coup-1970-b.mp3

ខ្មែរស្លាប់ ៣លាននាក់ មិនមែនជារឿងចៃដន្យ ឬខ្មែរត្រូវតែរងទុក្ខទោស តាមពុទ្ធទំនាយឡើយ។ តែវាជា កំហុសរបស់អ្នកដឹកនាំ គឺស្តេច សីហនុ នេះឯងយ៉ាងប្រាកដ។ ទីសដៅព្រះពុទ្ធអង្គ ស្វែងរកការត្រាស់ដឹង ដើម្បីរកផ្លូវជួយសត្វលោកអោយរួចផុតទុក្ខសោក ភាពអវិជ្ជាផ្សេងៗ។ ព្រះអង្គពុំបានដាក់ទំនាយទោសទណ្ឌ ជាតិ សាសន៍ណាឡើយ។ រឿងពុទ្ធទំនាយអាចជា កលល្បិច ខាងចិត្តសាស្ត្រមួយរបស់យួន គាត់តែងឡើងដើម្បីធ្វើអោយខ្មែរ សង្ឃឹមមេឃសង្ឃឹមផ្កាយ និងធ្វើអោយខ្មែរ អស់ជំនឿលើមាគ៌ារបស់ព្រះពុទ្ធអង្គ ដែលជាមាគ៌ាចាក់គ្រឹះក្នុងសង្គមខ្មែរ រាប់ពាន់ឆ្នាំមកហើយ និងក៏ជាមាគ៌ា ដែលធ្លាប់នាំខ្មែរអោយក្លាយជាចក្រភពមួយដ៏អស្ចារ្យ ក្រោមការដឹកនាំដ៏ឆ្លៀវឆ្លាតរបស់ ពូជពង្ស **វរ្ម័ន** ដូចជា ព្រះបាទជយ័វរ្ម័នទី៧ ជាដើម។ ដោយសារពុទ្ធសាសនានេះដែរ ដែលធ្វើអោយខ្មែរអាចឈ្នះ នឹងទំងន់ជាន់ឈ្លី ប៉ុនប៉ងរំលាយអក្សរសាស្ត្រខ្មែរ ពីអាណានិគមន៏បារាំង អោយនៅគង់វង់ សំរាប់កូនខ្មែររហូតដល់សព្វថ្ងៃ។ ជាក់ស្តែងជាងនេះ ដោយសារ ព្រះពុទ្ធសាសនានេះឯង ដែលបានធ្វើអោយយួន មិនអាចរំលាយឆន្ទះជាតិនិយមខ្មែរក្រោម បានងាយៗតាមទំនើងចិត្តវា។ មាគ៌ាផ្អែកលើ **ការពិត "សច្ចះ"** នេះហើយ ជាមាគ៌ា ខ្មែរសម័យចក្រភពអង្គរ និងអាមេរិកប្រកាន់យក។

ឱកូនខ្មែរអើយ សូមអ្នកសំលឹងមើលប្រាង្គប្រាសាទទាំងឡាយ នៅដេរដាសពាសពេញទឹកដីនៃជ្រោយសុវណ្ណភូមិនេះមានប្រាសាទអង្គរ ជាស្នូលដួងព្រលឹងរបស់ខ្មែរ ជាសក្ខីនៃ ទឹកដីចក្រភពដ៏ធំល្វឹងល្វើយ និងអតីតកាល ដ៏រុងរឿងអស្ចារ្យ គ្មានប្រៀបរបស់ខ្មែរ នាសម័យអង្គរ(ក្នុងរជ្ជកាល **ព្រះបាទជ័យវរ្ម័នទី២, សូរ្យវរ្ម័នទី១_ទី២, ជ័យវរ្ម័នទី៧**)។ តែឥឡូវនេះ គួរអោយសង្វេគហួសនិស្ស័យ ប្រាង្គប្រាសាទដែលមិនអាចកាត់ថ្លៃយ៉ាងល្អប្រណិតទាំងនេះ ត្រូវស្ថិតនៅក្រោមចោរយួនទៅវិញ នាពេលបច្ចុប្បន្ន (**សុខ គង់** អតីតទាហានយួន A50) ដែលកំពុងតែធ្វើអាជីវកម្ម លើអច្ឆរិយវត្ថុ ជាព្រលឹងដូនតាខ្មែរ តែពួកក្បត់ ហ៊ុន សែន មិនដែលនឹកខ្វល់ខ្វាយទាល់តែសោះ ទុកអោយខ្មែររស់ក្នុងអន្លង់ អត់ឃ្លាន ល្ងង់ខ្លៅ ភ័យខ្លាច។

អ្នកនិពន្ធខិតខំសរសេរ និងស្រាវជ្រាវតាមចំណេះ ដឹងបន្តិចបន្តួច ក្នុងពេលដែលរួចផុតពីគោលដៅតាមសំលាប់ របស់ឆ្កែបំរើយួន និងបក្សពួក **ហ៊ុន សែន**។ តែទោះជា រងនូវការតាមប្រមាញ់យ៉ាងណាក្តី សេចក្តីព្យាយាមចងក្រងនេះ អ្នកនិពន្ធមានបំណងតែមួយគត់ ចង់អោយកូនខ្មែរទាំងអស់ ភ្ញាក់រលឹក កុំខ្លាចរអាសេចក្តីស្លាប់ ខិតខំរៀនសូត្រ សិក្សាប្រវត្តិសាស្ត្រពិតរបស់ខ្មែរ ហើយក្រោកឈរឡើងធ្វើការតស៊ូការពារប្រទេសជាតិ កុំឱយរលាយបាត់បង់ទៅ ក្នុងដៃចោរយួនស័យសាសន៏ ដែលមានអាយ៉ង **ហ៊ុន សែន** ជាឆ្កែបំរើ។ សេចក្តីស្លាប់ មានចំពោះមនុស្សគ្រប់រូប គ្មានម្នាក់ណាអាចចៀសផុតឡើយ តែបើយើងហ៊ានលះបង់ជីវិត ហ៊ានស្លាប់ដើម្បីប្រយោជន៏ខ្មែរ ជាការស្លាប់ក្នុងកិត្តិយស។ យើងស្លាប់ពិតមែន តែកេរ្តិ៍ឈ្មោះយើង មិនស្លាប់ឡើយ នឹងនៅរស់ជាអមតៈ ក្រអូបពិរោះរណ្តំ ក្នុងចិត្តគំនិត ស្មារតី ដួងព្រលឹងអារម្មណ៏កូនខ្មែរ ជំនាន់ក្រោយ ជារាងដរាបមិនសោះសូន្យជានិច្ចគ្រប់ជំនាន់។ ខ្មែរគ្រប់រូប នឹងយកតំរាប់តាមគំរូវិរភាពដ៏ប្រពៃ ដើរតាមលំអានដ៏ល្អ របស់យើងនេះ ជាក់ជាមិនខានជារៀងរហូត។ តាមទ្រឹស្តីពុទ្ធសាសនា ជនទាំងឡាយ ដែលធ្វើទានដល់ប្រយោជន៏សាធារណៈ រមែងទទួលផលបុណ្យកុសល យ៉ាងច្រើនលើសលប់ ជាអនេកអនន្តជាងការធ្វើទាន ដោយចំពោះទៅលើបុគ្គល មានន័យថា វីរកម្មរបស់យើង ដែលបានលះបង់អាយុជីវិត ពេលវេលា ធនធាន និងសេចក្តីសុខផ្ទាល់ខ្លួន ដើម្បីការពារ ថែរក្សា ភាពរស់រានគង់វង្ស ការរីកចំរើននៃសង្គមជាតិខ្មែរ (ប្រយោជន៏សាធារណៈ) រមែងទទួលផលបុណ្យយ៉ាងឥតគណនា និងបានទៅកើតសោយសុខ យ៉ាងប្រសើរខ្ពង់ខ្ពស់ នៅអនាគតជាតិយ៉ាងប្រាកដ។ ការស្លាប់បែបនេះ ទោះជាកើតស្លាប់ ១០០ជាតិទៀត ក៏យើងជាខ្មែរ នៅតែពេញចិត្ត

ស្លាប់។ វីរបុរសខ្មែរយើង ច្រើនរាប់មិនអស់ បានបូជាជីវិត ដើម្បីការពារជាតិ ទឹកដីខ្មែរ អោយគង់វង្ស ដល់បច្ចុប្បន្ន មានជាអាទិ៍ **ព្រះបាទជយ័វរ្ម័នទី២ សូរ្យវរ្ម័នទី១-ទី២, ព្រះបាទជ័យ វរ្ម័នទី៧, អង្គ ឌួង, ឧកញ៉ា ក្រឡាហោម គង់, ឧកញ៉ា សឺន គុយ, ស៊ឹង ង៉ុកថាញ់, ប៉ាង ខាត់, ប៉ាច ឈឺន, នួន ឌួង, ប៊ុណ្ណ ច័ន្ទម៉ុល, អាចារ្យ ហែម ចៀវ, អាចារ្យ ពោរកំបោរ, សម្តេច សង្ឃរាជ ជួន ណាត, អៀវ កើស, យុត្តិវង្ស, សម សារី, ព្រាប អ៊ិន, ព្រះតេជគុណ សំ ប៊ុនធឿន**, ជាដើម។ល។

ខ្មែរភាគច្រើនមើលមិនដឹង ប្រឹងគិតមិនយល់ ខំសំគាល់ក៏មិនឃើញ បានដោយងាយឡើយ នូវកលល្បិច ខ្មៅក្រខ្វក់ ដែលយួន បានរៀបចំខំសំលាប់បំផុតពូជខ្មែរ។ ក្នុងរាជក្សត្រី **អង្គម៉ី** (១៨៣៥-១៨៤១) មេទ័ពយួន ឈ្មោះ **ទ្រឿង មិញយ៉ាង** បានប្រើវិធីក្តៅ រំលាយពូជសាសន៍ខ្មែរតែមិនបានសំរេច។ សតវត្សរ៍ទី ១៨ យួន បានប្រើស្រី ជាធ្នាក់ទាក់ស្តេច ជ័យជេដ្ឋា លេបយកទឹកដីខ្មែរក្រោមអស់មួយភាគធំ។ សតវត្សរ៍ទី២០ យួន **ហូ ជីមិញ** បានប្តូរយុទ្ធសាស្ត្រពីការប្រើវិធីក្តៅមកប្រើវិធីត្រជាក់ ដ៏ប្រកបដោយពិសពុល ដោយយកលទ្ធិកុម្មុនិស្តជាមធ្យោបាយ លេបត្របាក់ប្រទេសខ្មែរជាបន្ត។ ទសវត្សរ៍ឆ្នាំ ១៩៨០ ក្រោមលេសថា ជួយរំដោះខ្មែរ ពីរបបប្រល័យពូជសាសន៍ យួនបានឈ្លានពានទឹកដីខ្មែរ ប្លន់យកទ្រព្យសម្បត្តិខ្មែរអស់ បន្សល់ទុកតែសំបកប្រទេស។ យួន លើកបន្តុបជនកង្វាក់ **ហ៊ុន សែន** ល្មោភអំណាច ក្បត់ជាតិ អោយធ្វើការបំរើផលប្រយោជន៍វា ដើម្បីសំរេចគោលដៅចុងក្រោយ លេបបង្ហើយទឹកដីខ្មែរ ដូចយួន ធ្លាប់លេបយក ប្រទេសចំប៉ា និងដីខ្មែរកម្ពុជាក្រោមជាដើម។

កលល្បិច ដ៏ស្មុគស្មាញទាំងនេះ ត្រូវបានអាយ៉ង **ហ៊ុន សែន** កំពុងតែអនុវត្តន៏សព្វថ្ងៃតាមបញ្ជា យួនចៅហ្វាយវា។ វាប្រើគ្រប់មធ្យោបាយ ដើម្បីពង្វក់ខ្មែរ អោយងាប់ស្មារតីជាតិ នឹកស្មានថាប្រទេសជាតិ មានសន្តិភាព តែជាសន្តិភាព ស្ថិតនៅមាត់ជ្រោះមរណៈ ពូជសាសន៏ខ្មែរទាំងមូល នឹងត្រូវរលាយសាបសូន្យ។ យួន **ហ៊ុន សែន** ពង្វក់ខ្មែរឱយវក់វង្វេងនឹងថ្នាំញៀន ល្បែង ស្រីស្រា អំពើពាលាអាវ៉ាសែផ្សេងៗ ការសប្បាយ ហ៊ឺហា ងប់ងល់ នឹងមាសប្រាក់ សំភារះ បុណ្យសក្តិ មុខមាត់ អួតគ្នា។ តែជាអំនួតប្រហោងក្នុង ជាភាពភ្លើតភ្លើន នៅមាត់រណ្តៅមរណៈ។ ធ្វើឱយខ្មែរ បាត់ក្តីសង្ឃឹម បាត់ជំនឿលើសេចក្តីល្អ លើភាពត្រឹមត្រូវ លើការចេះដឹង លើគំនិតបញ្ញា ស្មារតី សមត្ថភាពខ្មែរខ្លួនឯង ដែលមាតុភូមិ ពន្ធុពង្សខ្មែរ បានផ្តល់អោយពីកំណើត។ វាញុាំងឱយខ្មែរមានតែគំនិតពឹងផ្អែកលើចោរយួន ដោយភ្លេចសេចក្តីស្លាប់ ។ វាធ្វើអោយសង្គមខ្មែរ ប្រែពីសទៅជាខ្មៅ ពីល្អទៅជាអាក្រក់ ពីចោរទៅជាឧកញ៉ា ពីភាពជាជនក្បត់ជាតិ លាភលទពណិជាអ្នកមានបុណ្យអំណាច។ ពីបាតដៃប្រឡាក់ឈាម រស់ក្នុងថ្លុកទុក្ខទារុណ្ឌខ្មែរ ស្រោបដោយស្រោមទេវតា ក្រឡៃពង្សាវតាខ្មែរ អោយប្រាសចាកការពិត ជាហេតុញុាំងអោយខ្មែរជំនាន់ក្រោយ វង្វេងវង្វាន់ រកខុសត្រូវមិនឃើញ។ កលល្បិចបែបនេះ យួនបានអនុវត្តន៏តាំងតែ សម័យរាជស្តេច សីហនុ ទី១ (ជយ័វរ្ម័នទី៩) មកម្លេះ តរហូតមកដល់នាយត្រសក់ផ្អែម (ប្រហែល សៀម ជាអ្នករៀបចំ) និងសព្វថ្ងៃនេះឯង។ សូមមេត្តាអានអានលំអិត ក្នុងសៀវភៅ **ឧស្សនវិជ្ជា នយោបាយ** របស់លោក សាស្ត្រាចារ្យ **ឡេង ណារិទ្ធ** និងស្តាប់ប្រវត្តិសាស្ត្រខ្មែរ ដែលផ្សាយដោយវិទ្យុអាស៊ីសេរី ភាគ ២២ ដល់ភាគ ២៤។

នៅទីបញ្ចប់ អ្នកនិពន្ធសូមរំលឹកដល់គុណបុព្វបុរសខ្មែរ វីរបុរស វីរះនារី ព្រលឹងអ្នកស្នេហាជាតិទាំងអស់ ដែលបានធ្វើពលិកម្មដើម្បីភាពរស់រាន គង់វង្សនៃជាតិ សាសនា ប្រជាជាតិខ្មែរទាំងអស់ ចូលមកសណ្ឋិត ក្នុងដួងព្រលឹងវិញ្ញាណកូនខ្មែរគ្រប់រូប អោយភ្ញាក់រលឹក មើលឃើញផ្លូវត្រូវ មានស្មារតីក្លាហានអង់អាចក្រោកឈរឡើងពួតដៃគ្នា ជួយសង្គ្រោះការពារ មាតុភូមិខ្មែរ ដ៏ជាទីស្រឡាញ់លើសជីវិតនៃយើង អោយរួចផុតពីក្រញុាំចោរយួន និងពួកអាយ៉ងក្បត់ជាតិ ដែលមានចេតនាយ៉ាងឃោរឃៅក្នុងការរំលោភរំលាយពូជពង្សខ្មែរ និងលេបយកទឹកដីខ្មែរ នាពេលបច្ចុប្បន្ន តាមរយៈអាណានិគមន៏យួន បែបថ្មីនេះ។

# មាតិកា


សេចក្តីថ្លែងអំណរគុណ ---------------------------------------------------------- i
អារម្ភកថា -------------------------------------------------------------------ii


## ផ្នែកទី ១


គោលការណ៍មេដឹកនាំស្នេហាជាតិខ្មែរ ---------------------------------------------១
I. យើងជាខ្មែរ ត្រូវស្គាល់អ្វីជាខ្មែរ ---------------------------------------------១
II. អ្នកស្នេហាជាតិខ្មែរពិតប្រាកដ ----------------------------------------------៦
III. គោលបំណង និងទិសដៅ ---------------------------------------------------១០
IV. សមត្ថភាព ឯកទេស និងការពិសោធន៍ច្បាស់លាស់ -----------------------------១១
V. សេចក្តីក្លាហាន ការលះបង់ និងការប្តេជ្ញាចិត្ត -------------------------------១៥
VI. សុខភាពល្អ ----------------------------------------------------------------១៦
VII. គុណធម៌ ---------------------------------------------------------------១៧
ក-ព្រហ្មវិហារធម៌ -------------------------------------------------------------១៧
១- មេត្តា-----------------------------------------------------------------១៧
២- ករុណា ---------------------------------------------------------------១៨
៣- មុទិតា ---------------------------------------------------------------១៨
៤- ឧបេក្ខា -------------------------------------------------------------១៨
ខ-ទសពិធធម៌ ----------------------------------------------------------------១៩
១- ទាន ------------------------------------------------------------------១៩
២- សីល------------------------------------------------------------------១៩
៣- បរិច្ចាគ --------------------------------------------------------------២១
៤- អាជ្ជវៈ ---------------------------------------------------------------២២
៥- មទ្ទវៈ ----------------------------------------------------------------២៤
៦- តបៈ ------------------------------------------------------------------២៤
៧- អក្កោធៈ -------------------------------------------------------------២៦
៨- អវិហឹង្សា-------------------------------------------------------------២៦
៩- ខន្តិ ------------------------------------------------------------------២៧
១០-អវិរោធនៈ-----------------------------------------------------------២៧
VIII. ធ្វើគំរូនាំមុខគេ ----------------------------------------------------------២៩
IX. ហ៊ានទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួនឯង ---------------------------------៣០

X. ឧស្សាហ៍សិក្សារៀនសូត្របន្ថែម ------------------------------------------------------------------------៣២
XI. ត្រូវសំរេចចិត្តអោយទាន់ពេលវេលា---------------------------------------------------------------------៣៣
XII-ត្រូវចេះជួយគ្នា លាក់គ្នា ការពារគ្នា ទៅវិញទៅមក-------------------------------------------------------៣៤

# ផ្នែកទី ២

សិល្បៈការដឹកនាំ ------------------------------------------------------------------------------------------------៣៦
I. ចក្ខុវិស័យ --------------------------------------------------------------------------------------------------------៣៦
១- នយោបាយវាតទឹកដីរបស់កុម្មុយនិស្តឥណ្ឌូចិន ---------------------------------------------------------------៣៦
២- របបកុម្មុយនិស្ត ហេង សំរិន ហ៊ុន សែន អាយ៉ងយួន ----------------------------------------------------------៤៩
៣- អាណានិគមន៍យួនបែបថ្មី និងជនអន្តោប្រវេសន៍យួន ----------------------------------------------------------៥១
៤- ហ៊ុន សែន គាបសង្កត់ជិះជាន់ប្រជាពលរដ្ឋខ្មែរអោយខ្សោយ ក្រីក្រ ល្ងង់ខ្លៅនិងភ័យខ្លាច ------------៥៧
ក- តើយួន ហ៊ុន សែន ធ្វើអោយខ្មែរក្រីក្រតាមវិធីណាខ្លះ? ------------------------------------------------៥៧
ខ- តើយួន ហ៊ុន សែន ធ្វើអោយខ្មែរល្ងង់ខ្លៅតាមវិធីណាខ្លះ? -----------------------------------------------៥៨
គ- តើយួន ហ៊ុន សែន ធ្វើអោយខ្មែរភ័យខ្លាចបាក់ស្បាតតាមវិធីណាខ្លះ? --------------------------------------៥៨
៥- ការសន្និដ្ឋានវាសនាអនាគតជាតិខ្មែរ-----------------------------------------------------------------------៥៩
II. គោលបំណង និងទិសដៅមេដឹកនាំជាតិខ្មែរ -----------------------------------------------------------------៥៩
III. យុទ្ធសាស្ត្រទឹក -----------------------------------------------------------------------------------------------៦០
១- ទឹកតាមនិយមន័យវិទ្យាសាស្ត្រ ---------------------------------------------------------------------------------៦០
២- ទឹកប្រដូចកម្លាំងអ្នកស្នេហាជាតិខ្មែរ------------------------------------------------------------------------៦១
៣- អត្តសញ្ញាណរបស់កម្លាំងអ្នកស្នេហាជាតិខ្មែរ ---------------------------------------------------------------៦១
៤- គុណសម្បត្តិ និងទឹកចិត្តរបស់កម្លាំងអ្នកស្នេហាជាតិខ្មែរ-------------------------------------------------៦២
៥- វិរភាពរបស់ទឹក ---------------------------------------------------------------------------------------------៦៤
៦- កំលាំងអ្នកស្នេហាជាតិខ្មែរពិតប្រាកដ -------------------------------------------------------------------------៦៤
៧- យុទ្ធសាស្ត្ររបស់ទឹកនៅក្នុងការប្រយុទ្ធ -------------------------------------------------------------------៦៥
៨- យុទ្ធសាស្ត្ររបស់ទឹកនៅក្នុងការការពារខ្លួន----------------------------------------------------------------៦៧
៩- ទឹក និងសិល្បៈសង្គ្រាម ស៊ុន ស៊ូ -----------------------------------------------------------------------------៦៧
១០-ល្បិចដ៏ល្បីល្បាញនានានៅក្នុងសង្គ្រាម -----------------------------------------------------------------------៦៨
ក- ល្បិចសំលាប់សត្រូវដោយខ្ចីដាវគេ-------------------------------------------------------------------------៦៨
ខ- ល្បិចប្តូរស្រមោល និងភាពពិត ------------------------------------------------------------------------------៧២
គ- ល្បិចទីក្រុងគ្មានមនុស្ស ---------------------------------------------------------------------------------------៧៣
ឃ-ល្បិចដកថយតាមយុទ្ធសាស្ត្រ---------------------------------------------------------------------------------៧៤

១១-បណ្ដាំព្រលឹងមេគង្គ ------------------------------------------------------------៧៥

IV. យុទ្ធសាស្ត្រ -------------------------------------------------------------------៧៦

១- គោលដៅ

ក- គោលដៅ យួន ហ៊ុន សែន--------------------------------------------------៧៨

ខ- គោលដៅមេដឹកនាំជាតិខ្មែរ -----------------------------------------------៧៨

២- វាយលុក ------------------------------------------------------------------៧៩

៣- ប្រមូលផ្ដុំ ------------------------------------------------------------------៨១

៤- កលល្បិច -------------------------------------------------------------------៨២

ក- យួនយកស្រីធ្វើផ្ទាក់ ទាក់មេដឹកនាំ -------------------------------------------៨២

ខ- ល្បិចក្ដៅធ្វើសង្គ្រាមឈ្លានពានខ្មែរ-------------------------------------------៨៤

គ- ល្បិចខ្ចីដាវសត្រូវប្រើ (យួនប្រើល្បិចអោយខ្មែរសម្លាប់ខ្មែរ)---------------------------៨៥

ឃ-ផែនការយួនសំលាប់ខ្មែរ ក្នុងរបបរាជាណាចក្រក្លែងក្លាយ ---------------------------៨៦

៥- ឯកភាពអ្នកដឹកនាំ ----------------------------------------------------------៩០

៦- សន្សំសំចៃ --------------------------------------------------------------៩១

៧- ឆ្មក់ -------------------------------------------------------------------៩១

៨- សន្តិសុខ------------------------------------------------------------------៩១

៩- ងាយស្រួល-----------------------------------------------------------------៩២

១០- ព្រមគ្នា ------------------------------------------------------------------៩៣

V. បង្កើតក្រុមការងារ -------------------------------------------------------------៩៣

១- ក្រុមការងារគឺជាមនុស្សមានឆន្ទៈតែមួយ ------------------------------------------៩៣

២- ជ្រើស តែងតាំងមនុស្សដែលមានថ្វីដៃ និងការពិសោធន៍ខ្ពស់ក្នុងការងារ ---------------------៩៤

៣- មនុស្សនៅក្នុងក្រុមការងារ ត្រូវប្ដេជ្ញាចិត្តទាំងអស់គ្នា----------------------------------៩៤

VI. ការរៀបចំ ------------------------------------------------------------------៩៥

១- ការជ្រើសរើសសមាជិក ---------------------------------------------------------៩៧

២- ភារៈរបស់សមាជិក ------------------------------------------------------------៩៧

VII. ភារៈអ្នកដឹកនាំ ---------------------------------------------------------------១០១

១- ប្រមូលពតិមាន---------------------------------------------------------------១០២

២- ធ្វើផែនការ------------------------------------------------------------------១០៣

៣- អនុវត្ត ---------------------------------------------------------------------១០៥

៤- តាមដានត្រួតពិនិត្យ ------------------------------------------------------------១០៥

៥- ត្រួតពិនិត្យលទ្ធផល------------------------------------------------------------១០៥

៦- សិក្សាឡើងវិញ ---------------------------------------------------- ១០៥
VIII. ការជួបប្រជុំ ---------------------------------------------------- ១០៦
IX. ការលើកទឹកចិត្តបុគ្គលិក ---------------------------------------------------- ១០៧
X. ការប្រាស្រយ័ទាក់ទង ---------------------------------------------------- ១០៨
XI ការកំណត់មិត្ត និងសត្រូវ ---------------------------------------------------- ១០៩
XII ការដោះស្រាយទំនាស់ ---------------------------------------------------- ១១០
XIII. ប្រភេទនៃការដឹកនាំ ---------------------------------------------------- ១១១
១- ការដឹកនាំបែបផ្តាច់ការ ---------------------------------------------------- ១១១
២- ការដឹកនាំបែបកុម្មុយនិស្ត ---------------------------------------------------- ១១២
៣- ការដឹកនាំបែបប្រជាធិបតេយ្យ ---------------------------------------------------- ១១២
៤- ការដឹកនាំបែបអនាធិបតេយ្យ ---------------------------------------------------- ១១៣
XIV. កត្តាសំខាន់ៗដើម្បីធ្វើឱ្យការដឹកនាំមានប្រសិទ្ធភាព ---------------------------------------------------- ១១៥
XV. កត្តាដែលនាំអោយបរាជ័យ ---------------------------------------------------- ១១៥
XVI. អំពើអាក្រក់ ២២ ប្រការ ដែលមេដឹកនាំជាតិខ្មែរត្រូវចៀសវៀង ---------------------------------------------------- ១២២
ឯកសារយោង ---------------------------------------------------- ១២៣

# ផ្នែកទី ១

# គោលការណ៍មេដឹកនាំស្នេហាជាតិខ្មែរ
# (Principles of Khmer Patriot Leaders)

អ្នកដឹកនាំខ្មែរ ជាជនដែលស្រឡាញ់ ជាតិ សាសនា និងប្រជាជាតិខ្មែរពិតៗ ប្តូរផ្តាច់ ថែរក្សា ការពារផលប្រយោជន៏ខ្មែរ ការពារ កសាងសង្គមជាតិខ្មែរអោយគង់វង្ស មានវិបុលភាព និងឧត្តមភាព ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ ។ មេដឹកនាំខ្មែរ ជាអ្នកមិនឈ្លក់វង្វេង នឹងអំណាច យសសក្តិ លាភសក្ការៈ ប្រយោជន៏ផ្ទាល់ខ្លួន បក្សពួក ឬអបាយមុខផ្សេងៗមានស្រី ស្រាល្បែង ថ្នាំញៀណជាដើម ។ មេដឹកនាំខ្មែរ ត្រូវតែជាជនមានឥស្សរភាព ទាំងការផ្តួចផ្តើមគំនិត ការគិត ការដឹកនាំ និងមិនស្ថិតក្រោមគំនាបបរទេសណាឡើយ ។ មេដឹកនាំខ្មែរ ត្រូវតែប្រកាន់មាគ៌ាមួយដ៏ជាក់លាក់ ក្នុងការធ្វើអោយសង្គមជាតិមានឯកភាពឥស្សរភាព មានអធិបតេយ្យភាព វិបុលភាព ប្រជាធិបតេយ្យ ជាជាតិមួយស្មើមុខ នៅលើលោកយើងនេះ ។ មេដឹកនាំខ្មែរ គិតជាចំបងដល់ សុខមាលភាពរបស់ខ្មែរ គ្រប់ស្រទាប់ក្នុងសង្គម ។ ត្រូវតែដឹងគុណជាតិ ដូចដឹងគុណ ឪពុកម្តាយខ្លួន ព្រោះជាតិទឹកដីខ្មែរនេះហើយ ដែលបានផ្តល់កំណើតឱយយើងមានឈាមជ័រជាខ្មែរ ។ ហេតុនេះ ក្នុងនាមយើងជាខ្មែរ ត្រូវតែធ្វើការតបស្នងសងគុណ ចំពោះជាតិយើង នៅគ្រប់កាលៈទេសៈដែលអាចធ្វើបាន ។ ក្នុងឋានៈជាអ្នកដឹកនាំខ្មែរ យើងត្រូវតែស្គាល់អោយច្បាស់ពីអ្វីជាខ្មែរ និង តាំងចិត្តស្រឡាញ់ ការពារអភិរក្ស និងអភិវឌ្ឍន៏ អ្វីដែលជាខ្មែរ នោះអោយគង់វង្ស រុងរឿងប្រសើរឡើងជានិច្ចនិរន្ត ។ មេដឹកនាំខ្មែរត្រូវស្គាល់អោយច្បាស់ពី អតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ។ មេដឹកនាំខ្មែរត្រូវរិះរកមធ្យោបាយជួយប្រជាជាតិខ្មែរទាំងអស់ នៅគ្រប់ទីសទី អោយរួចផុតពីការ បាត់បង់អត្តសញ្ញាណជាខ្មែរ ពីភាពក្រីក្រ អត់ឃ្លាន ល្ងង់ខ្លៅ ភ័យខ្លាច និងនាំមកនូវ សិទ្ធិសេរីភាពពេញលេញ ជូនដល់ ពលរដ្ឋខ្មែរទាំងអស់ ជាពិសេស ខ្មែរដែលកំពុងរស់រងទុក្ខនៅលើទឹកដីខ្មែរសព្វថ្ងៃ ។ "យួនធ្វើពលិកម្មធំធេង មុតស្រួចខ្លាំងណាស់ ទើបវាអាចយកដីខ្មែរបានដើម្បីរំដោះជាតិពីយួន យើងត្រូវតែមានស្មារតី លះបង់ ប្តូរផ្តាច់ អង់អាច ក្លៀវក្លា មុតស្រួច អត់ធ្មត់ ស៊ូទ្រាំ ប្រាកដនិយម សកម្មលើសយួនច្រើនសិបដង""ដើម្បីភាពរស់រានគង់វង្សស្ថិតស្ថេររបស់ប្រជាជាតិខ្មែរអ្នកដឹកនាំជាតិខ្មែរត្រូវតែហ៊ានធ្វើអ្វីគ្រប់យ៉ាងមិនថាជាអ្វីឡើយ" ។

## I. យើងជាខ្មែរ ត្រូវស្គាល់អ្វីជាខ្មែរ (We are Khmer so we have to know about Khmer)

អ្នកដឹកនាំជាតិខ្មែរ ត្រូវតែជាខ្មែរពិតប្រាកដ ត្រូវស្គាល់អ្វីជាខ្មែរ ស្គាល់ពីប្រវត្តិសាស្ត្រជាតិពិត ទំនៀមទំលាប់ប្រពៃណីខ្មែរ វប្បធម៌ខ្មែរ និងអ្វីដែលមានលើទឹកដីខ្មែរ ។ តាមទ្រឹស្តីរបស់លោក **ស៊ុន ស៊ឺ** បានពោលថា "*ស្គាល់ខ្លួនឯងច្បាស់ ស្គាល់សត្រូវច្បាស់* ស្គាល់បរិយាកាសជុំវិញខ្លួនឯងច្បាស់ *ច្បាំងមួយរយដង ឈ្នះទាំងមួយរយដង*"។ ដូចនេះ មុននិងយកឈ្នះលើ អ្នកដទៃ យើងត្រូវស្គាល់ខ្លួនឯងអោយច្បាស់ គឺយកឈ្នះខ្លួនឯងជាមុនសិន ។ *បើស្គាល់ខ្លួនឯង តែមិនស្គាល់សត្រូវអាចឈ្នះអាចចាញ់ ។ស្គាល់សត្រូវ តែមិនស្គាល់ខ្លួនឯង ក៏អាចឈ្នះ អាចចាញ់ ។ តែបើមិនស្គាល់ ខ្លួនឯង មិនស្គាល់សត្រូវការបរាជ័យរង់ចាំយើងជានិច្ច* ។

ត្រង់ចំណុចនេះ អ្នកដឹកនាំខ្មែរ ដែលស្គាល់ខ្លួនឯងច្បាស់ ធ្វើអោយអ្នកដឹកនាំនោះ មានភាពជឿជាក់លើខ្លួនឯង ភាពជឿ ជាក់លើខ្លួនឯង នាំឱ្យអ្នកដឹកនាំនោះ មានភាពប្រាកដនិយម ភាពប្រាកដនិយមជាក្តីសង្ឃឹម កាលណាមានក្តីសង្ឃឹម មានកំលាំងចិត្តនោះហើយជាថាមពលដ៏មហាសាល អាចរុញច្រានអោយឈានទៅរកជោគជ័យបាន ។ អ្នកដឹកនាំត្រូវស្គាល់ច្បាស់លាស់ នូវមាគ៌ា ដែលត្រូវនាំខ្មែរ ដើរទៅរកជោគជ័យ ភាពរុងរឿង វិបុលភាព និងអាចព្យាករណ៏ដឹងមុនពី ឧបសគ្គ និងភាព

បរាជ័យផងដែរ ដើម្បីចាត់វិធានការណ៍ការពារ មុនពេលផលវិបាកកើតមានឡើង។ ហេតុអ្វីបានជាអ្នកដឹកនាំខ្មែរ ត្រូវតែស្គាល់អោយច្បាស់ ពីអ្វីជាខ្មែរ? បើយើងស្គាល់ខ្មែរមិនច្បាស់ យើងនិងចាញ់ ឬក៏ឈ្នះដើម្បីចាញ់។ ជាក់ស្តែង អ្នកដឹកនាំបច្ចុប្បន្នមួយភាគធំ ជាជនជាតិយួន ដែលចេះនិយាយខ្មែរ ដូចជា **ហុក ឡុងឌី, ម៉ិន សម, សុខ គង់, ចាយ សាំងយុន, មាស សុភា, ផាន់ ខួន,** និងមួយចំនួនទៀត ព្រមទាំងពពួកឈ្លក់វង្វេងនឹងមនោគមន៍វិជ្ជាយួន (ពួកឆ្វេងនិយមជ្រុល) ដូចជា **ហ៊ុន សែន,** និង **ហេង សំរិន, ជា ស៊ីម**។ ពួកនេះមិនបានបំរើផលប្រយោជន៍ជាតិ និងប្រជាជាតិខ្មែរឡើយ ផ្ទុយទៅវិញ ពួកវាជាបិសាចជញ្ជក់ឈាម ជាតិ និងប្រជាជាតិខ្មែរ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន បក្សពួក នឹងជាខ្មោចក្នុងដែលអោយដៃ ទៅចៅហ្វាយវាគឺយួន ដែលជាអ្នកគ្រោងអោយមានការសំលាប់រង្គាលពូជសាសន៍ខ្មែរ ដោយវិធីបំភន្ត័យ៉ាងត្រជាក់បំផុត។ ហេតុនេះហើយជំហានដំបូងរបស់អ្នកដឹកនាំ គឺត្រូវសិក្សាពីខ្លួនឯង ដើម្បីស្វែងរកចំណុចខ្សោយ និងចំណុចខ្លាំង។ បើយើងដឹងពីចំណុចខ្សោយរបស់ខ្លួនឯងហើយ យើងត្រូវតែកែប្រែ សិក្សាបន្ថែម ធ្វើយ៉ាងណាអោយចំណុចខ្សោយនោះបាត់បង់ទៅ ហើយកែខៃខ្លួនអោយកាន់តែមានភាពរឹងប៉ឹងប្រសើរឡើង។ បើយើងដឹងពីចំណុចខ្លាំងរបស់ខ្លួនហើយ យើងត្រូវតែការពារ ថែរក្សានិងធ្វើខ្លួនអោយកាន់តែប្រសើរឡើងៗ រៀងរាល់ថ្ងៃបន្ថែមទៅមុខទៀត កុំឱយនៅដដែល ដោយប្រៀបធៀបជាមួយ នឹងគូរប្រជែងដែលខ្លាំងជាងយើង។ តើធ្វើដូចម្តេច ទើបសិក្សាដឹងពីខ្លួនយើងបាន? គឺយើងត្រូវតែខិតខំរកពត៌មាន ដែលទាក់ទងនឹងខ្លួនយើង តាមរយៈការស្តាប់ អាន មើល អង្កេត និងការស្រាវជ្រាវពីគ្រប់មជ្ឈដ្ឋាន យកមកត្រិះរិះពិចារណា ហើយប្រៀបធៀបខ្លួនយើងទៅនឹងអ្វីដែលបានអាន មើល ស្តាប់ ... ដើម្បី កែប្រែ ធ្វើខ្លួនអោយប្រសើរឡើង។ កាលណាអ្នកដឹកនាំ ស្គាល់ខ្លួនឯងច្បាស់នេះជាកត្តាចិត្តសាស្រ្តមួយធំណាស់ ក្នុងការដឹកនាំខ្លួនឯង ក៏ដូចជាការដឹកនាំជាតិផងដែរ។ តាមទ្រឹស្តី ពុទ្ធសាសនាថា "*ឈ្នះបុគ្គលដទៃពុំស្មើនឹងឈ្នះខ្លួនឯងឡើយ*" ។ ដូច្នេះអ្នកដឹកនាំខ្មែរ ត្រូវយកឈ្នះចិត្តប្រជាពលរដ្ឋខ្មែរទាំងអស់ជាមុនសិន។ ដើម្បីយកឈ្នះចិត្តប្រជាពលរដ្ឋបាន លុះត្រាតែយើងស្គាល់ពី ប្រវត្តិសាស្រ្តខ្មែរ ចរិតខ្មែរ ទំនៀម ទំលាប់ប្រពៃណីខ្មែរ វប្បធម៌ ចំណង់ចំណូលចិត្ត និងសេចក្តីត្រូវការ របស់ប្រជាជាតិខ្មែរ នាពេលបច្ចុប្បន្ន។ តើ ពលរដ្ឋខ្មែរកំពុងត្រូវការអ្វីជាចាំបាច់? ក្រុមអ្នកដឹកនាំខ្មែរត្រូវមាន*ការស្មោះត្រង់ នឹង ឧត្តមគតិរួម ហ៊ានលះបង់* ក្តីសុខផ្ទាល់ខ្លួន ទាំងអាយុជីវិត ទ្រព្យធន ពេលវេលា*យ៉ាង ប្តូរផ្តាច់*បំផុត ដើម្បីធ្វើប្រយោជន៍ជូន ជាតិ ជនរួមឈាមខ្មែរ និងត្រូវរស់នៅ*រួមសុខរួមទុក្ខ* យ៉ាងស្អិតរមួតជាមួយប្រជាពលរដ្ឋខ្មែរ ដោយមិនគេចវេសសំងំយករួចខ្លួន ក្នុងគ្រាអាសន្ន ជាពិសេស នៅក្នុងកាលៈទេសៈនេះ។

យើងត្រូវឆ្ងល់ថា ហេតុអ្វីបានជាយួន ដែលជាចោរតាមព្រំដែនចិនសោះ វាអាចវាតទីយកទឹកដីជាតិដ៏ទៃ បានធំល្វឹងល្វើយ រហូតយកទាំង ទឹកដីចំប៉ា និងទឹកដីខ្មែរនៅកម្ពុជាក្រោមបានទាំងស្រុង ហើយព្រមទាំងបន្ត មកលេបយកទឹកដីខ្មែរសព្វថ្ងៃទៀត។ ដោយសារ យួនបានសិក្សា ស្គាល់ច្បាស់ពីចំណុចខ្សោយរបស់ខ្មែរ របស់ពួកមេត្រួតត្រាខ្មែរ ដែលល្មោភនឹងអំណាច ស្រី ស្រា អំពើពាលា ស្រេកឃ្លានមុខមាត់ យសសក្តិ លាភសក្ការៈ គ្មានព្រំដែននេះឯង ។ ចំណែកឯប្រជាពលរដ្ឋខ្មែរ ឆាប់លង់ឆាប់ជឿ អ្នកដ៏ទៃ ជាតិដ៏ទៃ ដោយខ្វះការត្រេះរិះពិចារណារកខុសត្រូវ អោយបានជ្រៅជ្រះ និងការខ្វះចំណេះដឹងក្នុងការថ្លឹងថ្លែង នូវហេតុផលផ្សេងៗ ក៏ព្រោះតែការដឹកនាំ ខ្វះទសពិតធមិរបស់ស្តេចអាយ៉ងនេះឯង។ **ហូ ជីមិញ** បានរៀបចំផែនការបង្កប់ខ្មែរយៀកមិញ យួនយៀកមិញដែលចេះខ្មែរ ដែលយួនវាបាន បំពាក់បំប៉នមនោគមន៍វិជ្ជាកុម្មុយនិស្តរួចហើយ ជាចារកម្មរបស់វា អោយមកបង្កើត ភាពវឹកវរ ក្នុងជួរខ្មែរក្រហម នាំអោយមានការកាប់សំលាប់ខ្មែរ យ៉ាងរង្គាលក្នុងរបប ប៉ុល ពត (កម្ពុជាប្រជាធិបតេយ្យ )ក្នុង បំណងកកូរស្ថានការណ៍ ក្នុងរបបនេះអោយខ្មៅងងឹត បែកបាក់គ្នា។ ដោយសារភាពជ្រុលនិយមរបស់ក្រុមនេះ បានធ្វើឱយ ខ្មែរបែកបាក់ កាប់សំលាប់គ្នាវឹកវរ ចុះខ្សោយខ្លាំង ហើយយួនវា វាយឈ្លានពាន បួន់ទ្រព្យសម្បត្តិ

លេបយកប្រទេសខ្មែរតែម្តង និងកែក្លែង ប្រវត្តិសាស្ត្រខ្មែរ ទៅជាប្រវត្តិសាស្ត្រឥណ្ឌូចិន តំរូវអោយកូនខ្មែរ រៀនប្រវត្តិសាស្ត្រនេះទៅវិញ។ ដើម្បីបន្តផែនការលេប យកទឹកដីខ្មែរ យួនបានបន្តុបពួកខ្មែរក្រហម **ហ៊ុន សែន ហេង សំរិន** ជាអាយ៉ង ចាប់តាំងពីថ្ងៃទី ៧មករា ឆ្នាំ១៩៧៩ មក។ រឿងប្រវត្តិសាស្ត្រឥណ្ឌូចិន មិនខុសគ្នាពីសម័យក្រោយសម័យអង្គរបន្តិច សៀមបានរៀបចំ អោយមានបដិវត្តន៍មួយ នៅក្នុងប្រទេសខ្មែរ ហើយធ្វើអោយនាយត្រសក់ផ្អែម ដែលជាឃាតករសំលាប់ស្តេចនោះ មិនត្រឹមតែ មិនមានទោសប៉ុណ្ណោះទេ តែត្រូវបានគេ ចាត់ទុកថាជាអ្នកមានបុណ្យ ឡើងសោយរាជ្យជំនួសស្តេចគ្រងរាជ្យដែលត្រូវបានធ្វើឃាតនោះទៅវិញ ។ ចូរយើងនាំគ្នាគិតបន្តិចទៅមើលថា ក្នុង១000ឆ្នាំមុន អំណាចស្តេច កំពុងមានឥទ្ធិពលពេញបន្ទុក សឹងមិនមានរាស្ត្រណាមើលមុខចំបាន តើហេតុអ្វីបានជា នាយត្រសក់ផ្អែមធ្វើឃាតស្តេចហើយ ត្រឡប់ជាមិនមានទោសរួចហើយលើកឡើង ឱ្យសោយរាជ្យទៀត។ តើអាចកើតទៅរួចទេ បើសិនគ្មានកំលាំងពីក្រៅក្បៀបសង្កត់បង្ខំ អោយមន្ត្រីជាតិនិងពលរដ្ឋខ្មែរដែលស្មោះត្រង់ នឹងរាជវង្ស ទឹកដី ជាតិ ប្រជាជាតិខ្មែរ ទទួលយល់ព្រមយកទាំងបង្ខំទេនោះ។ ម្យ៉ាងទៀត ការករកើតជាមហាចក្រភពមួយទៅរួច តើមានមហាបណ្ឌិត អ្នកចេះដឹង ច្រើនស្អេកស្កះកិរិតណា ទើបអាចកសាងស្រុកទេស ឱ្យបានសំរេចដល់កិរិតនោះ ហើយតើ វរជនទាំងនោះ សុខចិត្តទទួលយក ភាពខ្មៅងងឹត បែបនេះដោយងាយៗ ឬ? ឬមួយក៏ ត្រូវពួកឈ្លានពាន (បើមិនមែន សៀម ក៏ យួន តែអាចសៀមច្រើនជាង) ប្រើល្បិចកាប់សំលាប់ យ៉ាងរង្គាលលើជនទាំងនោះ ដូចយួន ប្រើពួកកុម្មុយនិស្តឆ្វេងជ្រុល និយម អោយសំលាប់ខ្មែរកាលពី ១៩៧៥-៩៣ និងបន្តរហូតដល់សព្វថ្ងៃ ដូច្នេះដែរ។ ការប្រព្រឹត្តិការសំលាប់រង្គាលបែបសនេះ ត្រូវបានលប់ លាងបង្វែងដាន បំបាត់ការពិត ដោយការតាក់តែងប្រវត្តិសាស្ត្រក្លែងក្លាយលើកដំកើងឧក្រិដ្ឋជនរូបនេះ និងបងប្អូន(នាយ ត្រសក់ផ្អែម និងប្អូន)ថាជាអ្នកមានបុណ្យមានអាយុដល់ជាង ៤00ឆ្នាំ ដែលហួសពីវិស័យមនុស្សជឿបានអោយកូន ខ្មែររៀន រហូតដល់សព្វថ្ងៃ។ វាក៏មិនខុសគ្នានឹងពេលសព្វថ្ងៃដែរ ពួកក្បត់ជាតិអតីតខ្មែរក្រហមដៃប្រឡាក់ឈាម **ហ៊ុន សែន, ហេង សំរិន, ជា ស៊ីម** ដែលត្រូវខ្មែរទូទាំងប្រទេសមិនពេញចិត្ត ធ្វើការតស៊ូប្រឆាំងយ៉ាងគគ្រឹកគគ្រេងកាលពីឆ្នាំ ១៩៧៩-៩៣ និងបានបោះឆ្នោតទំលាក់ចោលកាលពីឆ្នាំ ១៩៩៣ ត្រូវបានយួនរៀបចំបន្តុបឱ្យកាន់អំណាច និងអោយពួកក្បត់មួយក្តាប់តូចនេះ បន្តុប ស្តេចអាយ៉ងបន្តទៀត។ ក្នុងបំណងឱ្យស្តេចអាយ៉ងជួយពង្រឹងអំណាចក្បត់ជាតិ ដែលមានចោរយួនជាចៅហ្វាយវានៅពីក្រោយខ្នងឱ្យកាន់តែរឹងមាំឡើង ដោយការតំឡើងងារ ពួកក្បត់ទាំងនេះ ជាសម្តេចមហាចោរដេកជោ ចក្រីនេះចក្រីនោះ ឬក៏ថាជា មគ្គុទេសក៏ជនទៅវិញ។ មិនយូរឡើយ ប្រវត្តិសាស្ត្រខ្មែរ នឹងត្រូវពួកវាកែក្រឡៃបន្តទៀត ដោយចាត់ទុក ពួកក្បត់ជាពូជអ្នកមានបុណ្យ ឬក៏ថា ជាខ្សែលោហិតព្រះបាទ **ហ៊ុន ទៀន** មកចាប់ជាតិជាក់ជាមិនខាន។ រួចហើយ វាឱ្យកូនខ្មែរសម័យក្រោយ រៀនប្រវត្តិក្លែងក្លាយឆ្កួតលីលានេះតទៅទៀត។ ហេតុអ្វីបាន ជាយួននិងអាយ៉ងរៀបចំ អោយមានប្រវត្តិសាស្ត្រក្លែងក្លាយ ? ដូចពោលរួចមកហើយ បើខ្មែរមិនស្គាល់ខ្លួនឯងជាអ្នកណា មកពីណាមានប្រវត្តិរុងរឿងយ៉ាងណា តើមានអ្វីអាចធ្វើឱយ កូនខ្មែរសម័យក្រោយ មានគំនិតជាតិនិយមដុះដាលទៅរួច។ ចុះបើយុវជនគ្មានគំនិតជាតិនិយម គ្មានគំនិតស្រឡាញ់ជាតិមាតុភូមិ តើមានគំនិតការពារជាតិពីណាមកកើត។ ជាទូទៅ ការដឹកនាំនានាបែបសម័យទំនើប គេតែងតែសិក្សាពីកំហុសឆ្គង អតីតកាល ឬពីអ្វី ដែលគេបានធ្វើរួចហើយ និងចងក្រងទុក ដើម្បីកុំអោយកំហុសឆ្គងដដែលៗ នោះកើតឡើងទៀតនៅពេលអានាគត។ តែការតាក់តែងប្រវត្តិសាស្ត្រក្លែងក្លាយ ជាវិធីមួយធ្វើអោយខ្មែរជំនាន់ក្រោយ មិនអាចរកកំហុសឆ្គងអតីតកាល ដែលជាបុព្វហេតុ នាំអោយខ្មែរចុះខ្សោយ នាំអោយបរាជ័យនោះបាន។ ដើម្បីទុកឱកាស អោយចោរយួនទាំងនេះ យកកលល្បិចដដែលៗហ្នឹង មកអនុវត្តលើជាតិយើង នៅពេលមុខទៀត។ ឯពួកស្តេចអាយ៉ងបានប្រយោជន៍តែម្យ៉ាង គឺដើម្បីកុំអោយខ្មែរសម័យក្រោយ ចាប់កំហុសចំពោះអំពើឆ្កួតលីលារបស់វា និងការការពារមុខមាត់រាជវង្សស្តេចអាយតែប៉ុណ្ណោះ បើទោះជា រាជវង្សស្តេចអាយនេះស្ថិតនៅក្រោមបាតជើង អាយ៉ងយួនក្តី ក៏សុខចិត្តដែរ

( មិនព្រមធ្វើសម្ពន្ធ័មិត្រជាមួយអាមេរិក មហាអំណាចលើលោកទេ តែសុខចិត្ត ត្បុលក្បាលតត្រុកទាំងពូជ មកធ្វើជាកញ្ជះបាត ជើង **ហ៊ុន សែន** អាយ៉ងយួន ទៅវិញ នេះជាគំនិតឆ្កែតឿ ) ។ សូមបងប្អូនខ្មែររួមឈាម រួមលោហិត មេត្តាពិចារណាឡើងវិញ អោយបានជិតដល់ ។ ជាពិសេស ពួកបណ្ឌិត ឬអ្នកសិក្សាប្រវត្តិសាស្ត្រ មេត្តាយកការចេះដឹង ធ្វើជាប្រយោជន៍ដល់ជាតិ កុំយក ការចេះដឹងទៅបំរើសត្រូវ ដូចបណ្ឌិតកម្មុយនិស្ត ដែលធ្លាប់បានជួយយួន ក្នុងការបំផ្លាញ ប្រទេសជាតិកន្លងមក ។

















សរុបមក *ក្នុងនាមយើងជាខ្មែរ ជាជាតិមួយធ្លាប់មានអារ្យធម៌រុងរឿង ជាពូជមានលោហិតដើម របស់មនុស្សនៅ តំបន់អាស៊ីនេះ ( តាមការសិក្សាស្រាវជ្រាវរបស់លោក សាស្ត្រាចារ្យ កេង វ៉ាន់សាក់ ដែលចុះផ្សាយតាមវិទ្យុអាស៊ីសេរីថា ខ្មែរ-មន មានខ្សែឈាម ក្នុងជំពូក* ***កុមប៉ូហ្សង់ អី*** *ជាលោហិត ពួកមនុស្ស ដំបូងគេនៅ តំបន់អាស៊ីនេះ) តើយើងអាចអោបដៃ* លាក់ខ្លួន ពួនយកសុខ *មិនហ៊ានក្រោក ការពារជាតិខ្លួនដោយខ្លួនឯងទេឬ? ឬមួយសុខចិត្តសំងំ បណ្តោយអោយ ចោរយួន ស័យសាសន៏ មកជិះជាន់ គេងប្រវ័ញ្ច យកទ្រព្យសម្បត្តិខ្មែរ ទឹកដីខ្មែរ* លុះរលាយពូជពង្សបង់សូន្យ តែម្តងឬយ៉ាងណា? ។ *តើយើងរស់នៅ មានន័យអ្វី? បើជាតិស្លាប់ យើងនឹងរស់នៅយ៉ាងវេទនា គ្មានតំលៃជាមនុស្សសោះឡើយ ។ មានគ្រប់គ្រាន់ហើយ បងប្អូនរួមលោហិតខ្មែរ ដែលនៅកម្ពុជាក្រោម ត្រូវវាធ្វើទុក្ខបុកម្នេញ ឆក់ប្លន់យកដីធ្លី បំបាត់សេរីភាព ជំនឿសាសនា ចាប់ផ្សឹកព្រះសង្ឃ យ៉ាងយង់ឃ្នង ហួសនិស្ស័យជាមនុស្ស ។ រស់នៅលើមាតុភូមិមិនកើត ខំប្រវេប្រវ៉ា*

*រត់ទាំងត្រដាបត្រដួសពីក្រោម មកនៅមាតុភូមិខាងលើ សង្ឃឹមថាជីវិតនឹងមានពន្លឺរស្មី តែគួរអោយអាសូរពេកក្រៃ មកដល់ដីកំណើតដូនតាខ្លួននៅខាងលើ ត្រូវពួកអាយ៉ងយួនចោទប្រកាន់ ថាជាយួន ទៅវិញ ដោយអោយតំលៃជាយួន ជនជាតិភាគតិច ហើយត្រូវពួកវាតាមចាប់ដាក់គុក ដាក់ច្រវាក់ព្រាត់ប្រពន្ធកូនបន្តទៀត ។ គួរអោយអនិច្ចា បងប្អូនរួមឈាមខ្មែរយើងទាំងនោះ ពន់ពេក សង្វេគចិត្តស្មើស្លាប់ទាំងរស់ មានទឹកដីដូនតាខ្លួនបន្សល់ទុកអោយនៅគង់វង្សដែរ តែមួយជីវិតរស់គ្មានជាតិ គ្មានទឹកដីនឹងគេ នៅខាងក្រោម ត្រូវយួនចោទថា ខ្មែរ មិនតូចចិត្តទេ ពេញចិត្តនឹងទទួល តែមកដល់លើត្រូវពួកក្បត់លង់លិលាចោទថា ជាយួនទៅវិញ ។ តែពេលនេះ មិនថាតែខ្មែរក្រោមឡើយ ខ្មែរលើ ត្រូវពួកវាធ្វើអោយរស់លេចលង់ ក្នុងភាពក្រតោកយ៉ាក អត់ឃ្លានគ្មានស៊ី លង់ ខ្លៅ ខ្លាចផ្សារ គ្រប់ពេលវេលា រងារភិតភ័យខ្លាច ក្នុងរបបភេរវកម្ម ។ យួនងាប់មួយ អាក្បត់ស្រែកស្មើបែកឧឃោសនសព្ទ តែខ្មែរស្លាប់រាប់រយ រាប់ពាន់ព្រោះការអត់ឃ្លាន គ្មានស៊ី ខ្លះត្រូវប្រទេសជិតខាងបាញ់សំលាប់ទាំងមានផ្ទៃពោះ តែអាក្បត់ធ្វើមិនដឹងមិនឮ ។ ផ្ទុយទៅវិញ មិនត្រឹមតែមិនរកខុសត្រូវ តែពួកអាក្បត់ចោទទាំងអគតិថា ជនទុំគត និងកុមារទាំងនោះ ស្លាប់ដោយ ស្រវឹងស្រា ស្ត្រីមានផ្ទៃពោះ ត្រូវគេបាញ់ស្លាប់នោះ ចចេសហាមឃាត់មិនស្តាប់ ចូលស្រុកគេខុសច្បាប់ អោយស្លាប់ទៅចុះ ! ។ ខ្មែរសព្វថ្ងៃ រស់នៅ ប្រៀបដូចជាកូនកំព្រា គ្មានឪពុកម្តាយថែរក្សារ ។ តើយើងជាអ្នកដឹកនាំខ្មែរ ដែលកាន់សៀវភៅនេះ នៅក្នុងដៃ សុខចិត្តបើកភ្នែក មើលទុក្ខវេទនារបស់ខ្មែរ ឬយើងក្រោកឈរ ដើម្បីការពារខ្មែរ? ។ តើយើងសុខចិត្តស្លាប់ ដោយ មិនបានតបត ឬខ្មែរសុខចិត្តរើដើម្បីខ្មែររស់? ។ ខ្មែរក្រ វេទនា ព្រាត់ប្រាស់គ្រួសារព្រោះ យួន និងការត្រួតត្រាអាក្បត់ ហ៊ុន សែន”* **ខ្មែរពិតជាមានភព្វ័ មានជោគជ័យ បើខ្មែរ ប្រុសស្រី រួបរួមពួតដៃគ្នា ។ សិទ្ធសេរីភាព ឯករាជ្យភាពជាតិ ជារបស់ខ្មែរ គ្រប់គ្នា ។ ជ័យជំនះរបស់ខ្មែរ កើតឡើងដោយការ ប្តូរឈាម ប្តូរជីវិត មិនមែនកើតឡើងដោយការសុំទាន ពីចោរយួន និងពួក ក្បត់ជាតិឡើយ ។ *សិទ្ធសេរីភាពរបស់ខ្មែរ កើតឡើងការប្តូរជីវិត ប្តូរឈាម !!!!! ។ ខ្មែរពិតជារស់ ព្រោះខ្មែរហ៊ានស្លាប់ !!!!!***















ដូចរៀបរាប់ក្នុងប្រយោគខាងលើរួចមកហើយ ប្រជាជាតិខ្មែរត្រូវតែប្រុងប្រយ័ត្ន មិនមែនឱ្យតែឃើញ ចេះភាសាខ្មែរ និយាយភាសាខ្មែរច្បាស់ យើងថាអ្នកដឹកនាំនោះជាខ្មែរ ពិតប្រាកដបានឡើយ។ មេដឹកនាំជាតិខ្មែរ ត្រូវប្រយ័ត្ន អ្នកចេះភាសាខ្មែរ តែមានគំនិតបំរើយួន តាមដែលយួនបានអប់រំមក និងជនជាតិយួន ឬចារកម្មយួនចេះភាសាខ្មែរ បន្លំដូរឈ្មោះជាខ្មែរជាដើម។ អតីតកាល បានបង្រៀនយើងរួចហើយ អាចារ្យ **មៀង** ជាជនជាតិយួន ដែលបានលបមកបួសរៀន នៅក្នុងវត្តខ្មែរ បានបន្លំ ដូរឈ្មោះពី **មៀង** ទៅជា **មាន** ហើយទៅជា **ស៊ឹង ង៉ុកមិញ** ដើម្បី ជាមធ្យោបាយឃោសនា ភូតកុហក ខ្មែរថាជា ប្អូនរបស់លោក **ស៊ឹង ង៉ុកថាញ់** ហើយឆ្លៀតទាញយកចំណេញខាងនយោបាយចិត្តសាស្ត្រ ពីប្រិយ៍ភាពរបស់លោក (**ស៊ឹង ង៉ុកថាញ់** ) ដែលត្រូវស្តេច សីហនុ សុំអោយបារាំងចាប់យកទៅដាក់គុក ព្រោះតែច្រណែន នឹងប្រិយ៍ភាពរបស់លោក។ ស៊ឹង ង៉ុកមិញ នេះហើយដែលជា មេក្លោងកកូរកកាយសង្គមខ្មែរអោយបែកបាក់។ តែយើងក៏មិនត្រូវចេះតែចោទប្រកាន់ ដោយគ្មានហេតុផល គ្មានភស្តុតាង គ្មានការសង្កេតពិនិត្យឡើយ។ ការចោទប្រកាន់ ដោយងងិតងងល់ គ្មានការពិចារណាអោយល្អិតល្អន់ នឹងនាំមកនូវការបែកបាក់។ បញ្ហានេះមិនពិបាករហូតដល់យើងធ្វើមិនកើតនោះឡើយ យើងអាចស្គាល់អ្នកទាំងនេះ ដោយធ្វើការស៊ើបអង្កេតអោយបានហ្មត់ចត់ តាមរយៈការតាមដានសិក្សាស្រាវជ្រាវ ជីវប្រវត្តិ ការសំភាសន៍ ការសេពគប់ និងចុះផ្ទាល់ ស៊ើបតាមដានអ្នកជុំវិញផ្សេងៗ ឬអ្នកភូមិ ម្ចាស់ស្រុក នៃពពួកបុគ្គល ដែលយើងមានមន្ទិលសង្ស័យនោះរស់នៅ។ យើងមិនមែនជាជាតិរើសអើង ពូជសាសន៍ឡើយ តែយើងជាខ្មែរ ចង់រស់ក្នុងសុខសន្តិភាព មិនចង់អោយជាតិណាមួយ មកកកូរកកាយ បំផ្លាញសេចក្តីសុខរបស់ខ្មែរ ដូចកន្លងមកហើយ ហើយវាអួតប្រាប់បរទេសថា វាជាជាតិឆ្លាត ឯខ្មែរជាជាតិល្ងង់ខ្លៅ។ ជាតិសាសន៍ណាក៏ត្រូវការ ការពារអភិរក្សពូជសាសន៍ខ្លួន ដូចខ្មែរដែរ ហើយនេះជាបុព្វសិទ្ធពីកំណើត ក្នុងការរស់រានជាជាតិមួយ។

## II. អ្នកស្នេហាជាតិខ្មែរពិតប្រាកដ (The Real Khmer Patriot)

តើខ្មែរអ្នកស្នេហាជាតិពិត ត្រូវធ្វើដូចម្តេច? ត្រូវតែជាអ្នកស្រឡាញ់ជាតិ សាសនា និងប្រជាជាតិខ្មែរ ដោយបួរផ្តាច់ មានទស្សនៈយល់ឃើញដោយឥស្សរះ មានគោលមាគ៌ាឯករាជ្យ ទាំងការគិត ការពិចារណា និងសកម្មភាព មិនលុះតាមការញុះញង់របស់បរទេស មិនបំរើបរទេសឡើយ។ មិនផ្តេកផ្តួល តែទៅលើជំនួយគ្រប់បែប ពីជាតិដ៏ទៃដោយ ហួសហេតុរហូតដល់បាត់បង់ គំនិតពឹងលើខ្លួនឯង។ ត្រូវរិះរកវិធី ប្រើប្រាស់ធនធាន មានស្រាប់ក្នុងប្រទេស ជាជាងដេកចាំតែជំនួយពីអ្នកដ៏ទៃ។ ការពឹងផ្អែកលើបរទេសទាំងស្រុង ជាគំនិតខ្ញុំគេ គំនិតគ្មានឯករាជ្យ។ បរទេសជួយយើង ព្រោះគេសំលឹងប្រយោជន៍អ្វីមួយពីខ្មែរ បើមិនដើម្បីផលប្រយោជន៍ ខាងនយោបាយ កងទ័ព សេដ្ឋកិច្ច ការឃោសនា ក៏ដើម្បីអ្វីមួយយ៉ាងដាច់ខាត បើមិនច្រើនក៏តិច ចៀសមិនរួច។ ដូចយួន ដែលជួយពួកកុម្មុយនិស្តទាំងពីរក្រុម (ប៉ុល ពត និងអាយ៉ង ហ៊ុន សែន)ក៏ ព្រោះតែ យួនត្រូវការខ្ញីដៃពួកនេះ អោយកកូរបរិយាកាសក្នុងសង្គមខ្មែរ បែកបាក់កាប់សំលាប់គ្នារីកររមើលអ្វីមិនយល់ ស្រួលងាយវា រៀបចំឱកាស មកសង្រ្គប់ផ្តាច់ព្រាត់តែម្តង ដោយយកលេសថាមកជួយខ្មែរ។ បើទោះបី ក្រុម ប៉ុល ពត ដឹងថា យួនប៉ងលេបខ្មែរ ហើយខំរកវិធី ដោះកុនក្តី ក៏ឥតប្រយោជន៍ ព្រោះយុទ្ធសាស្ត្រនយោបាយរបស់ខ្លួនគ្មានឥស្សរភាព គ្មានឯករាជ្យតាំងតែពីដំបូងមកហើយ។ តើអោយខ្មែររង់ចាំទឹកថ្លា ដើម្បីមើលឃើញបាតថា មានស្អីម្តេចកើត(សំដីលោក ខៀវ សំផន)បើទាំងយួន និងអាយ៉ង កកូរស្ថានការណ៍ខ្មែរ ឱយល្អក់រហូតដូច្នេះ។ យួន ពួកអាយ៉ង និងស្តេចនេះហើយ ជាដើមចមបញ្ហា ដែលបំផ្លាញ ឯកភាពជាតិ និងសេចក្តីសុខរបស់ខ្មែរ។ សូមកុំជឿ ពាក្យឆ្កួតលីលា ដែលយើងធ្លាប់ឮថា "អាកំប៉ោងបោកចិន អាខ្វិនបោកអាមេរិក"។ ត្រូវចាំថាមហាអំណាច ដែលអាចធ្វើខ្លួនត្រួតពិភពលោកបាន មិនមែនល្ងង់អោយមនុស្សម្នាក់រៀនបានត្រឹមកូន ឱប្លូមស្រុកយួនហ្នឹងបោកគេបានអោយសោះ។ មានតែអាកំប៉ោងល្ងើពកថ្វាសខ្លួនឯងនឹងហើយ ដែលត្រូវយួនបោកអស់ក្តិតខោ

បោកអស់ទឹកអស់ដីនោះ ។ រឿងស្រឡាញ់ជាតិទៀតសោត អ្នកណាក៏និយាយបាន ពោលកើតបានដោយមិនពិបាក ។ យើងត្រូវតែពិចារណា កុំស្រឡាញ់ ត្រឹមតែបបូរមាត់ មិនគ្រប់គ្រាន់សំរាប់អ្នកស្នេហាជាតិឡើយ តែត្រូវស្រឡាញ់ដោយសកម្មភាព ដោយការធ្វើយ៉ាងតាំងចិត្ត តាំងគំនិតមុតមាំបំផុត មិនលះបង់មិនថមថយចុះចាញ់ នឹងឧបសគ្គផ្សេងៗដោយងាយៗ ព្រោះតែ កត្តានេះនោះបន្តិចបន្តួច ។ ត្រូវតែជាសកម្មភាព ដែលធ្វើ ដោយស្មើ មិនអាក់មិនឈប់មិនឈរ ដោយរឹងប៉ឹងរហូតទទួលបានជោគជ័យផ្តាច់ព្រាត់ ។

### អ្នកដឹកនាំជាតិខ្មែរ ពិតប្រាកដត្រូវមាន ៈ

មានឥរិយាបថ ពាក្យសំដីប្រចាំថ្ងៃ មិនប្រែប្រួល សំដែងចេញនូវ ស្មារតីស្រឡាញ់ ការពារ និងលើកតំកើង អ្វីជាខ្មែរ មានអត្តសញ្ញាណជាខ្មែរ ផលប្រយោជន៍ជាតិខ្មែរ និងវប្បធម៌ខ្មែរ ( មិនមើលងាយ បន្ទាបបន្ថោក ឬ ញុះញង់ អោយខ្មែរបែកបាក់សាមគ្គីភាព ឯកភាពសង្គមឡើយ) មិនយកបញ្ហាផ្ទាល់ខ្លួនតូចតាច មកលាយឡំនឹង រឿងជាតិ ។

- មានស្មារតីជាតិខ្ពស់ ភ្ញាក់រលឹកស្វះស្វែងប្រមូលរកគ្នាមករួមគិត រួមធ្វើដោយមិនចាំបាច់ មានគេមកដាស់តឿនក្រើនរំលឹកច្រើនឡើយ ។ ខ្វល់ខ្វាយ ភ័យព្រួយពីអាយុជីវិតប្រជាជាតិ និងប្រទេសជាតិ គិតគូរពីផលប្រយោជន៍ជាតិខ្មែរជាធំ គ្មានគំនិតអាក្រក់ គេងប្រវ័ញ្ច ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន មិនអាត្មានិយម គ្មានបក្សពួកនិយម គ្មានគំនិតបោកប្រាស់ ប្រជាភិថុតិ ដើម្បីអំណាច បុណ្យសក្តិ ទ្រព្យសម្បត្តិឡើយ ។
- ហ៊ានលះបង់ខ្ពស់បំផុត ទាំងពេលវេលា ទ្រព្យសម្បត្តិ សេចក្តីសុខផ្ទាល់ខ្លួន និងអាយុជីវិតយ៉ាងប្តូរផ្តាច់មោះមុត ស្រួចស្រាវដោយសកម្មភាព ដើម្បីការពារជាតិ និងហ៊ានធ្វើអ្វីៗ ជាប្រយោជន៍ដល់ជនរួមជាតិខ្មែរ ។

ត្រង់ចំណុចនេះ អាចបញ្ជាក់បានថា គំនិតនាំអោយស្តែងចេញមកជាសំដី សំដីចេញមកជាសកម្មភាព សកម្មភាព នាំអោយមានទំលាប់ ទំលាប់នាំអោយក្លាយជា ចរិតលក្ខណៈ ចរិតលក្ខណៈប្រចាំថ្ងៃ នាំអោយអ្នកផង មើលឃើញ និងមានជំនឿលើយើង ថាតើ ជាអ្នកស្នេហាជាតិពិត ឬក៏ត្រឹមតែបបូរមាត់ ។ ប្រទេសជាតិ រុងរឿង ឬលិចលង់ អាស្រ័យលើមេដឹកនាំ ដែលមានសមត្ថភាព មានគុណសម្បត្តិគ្រប់គ្រាន់ ព្រមល្មមដឹកនាំទៅរកការរីកចំរើនបាន ។ ជាពិសេស ត្រូវសង្កេតពិនិត្យឱយល្អិតល្អន់ថា អ្នកដឹកនាំ នោះជាខ្មែរពិតប្រាកដ ជាបុគ្គលដែល ស្មោះស្ម័គ្រភក្តី ចំពោះជាតិ និងប្រជាជាតិខ្មែរ ដោយគ្មានលាក់លៀម ឬល្បិចកិច្ចកល្ប មិនក្រោមឥទ្ធិពលបរទេស ។ ហេតុនេះហើយ ខ្មែរទាំងអស់ ត្រូវពិចារណា អោយល្អិតល្អន់ ទៅលើ *ចិត្ត គំនិត ពាក្យសម្តី សកម្មភាព លទ្ធផលល្អ អាក្រក់ ទំលាប់ ចរិតលក្ខណៈ និងប្រវត្តិពិតប្រាកដ របស់បុគ្គលដែល យើងផ្តល់ការ ជឿទុកចិត្ត ឬលើកដំកើង អោយធ្វើជាមេដឹកនាំ ។* យើងមិនត្រូវប្រថុយប្រថាន ផ្តល់ជំនឿទៅលើអ្នកណាមួយ ដោយគ្រាន់តែគេមកធ្វើល្អ តែមួយភ្លែត ឬអោយប៊ីចេង មួយថង់ សារុងមួយ ថាគេល្អនោះឡើយ ។ យើងត្រូវមើល ទៅលើលទ្ធផល នៃទង្វើរបស់មេដឹកនាំ តើល្អឬអាក្រក់ រីកចំរើនឬទន់ខ្សោយ ស្នេហាជាតិ ឬបំផ្លាញជាតិ ជាខ្មែរឬជាចារកម្មបរទេសមកបន្លំខ្លួន ។ ចរិតខ្មែរ យើងតែងមាន ការអាណិតអាសូរ ចំពោះទុគ៌តជន មិនប្រកាន់ថាជាតិណាឡើយ ។ ជាការពិត ចរិតអាណិតអាសូរ ជាគុណធម៌ ដ៏ល្អ មិនអាចកាត់ថ្លៃបាន របស់ជនជាតិខ្មែរយើងមែនហើយ តែក៏ជាទោសមួយដែរ ដែលនាំអោយខ្មែរធ្លាក់ខ្លួន ដូចសព្វថ្ងៃនេះ ព្រោះយើងមានសេចក្តីសណ្តោសប្រណី ដោយខ្វះការពិចារណា ខ្វះការប្រុងប្រយត្ន័ ។ ទោសដែលខ្មែរ ទទួលតបស្នងពីការអាណិតអាសូរដោយខ្វះការពិចារណានេះ មិនខុសគ្នា នឹងរឿងល្បើកខ្មែរ *"អ្នកបរទេស និងក្រពើដាច់ទឹក ឬ អ្នកសុំផ្ទះស្នាក់*

ឬក៏ *ត្រី និងកុក* នោះឡើយ។ ហេតុនេះ ខ្មែរយើង មិនត្រូវផ្តល់ការទុកចិត្ត ដោយការអាណិតអាសូរ ភ្លេចការប្រុងប្រយត្ន័ ភ្លេចអតីតកាល ភ្លេចសេចក្តីសុខរបស់ខ្លួន និងជាតិខ្លួននោះទេ។ ដូនតាខ្មែរបានចងក្រង ជារឿងល្បើក ដើម្បីទូន្មានបង្រៀន យើងជំនាន់ក្រោយ ការពិសោធន៏ក៏ខ្មែរយើង ធ្លាប់ភ្លក់ ធ្លាប់សាកហើយដែរ មិនត្រូវដើរជាន់ដានចាស់ឡើយ។

យើងគួរលើកយករឿងល្បើក " **កុក នឹងត្រី** " មកសិក្សា និងពិចារណា។ នៅក្នុងថ្លុកមួយ ទឹករីងស្ងួតរកកលនឹងរីង អស់ ។ ត្រី កំពឹស ទាំងតូចធំនាំគ្នាភ័យព្រួយ ពីមហន្តរាយដែលកាន់តែជិតមកដល់ ក្នុងពេលឆាប់ៗ។ នៅមាត់ថ្លុក កុកកញ្ចាស់ មួយ ដែលមិនអាចចាប់ត្រីបាន ពោលទៅពួកត្រីថា "*ខ្ញុំអាណិតត្រីទាំងអស់ណាស់ យកល្អគួរទៅរកបឹងត្រពាំងធំៗ*"។ ពួកត្រី ដែលមិនធ្លាប់ស្គាល់កុកសោះ តែដោយការភ័យព្រួយនឹង គ្រោះមកដល់ ក៏ភ្លេចខ្លួនថា ពូជពង្សខ្លួនជាត្រី ជាចំណីដ៏ឆ្ងាញ់របស់ កុក សុខចិត្តជឿតាមចរិតលាក់ពុត របស់កុក ដោយក្លែងខ្លួនជាស្លូតបូត ។ ពួកត្រីឃើញដូច្នេះ សុខចិត្តអោយ កុក ពាំត្រីមួយ ទៅរកបឹងធំៗ។ កុក បាននាំត្រី ទៅបង្ហាញបឹងធំមួយ ហើយនាំត្រីមកវិញ។ រួចហើយនាំត្រីផ្សេងទៀត ទៅមើលបឹងពានោះ ហើយនាំត្រឡប់ មកដាក់នៅថ្លុកនោះវិញ។ ពួកត្រីដោយខ្វះពិចារណា ក៏យល់ព្រមអោយកុក នាំយកពួកខ្លួន ទៅម្តងមួយៗ ដើម្បីទៅរកបឹងធំនោះ។ កុក បាននាំត្រីទៅម្តងមួយៗ តែពុំបាននាំយកទៅបឹងធំនោះឡើយ គឺយកទៅស៊ីទៅវិញ រហូតដល់ អស់ត្រីពីត្រពាំង។

ការពិសោធន៏ថ្មីៗ ក្នុងសម័យយើងនេះ ជាមេរៀនដល់ខ្មែរគ្រប់រូប។ ចារកម្មយួន ដែលចូលមកលាក់ខ្លួនក្នុងស្រុកខ្មែរ នៅពេលវាមានគ្នាតិច តែងមានចរិតស្លូតបូតគួរអោយអាណិត ប៉ុន្តែដល់ពេលយួនពូនផ្តុំគ្នាបានច្រើន យួនចាប់ផ្តើមរាតត្បាត និងវាយក្បាលខ្មែរតែម្តង។ លើសពីនេះទៅទៀត នៅពេល ស្តេច សីហនុ អនុញ្ញាតអោយយួន ដាក់ទព័នៅលើទឹកដីខ្មែរ នៅ គ្រាដំបូងៗ ទព័យួនទាំងនោះ មានចរិតស្លូតបូត គោរពនូវប្រពៃណីខ្មែរយ៉ាងល្អ។ យួន នៅផ្ទះណា តែងជួយបោសច្រាសសំអាត ផ្ទះសំបែង ជំនួសខ្មែរម្ចាស់ផ្ទះនោះ។ យួន ជួយពុះអុស រែកទឹកដាក់ពាង កើបអាចម៏គោ អាចម៏ក្របី ជួយធ្វើការងារដកស្ទូង ផ្សេងៗ។ យួន មិនដេកនៅលើផ្ទះទេ សុខចិត្តដេកក្រោមផ្ទះអ្នកស្រុក បើសូម្បី ត្រូវកូនអ្នកស្រុកនោមដាក់ក្បាល ក៏យួនមិន ដែលសំដែងទោមនស្សសោះឡើយ។ នៅពេលយួន បេះផលដំណាំខ្មែរ យួនតែងចងលុយដាក់តាម ឈើទាំងនោះ ទុកអោយ ម្ចាស់។ បើយួនធ្វើអ្វី អោយខូចខាតដល់ប្រយោជន៏ខ្មែរ យួនធ្វើសង ឬសងជាលុយវិញភ្លាម។ ទង្វើបែបនេះហើយ បានធ្វើ អោយខ្មែរនៅតាមស្រុកស្រែចំការស្លាប់ចិត្ត ភ្លេចគិតប្រវត្តិតែអុង ភ្លេចគិតរឿងទឹកដីខ្មែរក្រោមដែលយួនលេបថ្មីៗ ដូចត្រីភ្លេច គិតថា កុក តែងស៊ីត្រីជាអាហារដូច្នោះដែរ។ ខ្មែរជឿជាក់ទាំងស្រុងថា យួនជាមនុស្សល្អ គួរអោយស្រឡាញ់ទំនុកបំរុង។ ជា រឿងគួរអោយអាម៉ាស់បំផុត ដែលយួននៅលើទឹកដីខ្មែរហើយ យួនបានបោះពុម្ពក្រដាស់ប្រាក់ខ្មែរ ក្លែងក្លាយ ដើម្បីយកមក បង្ខំ ខ្មែរអោយលក់ស្រូវអង្ករអោយវា និងដើម្បីសូកប៉ាន់ **ម៉ូនិក** ក្នុងការបញ្ចុះបញ្ចូលស្តេច សីហនុ ឱយយល់ព្រមអោយយួន បោះទព័ដោយខុសច្បាប់លើទឹកដីខ្មែរ។ លុះដល់យួនមានមូលដ្ឋាន មានការរៀបចំកំលាំងទព័ រឹងមាំ និងបានសាបព្រួស លទ្ធិ កុម្មុយនិស្ត ធ្វើអោយសង្គមខ្មែរ បែកបាក់រង្គោះរង្គើ ហើយយួនចាប់ផ្តើមកៀបសង្កត់លើខ្មែរ នៅតាមជាយដែនដែលជា តំបន់ វាដាក់ទព័នោះ ដោយការបង្ខំអោយលក់ស្បៀងអោយវាកែនខ្មែរម្ចាស់ស្រុកអោយដឹកគ្រាប់រំសេវ ស្បៀងអាហារទៅអោយ ទព័វានៅតាមសមរភូមិ និង ត្រួតត្រាតំបន់ទាំងនោះថា ជាទឹកដីរបស់វាតែម្តង។ លើសពីនេះ ការលួចឆ្លងដែន ចូលទៅវាយ ប្រហារទព័អាមេរិក នៅកម្ពុជាក្រោមយួនខាងត្បូង រួចរត់មកពួននៅក្នុងទឹកដីខ្មែរ យួនទាំងនោះ មិនបានលាក់ខ្លួននៅតាម ព្រៃភ្នំទេ វាតែងបោះទព័ នៅតាមភូមិរបស់អ្នកស្រុក ។ លុះកងទព័អាមេរិក និងយួនខាងត្បូង វាយប្រដេញមកវិញមាន ការ

បាញ់ផ្លោង ឬទំលាក់គ្រាប់បែកជាដើម តែងធ្វើការវាយប្រហារលើភូមិទាំងនោះ បណ្តាលអោយខ្មែរស្លូតត្រង់ ត្រូវស្លាប់ទាំងក្មេងចាស់ យ៉ាងអាណោចអាធម្ម។ រឿងអស់នោះ មិនមែនជាហេតុការចៃដន្យទេ តែជាគ្រោងការខ្មៅក្រខ្វក់ដ៏ជាក់លាក់មួយដែលយួនគ្រោងទុក និងបង្កើតឡើង ដើម្បីយកលេសដុតសង្គ្រាមមកក្នុងស្រុកខ្មែរ។ ពេលនោះហើយ ទើបខ្មែរភ្ញាក់ខ្លួន ក្តៅក្រហាយក្រោកឡើងធ្វើបាតុកម្មប្រឆាំងនឹងទព័យួនទាំងនោះ។ តែស្តេច សីហនុ ត្រឡប់ជាថ្កោលទោសបាតុករខ្មែរទៅវិញ។ គ្រានោះ យួនមានកំលាំងទព័ប្រកបដោយអាវុធទំនើប១ មានការពិសោធន៍ស្ទាត់ជំនាញក្នុងសង្គ្រាមទព័ព្រៃ ទព័រៀបរយ ដល់ទៅ ៦០ ០០០-៨០ ០០០នាក់ លើទឹកដីខ្មែរក្រោមការឧបត្ថម្ភគាំទ្រពេញទំហឹងពីស្តេច សីហនុ។ តែក្នុងខណៈជាមួយគ្នានោះ ទព័ជាតិខ្មែរមានអាវុធធុនអន់១ ខ្វះការហ្វឹកហ្វឺន ខ្វះការពិសោធន៍ គ្មានលទ្ធភាពរៀបចំត្រៀមសង្គ្រាម ព្រោះត្រូវបានស្តេច សីហនុ ករិតថវិកា និងចំនួនអោយមានត្រឹម៣០ ០០០នាក់ ប៉ុណ្ណោះ។ នេះជា ទង្វើដោយចេតនា ក្នុងការចងដៃទព័ខ្មែរ មិនអោយមានសមត្ថភាពតបត នឹងសត្រូវឈ្លានពាន។ សីហនុ ខ្លួនឯងក៏ដឹងដែរថា នឹងមានរឿងជាយថាហេតុ កើតឡើងដោយជៀសមិនរួច។ រឿងនេះ មិនខុសពី ទង្វើក្បត់ជាតិរបស់ ហ៊ុន សែន ដែល បំផ្លាញអាវុធ រាប់សែនដើម ចោលសព្វថ្ងៃនេះឡើយ ជាទង្វើធ្វើអោយខ្មែរស្លាប់ ដោយបិទភ្នែកមិនជិតនៅពេលខាងមុខ។ ទាំង កុម្មុនិស្ត ប៉ុល ពត ទាំងពួក កម្មុយនិស្ត ហ៊ុន សែន, ជា ស៊ីម, ហេង សំរិន, សុទ្ធសឹងជាមនុស្សដែលបណ្តុះបណ្តាលអប់រំដោយយួន។ ឯឃុតឆាក ដែលនាំអោយមានវាល ពិឃាតនិងភាពរីករវរសព្វថ្ងៃនេះ ក៏ចេញពីនយោបាយវាតទី ដែលគ្រោងទុកដោយ ហូ ជីមិញ នេះឯង។ ហេតុការដូចរៀបរាប់មកនេះហើយ ដែលជាដើមចម នាំអោយមានព្រឹត្តិការណ៍ ១៨ មិនា ១៩៧០ នោះកើតឡើង។ ភាពមានប្រៀប ខាងយោធា និងការគ្រោងទុកជាមុនរបស់ យួន ដែលមានស្តេច សីហនុ ជួយផងនោះ ហើយបានផ្តល់លទ្ធភាព អោយ យួន ព្រហើន វាយសង្គ្រប់ភ្លាម១ យ៉ាងសាហាវ សន្ធាប់មកលើទព័ជាតិខ្មែរ នៅគ្រាដំបូង១ ក្នុងបំណងប្រើប្រាស់ពេលដ៏ខ្លីបំផុត នឹង លេបត្របាក់យកដីខ្មែរអោយបានតែម្តង។ តែមិនដូចការគិតរបស់ចោរ យួន ឡើយ យុវជនខ្មែរបានក្រោកឡើងធ្វើការតតាំង យ៉ាងអង់អាច ធ្វើអោយយួនបាក់អំណួតទៅវិញ។ ឯចំណែកស្តេច សីហនុ មិនត្រឹមតែមិនជួយទប់ទល់ទេ តែបែជានាំប្រពន្ធ កូនទាំងពូជទៅជួយយួនអោយមកវាយខ្មែរ និងស្រែកថ្កោលទោស អ្នកដែលធ្វើការ ការពារជាតិទៅវិញ។ ក្នុងប្រវត្តិសាស្ត្រ ស្តេចដែលមានឈ្មោះ សីហនុ នេះ មានចំនួន ២នាក់ហើយ សុទ្ធសឹងតែធ្វើកញ្ចះយួនទាំងអស់។ ខ្មែរមិនត្រូវភ្លេច មេរៀន អតីតកាលទាំងអស់នេះទេ ការភ្លេចអតីតកាល នឹងធ្វើ អោយអតីតកាល លងវិញ នៅពេលណាមួយមិនខាន។

ត្រឡប់មកវិញ កត្តាស្លាប់រស់របស់ខ្មែរ ស្ថិតនៅលើការជ្រើសរើសអ្នកដឹកនាំ ជាខ្មែរពិតប្រាកដ ជាអ្នកស្មោះត្រង់ចំពោះជាតិ មានការភ្ញាក់រលឹក ហ៊ាន***និយាយពិត ធ្វើពិត ហ៊ានទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនដោយមិនគេចវេសដោះសារ*** ប្រកាន់ពាក្យ***ពិតសច្ចះ*** ហ៊ានលះបង់អ្វីគ្រប់យ៉ាង ដើម្បីអោយជាតិរស់ គង់វង្ស និងរីកចំរើន។ ***មិនមែនជាអ្នកអាត្មានិយម*** គិតតែប្រយោជន៍ខ្លួន ក្រុមគ្រួសារ និងបក្សពួកខ្លួនឡើយ។ កន្លងមកហើយ នៅពេលដែលខ្មែរមាន មេដឹកនាំ ជាអ្នកស្នេហាជាតិពិតប្រាកដ បានធ្វើអោយប្រទេសខ្មែរ មិនត្រឹមតែរើបំរះ ពីការរុករាន របស់សត្រូវបានប៉ុណ្ណោះទេ ថែមទាំងធ្វើអោយប្រទេសជាតិ ក្លាយជាមហាអំណាចមួយ ដ៏អស្ចារ្យនៅក្នុងតំបន់ មានទឹកដីធំ ល្វឹងល្វើយ។ ដូចមានរួចមកហើយ **ព្រះបាទជ័យវរ្ម័នទី ២ ទី ៧, សុរិយាវរ្ម័នទី១ទី២** ជាដើម បាននាំប្រទេសជាតិរីកចំរើន ដល់កំពូល នាសតវត្សរ៍ទី ៧-១៣ កន្លងមក។ លោក **សឺន គុយ** ហ៊ានលះបង់ជីវិត ដើម្បីអោយវប្បធម៌ខ្មែរ និងព្រះពុទ្ធសាសនានៅគង់វង្ស សំរាប់ខ្មែរក្រោម។ សម្តេចសង្ឃរាជ **ជួន ណាត, ស៊ឺង ង៉ុកថាញ់, អាចារ្យ ហែម ចៀវ, ប៉ាច ឈឺន, អ៊ីវ កើះ, យុត្តិវង្ស, ឧកញ៉ា ក្រឡាហោមគង់** ហ៊ានលះបង់ជីវិត រើបំរះចំពោះការ គាបសង្កត់របស់បរទេស ដើម្បីការពារជាតិ មាតុភូមិខ្មែរ ឱ្យគង់វង្ស រហូតមកដល់សព្វថ្ងៃ

ក៏ព្រោះតែអស់លោកទាំងនេះ ជាអ្នកស្នេហាជាតិពិតប្រាកដ។ ដូចនេះ យើងជាអ្នកស្នេហាជាតិខ្មែរ ត្រូវតែខិតខំរកវិធី ជួយសង្គ្រោះប្រជាពលរដ្ឋខ្មែរ ដែលកំពុងតែ រងនូវការឈឺចាប់ ទាំងផ្លូវកាយ ផ្លូវចិត្ត នឹងអំពើយង់ឃ្នង ជិះជាន់ សង្កត់សង្កិន កាប់សំលាប់ បែបព្រៃផ្សៃ យ៉ាងអយុត្តិធមិ ពីសំណាក់ពួកមានអំណាចក្បត់ជាតិ និងការរងគ្រោះដោយសារអំពើពុករលួយ របស់ពួកវា ដែលធ្វើអោយខ្មែររស់ក្នុង ភាពក្រីក្រ ល្ងង់ខ្លៅ ភ័យខ្លាច អត់ឃ្លាន។




## III.គោលបំណង និងទិសដៅ (Goal and Objective)

មេដឹកនាំជាតិខ្មែរ ចាំបាច់ត្រូវមានគោលបំណង និងទិសដៅច្បាស់លាស់ ជ្រើសរើស យុទ្ធសាស្ត្រ និង មធ្យោបាយឬវិធានការ ត្រឹមត្រូវ ស្របតាមស្ថានការណ៍តំរូវ ដើម្បីនាំផ្លូវ អ្នកក្រោមបង្គាប់ អនុវត្តកិច្ចការមួយ អោយបានជោគជ័យ ទទួលបាននូវលទ្ធផលដែលចង់បាន។ បើយើងជាមេដឹកនាំ គ្មានគោលបំណង និងទិសដៅច្បាស់លាស់ទេ នោះគ្មាន អ្នកក្រោមបង្គាប់ដើរតាមយើងឡើយ។ គោលបំណង ទៀតសោត ជាគោលបំណងធំចំបង មិនមែនជារឿងសំរាប់បុគ្គល ឬក្រុមគ្រួសារឡើយ។ គោលបំណង នៃមេដឹកនាំខ្មែរ ត្រូវតែគិតដល់ ***ផលប្រយោជន៍រួម ផលប្រយោជន៍ជាតិទាំងមូល***។*ប្រជាជាតិខ្មែរ និងអ្នកស្នេហាជាតិទាំងអស់ ត្រូវមានស្មារតី ស្ម័យភ្ជាក់រលឹកនយោបាយខ្ពស់ ដោយមិនចាំបាច់មានគេដាស់តឿនច្រើន ហើយហ៊ានក្រោកឈរ*

*ឡើងមុនគេ ស្វះស្វែងរកគ្នីគ្នា ចងក្រងកំលាំងស្នេហាជាតិ អោយភ្ញាក់រលឹករួមគ្នាជាធ្លុងមួយ ធ្វើការតស៊ូដើម្បីបុព្វហេតុជាតិ សាសនា និងប្រជាជាតិខ្មែរអោយរួច ចាកផុតពីការជិះជាន់ របស់ពួកមេត្រួតត្រាផ្តាច់ការ* ***ហ៊ុន សែន*** *ដែលជាកញ្ជះដាច់ថ្លៃ របស់យួន អោយបានទាន់ពេលវេលា ហើយពួតដៃគ្នា នាំជាតិយើងអោយទទួលបាននូវ ឯកភាពជាតិ សន្តិភាព ឯករាជ្យភាព អធិបតេយ្យភាព ប្រជាធិបតេយ្យពិត និងវិបុលភាពពិតប្រាកដមួយប្រកបដោយ ឧត្តមភាព អោយបានយ៉ាងដាច់ខាត* សំរាប់ខ្លួនយើង និងកូនចៅខ្មែរជំនាន់ក្រោយ។ គ្រប់ដង្ហើមចេញចូល យើងត្រូវទន្ទេញ រលឹក ចងចាំជានិច្ចថា តើយើងមានបំណងធ្វើអ្វី? ធ្វើយ៉ាងម៉េច? ធ្វើនៅពេលណា? ត្រូវធ្វើនៅកន្លែងណា? នរណា ចង់បាននូវលទ្ធផលនេះ?។ យើងត្រូវរៀបចំខ្លួនយើងជាមុន មុននឹងទៅដឹកនាំគេ ដូចព្រះសង្ឃដែរ ត្រូវបំពេញធមិជាមុន មុននឹងទទួលបានការអោនកាយថ្វាយបង្គំដោយសុទ្ធចិត្តពីពុទ្ធបរិសទ័។ ***មិនខ្វះទេអ្នកដើរតាម ខ្វះតែអ្នកដឹកនាំ ដែលធ្វើខ្លួន អោយគេទទួលព្រមដើរតាមប៉ុណ្ណោះ***។

## IV‿សមត្ថភាព ឯកទេស និងការពិសោធន៍ច្បាស់លាស់ ( Professional Skills and Experiences)

មេដឹកនាំ បីដូចជា អ្នកបើកបរនាវាម្នាក់ ជាអ្នកដែលស្គាល់ទឹសដៅច្បាស់ មានឯកទេសក្នុងការបើកបរពិតប្រាកដ ដើម្បីនាំខ្មែរឱ្យដល់ត្រើយ ប្រកបដោយសុវត្ថិភាព។ តែបើខ្លួនឯងមិនស្គាល់ផ្លូវច្បាស់ទេនោះ នឹងនាំឱយអ្នកដើរតាម វង្វេងផ្លូវ មានគ្រោះថ្នាក់ដល់អាយុជីវិត។ មេដឹកនាំខ្មែរពិតប្រាកដ គឺជាអ្នកដែល ***មានសមត្ថភាព មានឯកទេស ការពិសោធន៍ និងស្នាដៃអ្វីមួយពិតប្រាកដ*** ដូចជា ឯកទេសខាងច្បាប់ សេដ្ឋកិច្ច នយោបាយ យោធា សង្គមកិច្ច និងវិស័យាផ្សេងៗ ជាដើម។ មេដឹកនាំគ្មានសមត្ថភាព ឬគ្មានចំណេះដឹង បើទោះជាមានគំនិតស្នេហាជាតិធំប៉ុណ្ណា ក៏មិនអាចកែខៃបញ្ហាជាតិបានឡើយ។ បើយើងសង្កេតមើលប្រទេសខ្មែរបច្ចុប្បន្ន ក្រោមការត្រួតត្រាពួក **ហ៊ុន សែន** ជនពាលកំឡៅ, **ហេង សំរិន** អ្នកកាប់ជ្រូក អានអក្សរខ្មែរមិនត្រូវ, **ជា ស៊ីម** ជាចោរលួចគោនៅតាមព្រំដែន ហើយអួតខ្លួនថា ជាបណ្ឌិតទាំងងងិតងងល់ឥតអៀនខ្មាស តើប្រទេសជាតិនឹងរីកចំរើន ដូចម្តេចកើត? បើថា បំរើផលប្រយោជន៍យួន ដើម្បីអំណាចទើបត្រូវជាង។ ទង្វើរបស់ពួក ចោរ តាំងខ្លួនធ្វើចេះទាំងនេះ មានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់ប្រទេសជាតិ ឬអាចថាជាទង្វើក្បត់ជាតិដោយចេតនា ដូចគ្នានឹងពាក្យថា ***អ្នកខ្វាក់នាំផ្លូវ អ្នកវង្វេង*** ឬក៏ថា ***"ការដឹកនាំដោយភាព ល្ងង់ខ្លៅមានទោសស្មើនឹង អំពើក្បត់"*** យ៉ាងដូច្នោះ ដែរ។

ត្រង់ចំណុចនេះ សូមលើកយករឿងព្រេងខ្មែរមួយមកវិភាគ អំពីការដឹកនាំ គឺរឿង **ធនញ្ជ័យ**។ អ្នកនិពន្ធបង្ហាញពីវិរភាពរបស់ ធនញ្ជ័យ ដែលមានត្រកូលជារាស្ត្រសាមញ្ញ អាចការពារទឹកដីទល់នឹង ការឈ្លានពានពី បរទេស (ចិន)ដោយសារភាពឈ្លៀសវៃ និងសមត្ថភាព។ ដោយស្មារតីទទួលខុសត្រូវ មានគំនិតស្នេហាជាតិខ្ពង់ខ្ពស់ ធនញ្ជ័យ អាចដោះស្រាយប្រស្នា ជាមួយអ្នកប្រាជ្ញចិន បានដោយជោគជ័យ ចំណែកស្តេច គិតតែរឿង ស្រីញី ស៊ីជោរ ហើយលង់នឹងការអែបអបលុតក្រាប និងរាជបល្ល័ង្គ គ្មានសម្ថភាពការពារប្រទេសជាតិ មិនហ៊ានយកអ្នកប្រាជ្ញមកជិត ខ្លាចគេដណ្តើមអំណាច រហូតបញ្ជូអោយគេសំលាប់អ្នកប្រាជ្ញចោលថែមទៀត។ ទាំងនេះ សរបញ្ជាក់ថា ស្តេច អសមត្ថភាព ល្ងង់ខ្លៅ រមែងភ័យព្រួយខ្លាច ពួកបណ្ឌិតអ្នកប្រាជ្ញ។ ចំណែក ធនញ្ជ័យ ជាកូនរបស់ពលរដ្ឋក្រីក្រ សាមញ្ញសោះ បើទោះ ត្រូវរងនូវការពាធាព្យាបាទ ពីពួក ស្តេច ស្តេចសង្ឃ និងមន្ត្រីអែបឡបយ៉ាងណាក្តី ក៏មិនលះបង់នូវគំនិតខ្វល់ខ្វាយ ពីជោគវាសនារបស់ប្រទេសជាតិ ជនរួមលោហិតសោះឡើយ នៅតែរិះរកមធ្យោបាយ ជួយការពារប្រទេសជាតិ ទឹកដីអោយនៅគង់វង្សពីការរំលោភ បំពាន ចង់បាន ទឹកដីពីបរទេស (ចិន)ជិតខាង លុះត្រាតែបានសំរេចជោគជ័យ។ ដោយមានការព្យាយាមសិក្សាពី ព្រះគ្រូចៅអធិការរបស់ខ្លួន យ៉ាងស្វិតស្វាញ ធ្វើអោយធនញ្ជ័យ មានចំណេះប្រាជ្ញា អាចអូសទាញ ពួកសេដ្ឋី និងស្តេច ឱយលុះតាមគំនិតរបស់ខ្លួនបាន យ៉ាង

ប្រសើរ។ រឿងនេះអ្នកនិពន្ធចង់បញ្ជាក់ថា តួរអង្គស្ដេច ក្នុងរឿងនេះ គ្មានសមត្ថភាពដឹកនាំប្រទេសជាតិទាល់តែសោះ និង បង្ហាញថា ពលរដ្ឋ ក៏មានសមត្ថភាពអាចដឹកនាំប្រទេសផងដែរ តែពួកគេគ្មានឱកាស។ បានន័យថា មិនមែនមានតែពូជ ស្ដេច ទេ ទើបមានសមត្ថភាព ហើយក៏មិនមែន អោយតែរាស្ត្រសាមញ្ញ សុទ្ធតែអ្នកល្ងង់ខ្លៅនោះឡើយ។ អ្នកនិពន្ធចង់គូស បញ្ជាក់ ម្យ៉ាងទៀតថា ស្ដេចដែលបន្ទុបដោយបរទេស តែងមានចរិតមួយ គឺ " ពេលអាសន្ន ត្រូវការអ្នកក្លាហាន អ្នកប្រាជ្ញ ពេលបាន បល្ល័ង្ក បានអំណាចក៏ខ្លាចអ្នកប្រាជ្ញ អ្នកក្លាហានដណ្ដើមបុណ្យ ហើយក៏តាំងរកលេសសំលាប់អ្នកទាំងនេះចោល "។ ហេតុដូច្នេះ ហើយ បានជាប្រទេសពាក់កណ្ដាលលើពិភពលោក បានដើរទៅរកលទ្ធិប្រជាធិបតេយ្យ ឱយអំណាចប្រជាពលរដ្ឋជាធំ។ ពេល ធនញ្ជ័យជិតស្លាប់ ធនញ្ជ័យ បានផ្ដាំស្ដេចថា "*បើស៊ី ត្រីព្រួលកុំចោលស្រកា ស៊ីត្រីប្រា កុំចោល ស្រកី*" កុំថាឡើយ ដល់ទៅគិត ឃើញ សូម្បីតែអត្ថន័យនៃប្រយោគរបស់ ធនញ្ជ័យ ក៏ស្ដេចកំឡៅនេះមិនយល់ផង។ អ្នកនិពន្ធក៏ចង់គូស បញ្ជាក់ ផងដែរថា ក្រោយសម័យអង្គរ ខ្មែរកាន់តែចុះខ្សោយ រៀវរួញតូច មកដល់សព្វថ្ងៃ ក៏ព្រោះតែប្រទេសខ្មែរមានតែស្ដេចអសមត្ថភាពឡើង ត្រួតត្រាប្រទេសប៉ុណ្ណោះ ឬត្រូវបានត្រួតត្រាដោយពួកស្ដេច ដែលលើកបន្ទុបដោយបរទេស ឬជាអាយ៉ងបរទេសជារៀងរហូត មក (សូមអានប្រវត្តិសាស្ត្រខ្មែរ)។ ប្រទេសខ្មែរសព្វថ្ងៃ ក៏មានសភាពដូចគ្នា នឹងរឿងនេះដែរ។ នេះជាកត្តាស្លាប់រស់មួយ នាំ អោយខ្មែររលត់រលាយចុះខ្សោយ រកកលនឹងស្លាប់ដូចពេលបច្ចុប្បន្ន ។ ដោយហេតុដូចបានពន្យល់រៀបរាប់មកខាងលើ ទើប បានជា នៅក្នុងសង្គមប្រជាធិបតេយ្យ អ្នកដឹកនាំ គេអោយប្រជាពលរដ្ឋមានតំលៃ មានសិទ្ធិស្មើគ្នា ទាំងប្រុសស្រី។ ប្រជាពល រដ្ឋ ត្រូវបានបណ្ដុះអោយមានសមត្ថភាពគ្រប់គ្នា ដើម្បីដឹកនាំប្រទេស ទើបប្រទេស មានការរីកចំរើន មិនមែនមានតែមនុស្ស ម្នាក់ ដែលខ្លាំងដូច អាយ៉ងយួន **ហ៊ុន សែន** ឡើយ (គំនិតច្រើន ប្រសើរជាង គំនិតមួយ ឬក៏ថា ស្ដុកអ្នកចេះ ប្រសើរជាង ស្ដុកស្មៅ ស្ដុកមនុស្សខ្លៅ ស្ដុកស្មៅប្រសើរជាង)។

តាមពិតប្រទេសខ្មែរត្រូវទទួលបានស្ថេរភាព និងសន្តិភាព រុងរឿងចាប់តាំងពី បារាំងប្រគល់ឯករាជ្យនា ឆ្នាំ១៩៥៤ មកម្លេះ។ តែផ្ទុយទៅវិញ ប្រទេសខ្មែរបានធ្លាក់ចូលក្នុងសង្គ្រាមចាប់ពីឆ្នាំ១៩៦៤ បន្តរហូតដល់ ព្រឹត្តិការទំលាក់ **សី ហនុ** បាន កើតឡើងនៅថ្ងៃ ១៨ មីនា ១៩៧០។ **ស្ដេចនេះ មិនបានយកពេលវេលាដ៏មានតំលៃ នៃសន្តិភាពដ៏ល្អប្រសើរជិត ២០ឆ្នាំ នេះ ដើម្បីកសាងប្រទេសទេ តែបែជាលីលា ហាក់លោត តាមខ្សែវៀញក់ យួន ចិន ឆ្កួតនឹងអំណាច ស៊ីជោរតាមការ បញ្ចោរ ការ បញ្ចើចបញ្ចើ ពីពួក យួនចិន ទាំងនេះ និងគិតតែតែងកុនល្ខោន ដែលមើលមិនយល់នោះទៅវិញ។ សូម្បីតែដល់ ក៏រិតសព្វថ្ងៃ នេះទៅហើយ នៅតែឆ្កួតនឹងការរាំច្រៀង តែងកុន តែល្ខោនដដែល ។ បើជា កុនល្ខោន ប្រវត្តិសាស្ត្រជាតិ ដែលខ្លួនបាន ដឹង បានឆ្លងការនោះ ជាការប្រសើរ តែជារឿងលីលា ស្រីក្មេងទៅវិញ។**





















**ស្តេចតឿនេះ មិនព្រមធ្វើសម្ពន្ធ័មិត្រក្នុងភាពស្មើមុខ នឹងមហាអំណាចផុតលេខ លើលោកទេ តែសុខចិត្តប្រមូលទាំងពូជ ទៅធ្វើខ្ញុំកញ្ជះដាច់ថ្លៃរបស់ ឆ្កែបំរើ** (ហ៊ុន សែន) **យួន ទៅវិញ**។ កំហុសឆ្គងរបស់ ស្តេច សីហនុ ក្នុងការអនុញ្ញាតអោយចោរយួនយៀកកុង ដាក់តាំង ទ័ពជិត ១សែន នាក់ (ពេលនោះ ទាហានខ្មែរ មានមិនដល់ ៤០០០០នាក់ ផង) នៅលើទឹកដីខ្មែរ ជាហេតុនាំអោយសង្គមជាតិ បាក់បែកប្រេះឆាជាបក្ស ជាក្រុម និងជាដើមចមនាំអោយមានព្រឹត្តិការ ១៨ មិនា ១៩៧០ នោះកើតមានឡើង ក្រោមការដឹកនាំ របស់លោក **លន់ នល់** និងទ្រង់ ស៊ីសុវត្ថិ សិរិមតៈ ដើម្បីដេញ យួន យៀកកុង ពីទឹកដីខ្មែរ។ សូមបញ្ជាក់ថា ព្រិត្តិការណ៍ ១៨ មិនា ១៩៧០ នោះ មិនអាចកើតមានឡើងដោយឯកឯង ឬដោយចៃដន្យឡើយ បើគ្មានអំពើក្បត់ជាតិរបស់ស្តេច សីហនុ ទេនោះ។ សង្គ្រាមរីកវរ ពេញផ្ទៃប្រទេស រវាង កងទ័ពកុម្មុយនិស្ត ដែលមានយួន យៀកកុង ជួយគាំទ្រយ៉ាងពេញទំហឹង បានរីករាលដាលរហូត ដល់ថ្ងៃ ១៧ មេសា ១៩៧៥។ *ថ្ងៃ ១៧ មេសា ១៩៧៥ ជាថ្ងៃ ជ័យជំនះរបស់យួនកុម្មុយនិស្តឥណ្ឌូចិន មិនមែនជាជោគជ័យរបស់ពួកកុម្មុយហិស្ត ប៉ុល ពត ទេ។ ចាប់ពីថ្ងៃ ១៨ មិនា ១៩៧០ ដល់ ៧ មករា ១៩៧៥ យួនបានប្រើ ស្តេច* ***សី ហនុ*** *ដែលមានគំនុំសងសឹក នឹងជនរួមជាតិខ្មែរស្លូតត្រង់ ដែលមិនដឹងអី ហើយ និងសភាជាតិខ្មែរ ដែលបានទំលាក់ខ្លួនពីអំណាច អោយអំពាវនាវ តាមវិទ្យុប៉េកាំង ដល់ខ្មែរ អោយចូលព្រៃម៉ាគី (ចូល ព្រៃតស៊ូ) មកច្បាំងនឹងខ្មែរគ្នាឯង។ ស្តេចលីលានេះ ធ្វើដោយរីករាយ ទាំងងមើលពកថ្វាស ដោយមិនគិតថាខ្លួនកំពុងតែសំលាប់ជនជាតិខ្មែរទាំងឡាយ ដែលគោរព ដែលហៅខ្លួនឯងថា ឪ ឪ ឪ ពេញមាត់ ។ យួនប្រើប្រាស់ លទ្ធិកុម្មុយនិស្ត ជាមធ្យោបាយដើម្បីបំបែកបំបាក់សង្គមខ្មែរ និងប្រើប្រាស់ពួកខ្មែរយៀកមិញ ដែលយួនបាន ចាប់បញ្ចូនទៅ បំពាក់លទ្ធិកុម្មុយនិស្ត នៅយួនខាងជើង និងឆ្វេងជ្រុលនិយម ប៉ុល ពត សីហនុ ដោយមានភ្នាក់ងារយួន បន្លំខ្លួនជាខ្មែរ បង្កប់ជាមួយ ពួកក្របាម ទាំង ៣ក្រុមនេះ ធ្វើការញុះញង់ អោយមានការកាប់សំលាប់គ្នារវាងខ្មែរគ្នាឯង ជាពិសេស អោយធ្វើការកាប់សំលាប់សងសឹកទៅលើ ពួកអ្នកជាតិនិយម ដែលស្រឡាញ់លទ្ធិប្រជាធិបតេយ្យ (ពួកសាធារណរដ្ឋ* ***លន់ នល់*** *និង* ***សិរិមតៈ)*** *ហើយលាបពណ៌ទំលាក់*

*កំហុសទាំងស្រុងទៅលើ របប ប៉ុល ពត ។ រួចហើយយួនដដែលនេះ បានយកពួកខ្មែរយៀកមិញ មួយក្រុមទៀតដែលមាន ប៉ែន សុវណ្ណ, ហេង សំរិន, ជា ស៊ីម, ហ៊ុន សែន ជាខែល ដើម្បីវាយលុកចូលស្រុកខ្មែរ ដោយយកលេសថា មកជួយរំដោះខ្មែរពីរបបវាលពិឃាតទៅវិញ ។ យួនទុក* ***ស៊ី ចាន់*** *ជាខែលសំលាប់ចិត្តពលរដ្ឋខ្មែរ រហូតមកដល់បច្ចុប្បន្ន ។ ថ្ងៃ ៧ មករា ១៩៧៩ មិនមែន ជាថ្ងៃ រំដោះទេ តែជា ថ្ងៃដែលយួន ឈ្លានពានលេប យកទឹកដីខ្មែរ និងប្លន់យកទ្រព្យសម្បត្តិខ្មែរយ៉ាងប្រាកដ ហើយក៏ជាថ្ងៃដែលយួន លើកបន្តុប ពួកក្បត់ជាតិ* ***ហេង សំរិន, ហ៊ុន សែន, ជា ស៊ីម*** *អោយត្រួតត្រា ប្រទេសខ្មែរ ដើម្បីបន្តអនុវត្តនី នយោបាយកាប់សំលាប់ រំលាយពូជសាសន៍ខ្មែរតទៅទៀត ( សង្គ្រាមផ្ទៃក្នុង និង ក៥) រហូតដល់ឆ្នាំ ១៩៩៣ ។ រហូតមកទល់សព្វថ្ងៃនេះទៀតសោត អាយ៉ង ហ៊ុន សែន, ជា ស៊ីម, ហេង សំរិន, នៅតែអនុវត្តន៍នយោបាយកាប់សំលាប់នេះ ជាដរាបមកដោយគ្មានឈប់ឈរ ក្រោមផ្លាក រាជានិយមថ្មី មានស្តេច សីហនុ ជួយបិទបាំង នយោបាយក្បត់ជាតិរបស់ពួកវា និងផែនការខ្មៅក្រខ្វក់របស់យួន ។ បើយួន ជួយខ្មែរ ហេតុអ្វី បានជាមានការចងក្រងប្រវត្តិសាស្រ្តក្លែងក្លាយ ទុកអោយខ្មែររៀន នេះមិនគឺជាមហិច្ឆិតាលេបយកដីខ្មែរ ដែលមានការគ្រោងទុកយ៉ាងល្អិតល្អន់ទេឬ? ។*

ព្រះពុទ្ធជាអង្គម្ចាស់បានត្រាស់ថា " ***មិនត្រូវអោយជនពាលអវិជ្ជា មានអំណាចដឹកនាំឡើយ*** ***ព្រោះថាជន ប្រភេទនេះមានតែការលោភលន់ សាហាវយង់ឃ្នង និងការស្រេកឃ្លាមប្រជាពលរដ្ឋឯង ឬឪពុកម្តាយបង្កើតខ្លួនឯង ដើម្បីអំណាច*** " ។






គំនិតមួយទៀតបានពោលថា " ***មិនត្រូវឱ្យជនពាលមានអំណាចឡើយ តែត្រូវដកហូតអំណាចពីជនពាល មកប្រគល់ជូនអ្នកដែលមានគុណធម៌ មានសមត្ថភាព ស្មោះត្រង់នឹងជាតិ ប្រជាជាតិខ្មែរវិញ*** " ។

**កត្តាដែលនាំអោយខ្មែរមានសង្គ្រាមបង្ហូរឈាមដោយសារ :**

- "**កំហុសមេដឹកនាំ** " ( ជាស្តេច ដែលបន្តុបដោយបរទេសឈ្លានពាន ជាជនល្មោភអំណាច គ្មានគំនិតស្នេហាជាតិ សាសនា និងប្រជាជាតិខ្មែរទាល់តែសោះ ។ មេដឹកនាំ អសមត្ថភាព ដឹកនាំដោយបុគ្គលម្នាក់ មិនមែនជាក្រុមមេដឹកនាំ ) ។
- "**នយោបាយដឹកនាំ**" ( នយោបាយដឹកនាំមិនត្រឹមត្រូវ គ្មានចក្ខុវិស័យ គ្មានឯករាជ្យ គ្មានឥស្សរភាព ខាងគំនិត ។
- "**ប្រព័ន្ធគ្រប់គ្រង**" ( ប្រព័ន្ធដឹកនាំបែបបុគ្គលនិយម ចាស់គំរិល ផ្តាច់ការ អត្តាធិបតេយ្យនិយម ) ។
- "**វិប្បត្តិរាជវង្ស**" ( ទាស់ទែង ដណ្តើមអំណាចគ្នា ពឹងពាក់បរទេស នឹងភាពជាអាយ៉ងបរទេស ) ។
- **នយោបាយវាតទីនិយម លេបទឹកដីពីសំណាក់ យួន សៀម** ជាដើម ( យក មនោគមន៍វិជ្ជាកុម្មុយនិស្ត ឬ សាសនា ជាមធ្យោបាយ) ។

- **ខ្មែរមើលងាយខ្លួនឯង** ( មើលងាយខ្លួនឯង អោយតំលៃជាតិដ៏ទៃជាងខ្មែរគ្នាឯង ពឹងផ្អែកតែទៅលើ បរទេស ដើម្បីអំណាច ។ ខ្មែរបាត់បង់ ព្រលឹងឯកភាពជាតិ ព្រលឹងជាអ្នកក្លាហាន ព្រលឹងជាអ្នកកសាងអង្គរ ។

## V. សេចក្តីក្លាហាន និងការប្តេជ្ញាចិត្ត (Braveness and Commitment)

យើងជាមេដឹកនាំខ្មែរ ត្រូវតែមានសេចក្តីក្លាហាន នាំមុខគេ មុនគេ ពុះពារគ្រប់ឧបស័គ្គជានិច្ច មិនត្រូវរួញរា ឬកំសាក ខ្លាចស្លាប់នោះឡើយ ។ ពោលគឺ យើងមិនអាចដឹកនាំគេបានទេ បើយើងនៅពីខាងក្រោយគេ ។ ដូចពុំនោលមួយពោលថា *" បើដឹងហើយមិនហ៊ាន រៀនចេះហើយមិនធ្វើ ប៉ងហើយស្ទាក់ស្ទើរមិនប្តូរផ្តាច់ សំរេចចិត្តមិនទាន់ពេលវេលា តើនឹងមានប្រយោជន៍អ្វី? "* ។ យើងជាខ្មែរអ្នកស្នេហាជាតិគ្រប់រូប ត្រូវរៀនយកចំណេះមកជួយ បំរើជាតិយើងអោយរីកចំរើនរុងរឿង ។ គ្មាននរណាម្នាក់ដែលអាចរស់នៅ ជាអមតៈឡើយ កើតមកហើយគង់តែស្លាប់ទៅវិញ ។ ហេតុដូច្នេះហើយ ក្នុងនាមជាមេដឹកនាំខ្មែរមួយរូប យើងត្រូវតែហ៊ានធ្វើអ្វីមួយជាប្រយោជន៍ ដល់សង្គមជាតិ និងប្រជាជាតិខ្មែរ ដោយមិនខ្លាចរអា ចំពោះសេចក្តីស្លាប់ ព្រោះថា សេចក្តីស្លាប់មានចំពោះមនុស្សគ្រប់រូប គ្មាននណាម្នាក់ចៀសផុតឡើយ គ្រាន់តែមុននិងក្រោយតែប៉ុណ្ណោះ ។ ប្រទេសជាតិកំពុងធ្លាក់ក្នុងមហន្តរាយហើយ យើងជាមេដឹកនាំខ្មែរ ត្រូវតែស្វះស្វែងរត់រករួបរួមគ្នា ក្រោកឈរឡើង ធ្វើការ សង្គ្រោះ ការពារជាតិ កុំអោយបាត់បង់ ។

**សេចក្តីក្លាហាន** នៅទីនេះ សំដៅទៅលើអ្នកដែលហ៊ានក្រោកឈរ ហ៊ាននិយាយ ហ៊ានធ្វើ និងខិតខំប្រឹងប្រែង យ៉ាងពេញទំហឹង អស់ពីកំលាំង កាយ ចិត្ត ដោយមិនដេករង់ចាំមានមេដឹកនាំឯណាឡើយ ។ យើងជាខ្មែរ មានបុព្វសិទ្ធិពេញលេញ ត្រឹមត្រូវ ស្របច្បាប់ ក្នុងការនាំគ្នាក្រោកឡើង ដោយសេចក្តីតាំងចិត្ត យ៉ាងមុតមាំ ដើម្បីជួយស្រោចស្រង់ សង្គ្រោះជាតិខ្មែរ ដែលកំពុងឈានទៅរកហាយនភាព ដ៏ធ្ងន់ធ្ងរនេះ ។ ព្រោះថា បើជាតិខ្មែររស់ ទើបយើងជាប្រជាជាតិខ្មែរទាំងអស់ រស់នៅដោយមានតំលៃជាមនុស្ស មានកិត្យានុភាពនិងមោទនភាពជាខ្មែរ នៅលើពិភពលោកនេះ ។ យើងមិនត្រូវរង់ចាំអ្នកមានបុណ្យពីណាមកដឹកនាំខ្មែរឡើយ ព្រោះពាក្យថា អ្នកមានបុណ្យ គ្រាន់តែជាពាក្យ ធ្វើអោយខ្មែរដេកលក់ អាចជាពាក្យបោកប្រាស រៀបចំឡើងដោយ ពួកអ្នកសង្គ្រាមចិត្តសាស្ត្ររបស់យួន ដើម្បីគ្រាន់តែជាមធ្យោបាយធ្វើអោយខ្មែរ សង្ឃឹមនៅក្នុងរណ្តៅមរណៈតែប៉ុណ្ណោះ ។ ការរង់ចាំនេះ ជាការរង់ខ្យល់ រង់ចាំផ្កាយលើមេឃ ដែលគ្មានថ្ងៃកើតមានការពិតសោះឡើយ ហើយជាការរង់ចាំ ទុកឱកាសអោយយួនប្រើ **ហ៊ុន សែន** សំលាប់ឆន្ទៈខ្មែរ រហូតដល់កំរើកលែងរួច បាត់បង់ទឹកដីទាំងស្រុង ដូចប្រទេសចំប៉ា និងកម្ពុជាក្រោមតែប៉ុណ្ណោះ ។ ពេលនោះ ខ្មែរយើង ប្រាកដជា ហួសពេលទៅហើយ ។

បើយើងទាំងអស់គ្នាបណ្តែតបណ្តោយ ទុកអោយជាតិយើងស្លាប់ នោះ ប្រវត្តិសាស្ត្រ មនសិការ នឹងដៀលត្មះយើងថា ជាជនរមិលគុណជាតិ ដែលជាអ្នកបានផ្តល់កំណើតអោយយើងរាល់គ្នា ។ ជាតិយើង កំពុងតែមានជំងឺ បីដូចជាឪពុក ម្តាយយើងមានជំងឺដូច្នោះដែរ បើយើងមិនបីបាច់រក្សាការពារ ឬព្យាបាលលោក អោយមានជីវិតជីវ៉ា ទាន់ពេលវេលាទេ ពេលដែលលោកស្លាប់ ទៅវាគ្មានប្រយោជន៍អ្វី ដែលយើងនាំគ្នា យំសោកសង្រេងស្តាយក្រោយ ប្រឹងធ្វើបុណ្យអោយនោះសោះឡើយ ព្រោះថា លោកមិនអាចរស់មកវិញបានទេ ។ ចំពោះជាតិវិញក៏ដូច្នោះដែរ យើងត្រូវតែនាំគ្នាថែរក្សា កាពារជាមុន កុំអោយបាត់បង់ទឹកដី និងពូជសាសន៍យើងជាដាច់ខាត ។ ការរួបរួមពិត ជាកំលាំងចលករដ៏មហាសាល អាចវាយរុញច្រាន សត្រូវយួន

និង អាយ៉ងអោយរលាយសាបសូន្យបាន បើយើងទាំងអស់គ្នាមានសេចក្តីតាំងចិត្តមុតស្រួចជាងខ្មាំង តស៊ូអត់ធ្មត់ ទ្រាំអត់ ទ្រាំឃ្លានខ្ពស់ជាងខ្មាំង យើងប្រាកដជាបានជោគជ័យ។ ចង្កើះមួយបាច់ យួនកាច់មិនបាក់ បើយើងតែម្នាក់ យួននឹងបំបាក់បាន។ យ៉ាងណាមិញ បើទោះបីយើងមានគំនិតស្នេហាជាតិ ជ្រាលជ្រៅក៏រិតណា ប្តូរផ្តាច់ថ្នាក់ណាក្តី តែបើយើងមិនស្វះស្វែង រត់រកចងបាច់គ្នាជាបាច់ ជាធ្លុងមួយទេ យើងមិនអាចទទួលជោគជយ័បានសោះឡើយ។

យើងគួរលើកយក រឿងអាខ្វាក់អាខ្វិន មកពិចារណា នឹងធ្វើអោយយើងយល់បានថា អ្នកនិពន្ធចង់បញ្ជាក់ថា ស្តេចដែលតាំងខ្លួនជាម្ចាស់ផែនដី មានតែភាពកំសាក សុខចិត្តឱយរាស្ត្រ ស្លាប់ ជំនួសខ្លួនទៅវិញ ដោយធ្វើយ៉ាងណា អោយតែខ្លួនបានរស់នៅបល្ល័ង្គ លើអំណាចប៉ុណ្ណោះ ខ្វះការទទួលខុសត្រូវ ខ្វះក្តីក្លាហានអង់អាច អោយសមឋានៈ ខ្វះភាពប្តូរផ្តាច់រួមសុខរួមទុក្ខជាមួយរាស្ត្រខ្លួនឯង។ ផ្ទុយទៅវិញ ដោយស្មារតីសាមគ្គី រួបរួមគ្នា នាយខ្វាក់នាយខ្វិន ជាជនសាមញ្ញ បើទោះបីខ្លួនជាជនពិការ និងដឹងខ្លួនថាត្រូវស្លាប់ក្តី តែបានពួតដៃរួមគ្នា យ៉ាងក្លៀវក្លាអង់អាចក្លាហាន ពេញដើមទ្រូងជាកូនប្រុស ងើបឡើងតស៊ូ ដើមី្បការរស់រានរបស់ខ្លួន នឹងប្រជាជាតិ។ ពួកគេមិនត្រឹមតែ អាចការពារជីវិតខ្លួន ពីចំណើយក្សប៉ុណ្ណោះទេ តែអាចការពារជីវិត ប្រជាជាតិ ជនរួមជាតិ អោយរស់រួចផុតពីចំណើយក្ស បានដោយជោគជ័យ។ នាយខ្វាក់នាយខ្វិន មិនបានដេករង់ចាំអ្នកមានបុណ្យ អស្ចារ្យណា មកជួយខ្លួន ដោយភ្លេចការពឹងផ្អែកលើខ្លួនឯងសោះឡើយ។ នេះជាមេរៀនដ៏ប្រសើរ ដែលប្រជាជាតិខ្មែរទាំងអស់ គួរថ្លឹងថ្លែង  ត្រងត្រាប់ យកតំរាប់តាម ហើយក្រោកឡើងរួមគ្នា ធ្វើមេដឹកនាំដោយខ្លួនឯង ដូចនាយខ្វាក់នាយខ្វិន ដើម្បីអាយុជីវិតប្រជាជាតិខ្មែរ ផលប្រយោជន៏ជាតិ និងប្រទេសខ្មែរយើងអោយគង់វង្ស ក្នុងកាលៈទេសៈនេះ។

## VI-សុខភាពល្អ  (Healthy)

**សុខភាព**នៅទីនេះ សំដៅទាំងពីរយ៉ាង ទាំង*សុខភាពខាងផ្លូវកាយ* និង*សុខភាពផ្លូវចិត្ត*។ សុខភាពខាងផ្លូវកាយសំដៅទៅលើកាយសម្បទា។ ក្នុងឋានៈជា មេដឹកនាំ ត្រូវតែជាមនុស្សដែលមានលក្ខណៈពេញលេញ ប្រុស ឬស្រី ពិតប្រាកដ មិនមែនជាមនុស្សពិកា នូវញាណមួយណា ហើយគ្មាន ជំងឺឈឺធ្ងន់ធ្ងរ។ សុខភាពមេដឹកនាំ ប្រៀបដូចជាសសរ សំរាប់ទ្រទ្រង់ ផ្ទះ ទាំងមូល អោយមានលក្ខណៈរឹងមាំ។ មេដឹកនាំខ្មែរ ត្រូវមានអនាម័យជានិច្ច រហ័សរហួន សកម្មការងារ និងឧស្សាហ៏ ព្យាយាម។ មេដឹកនាំ មិនមែនជាមនុស្សដែលខ្ជិលច្រអូស ឬប្រមឹក ដែលប្រព្រឹត្តិអំពើទុច្ចរិត មាន ល្បែង ស្រី ស្រា ពុករលួយ អយុត្តិធម៌ និងភូតភរកុហក នោះឡើយ។ មេដឹកនាំខ្មែរ ត្រូវមានទឹកចិត្តរីករាយ ស្រស់ថ្លា រាក់ទាក់ដាក់អ្នកក្រោមបង្គាប់មុនជានិច្ច។ មេដឹកនាំជាតិខ្មែរ មិនប្រកាន់រឿងកំប៉ិកកំប៉ុក ឬក៏ប្រកាន់ ឬកក្រអឺតក្រទម ដាក់អ្នកក្រោមបង្គាប់ ឬក៏ កឹបកេង ជិះជាន់ រឹបយកផលប្រយោជន៏ប្រជាពលរដ្ឋ ដើម្បីជាប្រយោជន៏ផ្ទាល់ខ្លួន ឬបក្សពួកឡើយ។ មេដឹកនាំខ្មែរ មានឥរិយាបទ វិជ្ជមាន និង ស្មារតីរឹងប៉ឹង ទឹកមុខធម្មតា ជានិច្ច ទោះជាក្នុងពេលជួបឧបស័គ្គ ឬកាលៈទេសៈបែបណាក្តី។ (សូមសិក្សាបន្ថែម **វិធីធ្វើ  អោយចិត្តបរិសុទ្ធ** របស់លោក  យាន យាប )។

**សុខភាពផ្លូវចិត្តៈ** មេដឹកនាំត្រូវមានមនោមយិទ្ធិ។ មេដឹកនាំខ្មែរ ត្រូវមាន ចិត្តសាស្ត្រខ្ពស់ អាចស្គាល់ពីចិត្ត គំរូវការ និង អាចទាក់ទាញអ្នកក្រោមបង្គាប់ អោយគោរព ស្រឡាញ់ និង ចូលចិត្តខ្លួន។ មេដឹកនាំខ្មែរ មិនត្រូវមានចិត្តសៅហ្មង ទុក្ខព្រួយ ខ្វាយខ្វល់ អ្វីទាំងអស់។ មេដឹកនាំ ត្រូវមានសមាធិ (ចិត្តស្ងប់) ។ មេដឹកនាំ ត្រូវគ្រប់គ្រងអារម្មណ៏ខ្លួន អោយបានល្អមិនឆាប់រំភើប ស៊ីជោរ អំណួត អន់ចិត្ត ខឹងឆេវឆាវ ច្រណែនឈ្នានីស។ មេដឹកនាំខ្មែរ ត្រូវមានចិត្តល្អ ចិត្តទូលាយ និងចេះជួយ

អ្នកដទៃ។ ម្យ៉ាងវិញ ទៀត មេដឹកនាំខ្មែរ ត្រូវខិតខំព្យាយាម ហ្វឹកហាត់ អោយមានមនោឃិទ្ធិ។ មេដឹកនាំខ្មែរ អាចហាត់រៀន ដោយខ្លួនឯងបាន តាមរយៈការហាត់បញ្ជា លើអារម្មណ៍ខ្លួនឯង កាលណាយើងបញ្ជាលើអារម្មណ៍របស់ខ្លួនឯងបានហើយ ពេលនោះ យើងជាក់ជា អាចបញ្ជាលើអារម្មណ៍ អ្នកដទៃបានដូចគ្នាដែរ។

## VII-គុណធម៌ (Virtue)

មេដឹកនាំខ្មែរ ជាក្រុមជនដែលអាចដឹកនាំប្រទេសទៅរក សុខសន្តិភាព សុភមង្គល ប្រជាធិបតេយ្យ យុត្តិធម៌ រុងរឿង ដល់សង្គមជាតិ។ មេដឹកនាំខ្មែរ ត្រូវតែជាអ្នកមានគុណធម៌ ចំពោះប្រជាពលរដ្ឋខ្មែរ ព្រោះថាមេដឹកនាំ ប្រៀបដូចជា ***ឪពុក*** រីឯ អ្នកដើរតាម ឬប្រជាពលរដ្ឋខ្មែរ ប្រៀបដូចជា ***កូន*** និងជាក្តីសង្ឃឹម *សំរាប់ប្រជាជាតិខ្មែរ ជាលើកចុងក្រោយ* ។ ដូចនេះ មេដឹកនាំខ្មែរ ត្រូវប្រកាន់ខ្ជាប់នូវ ***ព្រហ្មវិហារធម៌*** និង ***ទសពិធរាជធម៌*** ។

### ក-ព្រហ្មវិហារធម៌

តើព្រហ្មវិហារធម៌មានអ្វីខ្លះ? ព្រហ្មវិហារធម៌ មានមេត្តា ករុណា មុទិតា និងឧបេក្ខា។

#### ១-មេត្តា (Love)

**មេត្តា** គឺ សេចក្តីអាណិត ស្រឡាញ់ ចង់អោយអ្នកផងបានសុខ។ មេដឹកនាំខ្មែរ តែងតែមានការអាណិតអាសូរជានិច្ច ដល់ អ្នកក្រោមបង្គាប់ និងប្រជាពលរដ្ឋខ្មែរ ។ យកចិត្តទុកដាក់ខ្ពស់បំផុត ពោលគឺ បើយើងស្រឡាញ់ខ្លួនឯងប៉ុណ្ណា យើងត្រូវតែ ស្រឡាញ់អ្នកដទៃ ក្រុមការងារ កូនចៅ អ្នកក្រោមបង្គាប់ និងប្រជាពលរដ្ឋខ្មែរ ប៉ុណ្ណឹងដែរ។ **ព្រះបាទជ័យវរ្ម័នទី៧** ជាក្សត្រ ដែលមាន ទសពិធរាជធម៌ និងព្រហ្មវិហារធម៌ពិតប្រាកដ ទ្រង់យកព្រះទ័យទុកដាក់ខ្លាយខ្វល់ចំពោះរាស្ត្រជានិច្ច *"ទ្រង់មានព្រះ ទ័យព្រួយបារម្ភ ចំពោះរោគរបស់ប្រជារាស្ត្រព្រះអង្គ ជាងព្រះអាពាធព្រះអង្គទៅទៀត ព្រោះថាសេចក្តីទុក្ខ របស់រាស្ត្រ គឺជា សេចក្តីទុក្ខរបស់អ្នកគ្រប់គ្រងទាំងឡាយ មិនមែនសេចក្តីទុក្ខផ្ទាល់ព្រះអង្គទេ ដែលនាំអោយព្រះអង្គព្រួយឈឺចាប់នោះ "*។ ចូរ យើងហាត់ស្រឡាញ់ អ្នកណាដែលអ្នកស្អប់បំផុត !។

#### ២-ករុណា (Help)

**ករុណា** ចេះជួយសង្គ្រោះ អ្នកដទៃឱយបានសេចក្តីសុខ។ មេដឹកនាំខ្មែរ ត្រូវចេះជួយសង្គ្រោះ អ្នកក្រីក្រលំបាក អ្នករងគ្រោះ អ្នកដែលស្ថិតក្នុងភាពល្ងង់ខ្លៅ និងអ្នកមានវិបត្តិផ្សេងៗ។ មេដឹកនាំខ្មែរ ត្រូវតែហ៊ានលះបង់គ្រប់បែបយ៉ាង ដើម្បីជួយសង្គ្រោះជនរួមជាតិខ្លួន ឱយរួចផុតពីសេចក្តីទុក្ខវេទនាទាំងអស់នេះ តែដំណោះស្រាយក្នុងការជួយសង្គ្រោះត្រូវដោះស្រាយពីដើមចម នៃបញ្ហា កុំព្យាយាមដោះចុងបញ្ហា វាជាការខាតពេល ខាតធនធានឥតប្រយោជន៍ ហើយបើយើងប្រឹងដោះ ខ្លាំងប៉ុណ្ណា បញ្ហាក៏នឹងកើនឡើងប៉ុណ្ណោះ ទោះដោះរហូតស្លាប់ទាំងខ្លួនទៀត ក៏ពុំអាចចប់បានឡើយ។ ព្រះពុទ្ធអង្គ ជាគំរូស្រាប់ ព្រះអង្គ ហ៊ានលះបង់ រាជសម្បត្តិ យសសក្តិ សេចក្តីសុខផ្ទាល់ខ្លួន និងកាមកិលេស តណ្ហាផ្សេងៗ រហូតដល់អាយុជីវិត ដើម្បី ស្វះស្វែងរកផ្លូវ សង្គ្រោះមនុស្សលោកទូទៅ ឱយរួចផុតពី អវិជ្ជា គឺ សេចក្តីទុក្ខ។ លោក ***សឺន គុយ*** ជាវីរៈបុរសខ្មែរក្រោម ហ៊ានលះបង់ជីវិត ដើម្បីរក្សាទុកនូវ ព្រះពុទ្ធសាសនា វប្បធម៌ ទំនៀមទំលាប់ និងប្រពៃណីខ្មែរ នៅកម្ពុជាក្រោមអោយគង់វង្សរហូតមកដល់បច្ចុប្បន្ន។ បុព្វបុរសខ្មែរ អ្នកស្នេហាជាតិ ជាច្រើនទៀត ដែលសុខចិត្តលះបង់បូជាជីវិត ដើម្បីជួយ ការពារ ជាតិ

ទឹកដី កេរ្តិ៍តំណែល និងវប្បធម៌ខ្មែរ អោយរួចផុតពីការឈ្លានពាន លេបត្របាក់របស់បរទេស ធ្វើអោយទឹកដីខ្មែរបាន គង់វង្ស រហូតមកដល់ពេលនេះ។ ចំណែកយើងជា អ្នកដឹកនាំខ្មែរម្នាក់ ដែលកំពុងអានសៀវភៅនេះនៅក្នុងដៃ យើងក៏ត្រូវតែមានការ តព្វកិច្ច ក្រោកឈរដោយស្វយ័ភ្ញាក់រលឹក ជួយសង្គ្រោះជាតិ បងប្អូនរួមឈាមខ្មែរទាំងអស់ អោយរួចផុតពីការលេបត្របាក់ របស់ ចោរយួន ដែលកំពុងធ្វើអាណានិគមទំនើបថ្មី ដោយមាន **ហ្វុក ឡុងឌី, សុខ គង់,** និង **ជនជាតិយួនច្រើន** ទៀត កំពុងលាក់ខ្លួនបង្កប់ក្នុងស្ថាប័នសំខាន់ៗ របស់ជាតិ ត្រួតត្រាប្រទេសខ្មែរ និងត្រូវជួយសង្គ្រោះជាតិខ្មែរអោយរួចផុត ពី របប កុម្មុយនីស្តផ្តាច់ការ **ហ៊ុន សែន** បំរើយួន ហើយនាំប្រជាជាតិ និងប្រទេសខ្មែរ ដើរឆ្ពោះទៅរកការរីកចំរើន គង់វង្ស ក្នុងវិបុល ភាព និងមានថាមពល ស្ថិតស្ថេរ ស្មើមុខនឹងប្រជាជាតិក្នុងលោកអោយបាន។ តើ យើងទាំងអស់គ្នា ជាជាតិខ្មែរ សុខចិត្ត ឈរ អោបដៃមើលទុក្ខវេទនា ប្រជាពលរដ្ឋខ្មែរ ដែលកំពុងតែដង្ហោយហៅរក យើងរាល់គ្នាជាអ្នកស្នេហាជាតិ អោយជួយសង្គ្រោះ ជួយរំដោះ រៀងរាល់ថ្ងៃបានទេ? ឬយើងទុក អោយពូជសាសន៍ខ្មែរយើង ត្រូវរលាយបាត់បង់ពីលោកនេះទៅ នាសម័យនេះ?

### ៣-មុទិតា (Unjealous)

មុទិតា មេដឹកនាំខ្មែរ មិនត្រូវមានចិត្តច្រណែនឈ្នានីស ឬអន់ចិត្តចំពោះការរីកចំរើន ជោគជ័យរបស់អ្នកដទៃ ឬ អ្នកក្រោមបង្គាប់ ឬប្រជាពលរដ្ឋឡើយ។ ផ្ទុយទៅវិញ មេដឹកនាំខ្មែរ ត្រូវសប្បាយត្រេកអរ នឹងសេចក្តីសុខចំរើន របស់ប្រជា ជាតិខ្មែរ ឬរីករាយសាទរ ពេលឃើញ ខ្មែរ បានសេចក្តីសុខដោយសារខ្លួន។ ក្រោយពីពេល ខ្លួនបានជួយសង្គ្រោះ ទោះបីជាគេ មិនថ្លែងអំណរគុណក៏ដោយ ក៏មិនត្រូវទោមនស្ស។ មានន័យថា មេដឹកនាំខ្មែរ មិនត្រូវរំលឹក គុណរបស់ខ្លួន អួតប្រាប់គេអោយ ដឹងពេលជួយអ្នកដទៃនោះទេ ។ តែផ្ទុយទៅវិញ មេដឹកនាំខ្មែរ ត្រូវសរសើរ និងអរគុណ ចំពោះប្រជាជាតិខ្មែរ ដែលបាន ធ្វើល្អ មកលើខ្លួន ទោះជាអំពើល្អនោះតិចក្តី ច្រើនក្តី។ ជឿរឿងគួរអោយអាម៉ាស់ និងឈឺចាប់ ដែលប្រជាជាតិខ្មែររស់ក្រោមបាតជើង ជនពាលកំឡៅដូចបក្សពួក **ហ៊ុន សែន** សព្វថ្ងៃនេះ។ ជនកំឡៅនេះ តែងតែបញ្ជាអោយ ដកហូតយកទៅវិញនូវ របស់របរ ទាំងឡាយ ដែលវាយកមកបោកខ្មែរ បើតំបន់នោះរាស្ត្រខ្មែរមិនបោះឆ្នោតអោយវា។ ពេលថ្មីនេះ វាបានប្រកាសក្តែងៗថាវា នឹងធ្វើជានាយករដ្ឋមន្ត្រី មួយជីវិត តែវានឹងមិនសាងសង់សាលារៀនទៀតឡើយ បើវាធ្លាក់ពីអំណាច។ វាមិនដែល ដឹងគុណ អរគុណខ្មែរទេ តែវារមែងរលឹកគុណ ដឹងគុណចោរយួន មិនដាច់ពីមាត់។ ដូចស្តេច សីហនុ មិនដែល អរគុណ ខ្មែរអ្នកតស៊ូក្នុង ការជូនដំណើរខ្លួនអោយបានឡើងសោយរាជ្យនោះ សោះឡើយ តែស្តេចនេះ អរគុណអាយ៉ងក្បត់ជាតិ ហ៊ុន សែន ទៅវិញ។

### ៤-ឧបេក្ខា (Justice)

ឧបេក្ខា មេដឹកនាំខ្មែរ ត្រូវប្រកាន់ចិត្តជាកណ្តាល មិនលំអៀង ព្រោះស្អប់ ស្រឡាញ់ ច្រណែន និន្ទាឈ្នានីស អន់ ចិត្ត។ មេដឹកនាំខ្មែរ ស្មោះស្មើចំពោះ ប្រជាជាតិខ្មែរទូទៅ ដោយមិនរើសអើង ដោយសារភាពអគតិ និងការប្រកាន់ បក្សពួក នយោបាយ ដូចអាក្បត់ ហ៊ុន សែន សព្វថ្ងៃនេះឡើយ។ អ្នកដឹកនាំខ្មែរ ត្រូវបង្កើតគោលការណ៍រួម និងច្បាប់រដ្ឋជាច្បាប់ មួយ មានសមភាពអនុវត្តន៍ លើជនទូទៅដូចៗគ្នា ហើយជាអ្នក នាំមុខគេ ប្រតិបត្តិ ប្រកាន់គោលការណ៍ និងអនុវត្តច្បាប់ ឱ្យបាន ត្រឹមត្រូវ។ តែក្នុងរបបក្បត់សព្វថ្ងៃច្បាប់ សំរាប់ចងដៃខ្មែរស្លូតត្រង់ទៅវិញ ឯក្រុមគ្រួសារពួកក្បត់ មិនដែលមានទោសសោះ ឡើយ។ ឧ: នៅ ឆ្នាំ ១៩៩៩ ប្រពន្ធ ហ៊ុន សែន បានចាត់អោយឆ្មែរបស់ខ្លួន បាញ់សំលាប់ សិល្បករខ្មែរដ៏ល្បី អ្នកស្រី ពិសិដ្ឋ ពលីការ ព្រោះតែការប្រច័ណ្ឌ ដោយគ្មានទោសពៃរ៍។ នៅឆ្នាំ ២០០៤ ក្មួយរបស់ ហ៊ុន សែន ឈ្មោះ **នួន សុភា** បាញ់សំលាប់

យ៉ាងវង្វាល លើអ្នកក្រីក្រទាំងកណ្ដាលថ្ងៃ កណ្ដាលទីក្រុងភ្នំពេញ ដោយគ្មានអ្នកណារកយុត្តិធម៌អោយសោះ។ លើសពីនេះ នៅតាមទីក្រុង ប្រជាពលរដ្ឋខ្មែរ ត្រូវបានពួកអាយ៉ង បណ្ដេញចេញពីផ្ទះសំបែងដោយគ្មានសំណង គ្មានការដោះស្រាយ ដើម្បី យកដីលក់ឱ្យឈ្មួញបរទេស។ ផ្ទុយទៅវិញ ជនជាតិយួន ដែលមកតាំងទីលំនៅខុសច្បាប់ ត្រូវបានពួកវាខ្ទះខ្ទែងរកផ្ទះ សំបែង ដីធ្លី និងការឧបត្ថម្ភយ៉ាងប្រសើរ។ មិនមែនត្រឹមតែ លំអៀងដោយអគតិ ទេ តែវាជាការបង្ហាញយ៉ាងច្បាស់ក្រឡែត នូវភាព ជាខ្ញុំកញ្ជះដាច់ថ្លៃ លក់ជាតិលក់ទឹកដី របស់ពួកអាក្បត់ ហ៊ុន សែន សព្វថ្ងៃនេះ។ *មេដឹកនាំ ត្រូវប្រកាន់យុត្តិធម៌ និងការគោរព ច្បាប់ជាធំ ជាចំបង ដោយផ្អែកលើប្រយោជន៍ ជាតិខ្មែរជាធំ។*

## ខ_ទសពិតធម៌

ទសពិធធម៌ គឺជាគោលធម៌ទាំង ១០ប្រការ ដែលមេដឹកនាំ គ្រប់រូបត្រូវតែប្រកាន់ខ្ជាប់ជានិច្ច។ គោលធម៌ទាំង ១០ ប្រការមាន :

### ១-ទាន (Donation)

ទាន គឺការផ្ដល់អោយដូចជា វត្ថុ សំភារៈ ចំណេះដឹង អប់រំ ក្បួនច្បាប់ និងការអប់រំព្រះធម៌ ដល់ប្រជាជាតិខ្មែរ ជាទី ស្រឡាញ់របស់ខ្លួនជាដើម។ មេដឹកនាំខ្មែរ ត្រូវហ៊ានលះបង់ធនធានផ្ទាល់ខ្លួន ធ្វើអំណោយទាន ដល់ប្រជាពលរដ្ឋខ្មែរ ដែលក្រី ក្រលំបាក។ ***មេដឹកនាំខ្មែរ ត្រូវធ្វើទាន ក្នុងគន្លងគតិបណ្ឌិត មិនមែនក្នុងបែបប្រជាភិថុតឡើយ។ ពោលគឺ អំណោយជា ថ្លៃ ខ្សែ សន្ទូច និងចំណេះដឹង ដើម្បីអោយខ្មែរ ចេះរក ចេះស្ទូចត្រី ចិញ្ចឹមជីវិតដោយខ្លួនឯង។ តែមិនមែន យកត្រី សំអុយមួយកន្ទុយ កន្ទបសារុងមួយ ទៅអោយរាស្ត្រខ្មែរ ហើយបង្គាប់ខ្មែរអោយស្អប់ខ្មែរគ្នាឯង ស្រឡាញ់ចោរយួនប្លន់ទឹកដីនោះឡើយ។*** ទង្វើ របស់បក្សពួក **ហ៊ុន សែន** ដែលយកអំណោយ ប៊ីចេងមួយកញ្ចប់ និងកន្ទបសារុងមួយ ទៅចែកអោយខ្មែរ ជាទង្វើបែបហុត ទឹកសំលឹងកាក ដើម្បីបោកប្រាស់ខ្មែរ ឬរយកសន្លឹកឆ្នោត យកអំណាចទៅបំរើផលប្រយោជន៍ បក្សពួកវាមួយក្ដាប់តូច និងយួន ចៅហ្វាយវា។

### ២-សីល (holy)

អ្នកដឹកនាំល្អ គឺជាអ្នកដែលប្រកាន់ខ្ជាប់វិន័យ អំពើល្អ តាមឱវាទព្រះពុទ្ធ។ មេដឹកនាំខ្មែរ ត្រូវមានសីល ៥ក្នុង ខ្លួន។

ទី១-សីលទាំង៥ រួមមាន÷

អ្នកដឹកនាំខ្មែរ **មិនសាហាវយង់ឃ្នង មិនប្រព្រឹត្តអំពើទុច្ចរិតផ្សេងៗ មិនបៀតបៀនមិត្តរួមការងារ អ្នកក្រោមឱវាទ ប្រជាពលរដ្ឋ**របស់ខ្លួន រហូតដល់ការកាប់សំលាប់ជាដើម។ ឧទាហរណ៍ ដូចជារបប **ហ្វាស៊ីស អ៊ីត្លែ, ម៉ូសូលីនី, ម៉ាក្ស លេនីន, ម៉ៅ សេទុង, ប៉ុល ពត,** កុម្មុយនិស្តវៀតណាម (យួន) ខ្មែរក្រហម **ហ៊ុន សែន** ដែលបានធ្វើអោយមនុស្ស ស្លាប់រាប់លាននាក់។

ទី២-អ្នកដឹកនាំខ្មែរ **មិនត្រូវពុករលួយ ស៊ីសំណូក លួចបន្លំ កេងយកទ្រព្យសម្បត្តិជាតិ ឬទ្រព្យបុគ្គល ឬក្រុមគ្រួសារ ណាមួយ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន** ឬប្រយោជន៍ក្រុមគ្រួសារ និងបក្សពួកឡើយ។ មេដឹកនាំ ត្រូវតែមានការស្មោះត្រង់ ចំពោះ ជាតិគ្រប់ពេលវេលា។

តើបក្សពួក **ហ៊ុន សែន** មានលុយមកពីណា រាប់លានដុល្លា ដាក់ធានាគារក្រៅប្រទេស និងទ្រព្យសម្បត្តិហូរហៀរ ផ្សេងៗ ទៀត? យើងគួរពិចារណាមើលថា **ហ៊ុន សែន ហេង សំរិន** និងបក្សពួក ចេញពីរបបប្រល័យពូជសាសន៍កុម្មុយនិស្ត

ឥណ្ឌូចិន មានបាតដៃទទេរ ដូចខ្មែរដទៃទៀតដែរ តែពួកនេះមានទ្រព្យសម្បត្តិច្រើនសន្ធឹកសន្ធាប់ ចាយមិនអស់ ហើយយកទៅលាក់ទុកចោលនៅធនាគារ បរទេសរាប់ពាន់លានដុល្លាទៀត នេះមិន គឺជាការលួចឆក់ប្លន់ទ្រព្យសម្បត្តិខ្មែរទេឬ? ។ សុខចិត្តលួចយកលុយជាតិ ទៅទុកចោល តែអោយប្រជាពលរដ្ឋខ្មែរ ក្រីក្រ រហេម រហាម អត់ឃ្លាន ដាច់ពោះស្លាប់ ។ ពួកជនផ្តាច់ការទាំងនេះ លួចទ្រព្យសម្បត្តិជាតិ ដើម្បីខ្លួនឯង គ្រួសារនិងបក្សពួកខ្លួនតែប៉ុណ្ណោះ ។ ព្រៃឈើ ធនធានធម្មជាតិក្រោមដី លើដី រ៉ែមាស រ៉ែត្បូង ត្រូវពួកនេះ ឃុបឃិតលក់អោយឈ្មួញបរទេស ធ្វើការកាប់គាស់កកាយ គ្មានសល់ ធ្វើអោយកើតគ្រោះរាំងស្ងួតទឹកជំនន់ ។ ការងារនេសាទ អាជីវកម្ម ជំនាញផ្សេងៗ ត្រូវពួកនេះបណ្តោយអោយយួន ចូលមកដណ្តើម យកគ្មានសល់ ធ្វើអោយខ្មែរក្លាយជាជនក្រីក្រ រត់លូនទៅរករស់ នៅប្រទេសជិតខាង យ៉ាងលំបាកវេទនា ហើយត្រូវគេបាញ់សំលាប់ ទាំងកូនក្នុងផ្ទៃ ដោយគ្មានប្រណីមេត្តា ។ ទោះដូច្នេះក្តី ពួកនេះមិនដែលរកខុសត្រូវអោយ ខ្មែរស្លូតត្រង់ទាំងនោះ ទាល់តែសោះ ។ ផ្ទុយទៅវិញ បើជនជាតិយួន ខុសច្បាប់ងាប់ម្នាក់ វាស្រែកស្ទើបែកវិទ្យុទូរទស្សន៍របស់ខ្មែរ ។ នេះជាភាពកញ្ជះដាច់ថ្លៃរបស់ពួកអាក្បត់ ហ៊ុន សែន ។ **ពួក ហ៊ុន សែន, ជា ស៊ីម, ហេង សំរិន ជាជនក្បត់ជាតិ ជាឈ្លើងសង្គម ជាព្រាយបីសាចជញ្ជក់ឈាមខ្មែរ ជាក្រុមចោរលួចជាតិ លក់ជាតិ ជាដើមចម នៃទុក្ខវេទនា ការព្រាត់ប្រាស់ ភាពល្ងង់ខ្លៅ ភ័យខ្លាច អត់ឃ្លាន របស់ខ្មែរ គ្រប់ស្រទាប់ ។** ដូចមានក្នុងរបាយការណ៍ ក្លុបបលវិដណែស ចេញផ្សាយ ជាឧទាហរណ៍ស្រាប់ ។ តើយើងជាបញ្ញវន្តខ្មែរ ជាអ្នកដឹកនាំខ្មែរ សុខចិត្តអោយ ជនក្បត់ជាតិទាំងនេះ បំផ្លាញខ្មែរ សំលាប់ខ្មែរ រហូតដល់ផុតពូជ ឬយើងត្រូវរើ ដើម្បីរស់ មាន ឥស្សរះភាព ស្មើមុខជាមនុស្ស ដូចជាតិនានា? ។



ទី៣-អ្នកដឹកនាំជាតិខ្មែរ **មិនត្រូវពោលពាក្យកុហក ត្រូវតែស្មោះត្រង់** តាំងពីការគិត និយាយ និងកាធ្វើឡើងទៅ ។ ពោល គឺ គិត និយាយ និងធ្វើ តែ១។ មេដឹកនាំជាតិខ្មែរ មិនត្រូវគិតផ្សេង១ និយាយផ្សេង ធ្វើផ្សេងនោះទេ។ អ្នកដឹកនាំខ្មែរ មិនត្រូវភូតភរ កុហក បោកប្រាស់ខ្មែរដើម្បីអំណាច ដូចពួកអាយ៉ង ហ៊ុន សែន ដែលធ្លាប់ធ្វើ និងកំពុងធ្វើសព្វថ្ងៃនេះឡើយ ។

ទី៤-អ្នកដឹកនាំជាតិខ្មែរ **មិនមែនជាអ្នកដែលល្មោភកាមតណ្ហា បុណ្យសក្តិ អំណាច និងទ្រព្យសម្បត្តិជាតិ**ឡើយ ។ មិនត្រូវប៉ះពាល់កូន ប្រពន្ធគេ ឬ ធ្វើអោយខូចខាតផលប្រយោជន៍ជាតិ និងប្រជាពលរដ្ឋខ្មែរ។ ជារឿងដ៏អាស្រូវបំផុត ដែលមានអំណាចដូច ហ៊ុន សែន ហើយទៅរំលោភបំពានលើប្រពន្ធកូនរាស្រ្តឯង ហើយបណ្តោយអោយប្រពន្ធ ខ្លួនឯង ប្រើអាម៉ឺអាថោងទៅបាញ់សំលាប់ព្រៃផ្សៃ ដោយគ្មានទោសពៃរ៍សោះនោះ( រឿង ពិសិដ្ឋ ពីលីកា) ។

ទី៥-មេដឹកនាំជាតិខ្មែរ **មិនត្រូវលង់ ក្នុងការសេពគ្រឿងញៀន អាភៀន កញ្ឆា ស្រី ស្រា ល្បែង** ព្រោះនាំអោយ ខូចស្មារតី និង ប៉ះពាល់ដល់សុខភាព។ ជាពិសេស មេដឹកនាំខ្មែរ ត្រូវប្រយ័ត្ន ចារកម្មយួន ដាក់ថ្នាំតាមម្ហូបអាហារ ថ្នាំពេទ្យ ដើម្បីសំលាប់យើង ឬធ្វើឱយយើងមានជំងឺផ្សេង១ ដូចជារលាកថ្លើម ស្លាប់មួយចំហៀងខ្លួន និងដាច់សរសៃឈាមខួរក្បាលជាដើម។ល។ ជាការចុកចាប់ បំផុតចំពោះមុខមាត់ខ្មែរគ្រប់រូប ដែលត្រូវបិទបាំងលាបលន ដោយជនញាណថ្នាំ ដូចអាក្បត់ ហ៊ុន សែន រូបនេះ។ តើនឹងបំបិទថ្នាំញាណ ម្តេចបាន បើវា ជាមេក្លោងញាណថ្នាំ និង ជាមេក្លោងរត់ថ្នាំញាណដូច្នេះ។







*សារុបមក មេដឹកនាំត្រូវគ្រប់គ្រងអារម្មណ៍ទាំង៦ អោយមានភាពប្រក្រតីជាដាច់ខាត គឺភាពសាមញ្ញ មិនវង្វេង និងលង់តាមអារម្មណ៍ទាំង ៦ នោះឡើយ ព្រោះនាំអោយយើងមានចំណុចខ្សោយភ្លេចស្មារតី។ ព្រះពុទ្ធទ្រង់ត្រាស់ទុកថា" **អ្នកធ្វេសប្រហែស បាត់បង់ស្មារតី ប្រៀបដូចមនុស្សស្លាប់**" ។*

### ៣ -បរិច្ចាគ ឬការលះបង់ (Sacrifice)

បរិច្ចាគ ឬ ការលះបង់។ មេដឹកនាំខ្មែរ ត្រូវលះបង់ខ្លួន ដើម្បីជួយសង្គ្រោះជាតិ អោយរស់រាន មានជីវិតគង់វង្ស។ ការលះបង់ ជាកត្តាសំខាន់ក្នុងទាក់ទាញជំនឿពី អ្នកក្រោមឱវាទ ឬអ្នកដីរិញ អោយដើរតាមខ្លួន។ ភាពកំណាញ់ស្វិត នឹងធ្វើអោយអ្នកដឹកនាំ បាត់បង់ប្រិយ៍ភាព បាត់បង់ជំនឿ ពីអ្នកផង។ ការលះបង់ទីនេះ ចង់និយាយសំដៅ ទៅលើការលះបង់ ដើម្បីសាង ប្រយោជន៏អ្វីមួយសំរាប់សង្គមជាតិខ្មែរ។ ក្នុងឋានះ ជាមេដឹកនាំខ្មែរ ត្រូវហ៊ានធ្វើគំរូ នាំមុខគេ ក្នុងការធ្វើពលិកម្មអាយុជីវិត លះបង់តាំងពី ធនធាន ពេលវេលា សេចក្តីសុខផ្ទាល់ខ្លួន កិត្តិយសមុខមាត់ រហូតដល់ជីវិត ដើម្បីធ្វើប្រយោជន៏ ជូនជាតិ និងជួយសង្គ្រោះ ប្រជាជាតិខ្មែរ ដែលកំពុងរងទុក្ខវេទនា ក្រីក្រ អត់ឃ្លាន ល្ងង់ខ្លៅ និងភ័យខ្លាច រស់ក្នុងរបបភេរវកម្ម។ តើត្រូវធ្វើការលះបង់អ្វីខ្លះ?

**-លះបង់ ភាពមុខមាត់និយម សំភារះហ៊ឺហា អំនួតអួតអាងនិយម អាត្មានិយម និងភាពភ្លើតភ្លើន ។**

ដូចពោលខាងលើខ្លះៗមកហើយ ដើម្បីដឹកនាំគេត្រូវធ្វើអោយគេមានជំនឿមកលើខ្លួនយើង ស្រឡាញ់គោរពយើងជាមុន ។ ដើម្បីអោយអ្នកផង ជឿស្រឡាញ់យើង យើងត្រូវធ្វើខ្លួនអោយសមសួន មានឫកពារថ្លៃថ្នូរ ដោយការវាចាក អំពើអបាយមុខផ្សេងៗ ។ ជាពិសេស លះបង់ការស្រេកឃ្លានមុខមាត់អំនួតអួតអាង ភាពភ្លើតភ្លើននិងសំភារះនិយម ហ៊ឺហាសំបូរ គ្មានព្រំដែន ។

**-លះបង់ ភាពមុខមាត់និយម**

-ក្នុងឋានៈជាអ្នកដឹកនាំខ្មែរ ត្រូវហ៊ានលះបង់ មិនត្រឹមតែទ្រព្យធន ពេលវេលាប៉ុណ្ណោះទេ តែត្រូវហ៊ានលះបង់តាំងពីមុខមាត់ កិត្តិយស ឡើងទៅ ។ ពោលគឺ ត្រូវតែចុះបំរើពលរដ្ឋដល់ទីកន្លែង ។ ដោយស្ថានភាព សព្វថ្ងៃអាយ៉ង ហ៊ុន សែន និងយួន បានប្រើគ្រប់មធ្យោបាយ ដើម្បីធ្វើអោយខ្មែរមិនទុកចិត្តគ្នា ។ ហេតុនេះហើយដើម្បីជំនះ ផែនការខ្មៅក្រខ្វក់នេះ យើងត្រូវតែហ៊ានដាក់ខ្លួន អោយទាប លាក់ខ្លួនតាមបែបផ្សេងៗ ដើម្បីអោយយើងបានផ្សារភ្ជាប់ជាមួយប្រជាជាតិខ្មែរ ដែលជាហេតុនាំអោយយើងអាចទាញយកការទុកចិត្តគ្នា ស្រឡាញ់គ្នាក្នុងនាមជនរួមជាតិខ្មែរតែមួយបាន ។ បើយើងមិននៅនែបណិតជិតស្និទ្ធរាល់ថ្ងៃទេ គេមិនជឿយើងឡើយ ។ ជាងនេះទៅទៀត ខ្មាំងប្រើប្រាស់គ្រប់កលល្បិចដើម្បីបំបែកបំបាក់យើង ។ ពលរដ្ឋយើងមានការព្រីរងារ ហេតុនេះយើងត្រូវតែជួយលើកស្ទួយស្មារតី ដាស់តឿនក្រើនរំលឹកជាប្រចាំ ។ យើងអាចរកវិធីទៅជួប ទៅរកដោយប្រើវិធីគំរបច្រើនយ៉ាង ដូចជា ½ ជាអ្នករត់ម៉ូតូ ជាកង់ឌុប ជាអ្នកប៉ះកង់ ។ល ។ ព្រះពុទ្ធអង្គសុខចិត្តលះបង់រាជសម្បត្តិ ក្តីសុខផ្ទាល់ខ្លួនដើម្បីស្វែងរកផ្លូវសង្គ្រោះជីវិតមនុស្សលោក សុខចិត្ត ទ្រាំទ្រលំបាកគ្រប់យ៉ាងដោយការរស់នឹងបាយបាត ។ ដើម្បីសំរេចផែនការ លេបត្របាក់យកប្រទេសខ្មែរ ជនជាតិយួន សុខចិត្តលះបង់ ឋានៈជាឧត្តមសេនីយ បន្ទំខ្លួនរស់ជាអ្នកប៉ះកង់ ជាស្រីពេស្យា ក្នុងការដឹកនាំអនុវត្តន៍កិច្ចការរបស់វា ។ យើងជាខ្មែរត្រូវតែមានការលះបង់ ហ៊ានធ្វើអ្វីគ្រប់យ៉ាងដោយភាព មុតស្រួចជាងវា ខ្លាំងជាងវា ទើបយើងអាចរំដោះជាតិយើងអោយរួចផុតពីឧបាយកលរបស់វាបាន ។ យើងមិនត្រូវធ្វើត្រឹមតែ ដើរ ពោលឡូឡា ខាតពេលឥតប្រយោជន៍ តែយើងត្រូវធ្វើអ្វីដែលជាគន្លឹះជាជំហាននាំទៅរកជោគជ័យ ។

**ជាតិខ្មែរនឹងរស់ បើប្រជាជាតិខ្មែរភ្ញាក់រលឹក រួបរួមសាមគ្គីគ្នាក្រោកឡើង ធ្វើការតស៊ូដោយមិនខ្លាចស្លាប់ ៕**

ពេលនេះ មាតុភូមិត្រូវការយើងឱ្យមានការលះបង់មួយដ៏ធំ សំរាប់ខ្មែរយើងទាំងមូល កុំរង់ចាំឱ្យយួន សំលាប់រង្គាលរហូតដល់បាត់ស្មារតី ងាប់សេចក្តីក្លាហាន ឬទុកអោយ យួន ប្រើល្បិចសំលាប់ខ្មែរ ប្រមាណ ២លាននាក់ ក្នុងសម័យពួកក្រហម ប៉ុល ពត ទៀត ។ វាលពិឃាត កន្លងមក ជាមេរៀន ដែលខ្មែរត្រូវតែភ្ញាក់ខ្លួន និងចងចាំជានិច្ច ។ សម្តេចសង្ឃ **ជួន ណាត, ស៊ឹង គុយ, ឃ្លាំង មឿង, ស៊ឹង ង៉ុកថាញ់, ប៊ុណ្ណ ចន្ទ័ម៉ុល, អាចារ្យ ហែម ចៀវ, ពោរ កំបោរ, ប៉ាង ខាត់, ហូ សុខ, ជា ទិង្វា** និងព្រះតេជគុណ **សំ ម៉ុនឆឿន** ព្រមទាំងបុព្វបុរសខ្មែរជាច្រើនរាប់មិនអស់ បានលះបង់ជីវិត ដើម្បីការពារជាតិ មាតុភូមិខ្មែរ អោយនៅគង់វង្សរហូតដល់សព្វថ្ងៃ ។ *តើយើងជាកូនចៅជំនាន់ក្រោយ ជាអ្នកទទួលខុសត្រូវ ចំពោះមុខប្រវត្តិសាស្ត្រ ដូនតា សុខចិត្តរស់នៅទាំងខ្លោចផ្សារ មើលយួន និងអាយ៉ង ធ្វើបាបជិះជាន់ខ្មែរ ឱ្យវិនាសដូច សម័យក្សត្រីអង្គម៉ី (១៨៣៥-១៨៤១ យួន* ***ត្រឿង មិញ យ៉ាង*** *) ឬយ៉ាងណា? ។*

**៤-អាជ្ញវៈ ឬ សេចក្តីស្មោះត្រង់ (Honest)**

អាជ្ញវៈ គឺជាសេចក្តីត្រង់ មិនវៀចវេរ ក្រឡិចក្រឡុច។ *មេដឹកនាំខ្មែរ ត្រូវស្មោះត្រង់ចំពោះ ឧត្តមគតិរួម មុខងារ តួនាទី របស់ខ្លួន ត្រង់ចំពោះ ក្រុមការងារ ត្រង់ចំពោះប្រទេសជាតិខ្មែរ និងប្រជាពលរដ្ឋខ្មែរ ត្រង់ទាំងការគិត ការនិយាយ និងការអនុវត្តការងារ ត្រង់ចំពោះអ្នកក្រោមបង្គាប់ និងត្រង់ចំពោះសេចក្តីល្អទាំងឡាយ។ ភាពស្មោះត្រង់ ជាផ្លូវដ៏ល្អមួយ ញុាំងអោយមានការជឿជាក់ ពីអ្នកជុំវិញខ្លួន។ ជំនឿជាក់ពីអ្នកផងទាំងពួង នឹងធ្វើអោយមាន ការរួបរួមសាមគ្គីគ្នាជុំវិញខ្លួន យើងជាអ្នកដឹកនាំ ហើយអាចជួយធ្វើឱ្យ ការដឹកនាំ របស់យើង ដើរទៅរកជោគជ័យបានឆាប់រហ័ស*។ ក៏ប៉ុន្តែ នៅពេល ដែលមានការរួបរួមជុំវិញខ្លួនហើយ យើងជាមេដឹកនាំ មិនត្រូវភ្លេចខ្លួនភ្លើតភ្លើន មើលងាយអ្នកផង ជុំវិញឡើយ។ កាន់តែមានការរួបរួមជុំវិញខ្លួន ខ្លាំងឡើងកាលណា កាន់តែផ្តល់សារៈសំខាន់ ដល់សហការីជុំវិញខ្លួន កាន់តែអោនលំទោន ប្រកបដោយសេចក្តីថ្លៃថ្នូរខ្ពស់ឡើងជានិច្ច។ មិនគួរនិយាយពីអ្នកក្រោមឱវាទ ថាអាក្រក់យ៉ាងនេះ មិនល្អយ៉ាងនោះឡើយ។ ត្រូវរិះរកវិធីកែខៃ ដោយភាពស្មោះត្រង់ ដើម្បីធ្វើអោយមានការរីកចំរើនទាំងអស់គ្នា ដើរទៅជាមួយគ្នាឆ្ពោះទៅរកជោគជ័យ។ ត្រូវចាំថា អង្គការនយោបាយដឹកនាំរបស់យើង ប្រៀបបីដូច ជាក្រុមតូរ្យតន្ត្រីមួយដែរ។ ត្រូវមានភាពប៉ិនប្រសប់ ក្នុងការងាររៀងខ្លួន ដូចគ្នាស្មើៗគ្នា។ បើ ស្គរលេងល្អ តែហ្គីតា លេងអន់ ក៏មិនកន្រ្តាក់ ទាក់អារម្មណ៏ អ្នកមើលអ្នកស្តាប់។ បើស្គ ហ្គីតា លេងល្អ តែបើអ្នកច្រៀង ច្រៀងមិនពិរោះ គ្មានការទាក់ទាញ នៅរឹងស្ងួក ក៏មិនអាចទាក់អារម្មណ៏ អ្នកក្រោមឆាក អោយហក់លោតឡើងរាំបានឡើយ។ ពោលគឺ ទាំងអស់គ្នា ជាក្រុមការងារ ដែលស្មោះត្រង់នឹងគ្នា មានការទទួលខុសត្រូវតាមមុខងាររៀងៗខ្លួនដោយស្មោះស្មគ្រ័ គ្មានល្បិចប៉ែងជើង ប៉ែងដៃគ្នាឡើយ។ យ៉ាងណាមិញ ក្នុងភាពជាអង្គការនយោបាយមួយ ត្រូវតែកសាងអោយ ទៅជា *ក្រុមការងារល្អរលូនបំផុត* (Best and smooth Team Work) ទើបអាចជំរុញអោយប្រជាជាតិខ្មែរទាំងអស់ ភ្ញាក់រលឹកជឿជាក់លើយើងបាន។ ម្នាក់ៗ មានភាពស្មោះត្រង់ចំពោះ ភារៈរបស់ខ្លួនជាអ្នកដឹកនាំ មិនថាថ្នាក់ណា នៅទីណា កន្លែងណា មិនចាំបាច់ ដេកចាំអោយមានអ្នកដាស់តឿន ឬធ្វើដើម្បីផ្គាប់មុខមាត់ឡើយ។ ម្នាក់ៗត្រូវគិតថា យើងចេះអ្វីមួយ ដែលអ្នកឯទៀតមិនចេះ តែអ្នកឯទៀត ក៏ចេះអ្វីមួយដែលយើងមិនចេះ។ ហេតុនេះ *ដើម្បីសំរេចជោគជ័យ អ្នកដឹកនាំមានភារៈពូត ប្រមូលផ្តុំ សមត្ថភាព និងការប្រឹងប្រែង របស់អ្នកជុំវិញខ្លួន ដើរឆ្ពោះទៅរកគោលដៅរួម ដោយភាពស្មោះត្រង់ និងពុះពារ ព្យាយាម ប្តូរផ្តាច់ យ៉ាងអត់ធ្មត់បំផុត ដោយការនាំមុខគេជានិច្ច ក្នុងការពុះពារឧបសគ្គផ្សេងៗ*។ ចូរពិចារណាចងចាំ និងយល់យ៉ាងជាក់ថា ខ្សែហ្គីតាមួយ មានសំលេងតែមួយប៉ុណ្ណោះ ខ្សែទាំង៥មានសំលេងខុសៗគ្នា តែដោយភាពប៉ិនប្រសប់ របស់អ្នកលេងហ្គីតា ចេះរួមផ្សំសំលេងខ្សែទាំងនោះ បញ្ចូលគ្នាធ្វើឱ្យអ្នកលេង អាចលេងភ្លេងបានយ៉ាងពិរោះរណ្តំ នាំព្រលឹងអាត្មន អ្នកស្តាប់ អ្នកទស្សនា អោយលង់លក់ ទៅតាមចំណង់របស់គេបាន។ តើអ្នកណាមួយ អាចទាយថា អ្នកលេងដែល ប្រើប្រាស់ ហ្គីតា នេះ នឹងលេងបាន ត្រឹមតែប៉ុន្មានបទ ប្រាកដជាគ្មានចំឡើយទេ។ យ៉ាងណាមិញ យើងជាអ្នកដឹកនាំជាតិខ្មែរ ដែលស្រឡាញ់ជាតិពិត ក៏ត្រូវរៀនសូត្រពីនេះដែរ ទើបយើងអាចកសាង ក្រុមការងារល្អរលូនបាន។ ក្រៅពីនេះ ការរួមសុខ រួមទុក្ខជាកត្តាសំខាន់ខ្លាំងណាស់។ យើងជាមេដឹកនាំ ត្រូវរស់នៅរួមសុខរួមទុក្ខជាមួយគ្នា មិនរត់មិនដោះយករួចខ្លួន ក្នុងគ្រាអាសន្ន មិនដេកស្រួល ស៊ីឆ្ងាញ់ យកសុខតែម្នាក់ឯង ឬប្រើហើយមិនទទួលខុសត្រូវ ឬមួយក៏ បោកប្រាសប្រើ នោះមិនមែនជាការល្អដល់មេដឹកនាំសោះឡើយ។ ដូចរៀបរាប់មកខាងលើ មកហើយគឺ *អ្នកដឹកនាំខ្មែរ ត្រូវតែស្មោះត្រង់ គ្រប់ឥរិយាបថទាំអស់ តាំងពី ការគិត ការនិយាយ ការធ្វើ ការរស់នៅដោយ ភាពប្តូរផ្តាច់ ចំពោះជាតិមាតុភូមិ ប្រជាជាតិខ្មែរ និងអង្គការនយោបាយរបស់ខ្លួន ដែលខ្លួនមានតួនាទីដឹកនាំ ដើម្បីជំរុញការតស៊ូឆ្ពោះទៅរកជោគជ័យផ្តាច់ព្រត្ស័ ដោយគ្មានវៀចវេរ*។

**“ដាក់ខ្លួនឱយទាប ដើម្បីមើលអោយបានដល់ផេរោបញ្ហា តែក្រោកឈរឱយខ្ពស់ ដើម្បីមើលឱយបានឆ្ងាយ ដោយភាពភ្លឺស្វាងនៃអនាគត”។**

ចូរ *"ខិតខំរៀន ខំធ្វើ ខំកសាងកំលាំង ដើម្បីដណ្តើមយកអំណាច ពីជនពាល មកបំរើប្រជាជាតិ និងជាតិ"* តែ *"កុំរៀនធ្វើ កសាងប្រមូលផ្តុំកំលាំង ដើម្បីទៅសុំអំណាចពីជនពាល ឬ ទៅបំរើជាខ្ញុំជាកញ្ជះដាច់ថ្លៃរបស់ពួកក្បត់ជាតិ "*។

### ៥-មទ្ទវៈ ឬ ភាពរាបសារទន់ភ្លន់ (Gentle)

មទ្ទវៈ ជាសេចក្តីរាបសារទន់ភ្លន់។ មេដឹកនាំខ្មែរ ត្រូវសំដែងនូវទឹកមុខញញឹម រួសរាយរាក់ទាក់ ជានិច្ច ចំពោះអ្នកក្រោមបង្គាប់ និង ប្រជាពលរដ្ឋខ្មែរទូទៅ ទោះជានៅពេល មានឧបសគ្គ ពិបាកយ៉ាងណាក្តី។ សេចក្តីរីករាយ របស់មេដឹកនាំ ជាឱសថ អាចលើកទឹកចិត្តទាហាន ឬអ្នកក្រោមឱវាទ អោយមានទឹកចិត្តប្រយុទ្ធ ឬមានក្តីសង្ឃឹមទៅមុខបាន។ ហេតុនេះ មេដឹកនាំខ្មែរ មិនត្រូវធ្វើមុខស្រពាប់ស្រពោន មុខក្រញូវមុខស្អុយ ប្រកាន់ ឬកក្រអឺតក្រទម ច្រងេងច្រងាង ឆេវឆាវ អាងថាខ្លួនឯងអ្នកធំមានអំណាច ឬមេគេនោះទេ។ មេដឹកនាំត្រូវតែ រាក់ទាក់ដាក់អ្នកតូច អ្នកក្រោមបង្គាប់ និងប្រជាពលរដ្ឋសាមញ្ញមុនជានិច្ច។ ត្រូវព្យាយាមស្គាល់ឈ្មោះអ្នកក្រោមឱវាទ អោយបានអស់ និងត្រូវហៅអោយចំៗឈ្មោះ ថាលោក. ក... ឬ លោក ...ខ ជាដើម។ ការហៅចំឈ្មោះ មានន័យខាងចិត្តសាស្រ្តមួយធំណាស់ ជាពិសេស ចំពោះអ្នកដែលមានឋានៈតូចទាបជាង ។ ក្រៅពីនេះ មេដឹកនាំត្រូវទទួលនូវសេចក្តីគោរព ពីអ្នកផង ដោយការយកចិត្តទុកដាក់ មិនព្រងើយកន្តើយ ហើយត្រូវដាក់ខ្លួនអោយមានលក្ខណៈសាមញ្ញ ជាមួយនឹងប្រជាពលរដ្ឋ និងអ្នកក្រោមបង្គាប់។ មិនស៊ីជោរ អួតអាង ពេលគេសរសើរ មិនត្រូវអង្គុយលើចង្អេរលើកខ្លួនឯង ហើយបន្ទុះបង្អាប់អ្នកដទៃ ពោល គឺមិនត្រូវនិយាយពីរឿង ខ្លួនឯងថា គ្រាន់បើជាង អ្នកដទៃ ឬតាំងខ្លួនឯងជា មេដឹកនាំរបស់អ្នកទាំងអស់នោះ។ ផ្ទុយទៅវិញ យើងត្រូវតាំងខ្លួនយើង ជាអ្នកបំរើ ប្រជាពលរដ្ឋខ្មែរ ទើបប្រសើរ។ មេដឹកនាំ ត្រូវហ៊ានសារភាពកំហុស ដោយការទទួលខុសត្រូវ និងដោយទឹកមុខញញឹមពេញចិត្ត ចំពោះអ្វីដែល យើងបានធ្វើខុស ឬយើងបានចាត់ការខុស ។ មេដឹកនាំខ្មែរ ត្រូវទន់ភ្លន់ តែមិនទន់ជ្រាយនោះទេ បើប្រៀបធៀបទៅ និងដើម ឈើ មេដឹកនាំត្រូវធ្វើដូចជាដើម ផ្ចឹក ក្រញូង និងបេង ជាដើម ដែលមានភាពទន់ខាងក្រៅ តែរឹងប៉ឹងខាងក្នុង។ មេដឹកនាំខ្មែរ មិនត្រូវធ្វើដូច ដើមល្ហុង និងអំពៅ ដែលមានលក្ខណៈរឹងក្រៅ តែប្រហោងក្នុងនោះទេ។ មេដឹកនាំត្រូវចេះ ស្គាល់កាលៈទេសៈ និងស្ថានការណ៍ តើពេលណា យើងត្រូវធ្វើមេដឹកនាំគេ? ហើយពេលណាយើងត្រូវធ្វើជាអ្នកក្រោមបង្គាប់គេ?។ កាន់តែមាន ការរួបរួម មានជោគជយ័ក្នុងការធ្វើអោយអ្នកផងរួបរួមគ្នាដើរតាមខ្លួន អ្នកដឹកនាំជាតិខ្មែរ កាន់តែមានភាពរាបសារទន់ភ្លន់អោនលំទោន ចំពោះអ្នកជុំវិញខ្លួន ខ្លាំងឡើងជាលំដាប់។ ភាពរួសរាយ រាក់ទាក់អោយលំទោន របស់អ្នកដឹកនាំ ជាមន្តស្នេហ៍មួយអាចធ្វើអោយគេដើរតាម គោលការណ៍នានារបស់ខ្លួន និងរបស់អង្គការនយោបាយខ្លួនបានយ៉ាងមានប្រសិទ្ធភាព។ " ដើម្បីដឹកនាំគេ ត្រូវធ្វើអោយគេស្រឡាញ់យើងជាមុន ដើម្បីអោយគេស្រឡាញ់យើង យើងត្រូវស្រឡាញ់ គេដោយស្មោះស្ម័គ្រ ជាមុន"។ នៅពេល ប្រជាជាតិខ្មែរទូទៅ មានការជឿជាក់លើយើង និងមានការភ្ញាក់រលឹក ដូចយើងហើយនោះ នោះនឹងញ៉ាំងអោយយើង អាចជំរុញការរំដោះជាតិរបស់យើងឆាប់បានដល់ទីសដៅ។ តែត្រូវចាំថា **"យើងជាអ្នកបំរើ ជាតិប្រជាជាតិ មិនមែនជាអ្នកជិះជាន់សង្កត់សង្កិនរាស្ត្រខ្មែរតូចតាចឡើយ"**

### ៦-តបៈ ឬស្អាតស្អំ (Clean)

**តបៈ** ការដុះខាត់សំអាតចិត្ត ឬកំចាត់នូវអំពើអាក្រក់ក្នុងខ្លួន។ តើត្រូវកំចាត់អ្វីខ្លះ? មេដឹកនាំ ត្រូវកំចាត់អារម្មណ៏ដែលនាំអោយយើង ប្រព្រឹត្តិអំពើអាក្រក់ទាំងឡាយ និងបញ្ហាអារម្មណ៏របស់ខ្លួនឯង មិនអោយក្តៅក្រហាយ។ មេដឹកនាំខ្មែរមិនធ្វើអោយក្តៅក្រហាយដល់ចិត្តអ្នកដទៃ អ្នកក្រោមឱវាទឡើយ។ យើងត្រូវមានផែនការ កាលវិភាគ កំណត់ច្បាស់លាស់សំរាប់កិច្ចការប្រចាំថ្ងៃ ហើយអនុវត្តតាមផែនការនោះ។ ដូច្នេះ យើងត្រូវសង្កេតមើលសកម្មភាព របស់យើងគ្រប់ពេលវេលា

បើយើងដឹងថា យើងធ្វើខុស ឬធ្វើអំពើអាក្រក់ យើងត្រូវកែប្រែចេញ។ ផ្ទុយទៅវិញ បើដឹងខ្លួនថាមានកំហុស ហើយមិនព្រមទទួលកំហុស មិនកែប្រែ ដូច **ហ៊ុន សែន** គឺជាមនុស្សគំរក់បំផុត។ បើយើងដឹងថា ខ្លួនយើងអាត្មានិយម គិតតែប្រយោជន៍ផ្ទាល់ខ្លួន យើងត្រូវឈប់ធ្វើ ដូច្នោះ យើងត្រូវត្រឡប់មកគិតដល់ប្រយោជន៍ជាតិ ប្រយោជន៍សង្គម និងប្រជាជាតិខ្មែរ ទាំងមូលវិញផង។ ក្នុងនាម យើងជាមេដឹកនាំខ្មែរ ត្រូវធ្វើដូចព្រះអាទិត្យផង និងជាព្រះច័ន្ទផង។ តើអ្វីខ្លះទៀត ដែលមេដឹកនាំខ្មែរ គួរលះបង់ចេញ? មេដឹកនាំខ្មែរ ត្រូវលះបង់ ឈប់គិតព្យាបាទ ខ្មែរគ្នាឯង ឈប់ឈ្លោះប្រកែកជាមួយខ្មែរ ឈប់ចងគំនុំ គុំគួន នឹងខ្មែរគ្នាឯង និងឈប់និយាយ ឌឺដងឡកឡឺយដៀមដាម ដោយពាក្យផ្អែផ្អារ ឬអំណួត បែបមនុស្សពាលបាតផ្សារ ឬ មួលបង្កាច់ទំលាក់កំហុសដាក់ អ្នកស្នេហាជាតិទៀត។ មេដឹកនាំខ្មែរ ត្រូវឈប់កំណាញ់ ឬមាយាលាក់ពុត។ មេដឹកនាំខ្មែរ មិនត្រូវធ្វើជាមនុស្សក្បាល រឹង ចចេស ត្រូវចេះស្តាប់ហេតុផល និងស្តាប់យោបល់អ្នកក្រោមបង្គាប់យកមកពិចារណា។ ត្រូវចាំថា បើយើងចង់ដឹកនាំគេ យើងត្រូវតែ យកគំនិត យោបល់អ្នកក្រោមបង្គាប់ មកគិតមកពិចារណា ថ្លឹងថ្លែង ជាគតិខ្លះ។ "អ្នកទាបតូចមិនសុទ្ធតែជាអ្នកល្ងង់ខ្លៅឡើយ ឯអ្នកដែលមាន មានសញ្ញាបត្រ័ បណ្ឌិត មិនមែនសុទ្ធ តែជាអ្នកគិត ត្រូវឆ្លៀវឆ្លាត ជាងគេឯងទាំងអស់ដែរ" (ឧះ បណ្ឌិតច្បាប់ នរោត្តម រណឫទ្ធ ជាដើម ធ្វើតាំងពីឈ្នះឆ្នោត រហូតដល់អស់ខោ ព្រោះតែ គំនិតអញនិយម អត្តាធិបតេយ្យនិយម)។ បើយើងបដិសេធគំនិត យោបល់ អ្នកក្រោមបង្គាប់ទាំងស្រុង នោះយើង មិនអាចធ្វើ ជាមេដឹកនាំគេបានទេ ពួកគេនឹងមិនដើរតាមយើងឡើយ។ មេដឹកនាំខ្មែរ ត្រូវលះបង់ចោលនូវការប្រកាន់ឬកខ្ពស់។ តាមការពិតទៅ ការកាច់ឬក កាច់រាង ជាភាពល្ងង់ខ្លៅរបស់មេដឹកនាំទៅវិញទេ។ ក្នុងភាពជា មេដឹកនាំខ្មែរ ឈប់គិតថាមានតែខ្លួនឯងខ្លាំង មើលងាយប្រមាថអ្នកដទៃ ត្រូវប្រកាន់យកគំនិតច្រើន ព្រោះថា គំនិតពីរប្រសើរ ជាងគំនិតមួយ ហើយរឹតតែល្អ កាលណាមានគំនិតកាន់តែច្រើននោះ។ ផ្អែកតាម ការរៀបរាប់ មកនេះ តើ គំនិតស្តេចសីហនុ តែម្នាក់ឯង ដែលរៀនមិនចប់ ឌីប្លូម ស្រុកយួន ផងនោះ អាចឈ្នះយួន ដែលវាប្រមូលគ្នាច្រើនគិត ហើយសុទ្ធសឹង តែជាអ្នកចេះដឹងស្មោះត្រង់នឹងជាតិវាទៀតផងនោះបានទេ។ មិនបាច់ស្រែកថា យួន រមិលគុណទេ នោះជាកំហុស ឆ្កួតលីលារបស់ ខ្លួនឯងទាំងអស់។ ស្តេច សីហនុ មិនដែលទុកចិត្តខ្មែរដែលដាក់ចិត្ត ដាក់កាយបំរើជាកូន ជាចៅ របស់ខ្លួនសោះឡើយ ។ តាំងពីនៅសោយរាជ្យ ស្តេច សីហនុ មិនដែលយកអ្នកចេះខ្មែរធ្វើ ទីប្រឹក្សាឡើយ លុះណាតែ អ្នកនោះឯងចេះបាទ ចេះហៃអើ រហូតទើបនៅជិតបាន។ ផ្ទុយទៅវិញ ស្តេចនេះ សុខចិត្តយកបារាំង ឬជនជាតិផ្សេងៗ ដែលសុទ្ធសឹងតែជាពួក និយមកុម្មុយនិស្ត ដែលយួនបានបញ្ជូនមក មកដាក់នៅអែបខ្លួនជានិច្ច។ បើសូម្បីតែសព្វថ្ងៃនេះទៅហើយក្តី ស្តេចនេះ មិនទុកចិត្តខ្មែរទេ សុខចិត្តយកអង្គរក្ស ជាជាតិដ៏ទៃ (កូរេខាងជើង) ទៅវិញ។ ដូចគ្នានេះដែរ អាយ៉ង ហ៊ុន សែន សុខចិត្តរើស ជនជាតិយួន មកធ្វើជាអង្គរក្ស ជាអ្នកការពារអំណាចរបស់វា ទៅវិញ និងបំពាក់អាវុធទំនើបៗ លើសកងទ័ពខ្មែរ ដែលវាទុកអោយ នៅតាមជនបទព្រៃភ្នំ តំបន់គ្រុនចាញ់ ដើម្បីការស្លាប់ជំនួស វានឹងយួន។ ប្រាង្គប្រាសាទអង្គរ ជាមរតកិ ខ្មែរ ហ៊ុន សែន មិនទុកចិត្តខ្មែរទេ តែបែរជាអោយទៅ សុខ គង់ ជនជាតិយួន មកកើបយកលុយទាំង លានទាំងកោដិដុល្លា យ៉ាងដូច្នេះ តើវាជាជនក្បត់ជាតិ ឬ ជាឆ្កែបំរើយួន។ បើមេដឹកនាំ សុទ្ធសឹងជាជន គ្មានចិត្តបរិសុទ្ធចិត្តស្អាតស្អំ គ្មានចិត្តស្មោះចំពោះជាតិ គ្មានគំនិតស្រឡាញ់អ្វីជាខ្មែរ ចិត្តពោរពេញដោយ ភាពសៅហ្មងស្មោគគ្រោក ដូច្នេះ តើប្រទេសជាតិ នឹងរីកចំរើន សុខក្សេមក្សាន្ត ទៅម្តេចបាន។

អ្នកដឹកនាំខ្មែរ ត្រូវតែស្អាតស្អំទាំងចិត្តគំនិត ទាំងស្មារតី មិនប្រព្រឹត្តិអ្វីដែល ជាអំពើស្មោគគ្រោក អាបាយមុខផ្សេងៗ ដែលនាំអោយ មានរឿងអាស្រូវដល់កេរ្តិ៍ឈ្មោះ និងធ្វើអោយការដឹកនាំមិនទទួលជោគជ័យ។ ក្រៅពីនេះ មិនត្រូវទទួលយកសំណូកសូកប៉ាន់ផ្សេងៗ ដែលនាំឱយប្រឡាក់ប្រឡូស ដល់កិត្តិយសរបស់ខ្លួន ឬនាំអោយមានអយុត្តិធម៌ ក្នុងការដឹកនាំ ដោយ

សារតែការទទួលយកសំណូកសូកប៉ាន់នេះ។ ទោះជា មេដឹកនាំខ្មែរ ត្រូវតែប្រកាន់នូវភាពស្អាតស្អំ មិនទាក់ទាមនឹង អំពើមិនល្អ មិនត្រឹមត្រូវតាមសីលធម៌ តែអ្នកដឹកនាំខ្មែរ មិនត្រូវរារែកនឹងអ្វី ដែលខ្លួនយល់ថា ត្រឹមត្រូវសំរាប់ការសង្គ្រោះជាតិ ការរំដោះប្រជាជាតិខ្មែរឡើយ។ **"ខ្មែររស់ព្រោះ ខ្មែរហ៊ានស្លាប់"** តែ **"ខ្មែរនឹងស្លាប់ បើខ្មែរកំសាកខ្លាចសេចក្តីស្លាប់"។**

**៧-អក្កោធៈ (Peace)**

អក្កោធៈ គឺការមិនងាយខឹងក្រេវក្រោធ។ មេដឹកនាំខ្មែរ មិនត្រូវខឹងក្រេវក្រោធ ឆេវឆាវជាដាច់ខាត ព្រោះការ ខឹងនេះ គឺជារនាំងបាំងអោយយើងងងឹត មិនស្គាល់ខុសនិងត្រូវ ល្អនិងអាក្រក់ យុត្តិធម៌និងអយុត្តិធម៌ ដោយសារតែសេចក្តី វង្វេងនឹង ភ្លើងកំហឹង។ បើមេដឹកនាំខ្មែរ មានសេចក្តីក្រោធ នោះមិនមែនជាការល្អសោះឡើយ ព្រោះសេចក្តីក្រោធ ប្រៀបដូច ជាច្រែះ របស់អាវុធក្នុងលោក ប្រៀបដូចជាភ្លើងឆេះសំរាប់នាំទៅរកសេចក្តីវិនាស។ អ្នកក្រោធរមែងមិនដឹងនូវ ហេតុផល និងធ្វើឱយ ចិត្តក្តៅ សោកសៅ(មិនស្ងប់)មានទុក្ខជានិច្ច។ គេសំគាល់សេចក្តីក្រោធ បានតាមរយៈ ការមិនពេញចិត្ត ការទាស់ចិត្ត ការក្តៅ ពុះកញ្ជ្រោល ការគិតឈ្លោះប្រកែក និងការចងគំនុំសងសឹក។ ម្យ៉ាងទៀតពាក្យថា **ក្រោធ** ក៏មានន័យថា **ខុស** ដូច្នេះបើមេដឹកនាំខ្មែរ ខឹង ឬខ្ញាល់ មានន័យថា **ខុស** ដូចពាក្យចាស់ពោលថា *"ខឹងខុស ខឹងខូច ខឹងខាត"*(ចូរមើលរឿង **មាយើង**)។ អាស្រ័យហេតុនេះ មេដឹកនាំខ្មែរ គប់លំដាប់ថ្នាក់ មិនត្រូវយកការខឹងក្រេវក្រោធ មកដាក់ខ្លួនឡើយ។

សព្វថ្ងៃនេះ ប្រទេសខ្មែរ គ្មានសុខសន្តិភាពឡើយ ព្រោះប្រជាពលរដ្ឋខ្មែរ រស់ទាំងត្រដរ ក្រោមបាតជើងរបស់ ជនពាល ជាភេរវករ ស្រេកឃ្លានឈាម ប្រព្រឹត្ត តែអំពើអយុត្តិធម៌ កៀបសង្កត់ជិះជាន់ បណ្តុះភាពល្ងង់ខ្លៅ បង្កើតអំពើចោរកម្ម ឃាតកម្ម កាប់សំលាប់បែបភេរវកម្ម ដែលអនុវត្តន៍ដោយជនក្បត់ជាតិ **ហ៊ុន សែន** និង ចោរយួន កំពុងធ្វើមកលើ ប្រជាពលរដ្ឋខ្មែរគ្រប់ទិនទី។ យួន ហ៊ុន សែន តែងឃោសនាថា ប្រទេសខ្មែរមានសន្តិភាពហើយ គ្មានសង្គ្រាមទេ។ ពាក្យសំដីពោរពេញដោយការចងគំនុំ ចងអាឃាដនឹងខ្មែរគ្នាឯង។ ទឹកមុខ ដូចជាបិសាច ស្រេកឈាម។ វាបង្កើត អោយមាន ការជិះជាន់ ការឆក់ប្លន់ដីធ្លី ការកាប់ សំលាប់ បែបភេរវកម្ម។ បក្សពួកវាដែលមានអំណាច តែងតែត្រូវ តែងតែឈ្នះ។ សន្តិភាព សព្វថ្ងៃ ជាសន្តិភាព នៅលើមាត់រណ្តៅភ្នំភ្លើង ដែលរកកលនឹងផ្ទុះ ក្រោមកលល្បិចរៀបចំដោយយួន។ វាជាការញុំាងអោយខ្មែរ យល់ខុសទាំងស្រុង ពាក្យ ថាមានសន្តិភាព លុះត្រាតែ ប្រទេសខ្មែរយើងមាន ឯករាជ្យ សន្តិសុខ ប្រជាពលរដ្ឋមាន ជីវភាពធូធារគ្រប់គ្នា មិនបារម្ភពីបញ្ហា ក្រពះ ភ័យខ្លាច និងសុវត្ថិភាព។ លុះត្រាតែ ប្រទេសខ្មែរ យើង មានប្រជាធិបតេយ្យ ពិតប្រាកដ តាមឆន្ទៈរបស់ខ្មែរចង់បាន ទើបមានសេចក្តីស្ងប់ នោះទើបហៅថា មានសន្តិភាព។

**៨-អវិហឹង្សា (Unviolent)**

**អវិហឹង្សា** មានន័យថា មិនបៀតបៀនធ្វើអោយអ្នកដទៃក្តៅក្រហាយ កើតទុក្ខដោយសារខ្លួន ជាពិសេសលើ ពលរដ្ឋរបស់ខ្លួនឯង។ មេដឹកនាំខ្មែរ មិនត្រូវយកអំណាចតួនាទីរបស់ខ្លួន ទៅគាបសង្កត់ជិះជាន់គំរាមកំហែងប្រជាពលរដ្ឋ ដើម្បីតែផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍បក្សពួកខ្លួននោះទេ។ មេដឹកនាំខ្មែរ ត្រូវតែគោរពសិទ្ធិពលរដ្ឋ កុមារ ចាស់ទុំ និងស្ត្រីភេទ។ មេដឹកនាំ មិនត្រូវប្រើអំពើហឹង្សាចំពោះជនរួមជាតិឡើយ ត្រូវប្រកាន់យកប្រជាធិបតេយ្យ យកប្រជាជាតិខ្មែរជាធំ។

មេដឹកនាំខ្មែរ ត្រូវអោយអភ័យ និងលើកលែងទោស ចំពោះអ្នកដើរតាម ឬប្រជាពលរដ្ឋរបស់ខ្លួន ដែលធ្វើខុស។ មិនមែនខុសដៃ យកដៃ ខុសជើង យកជើងទេ។ ត្រូវចាំថា អ្នកដើរតាម និងប្រជាពលរដ្ឋខ្មែរគ្មានកំហុសទេ *ខុសឬត្រូវ គឺជា*

*លទ្ធផលរបស់មេដឹកនាំ ព្រោះមេដឹកនាំជាអ្នកទទួលខុសត្រូវ។* ប្រជាពលរដ្ឋខ្មែរប្រៀបដូចជាកូនយើង ដែលពួកគេមិនដឹងអ្វីទេ។ ហេតុនេះហើយ មេដឹកនាំខ្មែរ ត្រូវធ្វើការអប់រំបណ្តុះបណ្តាល ពលរដ្ឋខ្មែរ ឱ្យមានចំណេះដឹង និងសមត្ថភាពគ្រប់ៗគ្នា។ បើអ្នកក្រោមឱវាទ ធ្វើខុស ឬបរាជ័យក្នុងកិច្ចការអ្វីមួយ កំហុសត្រូវធ្លាក់លើមេដឹកនាំ ជាអ្នកខុស មិនត្រូវដាក់កំហុស ឬដាក់ទោសលើ អ្នកក្រោមបង្គាប់នោះទេ។ មេដឹកនាំខ្មែរ ជាអ្នកសំរេចចិត្តលើ កិច្ចការគ្រប់យ៉ាងទាំងការប៉ាន់ប្រមាណ *ស្ថានការណ៍ ការរៀបចំផែនការ ការអនុវត្តន៍ ការដឹកនាំធ្វើ និងត្រួតពិនិត្យជាដើម។*

ក្រោមអំណាចក្បត់របស់បក្សពួក **ហ៊ុន សែន** ពួកវាលើកទឹកចិត្ត អោយបក្សពួកមានអំណាច ដណ្តើមដីធ្លីពី ប្រជាពលរដ្ឋខ្មែរ ក្រីក្រ ទន់ខ្សោយ ដើម្បីផលប្រយោជន៍បក្សពួកខ្លួន និងអំណាច។ លើសពីនេះ ហ៊ុន សែន ខ្លួនឯង ជាអ្នកដែលរំលោភលើ ស្ត្រី ភេទ ដោយបង្ខំ អោយប្តីប្រពន្ធ របស់ អ្នកស្រី ពិសិដ្ឋ ពីលិការ និងលោក ខៃ ប្រសិទ្ធ លែងលះគ្នាដោយបង្ខំ ដើម្បីអោយខ្លួន មានឱកាសប្រព្រិត្តអំពើអានាចារ្យលើ អ្នកស្រី ពិសិដ្ឋ ពីលិការ រហូតធ្វើអោយមានការធ្វើឃាដលើ សិល្បករ រូបនេះ។ យើងជា មេដឹកនាំ ត្រូវតាំងខ្លួនជាអ្នកបំរើរបស់ប្រជាពលរដ្ឋខ្មែរ មិនមែនធ្វើជាចៅហ្វាយកៀបសង្កត់ប្រជាពលរដ្ឋខ្មែរឡើយ។ **“សាងប្រជាធិបតេយ្យជាមួយសង្គមគ្រួសារ តែជាមួយអាយ៉ងផ្តាច់ការនិងយួនត្រូវផណ្តើមដោយចុងកាំភ្លើង”។**

### ៩-ខន្តី (Patient)

**ខន្តី** គឺការអត់ធន់។ មេដឹកនាំខ្មែរ នឹងទទួលបានជោគជ័យ លើកិច្ចការងារទាំងពួង បើសិនជា មេដឹកនាំខ្មែរទាំងអស់មានខន្តី គឺសេចក្តីអត់ធន់។ តើមេដឹកនាំខ្មែរត្រូវអត់ធន់និងអ្វីខ្លះ? មេដឹកនាំខ្មែរ ត្រូវអត់ធន់និងសេចក្តីលំបាក សេចក្តីវេទនា ការឈឺចាប់ទាំងពួង ការិះគន់ ការមើលងាយ មិនលើកទឹកចិត្ត។ល។ មេដឹកនាំខ្មែរ ត្រូវអត់ធន់និងតណ្ហា ឬមហិច្ឆតាផ្ទាល់ខ្លួន ដែលគាបសង្កត់ជំរុញ អោយប្រព្រឹត្តិអំពើមិនត្រឹមត្រូវ (ទុច្ចរិត)។ មេដឹកនាំខ្មែរ មិនធ្វើតាមតែអារម្មណ៍ ឬចិត្តរបស់ខ្លួន នោះឡើយ។ មេដឹកនាំខ្មែរ ត្រូវអត់ធន់ដុសខាត់ភាពល្ងង់ខ្លៅរបស់ខ្លួន និងភាពល្ងង់ខ្លៅរបស់ប្រជាពលរដ្ឋ ឬអ្នកក្រោមបង្គាប់។ មេដឹកនាំខ្មែរ ត្រូវអត់ធន់ ចំពោះការងាររបស់ខ្លួន ពាក្យណែនាំ ឬការប្រឹក្សាពីអ្នកផងទាំងពួង មិនថា អ្នកក្រោមបង្គាប់ ឬជាគ្រូអាចារ្យយើងឡើយ។ មេដឹកនាំខ្មែរ ត្រូវអត់ធន់ ចំពោះការត្មេះតេះដៀល ការប្រឆាំងពីសង្គម និងចំពោះពេលវេលា ដែលធ្វើការងារមិចបានសំរេច។ ចំណុចពិសេសមួយទៀត មេដឹកនាំត្រូវមានអំណត់ចំពោះការស្តាប់ ការជឿ។ មិនត្រូវជឿងាយ ខឹងងាយ ផ្តេសផ្តាស (ត្រចៀកស)ឡើយ។ឮ មួយរយដង មិនស្មើនិងឃើញម្តង ការឃើញមួយរយដង មិនស្មើយើងបានប៉ះម្តង ទោះជាមានហេតុផលក៏ដោយ ក៏មិនត្រូវ ដាក់ចិត្តជឿភ្លាមទេ។ មេដឹកនាំខ្មែរ ត្រូវចុះមើល ស្ថានការណ៍ពិតជាក់ស្តែងដោយខ្លួនឯង និងបង្កើតទំលាប់នេះដល់អ្នកក្រោមបង្គាប់។ ជាពិសេស ចំពោះអ្នកស្នេហាជាតិខ្មែរ ត្រូវមានការអត់ធន់ គ្រប់បែបយ៉ាង គ្រប់ពេលវេលាទាំងអស់ រហូតដល់សំរេចជោគជ័យចុងក្រោយ ក្នុងការតស៊ូ សង្គ្រោះប្រទេសជាតិ ឱ្យរស់ឡើងវិញ។ គោរព ប្រណិបត្តន៏តាមព្រះពុទ្ធបរមគ្រូនៃយើង ដែលអត់ធន់ស្វែងរកមាគ៌ាប្រោសសត្វលោករហូតបានសំរេចព្រះនិព្វន្ត។ **“សន្តិវិធី អហឹង្សាប្រើជាមួយប្រជាជាតិខ្មែរ តែជាមួយឆ្កែបំរើយួននិងយួន ត្រូវប្រើកំលាំងរួមផ្សំ”។**

### ១០-អវិរោធនះ (Keep doing right)

**អវិរោធនៈ** គឺការមិនធ្វើខុស។ មេដឹកនាំខ្មែរ ត្រូវធ្វើអោយបានត្រឹមត្រូវជានិច្ច ទាំងការគិតត្រូវ ការយល់ត្រូវ ការនិយាយត្រូវ ការធ្វើត្រូវ ការព្យាយាមត្រូវ ការភ្ញាក់រលឹកត្រូវ ការតំកល់ចិត្តត្រូវ និងការចិញ្ចឹមជីវិតត្រូវ។ តែមិនត្រូវរួញរាដល់មិនហ៊ានធ្វើអ្វីសោះ ព្រោះខ្លាចខុសនោះឡើយ ក្នុងភាពជាអ្នកដឹកនាំ ត្រូវហ៊ានប្រថុយ ហ៊ានអារកាត់ នៅក្នុងកាលៈទេសៈ ចាំបាច់។ ប៉ុន្តែការហ៊ានប្រថុយ ត្រូវផ្អែកលើ ផលប្រយោជន៍ជាតិ និងជនរួមជាតិជាធំ ផ្អែកលើកលយុទ្ធសាស្ត្រត្រឹមត្រូវ ស្ថានការណ៍ជុំវិញខ្លួន ពេលវេលា និង លទ្ធភាពហុចអោយ។ មិនត្រូវ ប្រថុយដោយគ្មានគ្រឹះ គ្មានការត្រេះរិះពិចារណាឡើយ។ មេដឹកនាំខ្មែរ មិនត្រូវប្រកាន់នូវ គុណធម៌មិងាប់ស្អុក គ្មានភាពបត់បែន តាមតំរូវការសំរាប់ អ្នកដឹកនាំនោះឡើយ ត្រូវចេះវិភាគរក អ្វីល្អ អ្វីអាក្រក់ អ្វីគ្រោះថ្នាក់ដល់សង្គមជាតិខ្មែរ ពោលគឺត្រូវហ៊ានធ្វើការអាកាត់ ដើម្បីផលប្រយោជន៍ប្រជាជាតិខ្មែរនិងជាតិជាធំ។

យើងគួរសិក្សាពី រឿងល្បើកខ្មែរមួយ ដែលនិយាយពីព្រះសង្ឃ ពីរអង្គ ធ្វើដំណើរទៅ ជួបនឹងព្រះពុទ្ធអង្គ ដើម្បីបានសំរេច ជាព្រះអារហន្ត។ នៅតាមផ្លូវ ព្រះសង្ឃទាំងពីរអង្គ ត្រូវដាច់ចង្ហាន់។ ពេលនោះ មានទេវតា មកនិមិត្តជា សត្វត្រី នៅចំពោះ ព្រះភ័ក្រ្តព្រះសង្ឃទាំងពីរអង្គ។ ព្រះសង្ឃមួយអង្គ គិតថា បើព្រះអង្គសំលាប់ត្រីនោះ ធ្វើចង្ហាន់ ព្រះអង្គនឹងត្រូវប្រាសចាកពីវិន័យធម៌ ដោយត្រូវដាច់អាបត្តិ។ ឯព្រះសង្ឃ មួយអង្គទៀតគិតថា បើអាត្មាអញ មិនសំលាប់ត្រីនេះ ធ្វើចង្ហាន់ទេ អាត្មាអញ នឹងត្រូវសុគត ដោយឥតប្រយោជន៍ ហើយមិនបានទៅទាន់ព្រះត្រាស់ដឹងឡើយ តែបើ អាត្មាអញសំលាប់ត្រីនេះ ឆាន់ អាត្មាអញនឹងបានរស់រានមានជីវិត ទៅទាន់ព្រះត្រាស់ដឹង ហើយពិតជាបានសំរេច អរហន្ត ជាមិនខាន។ បន្ទាប់មក ព្រះអង្គត្រឡប់មកប្រស់ត្រីនោះវិញ។ ព្រះសង្ឃអង្គ ដែលមិនបានឆាន់ត្រី ក៏សុគតទៅដោយមិនបានផលអ្វីឡើយ។ ឯព្រះសង្ឃអង្គដែលឆាន់ត្រី ក៏បានទៅទាន់ព្រះ ត្រាស់ដឹង ហើយបានសំរេច ព្រះអារហន្ត និងបានត្រឡប់ទៅ ប្រស់ត្រីនោះអោយរស់រានមានជីវិតឡើងវិញ។

រឿងល្បើកខ្មែរខាងលើនេះ បានបង្រៀនយើងថា ក្នុងឋានៈជាអ្នកដឹកនាំខ្មែរ យើងមិនត្រូវប្រកាន់ គុណធម៌ងាប់ស្អុក រហូតលែងហ៊ានធ្វើអ្វី ដែលខ្លួនយល់ថាជាប្រយោជន៍ដល់ជាតិ ដល់ប្រជាជាតិខ្មែរ ព្រោះតែខ្លាច ប្រាសចាកគុណធម៌នោះទេ។ ត្រូវហ៊ានអារកាត់ធ្វើអ្វីដែលខ្លួនយល់ថា ជាប្រយោជន៍ដល់ជាតិ និងប្រជាជាតិខ្មែរ ដោយស៊ូទ្រាំនឹងការរិះគន់ទាំងឡាយពី មជ្ឈដ្ឋានផ្សេងៗ ក្នុងសង្គមដែលយល់មិនដល់ជំរៅនៃស្ថានការណ៍ ឬក៏មាននិស្ស័យតែខាងរិះគន់ ខាងពេបជ្រាយ តែមិនហ៊ានធ្វើអ្វីជាប្រយោជន៍ដល់សង្គមសោះ។ មិនត្រូវតូចចិត្ត រាថយព្រោះតែ ការរិះគន់នោះឡើយ។ ព្រោះថា ពពួកជនអវិជ្ជមាន មិនមែនមានតែក្នុងសង្គមខ្មែរ បច្ចុប្បន្ននោះទេ តែមានតាំងសម័យព្រះពុទ្ធអង្គ នៅជាក្សត្រ័មកម្លេះ (ពួកមារ)។ តែបើយើងមានភាពរឹងប៉ឹង ទាំងផ្លូវចិត្ត ផ្លូវកាយគ្រប់គ្រាន់ ឈ្នះរឿងរ៉ាងអស់ទាំងនេះ យើងនឹងទទួលបានជោគជ័យយ៉ាងប្រាកដ ហើយពួកជនអវិជ្ជមាន(មារ)ទាំងនេះ នឹងក្លាយមកជាបរិវារ ជាអ្នកចុះញ៉មយើងវិញមិនខាន។

**-ការដែលធ្វើគំរោងផែនការមិនខុស**

មេដឹកនាំខ្មែរ មុននឹងធ្វើផែនការ ត្រូវតែស្គាល់ស្ថានការណ៍អោយច្បាស់ សិក្សាយកពត៌មានអោយបានជាក់លាក់។ មេដឹកនាំខ្មែរ ត្រូវចំរាញ់ពត៌មាន ដែលទទួលបាន រហូតទាល់តែពត៌មាននោះល្អិតល្អន់ល្អ ទើបយកពត៌មាននោះ មកធ្វើផែនការ ដើម្បីប្រៀបធៀបជា មួយគូប្រកួតប្រជែងរបស់យើង ដោយដឹងជាមុនថា គំរោងផែនការនោះពិតជាឈ្នះ ឬគំរោងផែន

ការនោះចាញ់។ មេដឹកនាំខ្មែរ ត្រូវដឹងពីខ្លួនឯង និង សត្រូវទាំងចំនួន កំលាំង សមត្ថភាព ស្មារតី ធនធាន បច្ចេកវិទ្យា សំភារះ ស្ថានការណ៍ និងបរិដ្ឋានជុំវិញខ្លួន ។ល។ បើសិនមានខ្វះចន្លោះ ត្រូវកែតំរូវ និងបំពេញបន្ថែម អោយបានត្រឹមត្រូវ មុននិងដាក់អោយគេអនុវត្តន៍។

**-ការមិនធ្វើខុសដោយសំដី ដោយចិត្ត ដោយកាយវិការ** ដោយការងារចំពោះខ្លួនឯង អ្នកក្រោមបង្គាប់ សហការី ការងារ ប្រជាពលរដ្ឋ ច្បាប់ តួនាទី ទំនៀមទំលាប់ វប្បធមិ និងប្រពៃណីជាតិខ្មែរ នេះហើយ ជាលក្ខណៈ មេដឹកនាំល្អរបស់ខ្មែរ។

*អ្នកដឹកនាំខ្មែរ មិនគាំទ្រ មិនសមគំនិតនឹងអ្នកធ្វើខុសឡើយ ។ ពេលធ្វើខុស អ្នកដឹកនាំខ្មែរ ត្រូវហ៊ានទទួលខុស មិនលំអៀង ព្រោះអគតិ ៤ យ៉ាង គឺការស្រឡាញ់ ស្អប់ ច្រណែន ឈ្នានីស ។*

## VIII. ធ្វើគំរូនាំមុខគេ (Set the Example)

មេដឹកនាំខ្មែរ ត្រូវធ្វើជាគំរូល្អ នាំមុខគេជានិច្ច តាំងពីកាយវិការ ដេក ដើរ ឈរ អង្គុយ និយាយស្តី និងអនុវត្តការងារគ្រប់យ៉ាង។ មេដឹកនាំខ្មែរ ត្រូវប្រយ័ត្នគ្រប់វិនាទី នូវសកម្មភាពរបស់ខ្លួន ពោលត្រូវអនុវត្តអោយបានត្រឹមត្រូវតាមភារៈជាអ្នកដឹកនាំ។ ចូរចាំថា " ទង្វើរបស់យើងជាអ្នកដឹកនាំ ទោះដោយចេតនា ឬ អចេតនា ជាតំរាប់របស់ អ្នកក្រោមឱវាទ" ។ នៅក្នុងកិច្ចការដែលលំបាក មានការប៉ះពាល់ដល់អាយុជីវិត ជាពិសេសពេលសង្គ្រាម អ្នកដឹកនាំខ្មែរ ត្រូវតែនាំមុខ ធ្វើកិច្ចការដ៏លំបាកមានគ្រោះថ្នាក់នោះមុនគេ។ ព្រោះថា "***ការដឹកនាំដោយទង្វើ ប្រសើរជាងការគ្រាន់តែនិយាយ***" ។ ការជ្រើសរើសសមាជិក ឬក៏ជ្រើសរើសមេដឹកនាំ ដែលយើងត្រូវដើរតាម ក៏ដូចគ្នាដែរ ***ត្រូវសំឡឹង ចាប់យកអ្នកធ្វើ*** *តែកុំចំណាយពេលស្តាប់ អ្នកដែលគ្រាន់តែនិយាយ* ហើយមិនធ្វើនោះឡើយ។ វាអាចនឹងធ្វើអោយយើងចំណាយពេលចោលឥតប្រយោជន៍ ឬជួនកាលធ្វើអោយយើងខកចិត្តទៀតផង។ គ្រាន់តែនិយាយ អ្នកណាក៏និយាយបាន តែរឿងសំខាន់ ផលកើតចេញពី ទង្វើ មិនមែនកើត ចេញ ពីពាក្យសំដីដែលគ្រាន់តែនិយាយអោយពិរោះស្តាប់នោះសោះឡើយ។ ក្រៅពីនេះ ការនៅរួមសុខទុក្ខ ទ្រាំទ្រការលំបាក អត់ឃ្លាន ជាមួយគ្នា មិនរត់ចោលគ្នា ក្នុងគ្រាមានអាសន្ន ជាកត្តាចិត្តសាស្ត្រមួយ យ៉ាងសំខាន់ ក្នុងការសាងការជឿទុកចិត្ត ពីអ្នកផងជុំវិញខ្លួន មកលើយើងជាអ្នកដឹកនាំ ។ ក្នុងកាលៈទេសៈ សព្វថ្ងៃនេះ ប្រទេសជាតិយើង កំពុងតែធ្លាក់លិចស្រឹមយ៉ាងគំហុកទៅ ក្នុងគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរជាងពេលណាៗទាំងអស់។ សេចក្តីស្រឡាញ់ស្ម័គ្រស្មោះ ពិតប្រាកដ ចំពោះជាតិមាតុភូមិ មិនស្ថិតនៅលើបបូរមាត់ ដែលគ្រាន់តែដើរពោលដើរនិយាយ ចាយពេលចោលឥតប្រយោជន៍នោះឡើយ តែស្ថិតនៅលើ ទង្វើរបស់យើង។ ពោលគឺ យើងមិនត្រូវរង់ចាំ អ្នកដឹកនាំពីណា មកដឹកនាំយើងឡើយ តែក្នុងឋានៈយើងជាខ្មែរ ត្រូវក្រោកឈរឡើង ធ្វើខ្លួនយើងអោយសក្តិសមជា អ្នកដឹកនាំខ្មែរពិតប្រាកដ ហើយចាប់ផ្តើមធ្វើកិច្ចការទាំងឡាយ ដែលអាចជួយដល់គោលដៅ នៃការស្រោចស្រង់សង្គ្រោះជាតិយើង មានការជួយឃោសនាពន្យល់ ប្រជាជាតិខ្មែរអោយយល់ពីគ្រោះអាសន្នរបស់ជាតិ និងបណ្តុះអោយមានស្មារតីជាតិនិយមខ្ពង់ខ្ពស់ឡើង ភ្ញាក់រលឹកក្រោកឈររួមគ្នា រំដោះជាតិមាតុភូមិ ជាទីស្រឡាញ់នៃយើង។ ពោលអោយងាយយល់គឺ យើងខ្លួនឯងត្រូវហ៊ាននាំមុខគេក្រោកឡើងធ្វើការតស៊ូ ដើម្បីជាគំរូ ដល់អ្នកដទៃដើរតាម។ មានន័យថា មេដឹកនាំខ្មែរ មិនចាំបាច់មានគេមក តែងតាំងយើងអោយធ្វើជា មេដឹកនាំនោះទេ តែយើងត្រូវហាត់រៀន ធ្វើជាមេដឹកនាំដោយខ្លួនឯង។ ព្រោះថា "***មិនខ្វះទេអ្នកដើរតាម ក៏ប៉ុន្តែ ខ្វះតែអ្នកដែលអាចធ្វើខ្លួនអោយគេដើរតាមតែប៉ុណ្ណោះ***"។ ភាពជាមេដឹកនាំ មិនមែនសុទ្ធសឹងតែកើតពីកំណើតនោះទេ តែយើងអាចហាត់រៀនបណ្តុះខ្លួនយើង អោយកើតឡើងបាន។ ហេតុនេះ ដើម្បីក្លាយខ្លួន ជាមេដឹកនាំ យើងត្រូវហាត់រៀន ប្រៀបដូចយើងរៀនមុខវិជ្ជាដទៃដែរ។ ឧទាហរណ៍ អុស និងភ្លើង។ រវាងអុស និងភ្លើង គេមិនដែលយកភ្លើងទៅដុត ដោយគ្មានអុសបានទេ គេត្រូវដើររកអុសសិន ទើបគេយកភ្លើងមកដុតជាក្រោយបាន។

យ៉ាងណាមិញ ការធ្វើជា មេដឹកនាំ ក៏ដូច្នេះដែរ យើងត្រូវហាត់រៀន និងហ្វឹកហាត់ អោយស្ទាត់ជំនាញក្នុងការដឹកនាំជាមុនសិន មុននឹងយើងអាចធ្វើអោយ គេស្មគ្រ័ស្មោះយល់ព្រម ដើរតាមយើង ដោយមិនបាច់រង់ចាំមានអ្នកណាមកតែងតាំងយើង អោយធ្វើមេគេឡើយ។ គ្មាននរណាកើតមកក្លាយ ជាមេដឹកនាំដោយគ្មានការរៀនសូត្រនិងអនុវត្តនោះឡើយ។ (សូមអានសៀវភៅ **គោលការណ៍ សកម្ម ១០០ ប្រការ ដើម្បី ជោគជ័យ**លោក ជុំ សមវាសនា) ឬសៀវភៅ **សាងខ្លួនឯង** ។

ប្រទេសខ្មែរបច្ចុប្បន្ន កំពុងស្ថិតនៅក្រោមការគាបសង្កត់របស់ជនផ្តាច់ការ **ហ៊ុន សែន** យួន **ហុក ឡុងឌី** និងបក្សពួកមួយក្តាប់តូច។ វាកៀបសង្កត់ បំបិទ សិទ្ធិសេរីភាពខ្មែរ ក្នុងការគិត ការិយាយស្តី ការសរសេរ ការបញ្ចេញយោបល់ គិតគូរបញ្ហា ប្រទេសជាតិ ផ្នែកសេដ្ឋកិច្ចជាតិជាដើម។ ប្រជាពលរដ្ឋខ្មែរ រស់នៅក្នុងភាព ក្រីក្រ ស្រេកឃ្លាន ខ្លាចភិតភ័យ និងសេចក្តីស្លាប់ លេចលង់រងទុក្ខដោយសារអំពើពុករលួយ ការកាប់បំផ្លាញព្រៃឈើ ភាពគ្មានការងារធ្វើ  ការបាត់បង់ទឹកដីតាមព្រំដែន ការរំលោភដីធ្លីពីអ្នកមានអំណាច ជនអន្តោប្រវេសន៏យួនកើនឡើង រហូតដល់ ៤ ៥០០ ០០០នាក់ តាមរយៈសមាគមន៏យួន ១៩ ខេត្ត ក្រុង។ សមាគមន៏នេះ ជារដ្ឋាភិបាលស្រមោលរបស់យួន។ យួនបានកែប្រែ បន្តិចម្តងៗ តាមគោលការណ៍ សហព័ន្ធឥណ្ឌូចិនរបស់វា ដើម្បីលេបយកទឹកដីខ្មែរ ហើយធ្វើឱយប្រជាជាតិខ្មែរយើង ក្លាយជាជនជាតិភាគតិចរបស់ប្រជាជនឥណ្ឌូចិន ដែលមានយួនជាអ្នកត្រួតត្រា ដោយការប្រើអោយយួនដែលចេះភាសាខ្មែរ កែប្រែរដ្ឋធម្មនុញ្ញ ដាក់ប្រទេសខ្មែរ ជាអាណាខេត្តមួយ របស់ប្រទេសយួន ដូចកាលយួនយកទឹកដីខ្មែរនៅកម្ពុជាក្រោមកន្លងមកដូច្នោះដែរ។ បន្ថែមពីលើនេះ វានឹងប្រើកំលាំងទព័យួន ដែលបង្កប់នៅក្នុងជួរប៉ូលិស ជួរទាហាន និងនៅជាអ្នកនេសាទនៅតាមទន្លេរសាប និងនៅលើដីសម្បទាន សំរាប់ដំណាំកៅស៊ូ ១០០០០០ម៉ឺនហិកតា (មានទាហានយួន ៣៥០០០-៥០០០០នាក់) ដែលអាយ៉ង ហ៊ុន សែន ទើបចុះហត្ថលេខាថ្មីៗនេះ ធ្វើការកៀបសង្កត់បង្ខំខ្មែរ អោយដើរតាមនយោបាយឧក្រិដ្ឋរបស់យួន។ ហេតុដូច្នេះ ក្នុងនាមយើងជាខ្មែរម្នាក់ ដែលបានមើលឃើញបញ្ហាបែបនេះ ត្រូវហ៊ានក្រោកឈរឡើង ធ្វើជាគំរូនាំមុខគេ ដឹកនាំប្រជាពលរដ្ឋខ្មែរ ពន្យល់ខ្មែរគ្រប់រូប អោយដឹងអោយយល់ ពីនយោបាយវាតទីរបស់យួន។ រួបរួមគ្នាពីគ្រប់ទឹសទី ក្រោកឈរពើងទ្រូង ឡើងមុនគេ ធ្វើការការពារប្រទេសជាតិ យើងអោយគង់វង្ស ទុកជាកេរ្តិ៍ ដំណែលដល់កូនខ្មែរជំនាន់ក្រោយ។

## IX-ហ៊ានទទួលខុសត្រូវចំពោះសកម្មភាពរបស់យើង (Take and Seek responsibility)

មេដឹកនាំខ្មែរត្រូវមាន ***ចក្ខុវិស័យ*** (*គំនិតផ្តួចផ្តើម ឆ្នៃប្រឌិត គំនិតថ្មី*) ដើម្បីនាំអ្នកដទៃចាប់ផ្តើមធ្វើ ការដឹកនាំ។ មេដឹកនាំខ្មែរ ត្រូវតែស្វែងរកផ្លូវ (ជ្រើសរើស យុទ្ធសាស្រ្ត ឧបករណ៍ និងវិធានការ) ដើម្បីធ្វើអោយក្រុមការងារ របស់យើង **ទទួលជោគជ័យ និងសំរេចគោលដៅរួម ដែលយើងចង់បាន។** មេដឹកនាំខ្មែរ ត្រូវហ៊ានទទួលខុសត្រូវ ចំពោះសកម្មភាព ខ្លួនឯងត្រូវចៀសវាងជាដាច់ខាត ពេលដែលផែនការទទួលបរាជ័យ ឬខុសទៅស្តីបន្ទោសអ្នកដទៃ ឬទំលាក់កំហុសដាក់អ្នកផ្សេង។ បើយើងជាមេដឹកនាំមិនហ៊ានទទួលកំហុស ដែលខ្លួនធ្វើខុសនោះ យើងមិនមែនជាមេដឹកនាំពិតប្រាកដទេ។ យើងត្រូវវិភាគស្ថានការណ៍អោយបានច្បាស់លាស់ និងល្អិតល្អន់ មុននឹងធ្វើផែនការណាមួយ ពោលគឺត្រូវរៀបចំភ្នាក់ងារពតិមាន ឱយមានប្រសិទ្ធភាព គួរទុកចិត្តបាន ឬធ្វើការពិនិត្យស្ថានការណ៍ដោយផ្ទាល់ខ្លួន។ យើងត្រូវទទួលខុសត្រូវរាល់ទង្វើ ដែលយើងបាន សំរេចចិត្តហើយ ។ នៅពេលការងារបានជោគជ័យ យើងជាអ្នកទទួលស្នាដៃ (ទទួលត្រូវ) ប៉ុន្តែ យើងមិនត្រូវលើកតំកើងខ្លួនឯងឡើយ ផ្ទុយទៅវិញ យើងត្រូវលើកស្នាដៃនោះ ដាក់អោយអ្នកដែលរួមការងារជាមួយយើង ដើម្បីអោយអ្នកទាំងនោះកាន់តែមានកំលាំងចិត្តប្តូរផ្តាច់ធ្វើការជាមួយយើងខ្ពស់ឡើងថែមទៀត។ ចូរចាំថា "*ខ្លែងហើរត្បិតខ្យល់ មេខ្លាំងត្បិតពល*"។ អ្នកដឹកនាំខ្មែរ

មិនត្រូវប្រើពាក្យថា **គងខ្ញុំ ជោគជ័យរបស់ខ្ញុំ** ទេ តែត្រូវប្រើពាក្យថា **គងយើង ជោគជ័យរបស់យើង** វិញ។ ចូរកុំកេងបន្លំ បំបាត់ស្នាដៃរបស់អ្នកដទៃ ឬកេងចំណេញ ពីស្នាដៃរបស់អ្នកដទៃនោះដាច់ខាត ទង្វើបែបនេះមិនមែន ជាអ្នកដឹកនាំខ្មែរ ពិតប្រាកដទេ។ ក្នុងឋានៈជាមេដឹកនាំខ្មែរ យើងត្រូវតែហ៊ាននិយាយថា *" នេះជាកំហុសរបស់ខ្ញុំ អស់លោកខិតខំធ្វើការ ខ្លាំងណាស់ "* សម្តីនេះនឹងជំរុញ ទឹកចិត្ត អ្នកដែលធ្វើខុស ខំប្រឹងធ្វើអស់ពីចិត្ត និងគោរពស្រឡាញ់លោកជានិច្ច។

កន្លងមកពួកមេត្រួតត្រាខ្មែរមួយចំនួន បានធ្វើកំហុសយ៉ាងធ្ងន់ធ្ងរមិនអាចវាស់បាន ចំពោះសង្គមជាតិខ្មែរ តែពួកទាំងនេះ មិនដែលព្រមទទួលកំហុសទាល់តែសោះ។ ផ្ទុយទៅវិញ ពួកនេះសុខចិត្តលាក់បាំងការពិត ខិតខំក្លែងបន្លំ ប្រវត្តិសាស្ត្រតាមផែនការយួន ចៅហ្វាយវា ធ្វើអោយកូនខ្មែរ ជំនាន់ក្រោយងងឹត មើលមិនឃើញថា តើអ្វីខុស? អ្វីត្រូវ? ដែលជាហេតុ ធ្វើឱ្យសង្គមជាតិ ត្រូវលិចលង់ក្នុងមហន្តរាយដោយសារ ខ្មែរគ្មានឆន្ទៈក្រោកឡើងការពារជាតិមាតុភូមិទាល់តែសោះ ព្រោះមិនយល់ការពិត។ នេះជាទង្វើ ដ៏លង់ខ្លៅរបស់ ពួកមេត្រួតត្រាសព្វថ្ងៃ កំពុងដើរតាមគន្លងយុទ្ធសាស្ត្រ យួន គូសអោយ។ ពួកក្បត់ទាំងនេះ ធ្វើឱ្យប្រទេសខ្មែរលិចលង់ និងប្រជាពលរដ្ឋខ្មែររាប់លាននាក់ **ស្លាប់យ៉ាងវង្វេង ដីសែនវទ្ធត់ហួសប្រមាណ ធនធានរបស់ប្រទេសជាតិត្រូវបាត់បង់គ្រប់បែបយ៉ាងស្ទើគ្មានសល់ តែពួកចោកទាបទាំងនេះ មិនដែលហ៊ាន ចេញមុខទទួលកំហុសសោះឡើយ តើខ្មែរនៅទ្រាំទុក្ខអោយពួកវាត្រួតត្រាខ្មែរតទៅទៀតរហូតដល់ស្លាប់ផុតពូជឬយ៉ាងណា?** ។

ហេតុដូច្នេះ ដើម្បីស្រាយបញ្ហាទុក្ខវេទនា និងភាពរីករវេ សួរពូជមិនចេះចប់ ខ្មែរត្រូវតែត្រូវសិក្សាប្រភពនៃបញ្ហាឱ្យបានដល់ឬសគល់ ច្បាស់លាស់ជាក់លាក់ ដោយផ្អែលលើ **ហេតុ ផល ពិត** មិនត្រូវផ្អែកលើការស្មាន តាមអារម្មណ៍ នឹកឃើញ គ្មានហេតុ ផល គ្មានការពិត ឬអ្វីជាអរូបិយ៍ នោះឡើយ។ យើងត្រូវ ពិចារណាថា តើហេតុអ្វីបានជាប្រទេសខ្មែរ មានសង្គ្រាម ខ្មែរស្លាប់ បាត់បង់ទឹកដី និងទ្រព្យសម្បត្តិជាតិត្រូវរលាយហិនហោច? ចំលើយ មានតែមួយគត់ គឺ **កំហុសមេដឹកនាំ** ។

*អ្នកដឹកនាំខ្មែរជំនាន់ក្រោយ ត្រូវហ៊ានប្រឈមនឹងការពិត ហ៊ានទទួលកំហុសចំពោះជាតិរបស់ខ្លួន ទើបសក្តិសម ជាអ្នកដឹកនាំ ពិតប្រាកដ។*

ខ្មែរត្រូវក្រឡេកមើល ប្រទេសនានា ជាមេរៀនខ្លះ។ នៅប្រទេស ជប៉ុន មេដឹកនាំរបស់គេ មានការទទួលខុសត្រូវខ្ពស់ណាស់ ។ បើមេដឹកនាំណាមួយ ដឹកនាំច្បាំងបរាជ័យ និងស្លាប់ទាហានច្រើន មេដឹកនាំនោះ ហ៊ានធ្វើអត្តឃាតខ្លួន ដើម្បីបង្ហាញពីការទទួលខុសត្រូវរបស់ខ្លួន។ ជារឿងគួរអោយអាម៉ាស់ ពួកមេត្រួតត្រា ដែលជាអាយ៉ងបរទេស សព្វថ្ងៃ សុខចិត្តប្រមូលទាំងកូន ពូនទាំងពូជ ទៅលាក់ខ្លួនក្រោមកន្ទុយក្បិន បញ្ចេញសំលេង រកពាក្យដោះសារយកត្រូវ យ៉ាងកំសាកទៅវិញ ដោយសុខចិត្តអោយប្រជាពលរដ្ឋស្លាប់ ដើម្បីអំណាចខ្លួន រួចដើរផ្សាយថាទាំងងងើលលីលាប្រាប់ខ្មែរថា ជារឿងនយោបាយទៅវិញទេ។ មេដឹកនាំជាតិសាសន៍ដទៃ ដឹកនាំនយោបាយ ដើម្បីអោយប្រទេសជាតិរីកចំរើនរុងរឿង ចំណែកពួកមេត្រួតត្រាសព្វថ្ងៃ សម្លាប់ប្រជាពលរដ្ឋឯង កាត់ទឹកដីអោយបរទេស បំផ្លាញទ្រព្យសម្បត្តិជាតិ ថាជារឿងនយោបាយ។ ពួកមេត្រួតត្រាបែបនេះ បោកបានតែប្រជាពលរដ្ឋខ្មែរ ដែលខ្វះការចេះដឹងតែប៉ុណ្ណោះ តែចាប់ពីពេលនេះតទៅ ប្រជាពលរដ្ឋខ្មែរ ឈប់លង់ឈប់ជឿការបោកប្រាស់របស់មេក្បត់ជាតិ ដូច **ហ៊ុន សែន** នេះទៀតហើយ។

មេដឹកនាំជាតិខ្មែរត្រូវមានការទទួលខុសត្រូវខ្ពស់ចំពោះប្រជាជាតិខ្មែរ ក្នុងនាមជាអ្នកកើតមកមានឈាមជ័រជាខ្មែរ ត្រូវហ៊ាន ក្រោកឡើង ធ្វើការ ស្រោចស្រង់សង្គ្រោះ ជាតិ ការពារទឹកដីខ្មែរ ពីពួកចោរយួន និងអាយ៉ង **ហ៊ុន សែន** ដែលវាមាន បំណងរំលាយពូជសាសន៍ខ្មែរ និង លេបយកទឹកដីខ្មែរ តាមនយោបាយដ៏ប្រកបដោយកលល្បិចពិសពុលនេះ។ ចោរយួនវាប្រើប្រាស់ **សី ហានុ** ធ្វើជាខែល និងយកព្រះពុទ្ធសាសនាជារនាំង។ មេដឹកនាំខ្មែរ ត្រូវខិតខំចងក្រង ប្រមូលផ្តុំ ជាក្រុម ជាពួក រួបរួមកម្លាំងគ្នា រវាងប្រជាជាតិខ្មែរ អោយស្អិតរមួត ដោយមិនបណ្តោយឱកាសកន្លងទៅទទេៗ ឬទុកពេលវេលាចោលឥតប្រយោជន៍ ដោយដេកសង្ឃឹម រង់ចាំអ្នកមានបុណ្យ មកដឹកនាំខ្មែរឡើយ យើងជាជាតិខ្មែរ មានបុព្វសិទ្ធិពេញទី ដើម្បី ការពារជាតិ សាសនា ប្រជាជាតិខ្មែរ ទឹកដីខ្មែរ មិនអោយរលាយបាត់បង់។ មេដឹកនាំជាតិខ្មែរ ត្រូវហ៊ានធ្វើជា មេដឹកនាំដោយខ្លួនឯង *មិនរង់ចាំថ្ងៃស្អែកឡើយ គឺត្រូវចាប់ផ្តើមធ្វើភ្លាមចាប់ពីពេលនេះ ថ្ងៃនេះទៅ* នូវ កិច្ចទាំងឡាយ សំរាប់ជាតិខ្មែរទាំងមូល។ ដូចភាសិតបុរាណខ្មែរ បានទូន្មានទុកថា "*ធ្វើអ្វីធ្វើឱយហើយ កុំទុកឡើយបង្កើតក្តី*"។ *បើមេដឹកនាំជាតិខ្មែរ ដែលអានសៀវភៅ នេះក្នុងដៃហើយ ពិតជាតាំងចិត្ត តំណាងអោយជាតិខ្មែរ ត្រូវតែទទួលខុសត្រូវចំពោះជាតិខ្លួន ដោយផ្អែកលើស្មារតីឥស្សរៈភាព ដែលស្របតាមឱវាទ ព្រះពុទ្ធជាអង្គម្ចាស់ ប្រដៅទុកថា* ***អត្តាហិ អត្តានោ នាថោ*** *(ខ្លួនទីពឹងខ្លួន)*។ **ការហ៊ានក្រោកឈរឡើង ដោយផ្អែកលើស្មារតី ខ្លួនទីពឹងខ្លួន នេះហើយ ជាធាតុយ៉ាងសំខាន់ របស់អ្នកដឹកនាំខ្មែរ ក្នុងការទទួលខុសត្រូវ ក្នុងឋានៈយើងជាខ្មែរមួយរូប។**

## X~ឧស្សាហ៍ព្យាយាម សិក្សារៀនសូត្របន្ថែម ( Industrous to study)

មេដឹកនាំខ្មែរ ត្រូវខិតខំសិក្សារៀនសូត្រ បន្ថែមគ្រប់ពេលវេលា ដើម្បីអោយខ្លួនមានចំណេះដឹងថ្មី គំនិតផ្តួចផ្តើមថ្មី និង ការឆ្នៃប្រឌិតថ្មី ដើម្បីឱយខ្លួន មានការរីកចំរើនឡើង ថែមទៀតស្របតាមស្ថានការ និងតំរូវការរបស់សង្គម បរិយាកាសជុំវិញខ្លួន ក្នុងក៏រិតជាតិ និងអន្តរជាតិ ។ ព្រោះថា ពិភពលោក វិលវិវត្តន៍ប្រែប្រួលទៅមុខជានិច្ច ពោរពេញដោយការប្រកួតប្រជែងគ្មានឈប់ឈរឡើយ បើយើងគ្មានការសិក្សាបន្ថែមទេ បានន័យថា យើងរស់នៅតាមសភាវគតិ ដូចសត្វធាតុ នោះ នឹងមិនអាចតទល់នឹងអ្នកជិតខាង ដ៏ពោរពេញដោយមហិច្ឆិតា និងការលោភលន់បានឡើយ។ ចូរកុំគិតថា ខ្លួនចេញពីសាលា មកចេះអស់ហើយ ត្រូវចាំថា ភាពអវិជ្ជា បីដូចជា ស្នឹមច្រែះដែក ដូច្នោះដែរ វាដើរមករកយើងរៀងរាល់ថ្ងៃ ហេតុនេះយើងត្រូវតែដុះខាត់វាជាប្រចាំ។ ក្នុងការសិក្សា រៀនសូត្របន្ថែម មិនមែន ចាំទាល់តែចូលសាលាមិនធ្វើអីនោះទេ តែមេដឹកនាំខ្មែរ អាចធ្វើតាមរយៈ ការអានសៀវភៅ ស្រាវជ្រាវដោយខ្លួនឯង ការធ្វើសិក្ខាសិលា ការឆ្លៀតរៀនតាមសាលាផ្សេងៗ ឬការស្រាវជ្រាវតាមបណ្តាញសារពតិមាន អ៊ីនធើណេត ការសែត វិទ្យុ ឬទូរទស្សន៍ (ប្រពន្ធ័ឃោសនាឯករាជ្យ ឬក្រៅប្រទេស)ជាដើម។ នៅក្នុងផ្ទះគ្មានសៀវភៅ ប្រៀបដូចជាមនុស្ស គ្មានវិញ្ញាណ។ ការឧស្សាហ៏អានសៀវភៅ ធ្វើឱយមេដឹកនាំកាន់តែ មានពន្លឺភ្លឺ ស្វាងក្នុងខ្លួន មើលឃើញកាន់តែវែងឆ្ងាយ។ ការអានសៀវភៅ ត្រូវអាន ឬស្រាវជ្រាវឱយចំទិសដៅ ដែលយើងត្រូវធ្វើ និងគោលបំណង ដែលយើងត្រូវដោះស្រាយដើម្បី សំរួចចក្ខុវិស័យដែលបានកំណត់។ ត្រូវចាំថា បើយើងអានសៀវភៅចប់ ចាប់តាំងពី ៣០០ ក្បាល ឡើងទៅនោះ យើងនឹងក្លាយជាអ្នកឯកទេសមួយយ៉ាងប្រាកដ។ លោក **អាប្រាហាម លិនខុន** ប្រធានាធិបតីអាមេរិក លោកគ្មានលទ្ធភាព រៀននៅសាកលវិទ្យាល័យទេ ព្រោះលោកកើតនៅក្នុងត្រកូលក្រីក្រ តែដោយសារឆន្ទៈមុះមុតរបស់លោក លោកបានព្យាយាម អានសៀវភៅ ដោយខ្លួនឯង ហើយចូលប្រឡូក ធ្វើជាមេដឹកនាំសហរដ្ឋអាមេរិក លុះត្រាបានសំរេច។ មេដឹកនាំជាច្រើនទៀត នៅលើពិភពលោក ដែលមានស្ថានភាពដូចគាត់ ក៏បានធ្វើយ៉ាងដូច្នេះ និងទទួលបានជោគជ័យដ៏ត្រចះត្រចង់ផងដែរ។

## XI-ត្រូវសំរេចចិត្តអោយទាន់ពេលវេលា (Make the Puntual Decision)

ការសំរេចចិត្ត ជាកត្តាមួយសំខាន់ណាស់សំរាប់មេដឹកនាំ បើមេដឹកនាំសំរេចចិត្តត្រូវ ហើយទាន់ពេលវេលា នោះអាចនាំអោយអង្គការដឹកនាំទទួលបានជោគជ័យ។ តែបើមេដឹកនាំសំរេចចិត្តខុស មិនទាន់ពេលវេលា នោះនឹងធ្វើអោយឱកាស នៃការទទួលជោគជ័យបាត់បង់ទៅ ហើយធ្វើអោយអង្គការដឹកនាំ ទទួលបរាជ័យ និងឈានទៅរកការខាតបង់ ផលប្រយោជន៍ផ្សេងៗ និងបង្ករការគ្រោះថ្នាក់ដល់អ្នកដើរតាម ឬប្រជាជាតិ និងប្រទេសជាតិទៀតផង។ ក្នុងការសរេចចិត្ត មេដឹកនាំខ្មែរ ត្រូវប្រមូលពតិមានអោយច្បាស់លាស់ គ្រប់ជ្រុងជ្រោយ មកចំរាញ់ ដោយផ្អែកលើ ហេតុ ផល ពិត ដោយភាពល្អិតល្អន់សិន។ មិនត្រូវជឿលើពាក្យសំដី របស់ជន ដែលគ្មានហេតុផល ឬពួកដែល អារម្មណ៍និយម ស្រមើស្រមៃនិយម។ **ភាពស្ទាក់ស្ទើរមិនប្តូរផ្តាច់ ជាកត្តានាំមកនូវបរាជ័យ**

ជារឿយៗ យើងតែងជួបប្រទះនូវជំពូកជន មួយចំនួន បាននិយាយថា" *សម័យនេះទៅហើយ មិនអាចប្រទេសណារំលោភយកប្រទេសណាមួយបានឡើយ ឬក៏ថា ខ្មែរចូលអាស៊ានទៅហើយ មិនភ័យខ្លាចគេយកទឹកដីទៀតទេ* " ។ សំដីទាំងនេះជាគំនិត ដែលមើលមិនឆ្ងាយ ឬក៏ជាគំនិត ដែលប្រើអារម្មណ៍ ។ ចូរយើងជាអ្នកដឹកនាំខ្មែរ ចាំជាប់ជានិច្ចថា " ***សម័យណាក៏គេអាចលេបយកទឹកដីយើង បំបាត់ពូជយើង បានដែរ បើយើងមិនឆ្លាត ឬបើយើងមានតែអ្នកដឹកនាំជាអាយ៉ង ជាមនុស្សពាលល្ងង់ខ្លៅមិនគិតជាតិ។ របៀបយកគេអាចផ្លាស់ប្តូរវិធីទៅតាមពេលវេលា និងសម័យកាលតំរូវអោយ តែគេនៅតែយក បានយ៉ាងប្រាកដ*** ។***តែបើយើងមានអ្នកដឹកនាំឈ្លៀវឆ្លាត មានស្មារតីលះបង់ ហ៊ានប្តូជាជីវិត ដើម្បីជាតិ និងប្រជាជាតិខ្មែរយ៉ាងប្តូរផ្តាច់ " សម័យកាលណាក៏យើងអាចរើបំរះ យកទឹកដីយើងដែលបាត់បង់មកវិញបានដែរ*** ។ ព្រោះអ្វី ? ព្រោះយើងមានរបស់ដ៏មាន តំលៃដែលមិនអាចកាត់ថ្លៃបាន ដែលពួកមេត្រួតត្រាបន្ទុបដោយបរទេស មិនដែលទឹកនាវីរវល់ទាល់តែសោះ គឺ ប្រជាជាតិខ្មែរ យើងដែលរស់នៅទីនោះ ជាប់រហូតមក និងស្លាកស្នាមប្រវត្តិសាស្រ្តសំខាន់រាប់មិនអស់ ជាអំណោយដល់យើង យ៉ាងសំបើម។ ប៉ុន្តែ វានឹងកើតឡើងបាន អាស្រ័យលើថាមពលរបស់យើងជាខ្មែរផងដែរ (ថាមពល នយោបាយ កងទ័ព សេដ្ឋកិច្ច និងឯកភាព នៃសង្គមខ្មែរ ក្រោមទស្សនៈវិស័យ នៃអ្នកដឹកនាំមួយក្រុមដ៏ស្មោះត្រង់ និងមានព្យាយាម)។ មានប្រទេសអ៊ីស្រាអែល ជាគំរូស្រាប់ ត្រូវបានពួក អេហ្ស៊ីប និងអារ៉ាប់ រំលាយពូជ រាប់ពាន់ឆ្នាំមកហើយ តែជនជាតិនេះ អាចក្រោកឡើងរួបរួមគ្នាជាជាតិមួយ ដែលខ្លាំងមិនអាចអ្នកណាប៉ះបានឡើយ ។ ចុះយើង ត្រូវធ្វើ យ៉ាងណា ? ទុកអោយជាតិស្លាប់ សិនសឹមរើ ឬត្រូវរើក្នុង ពេលដែលជាតិនៅរស់?។ ហេតុនេះហើយ យើងជាអ្នកដឹកនាំខ្មែរ ត្រូវតែធ្វើការថ្លឹងថ្លែងពិចារណាអោយល្អិតល្អន់ ធ្វើការសំរេចចិត្តអោយបានទាន់ពេលវេលា ដោយផ្អែកលើ **ហេតុ ផល ពិត** (Causes, Fact and Effects) និងស្ថានការណ៍ពិតជាក់ស្តែង នោះទើប យើងអាច សង្គ្រោះជាតិ របស់យើងបាន។ ***"ភាពកំសាក នាំមកនូវសេចក្តីស្លាប់ដល់ខ្លួន"*។**

ភាពស្រមើស្រមៃ ឥតហេតុផលនេះ មានជាប់ក្នុងស្មារតីអារម្មណ៍ រហូតមកដល់សព្វថ្ងៃនេះ ដែលជាកត្តា ធ្វើអោយយើងស្ទាក់ស្ទើ ខ្វះការពិត ការប្រឹងប្រែង។ ប្រជាពលរដ្ឋខ្មែរ យើងដ៏ច្រើនលើសលប់ ទាំងអ្នកគ្មានចំណេះដឹង ទាំងមានចំណេះដឹង កំពុងរង់ចាំអ្នកមានបុណ្យ ឬមេដឹកនាំនេះឯង ។ តែរឿងអ្នកមានបុណ្យ ដែលខ្មែរដេករង់ចាំក្នុងក្តីស្រមើស្រមៃ តាមល្បិចឃោសនារបស់យួន ដែលបានផ្សព្វផ្សាយរឿង "**ពុទ្ធទំនាយ**" នោះ ជាអ្នកមានបុណ្យ ដែលខ្មែរគិតថា ចុះពីលើមេឃ លើផ្កាយមក និងដែលគ្មានថ្ងៃនឹងកើតមានការពិតទាល់តែសោះ។ ផ្ទុយទៅវិញ វាជាឧបាយកលយួន សាបព្រួស ដើម្បីអោយខ្មែរដេកសង្ឃឹមខ្យល់ និងទុកឱកាសអោយចោរយួន រៀបចំផែនការលេបយកដីខ្មែរ តែប៉ុណ្ណោះ ទំរាំខ្មែរដឹងខ្លួន ក៏ហួសពេលកំរើកលែងរួច និងដល់ថ្ងៃបញ្ចប់ជីវិតខ្មែរទៅហើយ។ សូមខ្មែរទាំងអស់ជ្រាបថាមុនដំបូង យួន សំលាប់ជីវិត អ្នកចេះដឹងខ្មែរ និងគ្រឹះ

ពុទ្ធិខ្មែរក្នុងរបបក្រហម តែពេលនេះយួនប្រើ **ហ៊ុន សែន** សំលាប់ **ព្រលឹងខ្មែរ ឆន្ទៈខ្មែរ ស្មារតីខ្មែរ** អោយរលាយសូន្យ ថែមទៀត ( សូមមេត្តាអានបន្ថែមសៀវភៅ "ដំណើរឆ្ពោះទៅទិសខាងលិចឆ្នាំ ២០០០ របស់លោកសាស្ត្រាចារ្យ នួន ឃឿន ) ។

*ដូច្នេះ ក្នុងនាមយើងជាកូនខ្មែរ ជាសរសរទ្រូងប្រទេសជាតិ ជាទំពាំងស្នងឬស្សី បើដឹងហើយ ឃើញហើយ ឮហើយ ហើយ នៅវារែកស្ទាក់ស្ទើរ សំរេចចិត្តជួយស្រោចស្រង់ប្រទេសជាតិមិនទាន់ពេលវេលាទេនោះ ប្រទេសខ្មែរនឹងក្លាយ ដូចជាប្រទេសចំប៉ា និងខ្មែរកម្ពុជាក្រោម ដែលយួនកំពុងត្រួតត្រាបច្ចុប្បន្ននេះយ៉ាងប្រាកដក* គឺ ឈ្មោះ ប្រទេសកម្ពុជានៅតែមាន ក៏ប៉ុន្តែមិនមែនកម្ពុជា ដែលមានខ្មែរជាម្ចាស់ស្រុកដឹកនាំទេ ជាកម្ពុជាមានយួន ជាជនជាតិភាគច្រើន ជាអ្នកកាច់ចង្កូតវាសនាប្រទេសជាតិទៅវិញ ។ សម័យកាលនេះ ប្រជាជាតិនានា ដែលត្រូវពួកវាតទី រំលោភរំលាយពូជសាសន៍ ក្រោកឡើងធ្វើការតស៊ូប្រកបដោយជោគជ័យ និងដណ្តើមបានស្វ័យភាព ឯករាជ្យភាព កសាងជារដ្ឋ ឡើងវិញបានជាបន្តបន្ទាប់ ដូចជា អ៊ីស្រាអែល ទីម័រ ខាងកើត ប៉ាឡេស្ទីន ជាគំរូស្រាប់ ហើយមានប្រជាជាតិខ្លះទៀត កំពុងតែធ្វើការតស៊ូរើបំរះ ដូចមាននៅ ទីបេ ប្រទេសចិនជាដើម មានដំណើរការប្រកបដោយភាពវិជ្ជមាន ទាំងលើឆាកអន្តរជាតិ និងក្នុងមជ្ឈដ្ឋានប្រជាជាតិរងគ្រោះ ទាំងនេះ ។ ចុះយើងជាខ្មែរ សុខចិត្តអោយផុតពូជ រលាយជាតិ នាយុគសម័យនេះបានដែរឬ? វាជារឿងអាម៉ាស់បំផុត បើមិនបានដណ្តើមយកកម្ពុជាក្រោម ដែលបាត់បង់មកវិញទេ ក៏ត្រូវតែការពារ ទឹកដីដែលនៅសល់នេះអោយគង់វង្សដែរ ។ **"អ្នកដឹកនាំខ្មែរ ជាមេចនោតមនវិជ្ជានយោបាយ ជាឃោសនិកជំពិនប្រសប់ ជាគ្រូបង្វឹកជំពូកែ ជាអ្នកដឹកនាំទព័ប្រយុទ្ធជំក្លៀវក្លាប្តូរផ្តាច់មុតស្រួច និងមានប្រសិទ្ធិភាពខ្ពស់ផង តែមិនមែនជាចៅក្រមចាំកាត់ក្តីនោះទេ" ។**

## XII. ត្រូវចេះជួយគ្នា លាក់គ្នា ការពារគ្នា ទៅវិញទៅមក

ការជួយគ្នាទៅវិញទៅមក ជាកក្តានាំឱ្យមានសាមគ្គីភាព និងជោគជ័យ ។ ចោរយួន និងពួកអាក្បត់ ហ៊ុន សែន បានខិតខំរិះរកប្រើប្រាស់គ្រប់មធ្យោបាយ ធ្វើឱ្យសង្គមខ្មែរពោរពេញដោយការបែកបាក់ និងមិនទុកចិត្តគ្នា ។ មុននឹងចាប់ចងចោទប្រកាន់ អ្នកស្នេហាជាតិខ្មែរ វាតែងតែ ប្រឌិតចោទប្រកាន់អ្នកស្នេហាជាតិថា យ៉ាងនេះយ៉ាងនោះ ដូចភាសិតខ្មែរតែង និយាយថា " ***ដើម្បីវាយឆ្កែជា គេត្រូវចោទថាឆ្កែនោះឆ្កួត*** "។ ការប្រើប្រាស់កលល្បិចខ្មៅក្រខ្វក់ដូច្នេះ ដើម្បីធ្វើឱ្យអ្នកស្នេហាជាតិ ខ្មែរយើងបាត់បង់ភាពត្រឹមត្រូវ បាត់បង់មុខមាត់ត្រឹមត្រូវខាងនយោបាយ និងត្រូវរងនូវការថ្កោលទោសពី ជនាទុជនក្នុងសង្គមជាតិ និងសាធារណមតិ ។ ក៏ប៉ុន្តែ ទោះជាចោរយួន បង្ហូរជនជាតិយួន ដ៏សន្ធឹកសន្ធាប់ចូលមកតាំងទីលំនៅពាសពេញស្រុកខ្មែរ វាមិនដែលអើពើយកភ្នែកមើលសោះឡើយ ។

ហេតុដូច្នេះហើយ ក្នុងនាមយើងជាខ្មែរ មិនថាជាអ្នកដឹកនាំ ឬជាប្រជាពលរដ្ឋសាមញ្ញឡើយ ត្រូវចេះជួយលាក់ ជួយការពារ ជនរួមជាតិខ្មែរទាំងឡាយដែលត្រូវរងនូវការចោទប្រកាន់ ពីសំណាក់ពួកក្បត់ ។ ការជួយលាក់ ជួយការពារ ជួយបិទបាំង អ្នកស្នេហាជាតិ ជាមធ្យោបាយមួយ ជួយរក្សាកំលាំងស្នេហាជាតិ ឱ្យគង់វង់ និងជាការលើកទឹកចិត្តឱ្យមានអ្នកស្នេហាជាតិកាន់តែច្រើន ក្រោកឈរតស៊ូប្រឆាំងនឹងរបបត្រួតត្រាក្បត់សព្វថ្ងៃនេះ ។ មិនត្រឹមតែ ជនរួមជាតិខ្មែរទាំងលើនិងក្រោមប៉ុណ្ណោះទេ សូម្បីតែជន ជាតិនានាដែលរងគ្រោះដោយសារការរាតត្បាតពីសំណាក់ចោរយួន ដូចជា យួនសេរី ម៉ុង លាវសេរី ជាដើម ។ល។ យើងត្រូវតែជួយលាក់បាំងការពារយកអាសារដោយចិត្តស្មោះសរ ភាតរៈដូចជាបងប្អូនរួមឈាមរួមលោហិត ។ នេះជាមធ្យោបាយមួយធ្វើឱ្យយើងកាន់តែមានកំលាំង អ្នកប្រឆាំងនឹងយួន ច្រើនឡើង ដែលជាថាមពលមួយអាចវាយរុញច្រានឱ្យចោរយួន ដួលរលំបាន ។

# ផ្នែកទី ២

# សិល្បៈនៃការដឹកនាំ

**(The Art of Leadership)**

## I.ចក្ខុវិស័យអ្នកដឹកនាំខ្មែរ (Vision of Khmer Leader)

អ្វី១ទាំងអស់ ចាប់ផ្តើមឡើងត្រូវតែ មានចក្ខុវិស័យ។ ចក្ខុវិស័យ ជាប្រភពអរូបីយ៍ ដ៏មានប្រសិទ្ធភាព ក្នុងការដឹកនាំ វាគឺ ជាអ្វីដែលមេដឹកនាំ មើលឃើញដល់ជំរៅនូវ អតីតកាល បច្ចុប្បន្នកាល និង អនាគត ដ៏វែងឆ្ងាយ ហើយអាចទស្សន៍ទាយ ប្រមើលស្ថានការណ៍ ដែលអាចកើតមានខាងមុខ ទុកជាមុន ព្រមទាំងអាចកំណត់នូវ បន្ទាត់នយោបាយដឹកនាំ របស់ខ្លួនឆ្ពោះ ទៅរកជោគជ័យ សំរាប់អង្គការនយោបាយរបស់ខ្លួនបានទៀតផង។ បើមេដឹកនាំ គ្មានចក្ខុវិស័យទេ នោះនឹងគ្មានអ្នកដើរតាម ឡើយ។ ហេតុនេះ មេដឹកនាំខ្មែរ ទោះក្នុងលំដាប់ណាក្តី ត្រូវតែមានចក្ខុវិស័យជាក់លាក់ និងស្គាល់ច្បាស់លាស់ នូវផ្លូវដែល ត្រូវនាំទៅរកគោលដៅ និងជោគជ័យផ្តាច់ព្រ័ត្យ។ នៅក្នុងចក្ខុវិស័យ របស់មេដឹកនាំ ត្រូវមានគោលបំណង មនោគមន៍វិជ្ជានយោបាយ គោលការណ៍ ទិសដៅ គោលដៅ និងទំរង់នៃអង្គការនយោបាយដឹកនាំមួយ ដែលត្រូវបានគ្រោងឡើង អោយស្រប ទៅតាមស្ថានការណ៍ ជុំវិញខ្លួន តំរូវអោយ។ ក្រៅពីនេះ ត្រូវមានការលើកទឹកចិត្ត កិច្ចប្រតិបត្តិការអប់រំ ខាងប្រវត្តិសាស្ត្រ ចិត្តសាស្ត្រ ក្បួនច្បាប់ យុទ្ធសាស្ត្រ (វិធីធ្វើ ក្បួនខ្នាតគំរូ) ដែលបង្កប់ដោយ គំនិតរួបរួមជាតិ ឯកភាពជាតិតែមួយ តាមយុទ្ធសាស្ត្ររួមតែមួយ ប្រកបដោយ ឥស្សរភាព ដើម្បីដើរឆ្ពោះទៅរកជោគជ័យ។ ខាងក្រោមនេះ ជាទស្សនៈ និងចក្ខុវិស័យរបស់ មេដឹកនាំខ្មែរ ដែលមើលឃើញពី មហិច្ឆតា របស់ប្រទេសជិតខាងមានផែនការលេបត្របាក់យកទឹកដីខ្មែរ រំលាយពូជសាសន៍ខ្មែរ តាំងពីអតីតកាលរហូតមកដល់ បច្ចុប្បន្នកាល និងពេលអនាគត។

### ក-គោលបំណង និង ទិសដៅរបស់ យួន

យួន មានគោលបំណងយ៉ាងជាក់លាក់ ក្នុងការរំលាយពូជសាសន៍ខ្មែរ លេបត្របាក់ទឹកដីខ្មែរ និងពង្រីកអំណាចត្រួតត្រា នៅលើ ប្រទេសទាំងបីនៅជ្រោយឥណ្ឌូចិន។ យួនមានមហិច្ឆតា ត្រួតត្រាប្រទេសនៅទឹកដីទាំងនេះ ដូចយួនធ្លាប់បានសំរេចលេប យកប្រទេសចម្ប៉ា ខ្មែរកម្ពុជាក្រោមរួចមកហើយដែរ។ យួនកំពុងដាក់អណានិគមន៏បែបថ្មីលើប្រទេសលាវ និងប្រទេសខ្មែរបច្ចុប្បន្ន។ យួនបានឈ្លានពានលេបយកទឹកដីប្រទេសចម្ប៉ា ត្រួតត្រាចាប់ពីឆ្នាំ១៦៨៧ ?។ ថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៤៩ យួនបានលេបយកទឹកដី ខ្មែរកម្ពុជាក្រោម ថែមទៀតក្រោមការឃុបឃិតជាមួយបារាំង ដែលខ្មែរមិនបានដឹងសោះ ឬបែបធ្វើរំលង ពីលើក្បាលខ្មែរ ។ វាជាការរំលោភ មើលងាយមួយ មិនអាចទទួលយកបាន ចំពោះយើងជាប្រជាជាតិម្ចាស់ទឹកដី។ យួនបានឈ្លានពាន ត្រួតត្រាប្រទេសខ្មែរ ចាប់ពីថ្ងៃទី៧ ខែ មករា ឆ្នាំ១៩៧៩ ព្រមទាំងលើក បន្តុបជនកុម្មុយនិស្ត ក្បត់ជាតិ ដែលបំរើផលប្រយោជន៏អោយវា មានដូចជា **ហ៊ុន សែន** និង **ហេង សំរិន, ជា ស៊ីម** តាមរយៈ សន្ធិសញ្ញាំ សន្តិភាព មិត្តភាព សហប្រតិបត្តិការ ខុសច្បាប់ ឆ្នាំ ១៩៧៩ ១៩៨២ ១៩៨៣ ១៩៨៥ រវាងពួកអាយ៉ង និង យួន។ ទោះជាមានការបោះឆ្នោតជាបន្តបន្ទាប់មកក៏ដោយ លទ្ធផលនេះមិនមែនចេញពីឆន្ទះខ្មែរទេ តែជាការរៀបចំដោយ យួន និង បក្សពួក ហ៊ុន សែន។

## ១_នយោបាយរាតត្បាតទឹកដីរបស់ យួន កុម្មុយនិស្តឥណ្ឌូចិន

## (Territories Aggression of Vietnamese Communist Indochina)

កាលពីសម័យអង្គរ ក្នុងរាជ្ជកាល **ព្រះបាទជ័យវរ្ម័នទី២ ព្រះបាទជ័យវរ្ម័នទី៧** ខ្មែរជាអាណាចក្រមួយដែល មានទឹកដីធំល្វឹងល្វើយ មានព្រំប្រទល់ ទល់នឹងប្រទេសចិន នាពេលនោះ យួនមិនមានទឹកដី ឬបង្កើតបានជារដ្ឋឯករាជ្យនៅឡើយទេ យួននៅជាពួង នៅខាងត្បូងប្រទេសចិននៅឡើយ។ យួនបានប្រមូលផ្តុំគ្នា រស់នៅជាកុលសម្ព័ន្ធ ស្ថិតនៅក្រោមការត្រួតត្រារបស់ចិន។ ក្រោយពីយួនបាន រំដោះខ្លួនចេញពីការត្រួតត្រារបស់ចិនមក យួនបានអនុវត្តន៏នយោបាយរាតទឹកដី ដោយការធ្វើសង្គ្រាមច្បាំងទន្រ្ទានយក ទឹកដីពីប្រទេសជិតខាង មានប្រទេសខ្មែរ និងចំប៉ាជាដើម។ យួន បានប្រើកលល្បិចគ្រប់បែបយ៉ាង។ យួនបានថ្វាយស្រីស្អាត មករៀបការជាមួយស្តេច ប្រទេសចំប៉ា ក្រោយមកស្រីយួន បានសុំស្តេចប្រទេស ចំប៉ា ដើម្បីអនុញ្ញាតអោយជនជាតិយួនមករស់ក្នុងប្រទេសចំប៉ា។ ជនជាតិយួន កាន់តែច្រើនទៅៗ យួនបានបង្កើតសង្គ្រាមផ្ទៃក្នុងសំលាប់ ស្តេចចំប៉ានោះចោលទៅ ហើយដណ្តើមយកប្រទេស ចំប៉ា ត្រួតត្រាចាប់ពីឆ្នាំ ១៦៨៧ មក។ ទោះបីជាជនជាតិ ចាម ងើបបះបោរប្រឆាំងយ៉ាងណាក្តី ក៏ត្រូវរងនូវការបង្រ្កាបយ៉ាង សាហាវបំផុតពីសំណាក់យួន។

*Thailand: A Country Study*




*Figure 3. Centers of Power in Southeast Asia, Second to Thirteenth Centuries*

ចំណែកប្រទេសខ្មែរយើង ក៏បានធ្លាក់ក្នុងឥទ្ធិពលយួនដែរ ក្នុងរជ្ជកាលព្រះបាទ ជ័យជេដ្ឋាទី២ ឆ្នាំ១៦៣០។ ស្តេចនេះបានរៀបការជាមួយកូនស្រីស្តេចយួន ដែលមានឈ្មោះថានាង **ភូជីនស៊ីន** CO CHIN XIN។ **ភូជីនស៊ីន** បាននាំញាតិសណ្តាន

កងទ័ព អ្នកបច្ចេកទេស តុលាការ វប្បធម៌ និងអរិយធម៌ មករស់នៅក្នុងទឹកដីខ្មែរ នៅតំបន់ព្រៃនគរ និងកោះក្របី ដើម្បីធ្វើការហ្វឹកហាត់ទ័ព។ យួន បានសុំស្តេចខ្មែរ កុំឱយយកពន្ធអាករជនជាតិយួនទាំងនោះ។ **“សេចក្តីមេត្តា ដោយភាពល្ងង់ខ្លៅ នាំមក នូវសេចក្តីវិនាសដល់ខ្លួននិងផងរួមជាតិខ្មែរ”**។

ជនជាតិយួន ជាភ្នាក់ងារចារកម្ម ចូលមករស់នៅតំបន់នេះ កាន់តែច្រើនឡើងៗ ដូចយួនកំពុងហូរចូលប្រទេសខ្មែរបច្ចុប្បន្ន។ ក្រោយមកស្តេច **ជ័យជេដ្ឋាទី ២** បានសុគតទៅ សង្គ្រាមរឹករវរ បានកើតឡើងនៅក្នុងតំបន់នេះ ពេលនោះយួនបានលើកទ័ពមកបង្ក្រាបខ្មែរ យ៉ាងសាហាវលើទឹកដីខ្មែរក្រោម ដូចជា ព្រៃនគរ កោះក្របី និង ខេត្ត មួយចំនួនទៀតបានធ្លាក់ក្នុងកណ្តាប់ដៃ យួនចាប់ពីពេលនោះមក។ ហេតុនេះហើយ ទើបបានជាយួន ហៅដែនដីនេះថាជាដែនដី **ត្រូវិនសុីន** មានន័យថាដែនដី **អ្នកស្រីធីឥសុំ**។

នៅសម័យ **ឡេវ៉ាន់ មិញយ៉ាង** រជ្ជកាលស្តេចក្សត្រីអង្គម៉ី ឆ្នាំ(១៨៣៥-១៨៤១) យួនបានប្រើវិធីក្តៅរំលាយ ពូជសាសន៍ខ្មែរ និងឈ្លានពានលេបយកទឹកដីខ្មែរម្តងរួចហើយ តែមិនបានសំរេច។ កាលនោះប៉ែកខាងលិចប្រទេសខ្មែរ កាន់កាប់ដោយសៀម ឯប៉ែកខាងកើតកាន់កាប់ដោយយួន។ យួនបានបង្ខំ ឱយខ្មែរធ្វើការជាទំងន់ ជីកព្រែកវិញតេ សំលាប់ខ្មែរ ដោយយួន យកខ្មែរទៅកប់ទាំងរស់ ទុកត្រឹមកមកលើ ដាក់ជា បីមុំ ហើយយកខ្ទះត្នោតមកដាំពីលើក្បាលខ្មែរ រួចយកភ្លើងមកដុតដាំតែ។ ពេលខ្មែររងគ្រោះទាំងនោះ ក្តៅរើបំរះ យួនវាស្រែកថា "ប្រយត្ន័កំពុបតែអុង" ។ អ្នកខ្លះទៀត ត្រូវកប់ទាំងរស់ហើយយករនាស់មករាស់ពីលើ។ ដើម្បីរំលាយខ្មែរអោយទៅជាយួន បង្ខំខ្មែរឱយស្លៀកពាក់អាវផាវរបៀបយួន និងត្រូវលប់បំបាត់វត្តអារ៉ាម ដោយបង្កើត សាសនាព្រះពុទ្ធក្លែងក្លាយ និងយកមកឃោសនា ថា អ្នកមានបុណ្យនៅទឹសខាងកើត ដើម្បីធ្វើឱយខ្មែរ វឹកវរខាងជំនឿសាសនា ដូចគ្នានឹងពេល រាល់ថ្ងៃវាយក ជនកុម្មុយនិស្តយៀកមិញ ទេព វង់ មកបំបួសធ្វើជាសង្ឃរាជខ្មែរដូច្នោះដែរ។ យួនប្រើគ្រប់មធ្យោបាយ ក្នុងការរំលាយខ្មែរ និងជាបណ្តើរៗ វាបញ្ជូនជនជាតិយួនខុសច្បាប់ មកតាំងទីនៅលើទឹកដីខ្មែរក្នុងខេត្តទាំងនោះ និងចាត់ឱយជនជាតិយួនមកធ្វើជាចៅហ្វាយខេត្ត ខ្មែរជាដើម។ ផែនការ **ឡេវ៉ាន់ មិញយ៉ាង** ក្នុងការរំលាយពូជសាសន៍ខ្មែរ និងលេបយកទឹកដីខ្មែរ មិនបានសំរេចជោគជ័យ ព្រោះខ្មែរទាំងអស់ងើបឡើងទូទាំងប្រទេសបះបោរបង្ក្រាបយួន ។ ការបះបោរនោះ ខ្មែរបានក្រោកព្រមគ្នា ហើយដេញកាប់សំលាប់ យួន ធ្វើអោយយួន ខ្លះរត់ទៅ ពួនក្នុងទឹកបឹងដោយយក ស្រកីដូង មកគ្របដោយទុកត្រឹមតែច្រមុះ សំរាប់ដកដង្ហើមប៉ុណ្ណោះ។ រឿងនេះ ហើយដែលមានទំនៀម ខ្មែរហៅយួន ថា អាស្រកីដូង រហូតមក។

ក្រោយមកទៀត ផែនការ **ហូ ជីមិញ** បានបន្ត នយោបាយត្រដាក់លេប ទឹកដីខ្មែរបច្ចុប្បន្នសារជាថ្មី។ ដំបូងឡើយយួន បានបង្កើតកុម្មុយនិស្តឥណ្ឌូចិន នៅទីក្រុងហុងកុង ដឹកនាំ ដោយ **ហូ ជី មិញ** នៅ ថ្ងៃទី ២កុម្ភៈ ឆ្នាំ១៩៣0។ យួនមានបំណង យកលទ្ធិកុម្មុយនិស្ត ជាមធ្យោបាយ ដើម្បីអោយសំរេចបំណងខ្លួន ក្នុងការពង្រីកទឹកដី ដោយត្រួតត្រា លើប្រទេសទាំង ៣ នៅតំបន់ឥណ្ឌូចិនទាំងមូល (ខ្មែរទាំងមូល ខ្មែរក្រោមក្រោមការត្រួតត្រារបស់យួនខាងត្បូង និង លាវ)។

**ដើម្បីសំរេចគោលដៅនេះ យួន បានប្រើកលល្បិចដដែលៗ ដូចពីមុន តើកលល្បិចនោះ ដូចម្តេចខ្លះ ?**

យួន បានបញ្ចុះបញ្ចូលពលរដ្ឋ **លាវ** និង**ខ្មែរ** អោយចូលរួម ដោយយកលេសថាប្រឆាំងនឹងអាណានិគមបារាំង និងអាមេរិកាំង។ ក្រោយមកទៀត យួនបញ្ជូន ចារបុរស-នារី ជាច្រើនមកក្នុងប្រទេសខ្មែរ ពេលនោះស្តេច **សីហនុ** មានមហេសីជាផ្លូវការ ៥ រូបហើយ សរុបទាំងអស់ ៦ រូបទាំង **ម៉ូនិច** ជាអគ្គមហេសី សព្វថ្ងៃ។(សូមបញ្ជាក់ថា **ម៉ូនិច** ជាចារៈនារីយួន គ្មានឈាមជ័រជាខ្មែរបន្តិចឡើយ ម្តាយជាកូនយួនកាត់ចិន ឪពុកជាជនជាតិ អ៊ីតាលី។ សូម្បីតែព្រះកុសមៈ មាតារបស់ **សី ហនុ** ក៏មិនយល់ព្រមអោយ **សីហនុ** រៀបអភិសេកទេ ប៉ុន្តែ **សីហនុ** ចចេសរៀបអភិសេក។ ហើយភាពរកាំរកុះ និងការមិនព្រមស្តាប់យោបល់របស់ព្រះអង្គ បានធ្វើអោយព្រះមាតា **កុសមៈ** ឈឺសុគតទៅ) ។ បារាំង បានកាត់ទឹកដី ខ្មែរកម្ពុជាក្រោម ទៅអោយយួន នៅ ថ្ងៃទី ៤ ខែមិថុនា ឆ្នាំ១៩៤៩ ដែលមាន ទឹកដីខ្មែរចំនួន ២១ ខេត្ត ក្នុងរជ្ជកាល **សីហនុ** ស្តេច សីហនុនេះ ឯង។







ក្រោយពីពេល ដែលយួនដណ្តើមយកទឹកដីកម្ពុជាក្រោមហើយ យួនបានបន្តផែនការលេបយកទឹកដីខ្មែរសព្វថ្ងៃ នេះទៀត។ នៅឆ្នាំ១៩៤៥-៥៤ យួនបានចាប់យកកូនក្មេងខ្មែរតូចៗ ទៅបំពាក់បំប៉នមនោគមវិជ្ជាកុម្មុយនិស្តចំនួនជាង ៤៥០០នាក់ ដែលពួកនេះ ហៅថាក្រុមខ្មែរយៀកមិញ។ ពេលនោះហើយ ដែលស្រុកខ្មែរ កើតរឿង ប្រមាត់ប្រមង់ សារជាថ្មី ម្តងទៀត។

## ក-ទំនាក់ទំនងរឿងប្រមាត់ប្រមង់និង វាលពិឃាត

តាមការសិក្សាស្រាវជ្រាវរបស់លោក សាស្ត្រាចារ្យ កេង វ៉ាន់សាក់ បានឱយដឹងថា នៅរាជ្យស្តេច ជ័យវរ្ម័នទី ៩ (ស្តេច សីហនុ ទី១) ប្រទេសខ្មែរ ត្រូវបានប្រទេសចិន ឬម៉ុងហ្គោល តំរូវអោយប្រមូលប្រមាត់ មនុស្ស ទៅឱយប្រទេសនេះជាប្រចាំរៀងរាល់ឆ្នាំ។ ដោយសារភាពកំសាក ស្តេចនេះ សុខចិត្តអោយគេសំលាប់ខ្មែរ ដើម្បីយកប្រមាត់ ពីគ្រប់ទីសទិ។ នាពេលនោះគ្មានស្តេច ឬអ្នកប្រាជ្ញបណ្ឌិតណា ក្រោកឈរឡើងប្រឈមមុខដោះស្រាយរឿងនេះទេ។ តាមការបកស្រាយ របស់លោកសាស្ត្រាចារ្យ បានអោយដឹងថា ពួកអ្នកចេះដឹងខ្មែរ ដែលនៅក្រោមអំណាចស្តេចមិនអាចសរសេរការពិត ហេតុនេះ ទើបបានតាក់តែងរឿង អាខ្វាក់ អាខ្វិន នេះឡើង ក្នុងបំណងអោយ កូនខ្មែរជំនាន់ ក្រោយបានដឹង រឿងប្រវត្តិសាស្ត្រដ៏ជូរចត់នេះ។ អ្នកនិពន្ធបានពន្យល់យើងថា ការតស៊ូរើបំរះ ពីការគំនាប ដ៏ល្វីងជូរចត់របស់ប្រទេសចិន ក្នុងការធ្វើឃាតខ្មែរ ដោយមិនរើសមុខ ដើម្បីយកប្រមាត់នេះ មានតែពួកអ្នកដែលរស់ក្រោមស្រទាប់បាតជើងគេដូច នាយខ្វាក់នាយខ្វិន ប៉ុណ្ណោះដែលហ៊ានក្រោកឡើងធ្វើការតស៊ូ យកឈ្នះសត្រូវដ៏ធំនោះបាន។ អ្នកនិពន្ធក៏បានបញ្ជាក់ដែរថា មិនមែនចាំបាច់ទាល់តែពូជស្តេច ឬនាម៉ឺនធំៗទេ ដែលមានសមត្ថភាព ចូលរួមដោះស្រាយវិប្បត្តិ ប្រទេសជាតិ រាល់គ្រាមានអាសន្ន កើតឡើងនោះ។ រាស្ត្រសាមញ្ញគ្រប់រូប ក៏ត្រូវមានការទទួលខុសត្រូវ ក្នុងការជួយការពារ កសាងជាតិ និងការ ការពារទូវបុព្វសិទ្ធិពីកំណើតរបស់ខ្លួនផងដែរ។ រឿង

ធនញ្ជ័យ ជាឧទាហរណ៍មួយយ៉ាងល្អ ស្តីពី សមត្ថភាពរបស់ពលរដ្ឋខ្មែរ ក្នុងការដោះស្រាយវិបត្តិប្រទេសជាតិ និងបង្ហាញម្យ៉ាងទៀតថា ពួកស្តេច នាម៉ឺន ធំតូចភាគច្រើន ជាមនុស្សកំសាក យកតែរួចខ្លួន និងគិតតែរាជបល្ល័ង បុណ្យសក្តិមុខមាត់ប៉ុណ្ណោះ ។

រឿងនេះ យួន ប្រាកដជាបានលើកយកទៅសិក្សា យ៉ាងល្អិតល្អន់ ដើម្បីជាប្រយោជន៍ ក្នុងការធ្វើ សង្គ្រាមចិត្តសាស្ត្រផ្សេងៗ សំរាប់លេបយកប្រទេសខ្មែរ ។ នៅចន្លោះឆ្នាំ ១៨៦៣-១៩៥៤ ពេលដែល ប្រទេសខ្មែរ ស្ថិតនៅក្រោមអណានិគមន៏របស់ បារាំង រឿងប្រមាត់ប្រមង់នេះ បានកើតឮ សុះសាយ នៅពាសពេញប្រទេសខ្មែរ ហើយរឿងនេះ មានឮដំណាលតៗ គ្នារហូតមកដល់ ទសវត្សរ៍ឆ្នាំ ៨០ ។ តើហេតុអ្វី បានជាមានរឿងប្រមាត់ប្រមង់នេះ កើតមានឡើងទៀត ក្រោយពីរឿងនេះ បាត់ទៅជិត ៨០០ឆ្នាំហើយនោះ? ។ តាមការសិក្សាស្រាវជ្រាវ អាចអោយយើងមើលឃើញថា ដើម្បីរៀបចំលេបយកប្រទេស ខ្មែរ យួនបានរៀបចំដោយអត់ធ្មត់ យ៉ាងហ្មត់ចត់ ដើម្បីធ្វើអោយប្រទេសខ្មែរចុះខ្សោយ សង្គមខ្មែរបាក់បែកសាមគ្គីគ្នា ជាក្រុមបក្សពណិសំបុរ នយោបាយ ច្រើនក្រុម ច្រើនពួក ជាប្រយោជន៏ អោយវាអាច គ្រប់គ្រងត្រួតត្រាបាន មុនពេល វាធ្វើការវាយលុកដោយកំលាំងទព័ នៅពេលណាមួយ ។ ម្លោះហើយ ក្នុងអំឡុងពេលដែល ប្រទេសខ្មែរនៅក្រោមការត្រួតត្រារបស់ បារាំង យួនវាបានបញ្ចុះបញ្ចូលខ្មែរ ដែរមានស្មារតីជាតិនិយម ទាំងនៅទីក្រុង ជនបទ អោយងើបធ្វើការ ប្រឆាំងនឹងការត្រួតត្រា របស់បារាំង ដើម្បីទាមទាឯករាជ្យ ។ ក្រោមការត្រួតត្រា របស់បារាំង រាស្ត្រខ្មែរ មិនបានពេញចិត្តឡើយ ។ បារាំង បានរៀបចំ តំបន់សេដ្ឋកិច្ចជាច្រើន ដើម្បីដឹកជញ្ជូនយកទៅប្រទេសគេ ជាពិសេស ចំការកៅស៊ូ ឈើល្អប្រណិតជាដើម ។ បារាំង បានខិតខំកសាងផ្លូវគមនាគមន៏ជាច្រើន ក្នុងប្រទេសខ្មែរ ដើម្បីបំរើគោលដៅលផ្សេងៗរបស់ខ្លួន ទាំងខាង សេដ្ឋកិច្ច កងទព័ និងការគ្រប់គ្រងផ្នែករដ្ឋបាល របស់ខ្លួន ។ ដោយការមិនពេញចិត្ត នឹងភាពជាខ្ញុំកញ្ជះបារាំង ខ្មែរមិនពេញចិត្ត នឹងធ្វើការជាមួយបារាំងឡើយ ។ នេះជាហេតុធ្វើអោយ បារាំង នាំជនជាតិយួន ប្រហែល ៤០០០០នាក់ ចូលមកក្នុងស្រុកខ្មែរ ដើម្បីបំរើការ នៅក្នុងតំបន់ សេដ្ឋកិច្ចទាំងនោះ ជាពិសេស តំបន់ចំការកៅស៊ូ និងក្នុងរដ្ឋបាលគ្រប់គ្រងរបស់ បារាំងតាំងពីរាជវាំង រហូតដល់ថ្នាក់ ស្រុក ឃុំ រមែងមានយួន ធ្វើការជាមួយ បារាំង ជាជំនួសខ្មែរ ម្ចាស់ស្រុក ។

ក្រោយពេលដែល ង្វៀង អៃកុក ឬ ហូ ជីមីញ បានចូលជាសមាជិកកុម្មុយនិស្តអន្តរជាតិ ។ ហូ ជីមិញ បានត្រឡប់មកប្រទេសកំណើតវិញ និងបានរៀបចំ បង្កើតបក្សកុម្មុយនិស្តឥណ្ឌូចិនមួយឡើង ក្នុងបំណង ទី១ ប្រមូលកំលាំង ប្រជាជាតិនានានៅតំបន់នេះអោយជួយយួនក្នុង ការរំដោះប្រទេសពី អាណានិគមន៏បារាំង ។ តែពីក្រោយខ្នង គោលដៅនេះ យួន មានបំណងយកលទ្ធិកុម្មុយនិស្ត ជាមធ្យោបាយ ដើម្បីលេបយកប្រទេសខ្មែរ ខ្មែរក្រោម និង លាវ ជាអាណាខេត្ត របស់យួនតែម្តង ។ ការសាបព្រួស លទ្ធិកម្មុយនិស្ត នៅប្រទេសទាំងបី ខ្មែរ យួន លាវ គ្រាន់តែជាមធ្យោបាយ ធ្វើអោយសំរេច គោលដៅរបស់វា តែប៉ុណ្ណោះ។ យួន បានទាញយកប្រយោជន៏យ៉ាងច្រើនពីជនជាតិយួន ដែលបារាំង បានបញ្ជូនមក ក្នុងប្រទេសខ្មែរ ដើម្បីបំរើសកម្មភាពនយោបាយ និងកងទព័របស់វា។ ទន្ទឹមនឹងពេលនេះដែរ ដើម្បីអនុវត្តគំរោង ការយូរអង្វែង ហូ ជីមិញ បានចាត់ឱ្យលបលួចចាប់ ឬដោយការបញ្ចុះបញ្ចូលតាមការបោកប្រាសផ្សេងៗដល់កូនខ្មែរ នៅតាមស្រុកស្រែចំការ ដែលមានអាយុពី១០-១៥ ឆ្នាំ ដែលមិនទាន់ស្គាល់ ដឹងអ្វីច្បាស់លាស់ ពីខ្មែរនៅឡើយ រួចហើយបញ្ជូនទៅ យួនខាងជើង ។ សកម្មភាពបែបនេះ យួនបានអនវុត្តន៏ជារៀងរហូត តាំងពីរឆ្នាំជាង១៩៤០-៧០ ។ ជាពិសេស នៅពេលក្រោយសន្និសិទ្ធហ្សឺណែវ ២០ កក្កដា ឆ្នាំ១៩៥៤ តំរូវអោយ យួនដកទព័ ចេញពីស្រុកខ្មែរ តែមួយពេល យួនបានបញ្ចុះបញ្ចូលនាំយកកូនខ្មែរ ប្រមាណជា ៤៥០០នាក់ យកទៅដាក់តាមជុំរំនានានៅយួនខាងជើង ។ ក្នុងចំណោមនោះ មានទាំងកូនខ្មែរសុទ្ធសាធ និងកូនយួន ដែលកើតនៅស្រុកខ្មែរ ចេះខ្មែរ

ច្បាស់។ នៅស្រុកខ្មែរ ទូទាំងជនបទ និងទីក្រុង យួន បានធ្វើការឃោសនាពាក្យចចាមអារាមថា មានប្រមាត់ ប្រមង់ ចាប់យកកូនក្មេង ទៅកប់ទាំងរស់ ដើម្បី ធ្វើជាគ្រឹះថ្នល់ ស្ពាននានា ដែល បារាំង កំពុងកសាងនៅប្រទេសខ្មែរ។

**ហេតុអ្វីបានថា យួន វាធ្វើការឃោសនា រឿងប្រមាត់ប្រមង់នេះឡើង ?**

១-ដើម្បីលាក់បាំង ផែនការ ចាប់នាំយកកូនក្មេងខ្មែរនោះ អោយស្ថិតនៅស្ងាត់កំបាំង។

២-ដើម្បីលាក់បាំង ផែនការដ៏ខ្មៅក្រខ្វក់ របស់យួន ដែលរៀបចំផែនការលេបយកដីខ្មែរ ។

៣-ដើម្បីធ្វើអោយ សង្គមខ្មែរ កើតការភ័យខ្លាច វឹកវរ ច្របូកច្របល់ អស្ថេរភាពពាសពេញប្រទេស។

៤-ដើម្បីធ្វើអោយ ខ្មែរប្រឆាំងនឹង ផែនការកសាង ថ្នល់ ស្ពាន របស់បារាំង នៅប្រទេសខ្មែរ ត្រូវរាំងស្ទះ។

៥-ដើម្បីធ្វើអោយ ប្រទេសខ្មែរ មានគមនាគមន៍ទន់ខ្សោយ ជាងយួន ជាហេតុធ្វើអោយសេដ្ឋកិច្ចទន់ខ្សោយ ងាយស្រួលយួន ងាកមកលេបត្របាក់ពេលវារួចដៃ ពីបារាំង។

**តើ ពួកក្មេងប្រមាត់ប្រមង់ មានផលប៉ះពាល់ និងមានកជាប់ទាក់ទងធ្ងន់ធ្ងរកើតឡើងឲ្យ ការសំលាប់រង្គាលខ្មែរជាងបីលាននាក់ នៅក្នុងរបប ប៉ុល ពត ។**

អ្នកណាក៏ដឹងដែរថា របបវាលពិឃាដ ត្រូវបានរៀបចំ ឧបត្ថម្ភគាំទ្រដោយយួន។ នៅក្នុងសៀវភៅ "ក្រោយស្នាមញញឹមរបស់ ខ្មែរ" បានសរសេរថា ជនកុម្មុយនិស្តដំបូងៗ ដែលកើតមាននៅក្នុងប្រទេសខ្មែរ សុទ្ធសឹងតែជាអនិកជនយួន ដែលបារាំង បាននាំចូលមកនៅក្នុងតំបន់សេដ្ឋកិច្ចនានា ពុំមានខ្មែរទេ។ លុះក្រោយមកទើបមានពួកខ្មែរជាតិនិយមងើបឡើងបះបោរប្រឆាំងនឹងការត្រួតត្រារបស់បារាំង ដែលត្រូវរបបស្តេច សីហនុ តាមរកចាប់ខ្លួន រត់គេចមកនៅក្នុងព្រៃ។ ដោយគ្មានជំរើសឬដោយមិនអាចរកឃើញកំលាំងអ្នកជាតិនិយមខ្មែរ ទើបពួកនេះត្រូវបង្ខំចិត្ត ឬដោយការលួងលោមបោកប្រាសបង្ខំចិត្តអោយចូលក្នុងចលនាកុម្មុយនិស្តដឹកនាំ ត្រួតត្រាដោយយួន។ យួន ខ្លួនឯងក៏ធ្លាប់បានអួតអាងដែរថា របបសាធារណរដ្ឋខ្មែរ អាចគង់វង់បាន ៥ឆ្នាំ ក៏ព្រោះតែខ្លួនមិនទាន់ចង់អោយរបបនេះដួលរលំតែប៉ុណ្ណោះ(ដើម្បីទុកឱកាសអោយយួនខ្លួនឯង រើសមនុស្សដាក់បន្ទុប ព្រោះមនុស្សដែលយួន បានរៀបបំរុងហើយនោះ ត្រូវពួក ប៉ុល ពត បោសសំអាត ទាន់ពេលស្ទើតែទាំងអស់)។ តែទោះជាយ៉ាងណាវាមិនដូចយួន អួតអាងនោះទេ គឺសាររបបសាធារណរដ្ឋខ្មែរ ត្រូវបានប្រមូលផ្តុំដោយបញ្ញវ័ន្តជាតិក្រោកឡើងតទល់នឹងយួន ធ្វើអោយយួនបាក់អំណួតទៅវិញ (យួនបានអួតប្រាប់សីហនុថា យួន នឹងវាយយកប្រទេសខ្មែរតែ ១អាទិត្យប៉ុណ្ណោះ នឹងយកបល្ល័ងថ្វាយសម្តេចវិញមិនខាន)។ ហេតុដូច្នេះ អាចអោយយើង មើលឃើញថា រឿងរ៉ាវដែលកើតនៅលើទឹកដីខ្មែរ ឬសង្គ្រាមតណ្ហចិននោះជារឿងយួន រៀបចំឡើងដើម្បីយកប្រទេសខ្មែរ និងលាវ តែប៉ុណ្ណោះ។ ឯរឿងបដិវត្តន៍ របស់ពួក ប៉ុល ពត ខៀវ សំផន និងរឿង សីហនុ ប្រឆាំងនឹងចក្រពត្តិអាមេរិកនោះ គ្រាន់តែជារឿងដែលពួកនេះ លោតតាមខ្សែញាក់ចិន យួន តែប៉ុណ្ណឹង មិនមែនជារឿងកើតឡើងដោយមនសិការ ដែលមានឥស្សរៈ ផ្នែកគំនិតនោះឡើយ។ បើសិនជារឿងនេះកើតឡើងដោយ មនសិកាឥស្សរៈ ម្លេះសមពេលនោះ ទាំង នួន ជា, ខៀវ សំផន, សីហនុ មិនសុខចិត្តឲ្យលក្បាល ទៅជ្រកក្រោមបាតជើងអាយ៉ងយួន ឬក៏បណ្តោយខ្លួនទុកអោយពួកអាយ៉ងចាប់យកទៅកាត់ទោសនោះឡើយ ម្លេះពួកនេះត្រូវក្រោករៀបចំ (ទោះដោយប្រយោល ឬដោយចំពោះ)ធ្វើការរំដោះជាតិ ក្នុងគ្រានេះជាមិនខាន។ ហើយអ្នកណាក៏ដឹងថា បើគ្មានយួនពួក កុម្មុយនិស្ត ប៉ុល ពត ហ៊ុន សែន មិនអាចមានរូបរាងឡើងបានឡើយ។

ក្រោយការបញ្ជូនពួកទាំងនេះ ទៅនៅយួនខាងជើង យួន បានបែងចែក ក្មេងទាំងនេះ ជាក្រុមៗ ទៅតាមជុំរុំនានា ដោយលាយឡំគ្នាវាំង កូនខ្មែរស្រុកស្រែចំការសុទ្ធ និងកូនយួន ដែលចេះខ្មែរ ។ តែមុនពេលដាក់បញ្ចូលគ្នា ក្មេងទាំងអស់សុទ្ធសឹង បង្គាប់អោយប្តូរឈ្មោះទៅជាឈ្មោះ បដិវត្តន៍ទាំងអស់ ។ ឯកូនយួន ដែលចេះខ្មែរ អោយដូរឈ្មោះពីយួន មកជាឈ្មោះខ្មែរវិញ ។ នេះជាវិធីលាក់អត្តសញ្ញាណ ដើម្បីស្រួលងាយ ក្នុងការបញ្ចូលពួកនេះ មកក្នុងចង្កោមពួកកូនខ្មែរ និងដើម្បីស្រួលងាយក្នុងការធ្វើចារកម្ម បំរើនយោបាយ វាតទឹលេបទឹកដីរបស់វា នៅក្នុងសង្គមខ្មែរ ឬអាចហៅឈ្មោះម្យ៉ាងថា "*ខ្មែរថ្មី*" គឺ*ជាជនដែលមានឈ្មោះជាខ្មែរ តែឈាមជ័រ ខួរក្បាល យួនសុទ្ធសាធ* ។ ពួកទាំងនេះ ត្រូវបានគេនិយម ហៅថា "*ពួកខ្មែរ យៀកមិញ* " ឬ " *ពួកភាគខាងជើង* " ។

## ការអប់រំខុសទិស និងការបណ្តុះបណ្តាល លទ្ធិកុម្មុយនិស្ត ចល់ពួកខ្មែរយៀកមិញ

ដោយពិត ក្មេងជំទង់ទាំងនេះ មិនគ្រាន់តែនៅវ័យក្មេងខ្ចីទេ តែថែមទាំងមិនដឹងច្បាស់ពីអ្វី ជាឫសគល់ ស្រុកទេស វប្បធម៌ ប្រពៃណីរបស់ខ្លួនជាខ្មែរ សោះឡើយ ។ លើសពីហ្នឹង ពួកក្មេងទាំងនេះ ជាក្មេងកើតនៅក្នុងក្រុមគ្រួសារ ឪពុកម្តាយក្រីក្រ តាមស្រុកស្រែចំការជនបទ ដែលមិនទាន់ចេះអក្សរខ្មែរ ថែមទៀត ឧទាហរណ៍ដូចជាលោក ប៉ែន សុវណ្ណ, ទា បាញ់, ជាដើម ។ យួន បានចាត់អោយមានការសិក្សាអប់រំ តាមបែបផែនផ្សេងគ្នា រវាងពួកខ្មែរវៀតមិញ និងខ្មែរថ្មី ។ ខ្មែរវៀតមិញ ត្រូវបានអប់រំបង្រៀន អោយនៅក្នុងកំរិតមួយ ដែលខុសទិសដៅ ខាងសីលធម៌ និងក្នុងកំរិតមួយ ត្រឹមតែជាអ្នកបំរើផែនការ ឬក្នុងកំរិត**កលយុទ្ធ**(Tactical Level) ។ **ខ្មែរថ្មី** ត្រូវបានយួនរៀបចំអោយមានការរៀនសូត្រល្អប្រសើរជាងក្នុងកំរិតមួយជាអ្នកតំរង់ទិសដៅ ទៅជាអ្នកបង្គាប់បញ្ជា (កម្មាភិបាលជាន់ខ្ពស់ឬ Operational Level )ផ្សេងៗ សំរាប់រ៉ាប់រងទទួលអនុវត្តន៍ផែនការ និងការបញ្ជាពីក្របខណ្ឌ័កំពូល របស់ពួកមេដឹកនាំ យួន និងក្នុងកំរិតមួយ ជាអ្នកគ្រប់គ្រង(ជំនាញការ)ដឹកនាំបញ្ជាលើក្បាលពួកខ្មែរយៀកមិញ(កម្មាភិបាលជាន់ទាប) និងខ្មែរឯទៀតដែល យួន បានខិតខំរៀបចំ អប់រំ ហ្វឹកហ្វឺន យ៉ាងសកម្ម នៅតាមទីជនបទស្រុកស្រែ ឯក្នុងប្រទេសខ្មែរ ។

## ក - ការបណ្តុះគំនិតជាតិយម

ក្នុងការអប់រំ ហ្វឹកហ្វឺន យួន បានអប់រំពួកខ្មែរយៀកមិញ តាមបែបមួយខុសទិសដៅ ដើម្បីស្រួលងាយក្នុងការត្រួតត្រា ។ ឧទាហរណ៍ ទាក់ទងនឹងគំនិតស្នេហាជាតិនិយម យួន ពុំបានបន្តុះអោយពួកទាំងនេះមានគំនិត ស្រឡាញ់ជាតិ ស្រឡាញ់អ្វី ជាខ្មែរឡើយ ។ ផ្ទុយទៅវិញ យួន បណ្តុះពួកនេះ អោយមានតែការឈឺចាប់ សងសឹក ចងអាឃាដក្នុងសង្គមខ្មែរ ដូចដែលពួក ហ៊ុន សែន តែងតែធ្វើការរំលឹក ពីរបបខ្មែរក្រហម នៅគ្រប់ៗម៉ាត់មិនដាច់ តែមិនដែលរំលឹក ចងអាឃាដ នឹង ចៅហ្វាយយួន វាកាត់យកដីខ្មែរ យកក្បាលខ្មែរ ដាំតែអុង នៅព្រៃកវិញតេ កាលពីអំឡុងឆ្នាំ ១៨១៣ នោះសោះឡើយ ។ លើសពីនេះ ពួកគេបែជានិយាយដោយគ្មានការឈឺចាប់ថា "***រឿងដីបាត់បង់ជារឿងស្តេច មិនទាក់ទងនឹងពួកគេទេ***" ។ របៀបឡកឡឺយមួយទៀត ដែលពួកនេះតែងតែនិយាយលេងសើចជាប់មាត់នោះគឺថា "***បើដឹងថារបស់ស្រីយួនល្អអីចឹង កាត់ដីអោយយួន ច្រើនជាងស្តេច ទៅទៀត***" ។ ការបណ្តុះគំនិតជាតិនិយមត្រូវបានយួនបង្វែអោយទៅជា គំនិតអន្តរជាតិនិយម យុទ្ធសាមគ្គីភាព ឬ សាមគ្គីភាព រវាង យួន ខ្មែរ លាវ ជាបងប្អូន ដែលប្រាសចាកការពិតទៅវិញ(ខ្មែរ លាវ គ្មានអំបូរ ឈាមជាមួយយួនទេ សូម មើលប្រវត្តិ

សាស្ត្រ លោកនានា) ។ មិនតែប៉ុណ្ណោះ យួន បានដាក់កំហុសថា ការបន្ទុះអោយមានគំនិតជាតិនិយម នៅក្នុងជួរអ្នកដឹកនាំជាតិ ជារឿងដែលត្រូវវង់នូវការថ្កោលទោសពីអន្តរជាតិទៅវិញ (សំដីនេះអ្នកនិពន្ធផ្ទាល់ធ្លាប់បានទទួលការរិះគន់ពីពួកកម្មាភិបាល ឧត្តមសេនីយ របស់អាយ៉ង ហ៊ុន សែន នៅនាឆ្នាំ ១៩៩៩ ក្នុងពេលដែលអ្នកនិពន្ធបានលើកយក គោលការណ៍ បណ្តុះ គំនិតជាតិនិយម ដាក់នៅក្នុងការអប់រំអ្នកដឹកនាំកងទ័ពជាតិសព្វថ្ងៃនេះ) ។ តែនៅក្នុងការអប់រំ ពួកយួន ឬខ្មែរថ្មី ត្រូវបានយួន វាអប់រំ ពួកនេះអោយមាន គំនិតជាតិនិយមយួន យ៉ាងជ្រាលជ្រៅទៅវិញ ។

## អន្តរជាតិនិយម ដែលនិយមតែយួន

ក្នុងចំណោមពួកក្បត់ជាតិទាំងនេះ ត្រូវបានវាអប់រំអោយគិតអោយយល់ថា មិត្តភាពយួន និងពួកវាសំខាន់ជាងអាយុជីវិតជាតិ និងប្រជាជាតិខ្មែរ ។ ដូចមានថ្មីៗនេះ ស្តេចសង្ឃកុម្មុយនិស្ត ទេព វង្ស បានចាប់ព្រះតេជគុណ **ទឹម សាខន** ផ្សឹកបញ្ជូនទៅអោយចោរយួន យកទៅដាក់គុកធ្វើទុកបុកម្នេញ ដោយសំអាងលេសថាប៉ះពាល់មិត្តភាព ។ ក្នុងការប្រជុំមួយក្នុងចំណោមកងទ័ពជើងគោកអាស៊ាននាឆ្នាំ២000 នៅប្រទេសសៀម ។ បើទោះជាមានតំណាងកងទ័ពខ្មែរលាវ ចូលរួមក្តី យួនបានក្រោកឈរថ្លែងការយ៉ាងព្រហើន និងឥតអៀនខ្មាស់ដោយអះអាងខ្លួនជាតំណាងកងទ័ពឥណ្ឌូចិន ។ នាពេលនោះ ពួកឧត្តមសេនីយក្បត់ ដែលជាអាយ៉ង យួន មិនហ៊ានក្រោកជំទាស់ឡើយ ដោយខ្លាចប៉ះពាល់ មិត្តភាព យួន-ហ៊ុន សែន ។

ការអប់រំ អោយមាន ស្មារតីអន្តរជាតិនិយម នេះ មានចំពោះតែជនជាតិយួនខ្លួនឯងតែប៉ុណ្ណោះ តែជាមួយជនជាតិផ្សេងៗ ទៀត ដូចជា សូវៀត និងប្រទេសនានាដែលជាប្រទេសកុម្មុយនិស្តដូចគ្នា ឬក៏ជាម្ចាស់ជំនួយ យួន និងអាយ៉ង មិនបានតំរូវអោយខ្វល់ខ្វាយពីការបាត់បង់មិត្តភាព សោះឡើយ ។ ជារឿយៗ ពួកវិនិយោគទុន បរទេស ដែលមានជំហរ មិនរណបយួន តែងត្រូវបានពួកវាចោទប្រកាន់ដោយប្រការនេះ ប្រការនោះជាដ៏រាប ដូចជាការរំលោភលើកុមារ ការរំលោភសិទ្ធ ការប្រព្រឹត្តិរឿងអនាចារ្យផ្សេងៗ ដើម្បីយកលេសចាប់ជនទាំងនោះដាក់គុក ឬធ្វើអោយមានពិរុទ្ធ ធ្វើអោយជនទាំងនោះដកថយ ឬអស់ជំនឿក្នុងការរកស៊ីនៅប្រទេសខ្មែរ ដែលធ្វើអោយមានការប៉ះពាល់ដល់ការវិនិយោគនៅប្រទេសខ្មែរ ។ លើសពីនេះ អ្នកដែលបានទទួលការសិក្សាវិជ្ជាយោធា ពីប្រទេសនានា មិនថាប្រទេសសេរី ឬសង្គមនិយមឡើយ មិនត្រូវបានពួកវាតំឡើងដំកើងឋានៈសោះឡើយ ។ តែពួកដែលយល់ព្រមទៅសិក្សាវិជ្ជាកងទ័ពពីប្រទេសយួន ដែលត្រូវបានយួនបង្រៀនអោយចេះតែ របៀបសំលាប់ខ្មែរនោះ ត្រូវបានពួកវាលើកដំកើងអោយមានឋានៈដឹកនាំសំខាន់ក្នុងកងទ័ព បន្ទាប់ពីពួកកូនយួន ដែលចេះខ្មែរ ។

## ៩-ការអប់រំ ដើម្បីបណ្តុះស្មារតីប្រយុទ្ធ

ដូចបានពោលខ្លះៗពីខាងលើមកហើយ ពួកនេះពោលមិនដាច់មាត់ ពីរឿងវាលពិឃាដ តែពួកនេះ តែងតែអះអាងថាជយ័ជំនះ ១៧ មេសា ១៩៧៥ ជាជយ័ជំនះរបស់ពួកគេ តែត្រូវរបប ប៉ុល ពត ដណ្តើមយកទៅ ។ តែពួកនេះមិនដែលទទួលថា អំពើកាប់សំលាប់ បែបភេរវកម្ម នៅចន្លោះឆ្នាំ ១៩៧០-៧៥ តាមទីប្រជុំជន ទីសាធារណនានា ឬនៅតាមជនបទចុងកាត់មាត់ញក ឬ ១៩៧៥-៩៣ និងបន្តរហូតដល់សព្វថ្ងៃថា ជារបស់ដែលវាបានប្រព្រឹត្តិសោះឡើយ ។ នៅតាមទីជនបទ យួន រើសយកតែអ្នកដែលគ្មានចំណេះដឹង គ្មានការសិក្សាប៉ុណ្ណោះ ដើម្បីខ្លួនងាយស្រួលបង្វក់ ។ យួន បានភូតកុហកថា យួន នឹងខ្មែរជាបងប្អូនគ្នា ថាយួនធ្លាប់ជួយខ្មែរជារៀងរហូតមក តែយួន មិនដែលរំលឹកពីទឹកដីដែលយួន បានឆក់ប្លន់ពីខ្មែរជាហូរហែមកសោះឡើយ ។ ក្រៅពីនេះ វាដុតអោយមានកំហឹងឈឺចាប់ ដោយការបំបែកខ្មែរជាក្រុម ពួក ដូចជាការតំរូវ ហៅខ្មែរអ្នកស្រុកលើថាជា " ជន

ជាតិភាគតិច " ឬហៅខ្មែរដែលរត់ភៀសខ្លួនទៅ នៅប្រទេសក្រៅថាជា " ពួកអណិកជន" ជាដើម ។ តែវាមិនដែលអោយហៅ យួន ថាជាអនិកជនសោះឡើយ ។ ផ្ទុយទៅវិញ វាតំរូវអោយរដ្ឋាភិបាលអាយ៉ង ដាក់បញ្ចូលជនជាតិយួន នៅតាមខេត្តក្រុង យួន ១គ្រួសារ ក្នុងខ្មែរ ៥គ្រួសារ ដែលជាការបង្ហាញយ៉ាងច្បាស់ក្រឡែតនូវគំនិត យួនបនីយកម្មលើទឹកដីខ្មែរ ។ ទង្វើអស់នេះ ពួកអាយ៉ងមិនដែលធ្វើ ធ្វើព្ទទាល់តែសោះ ។ បើយួន សំលាប់ខ្មែរ ប្លន់ដីខ្មែរ វាធ្វើព្រងើយ តែបើ យួន ងាប់មួយ វាស្រែកឆ្កា ដៃឆ្កាជើង ។ ជាងនេះទៅទៀត វាតែងអប់រំ ធ្វើអោយខ្មែរ ស្អប់ខ្មែរគ្នាឯង ទៅវិញ ។

## គ –របៀបធ្វើការសំរេចចិត្ត

"***ដីកស្មៅដីកទាំងឫស***" "***សុខចិត្តចាប់ច្រឡំ សំលាប់ច្រឡំ ប្រសើរជាងការលែងច្រឡំ***"។ មានន័យថា បើចាប់ ឬត្រូវ បោសសំអាតគេត្រូវសំលាប់ ឬបោសសំអាតអស់ មួយខ្សែមិនថាអ្នកនោះស្មោះត្រង់ ឬមិនស្មោះត្រង់ឡើយ ។ នេះជារបៀប រំលាយគំនិតជាតិនិយម គំនិតស្មោះត្រង់ និងរបៀបអោយកាប់សំលាប់ដោយមិនរើសមុខ ដែលជាហេតុអោយមានវាលពិឃាដ កើតឡើង ។ របៀបនេះហើយ ដែលពួក ប៉ុល ពត និង ពួកកុម្មុយនិស្ត ធ្លាប់បានប្រព្រឹត្តមកលើប្រជាជាតិខ្មែរ ព្រោះពួកនេះក៏ ទទួលការអប់រំពី យួន មកដោយផ្ទាល់ដូចគ្នានឹងពួក ហ៊ុន សែន ដែរ ។ ស្មេរធ្លាប់បាន ជួបសំភាសន៏ជាមួយលោក នួន ជា ដោយ ផ្ទាល់នៅអំឡុង ខែ តុលា ២០០៥ ។ លោក នួន ជា បានបញ្ជាក់ថា អ្នកដែលសរសេរនិងរៀបចំមនោគន៏វិជ្ជានយោបាយរបស់ ពួកខ្មែរក្រហម គឺមាន ខ្លួន លោក និង ប៉ុល ពត អៀង សារី ។ លោកបានបន្ថែមថា គំនិតនយោបាយ និងយុទ្ធសាស្ត្រផ្សេងៗ ច្រើនសិក្សាយកតាមយួន និងចិន ។ លោកក៏បានបញ្ជាក់ផងដែរថា ក្រុមរបស់លោក មិនដែលបានអាន ឬយកគំនិតលោក ខាង លិច មកធ្វើការសិក្សប្រៀបធៀប សោះឡើយ ។ បន្ថែមពីលើនេះទៀត លោកបាននិយាយថា " *តែស្រួល មិនស្រួល លេងមុន មិនទុកអោយអ្នកនោះ*( អ្នកដែលជាប់ការសង្ស័យថាក្បត់ ) *ធ្វើមុនបានឡើយ* "។ ពាក្យថា " តែស្រួល ឬមិនស្រួល " ក្នុងន័យ ថា" *បើសង្ស័យថាអ្នកនោះក្បត់ ទោះគ្មានភស្តុតាងគ្រប់គ្រាន់ ឬគ្មានធ្វើការតាមច្បាស់លាស់* "ក៏ដោយ ត្រូវតែសំលាប់ចោល ។ ទាំងនេះជាចំណុចអាចគូសបញ្ជាក់ បង្ហាញអោយឃើញថា ដោយខ្លួនអោយតំលៃ យួន ខ្ពង់ខ្ពស់ហួសហេតុ ទើបធ្វើឱ្យ ពួកនេះ ទទួលយករបៀបអប់រំហ្វឹកហ្វឺនមួយ បែបជ្រុលនិយម ខុសទីសដៅ និងប្រាសចាកពី តក្កវិជ្ជា ពីសំណាក់ យួន ដោយចេតនា ឬ ដោយមិនដឹងខ្លួន ភ្លេចខ្លួន ថាយួន នៅតែមានបំណងលេបយកដីខ្មែរ ហើយជាហេតុធ្វើ អោយខ្លួនមានទីសដៅជ្រុលនិយម រហូតដល់ មានការសំលាប់រង្គាលមកលើជាតិសាសន៏ឯង ។

របៀបម្យ៉ាងទៀត ចិន យួន បានអប់រំបញ្ចុះបញ្ចូល ទាំងស្តេច សីហនុ និងងពួកក្រហមទាំង ២ក្រុមថា " *ចង់ចំណេញ ត្រូវធ្វើសង្គ្រាម*" ។ តែ ចិន និងយួន មិនបានបកស្រាយពល្យល់អោយបានក្បោះក្បាយថា ការធ្វើសង្គ្រាម ដែលបានចំណេញ ត្រូវធ្វើដោយរបៀបណានោះឡើយ ។ សំដី " *ចង់ចំណេញ ត្រូវធ្វើសង្គ្រាម* " ត្រូវបានស្តេច សីហនុ លើកយកមកនិយាយជា សាធារណនៅក្នុងពិធីសំភោធន៏ នាឆ្នាំ ១៩៦៧ ។ ហេតុដូច្នេះហើយទើបបានជា ស្តេចនេះ មានការរីករាយខ្លាំងណាស់ នៅនាទី ដំបូងនៃព្រិត្តិការព្រើ ១៨មិនា ១៩៧០ ព្រោះការស្រមើស្រមៃចង់ធ្វើជា ស្តេចក្រហម ដែល ស្តេច សីហនុ ធ្លាប់និយាយពីរឿង ខ្មែរពណិជំពូ នោះត្រូវបានធ្វើអោយកើតឡើងតាមចំណង់គ្មានផែនការណ៏គោលដៅរបស់ខ្លួន ។ យ៉ាងជាក់ស្តែង នៅក្នុងពិធី បង្ហាញ ពង្រៀងរដ្ឋធម្មនុញ្ញ របស់រដ្ឋាភិបាលនិរទេស ឈ្មោះ រដ្ឋាភិបាលរួបរួមជាតិកម្ពុជា នៅទីក្រុង ប៉េកាំង ឆ្នាំ ១៩៧០ ។ ទាំងនេះសរអោយឃើញថា ជារឿងឈុតឆាកដែលរៀបចំឡើងដោយ ស្តេច សីហនុ និងយួន ចិន យ៉ាងច្បាស់ក្រឡែត ។ ការធ្វើសង្គ្រាម ដែលអាចថាចំណេញនោះ គឺការធ្វើសង្គ្រាមនៅលើទឹកដីឯប្រទេសដ៏ទៃ ដូច ដែលស្តេច ខ្មែរសម័យអង្គរ ធ្លាប់បានធ្វើរួចមកហើយ ។ ឯការ ធ្វើសង្គ្រាមនៅលើទឹកដីខ្លួនឯង ជាការដុតបំផ្លាញប្រទេសជាតិ ប្រជាជាតិខ្លួនឯង ។

ការធ្វើសង្គ្រាមនៅលើទឹកដីខ្លួនឯងអាចនឹង ត្រូវធ្វើក្នុងកាលៈទេសៈមួយដែលត្រូវបរទេសឈ្លានពានហើយ យើងត្រូវធ្វើការតស៊ូរើបំរះរំដោះជាតិ ជាចាំបាច់ ពោលគឺជា ការធ្វើសង្គ្រាមដើម្បីការរស់រានរបស់ប្រជាជាតិ របស់ជាតិយើង ។





រូបខាងឆ្វេង ៖ សម្តេចសីហនុ និងលោកប៉ែន-នុត កំពុងធ្វើសេចក្តីប្រកាសបង្កើត«រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា» (GR-UNK) នៅទីក្រុងប៉េកាំង, ខែឧសភាឆ្នាំ ១៩៧០ ។ រូបខាងស្តាំ ៖ សម្តេចសីហនុញញឹមពព្រាយ កំពុងលើកបង្ហាញរដ្ឋធម្មនុញ្ញនៃរាជរដ្ឋាភិបាលថ្មី ។

**ឃ -របៀបរើសគោលដៅវាយប្រហារ**（Objective）

ការជ្រើសរើសគោលដៅ ដែលមានកំហុសឆ្គង ប្រាសចាក តក្កវិជ្ជា ។ ឧទាហរណ៍ខាងក្រោមអាចអោយយើងធ្វើការពិចារណាបាន ÷

-តាមទ្រឹស្តីពិត ដើម្បីយកជោគជ័យលើគោលដៅ "ក" ត្រូវធ្វើការកាត់ផ្តាច់ការអន្តរាគមន៍ ពីកំលាំងជំនួយរបស់ខ្មាំងតាមផ្លូវគមនាគមន៍ នានាដែលជាប់ទាក់ទងទីតាំង " ក " នោះ ដោយការធ្វើពួនស្ទាក់ ការទប់ស្កាត់កុំអោយខ្មាំងមកជួយបាន ឬដោយការកាត់ផ្តាច់ ស្ពាន ថ្នល់ អ្វីទាំងអស់ ដែលទាក់ទងនឹងគោលដៅ " ក" នេះអោយបាន ។ តែតាមទ្រឹស្តីពិត រាល់ការកាត់ផ្តាច់ ត្រូវធ្វើការថ្លឹងថ្លែង លើកត្តាហិរញ្ញវត្ថុ និងកត្តាចិត្តសាស្ត្រ ជាដើម ។ កត្តាហិរញ្ញវត្ថុ ត្រូវថ្លឹងថ្លែងថា បើសិនជា គេត្រូវការកាត់ផ្តាច់ស្ពាន មួយ តើតំលៃ ជោគជ័យ នៃគោលដៅ " ក " អាចសក្តិសមនឹងការកាត់ផ្តាច់ស្ពាននោះឬទេ? ។ កត្តាចិត្តសាស្ត្រត្រូវថ្លឹងថ្លែងថា តើការផ្តាច់ស្ពានថ្នល់នោះ មានផលប៉ះពាល់ដល់ទឹកចិត្ត ប្រជាពលរដ្ឋតំបន់នោះឬទេ ? ក្នុងកំរិតណា? ប៉ះពាល់ដល់ការប្រើប្រាស់របស់យើងឬទេ ? បើត្រូវការជួសជុល ប្រើពេលប៉ុណ្ណា? ជាដើម្បី ។ល។ តែនៅពេលយួន បង្រៀនពួកនេះ វាពុំបានធ្វើដោយត្រង់ដូច្នេះឡើយ ពោលគឺ ÷

-ដើម្បីយកជោគជ័យលើគោលដៅ "ក" ត្រូវធ្វើការបំផ្លាញ ផ្លូវគមនាគមន៍ ស្ពាន ថ្នល់ អ្វីទាំងអស់ ដែលទាក់ទងនឹង គោលដៅ " ក" នេះចោល ដើម្បីកុំអោយសត្រូវមានលទ្ធភាពជួយគោលដៅ "ក"បាន ។ នេះជាឧទាហរណ៍មួយ ។

-ដើម្បីបំបាត់អាវុធជាតិផ្ទុះ ប្រមូលអាវុធ រាប់សៃនដើម ដុតបំផ្លាញចោលអាវុធទាំងនោះចោល ។

-ដើម្បីទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ ប្រមូលឈើ ប្រមូលគ្រឿងចក្រ ឡាន សំភារះ ដុតចោល ។

-ដើម្បីទប់ស្កាត់ការនេសាទខុសច្បាប់ ប្រមូលទូក អួន សំណាញ់ដុតបំផ្លាញចោលទាំងអស់ ។

-ដើម្បីទប់ស្កាត់ការតស៊ូនានា ត្រូវកាប់បំផ្លាញព្រៃឈើចោល " ក៥ និង ពេលបច្ចុប្បន្ន" ។

-ដើម្បីទប់ស្កាត់ចារកម្មខ្មាំង ត្រូវតែសំលាប់ទាំងខ្សែ( *ជីកស្មៅជីកទាំងឫស*) មិនថា អ្នកក្បត់ឬអ្នកស្មោះត្រង់ឡើយ ។

ដោយពួកទាំងនេះ ខ្វះការសិក្សា និងដោយការជឿលើគំនិតយួន ហួសហេតុ ធ្វើអោយពួកនោះ តែងតំកល់ គំនិតយួនសុទ្ធសឹងតែត្រូវ ជាការធ្វើអោយខកខានមិនបានធ្វើការសិក្សាប្រៀបធៀបវែងឆ្ងាយអ្វីឡើយ ។ ហើយពួកនេះប្រព្រិត្តិតាមគន្លងយួន ផ្តល់គំនិតអោយ រហូតដល់ប្រព្រិត្តិបែបជ្រុលនិយម ដល់សព្វថ្ងៃនេះ ។

## ង-របៀបគ្រប់គ្រង និង ចាត់ការ

នៅក្នុងរបប របស់ខ្មែរក្រហម គេតែងឬពាក្យថា "ការតស៊ូបើដាច់ ខ្សែរយះ នឹងមិនងាយបានឡើងឋានៈ ឬមុខងារ ខ្ពង់ខ្ពស់ឡើយ "។ មានន័យថា បើចូលធ្វើការតស៊ូតាមអ្នកដឹកនាំណាម្នាក់ត្រូវតែធ្វើការអោយជាប់លាប់ជាមួយអ្នកនោះ ដើម្បីអោយអ្នកនោះស្គាល់ដឹងពីវិរភាពរបស់ខ្លួន។ តែបើមិនមែនជាអ្នករើសខ្លួនមកបញ្ចូលទេ នឹងគ្មានតំលៃឡើយ។ ទាំងនេះហើយជាហេតុធ្វើឱ្យគេសង្កេតឃើញថា ពួកនេះនឹងមិនស្ដាប់អ្នកមានឋានៈខ្ពស់ជាងខ្លួនណាឡើយ ក្រៅពីមេដឹកនាំផ្ទាល់របស់ខ្លួន។ បើយើងសង្កេតអោយបានជិតដល់ នៅក្នុងចលនា កុម្មុយនិស្តរបស់ខ្មែរក្រហម មានចលនាជាច្រើន គឺពួកកុម្មុយនិស្តនិយមយួន (ពួកដែល យួន បានជ្រើសរើសរៀបចំ) ពួកកុម្មុយនិស្តជាតិនិយមចិន (ក្រុមប៉ុល ពត) ពួករាជានិយម ពួកអ្នកជាតិនិយម និងពួកដែលដោយរោយតាមខ្យល់។ ក្នុងចំណោមនេះ ពួកដែលមានឥទ្ធិពលខ្លាំងជាងគេ គឺ ពួកកុម្មុយនិស្តនិយមយួន និង ពួកកុម្មុយនិស្តនិយមចិន។ ដោយហេតុថា នៅឆ្នាំ ១៩៦០ លោក សាឡុត ស. អៀង សារី មកពីបារាំង ដើម្បីចូលរួមធ្វើការតស៊ូ និងដណ្ដើមកាន់កាប់ ក្បាលម៉ាស៊ីនបក្សកុម្មុយនិស្តកម្ពុជា យ៉ាងណាក្ដី តែអ្នកដឹកនាំនៅគ្រប់ស្រទាប់ ជាពិសេសនៅស្រទាប់ក្រោមតាមជនបទ ត្រូវបានយួនរៀបចំរួចទៅហើយ។ នៅពេលដែល ប៉ុល ពត ឬសាឡុត ស កាន់កាប់ក្បាលម៉ាស៊ីនបក្ស គាត់ត្រួតត្រាបានត្រឹមតែក្បាលខាងលើតែប៉ុណ្ណោះ ឯស្រទាប់ក្រោម និងថ្នាក់កណ្ដាល ដែលមានពួកខ្មែរថ្មី (យួនដែលប្ដូរឈ្មោះ ជាខ្មែរ)ជាអ្នកដឹកនាំ មិនស្ដាប់ការបញ្ជារបស់គាត់ឡើយ។ ឬម្យ៉ាងទៀត ពួកនេះធ្វើដើម្បីយកពត៌មាន និងផែនការផ្សេងៗ ពីពួក ប៉ុល ពត ផ្ដល់ទៅអោយយួនដឹងទាំងអស់។ ហើយបើស្ដាប់ធ្វើតាមបញ្ជា ក៏ធ្វើដោយមិនពេញលេញ (ដូចគ្នានឹងរដ្ឋាភិបាល របស់ ទ្រង់ រណរិទ្ធ នាឆ្នាំ ១៩៩៣-១៩៩៧ ដូច្នោះដែរ)ឬក្នុងរបៀបមួយ ដែលសុភាសិតខ្មែរតែពោលថា "**ដុតអោយខ្លោច រោចអោយនៅ**" យ៉ាងដូច្នោះឯង។ ការពិសោធន៍នៅក្នុងអំឡុង រដ្ឋាភិបាលចំរុះរបស់ទ្រង់រណរិទ្ធ ជាគំរូស្រាប់។ បើមនុស្សរបស់ ហ៊្វុនស៊ិនប៉ិច ត្រូវបានតែងតាំងជាប្រធាន ស៊ីភីភី ជាអនុប្រធាន។ ពេលនោះ មនុស្ស ស៊ីភីភី ដែលជាអនុប្រធាន តែងធ្វើអ្វីៗ ដើម្បីកុំអោយមនុស្សខាង ហ៊្វុនស៊ិនប៉ិច ធ្វើអ្វីកើត។ ឬម្យ៉ាងទៀត ពួកស៊ីភីភី តែងលួករំលងការងារទៅខាងលើ ដោយមិនបានធ្វើតាមឋានានុក្រម ការងារឡើយ។ តែបើ ស៊ីភីភី ជាប្រធាន ហ៊្វុនស៊ិនប៉ិច ជាអនុប្រធាន ពួក ស៊ីភីភី តែងធ្វើរំលងទៅខាងក្រោម ដោយមិនបានគោរពតាមឋានានុក្រមការងារសោះឡើយ ឬមួយធ្វើអោយការងាររបស់ មនុស្ស ហ៊្វុនស៊ិនប៉ិច ត្រូវរាំងស្ទះ។

-តាមផ្លូវចិត្តសាស្ត្រ មនុស្សទូទៅ តែងតែធ្វើដើម្បីផលប្រយោជន៍របស់ខ្លួន ដោយជៀសមិនរួច។ ជាពិសេស មនុស្សដែល អវិជ្ជា រមែងស្រេកឃ្លាន មុខមាត់បុណ្យសក្ដិដោយខុសទំនង។ យួន ដែលមានផែនការលេបយកដីខ្មែរ មិនត្រូវការគុណភាពមនុស្សទេ គេត្រូវការតែ មនុស្សដែលស្មោះត្រង់នឹង យួនតែប៉ុណ្ណោះ។ ឯចំណែក ពួកកុម្មុយនិស្តនិយម ចិន មានប៉ុល ពត បើទោះជា មានចរិតឃោរឃៅម្ដេចក្ដី ក៏ពួកនេះត្រូវការមនុស្សដែលមានគុណភាព រួមផ្សំនឹងអ្នកដែលស្មោះត្រង់នឹងបក្សយ៉ាងពិតប្រាកដ ដើម្បីជាសសរទ្រទ្រង់របស់អង្គការនយោបាយខ្លួន។ ការសឹរិតសំរាំងគុណភាពមនុស្ស មានផលប៉ះពាល់ដល់ការបែកបាក់ផ្ទៃក្នុង និងជាឱកាសអោយយួន ដែលចាំតែឆក់យកប្រយោជន៍នោះ ងាយស្រួលលូកដៃ មកកកូរកកាយផ្ទៃក្នុងរបស់ពួកកុម្មុយនិស្ត ប៉ុល ពត។ ពួកកុម្មុយនិស្ត ប៉ុល ពត ប្រាកដជា មិនរើសយក មនុស្សដែល បណ្ដុះបណ្ដាលដោយ យួន ឡើយ។ ហេតុនេះហើយ ពួកខ្មែរយៀកមិញនេះ នឹងងាកទៅរក យួនដោយស្វ័យប្រវត្តិ។ គោលបំណងយួន មិនត្រូវការអ្នកដែលមានសមត្ថភាពទេ តែគេត្រូវការពួកនេះ គ្រាន់តែជាខ្មោចក្នុងអោយដៃ ប៉ុណ្ណោះ ដើម្បីធ្វើអោយរបប ពួកកុម្មុយនិស្ត ប៉ុល ពត ចុះខ្សោយបែកបាក់គ្នា។

-ដោយហេតុថា ក្នុងផែនការរៀបចំ យួន បានចាត់អោយពួកខ្មែរថ្មី (កូនយួន) នៅគ្រប់គ្រងថ្នាក់សំខាន់ៗទាំងអស់ ។ ឯពួកខ្មែរល្ងង់ខ្លៅនៅតាមជនបទ ត្រូវបានយួនចាត់អោយធ្វើការនៅថ្នាក់ក្រោម។ ដោយហេតុថា ពួកក្របខណ្ឌ កុម្មុយនិស្ត ដែលយួន បានរៀបចំ នៅពាសពេញគ្រប់ទាំងស្រទាប់ក្រោម និងថ្នាក់កណ្តាល បើទោះបីពួក ប៉ុល ពត បានបោសសំអាតនៅថ្នាក់កំពូលហើយក្តី តែការអនុវត្តនីផែនការយុទ្ធសាស្រ្តធំៗនានា ត្រូវតែអនុវត្តនីតាមរយះក្របខណ្ឌថ្នាក់កណ្តាល។ ដោយថ្នាក់កណ្តាល សុទ្ធសឹងជាមនុស្សដែលយួន រៀបចំហើយពួក ប៉ុល ពត (មជ្ឈឹម) មិនអាចស្គាល់ពួកនេះអស់ឡើយ។ ហេតុនេះហើយ នៅពេលដែលបញ្ជាពី មជ្ឈឹមមកអោយធ្វើកិច្ចការអ្វីមួយ ពួកខ្មែរថ្មីនេះ តែងតែធ្វើតាមរបៀប " **ដុតអោយខ្លោច រោជអោយឆៅ** " នេះឯង។ បានន័យថា បើមជ្ឈឹមអោយ បោសសំអាត ពួកខ្មែរថ្មី (យួន ដែលប្តូរ ឈ្មោះជាខ្មែរ) ១០០នាក់។ ពួកខ្មែរថ្មីដែលនៅថ្នាក់កណ្តាលនេះ នឹងបោសសំអាតខ្មែរស្លូតត្រង់នៅថ្នាក់ក្រោមៗ ១០០០ ឬ ១០០០០នាក់។ នេះជារបៀប" **ស្វាស៊ីបាយលាបមាត់ពពែ** "។ ហើយរបៀបនេះ យួន ធ្លាប់បានធ្វើមកលើ ជនជាតិយួន កាន់សាសនាកាតូលិក នៅក្នុងរបបសាធារណរដ្ឋ នៃគ្រាដំបូងនៃសង្រ្គាមដូច្នោះដែរ។ ដែលជាហេតុធ្វើអោយមតិជាតិ និងអន្តរជាតិថ្កោលទោសលើ របបលោកសេនាប្រមុខ លន់ នល់ យ៉ាងធ្ងន់ធ្ងរ។ ក្នុងបំណងធ្វើអោយអំណាចគ្រប់គ្រងរបស់ពួក ប៉ុល ពត ត្រូវរង្គោះរង្គើ សង្ស័យគ្នា លែងទុកចិត្តគ្នា។ ហើយនេះហើយជាផ្នែកមួយ នៃបច្ច័យដែលនាំទៅរកវាលពិឃាដ។

អ្នកនិពន្ធសរសេរបកស្រាយ ដូច្នេះ មិនមែនបានន័យថា កែតំរូវអោយពួក ប៉ុល ពត ត្រូវនោះឡើយតែ ដើម្បីអោយឃើញថា អ្នកដែលកាប់សំលាប់ ខ្មែរមិនមែនមានតែ ពួក ប៉ុល ពត ប៉ុណ្ណោះទេ តែមានស្តេច សីហនុ ជាពិសេសគឺ យួន នេះតែម្តងដែលបានគូសវាផែនការ វាលពិឃាដនេះឡើងដើម្បីបំរើនយោបាយវាតទីរបស់ខ្លួន។ យោងតាមឯកសារស្តីពី " **យុទ្ធវិធីបញ្ចូលមនុស្ស** " របស់ក្រុង ហាណូយ(សូមអានទំព័រខាងក្រោយ) ដែលដកស្រង់ផ្សាយដោយវិទ្យុអាស៊ីសេរី អាចគូសបញ្ជាក់អោយយើងមើលឃើញកាន់តែច្បាស់ឡើងថែមទៀត ពីផែនការរបស់យួន ក្នុងការលេបយកទឹកដីខ្មែរ តាមរយះមនុស្ស ដែលយួនរៀបចំទុក និងអាចអោយយើងមើលឃើញថា ការរៀបចំនេះមិនមែនទើបត្រឹមតែ ពួកក្មេងប្រមាត់ប្រមង់ ៤៥០០នាក់នេះឡើយ គឺតាំងពីមុននេះយូរយាមកហើយ ឧទាហរណ៍រាប់មិនអស់ ដូចជា មេខ្មែរយៀកមិញ ដែលយួន បានបន្តុបអោយ ធ្វើជា មេបក្សកុម្មុយនិស្តខ្មែរ ឈ្មោះ **ម្សៀង** បានដូរឈ្មោះមកជា **ម្សៀន** ហើយមកលាក់ខ្លួនបួសរៀន ក្នុងវត្តខ្មែរ។ បន្ទាប់មកបានប្តូរឈ្មោះជា **សឺង ង៉ុកមិញ** ដើម្បីបន្លំធ្វើជាប្អូនរបស់លោក **សឺង ង៉ុកថាញ់** ដែលជាវរជនខ្មែរ ពេញនិយមនាសម័យនោះ។

### ការបោកប្រាស់តាមជំនឿអរូបីយ

យួនខាងជើង (យួនកុម្មុយនិស្ត) បានធ្វើសង្រ្គាមជាមួយ យួនខាងត្បូង។ យួន បានបោកស្តេច សីហនុ ថាពេលរំដោះយួនខាងត្បូង (កម្ពុជាក្រោម) បាននឹងប្រគល់អោយ សីហនុ វិញ។ ហើយយួន បានបញ្ចុះបញ្ចូល ម៉ូនិក អោយពន្យល់ស្តេច សីហនុ ថា សីហនុ នេះហើយជាតួរអង្គព្រះបាទ ធម្មិក និងជា តួរស្តេច ស តូចស្តើង ត្រូវបានសោយរាជ្យលើប្រទេសទាំង ៣។ តែ ពេលជាមួយគ្នា យួន បានជួយពួកខ្មែរ កុម្មុយនិស្ត ឆ្វេងនិយម(ទាំងពួកខ្មែរយៀកមិញ ពួក ប៉ុល ពត និងកុម្មុយនិស្តនិយមយួន) ថា យួនធ្វើសង្រ្គាម ដើម្បីជួយរំដោះប្រជាជាតិនៅ ជ្រោយឥណ្ឌូចិន (ខ្មែរ ខ្មែរក្រោម យួនខាងត្បូង និងលាវ) ពី ការត្រួតត្រា របស់អាណានិគមន៍បារាំង និង អាមេរិច។ ដើម្បីសំរេចគោលដៅនេះ យួនខាងជើង សុំអោយ **សីហនុ** ជួយ។ តែផ្ទុយទៅវិញ នេះជាល្បិចកលយួន ដើម្បីរុញសង្រ្គាមនេះ អោយធ្លាក់មកលើប្រទេសខ្មែរទៅវិញ។ ស្តេច **សីហនុ** បានចុះហត្ថលេខាជាមួយយួនខាងជើង(យៀកកុង) ស្ងាត់ៗ ( *ដោយគ្មានសភាខ្មែរយល់ព្រមឡើយ នេះជាទង្វើ ក្បត់ជាតិ ព្រោះអាងអំណាចជាស្តេច* ) ឱយដាក់ទ័ពក្នុងទឹកដីខ្មែរភាគខាងកើត(ខេត្តក្រចេះ មណ្ឌលគីរី កំពង់ចាម ព្រៃវែង ស្វាយរៀង

)ចំនួនពី ៦០០០០-៨០០០០នាក់ (ពេលនោះស្តេច សីហនុ កំណត់អោយកងទ័ពខ្មែរ មានត្រឹមតែ ៣០០០០នាក់ ប៉ុណ្ណោះ)។ ក្នុងស្ថានភាពបែបនេះ ប្រទេសខ្មែរ បានបាត់បង់អព្យាក្រិត្យភាព ទៅហើយ។ យួនយៀកកុង បានចូលលុកលុយ ប្រទេសខ្មែរ រុញសង្គ្រាមនោះ អោយធ្លាក់មកលើប្រទេសខ្មែរ បង្ករវិនាសកម្មយ៉ាងធ្ងន់ធ្ងរ ដល់ប្រជាពលរដ្ឋខ្មែរស្លូតត្រង់ទាំងក្នុងស្រុក ទាំងនៅតាមជាយដែន ស្លាប់យ៉ាងខ្លោចផ្សារដោយការបង្កពីកងទព័យួន និងកងទព័យួនខាងត្បូង នឹងអាមេរិក អស់ចំនួន រាប់ពាន់នាក់ រៀងរាល់ថ្ងៃ។

នាពេលនោះ លោក ស៊ឹង ង៉ុកថាញ់ បានធ្វើការឃោសនា ពន្យល់ដល់ខ្មែរទូទៅ អោយមានភ្ញាក់រលឹក និងអោយយល់ដឹងថា នយោបាយដែល ស្តេច សីហនុ កំពុងធ្វើជានយោបាយសំលាប់ជាតិឯង។ លោក ស៊ឹង ង៉ុកថាញ់ ក៏បានពន្យល់ផងដែរថា ការរីកចំរើននៅក្នុងរបស់ ស្តេច សីហនុ ជាការរីកចំរើនបែបពពុះទឹក ជាការរីកចំរើនសំរាប់តែរលាយទៅវិញដោយចៀសមិនរួច។ ស្តេច សីហនុ បានថ្កោលទោសលោក ស៊ឹង ង៉ុកថាញ់ ថាក្បត់ជាតិ។ ខ្មែរ សឹងទូទាំងប្រទេស ជឿលង់តាមស្តេច សីហនុ។ អ្នកស្នេហាជាតិ ជាច្រើនត្រូវបានស្តេច សីហនុ បោកយកមកបាញ់សំលាប់ចោលនៅត្រពាំងក្រឡឹង យ៉ាងសែន អាណោចអាធម្ម ដោយអយុត្តិធម៌។ អ្នកទាំងនោះមិនបានក្បត់នឹងខ្មែរទេ តែគេប្រឆាំងនឹងនយោបាយសំលាប់ជាតិឯងរបស់ស្តេចនេះប៉ុណ្ណោះ។




ពេលនោះ យួនយៀកកុង(យួន កុម្មុយនិស្ត) បានធ្វើនយោបាយបែបត្រជាក់ ចំពោះប្រជាពលរដ្ឋខ្មែរស្លូតត្រង់ នៅតាមជនបទ។ ឯ យួន ខាងត្បូង(យួន ធីវគី) វិញ ប្រើនយោបាយក្តៅ។(សូមមើល ឯកសារប្រវត្តិសាស្ត្រ ស៊ីឌី បន្ថែម)។ ដោយសារទាហានយួនយៀកកុង នៅពេញប្រទេសខ្មែរ និងទង្វើក្បត់ជាតិ របស់ស្តេច សីហនុ ដែលមានពួក ជា ស៊ីម, ហ៊ុន សែន, ហេង សំរិន,ជនកុម្មុយនិស្តល្ងង់ខ្លៅដុតកំឡោចប្រទេសខ្មែរនេះហើយ ដែលនាំអោយក្រុមជាតិនិយមទ្រង់ **ស៊ីរីមតៈ, លន់ នល់** ធ្វើរដ្ឋប្រហារទំលាក់ **សីហនុ** ដើម្បីដេញយួនចេញពីប្រទេសខ្មែរ ។

ចិន និងយួន បានខ្ចីដៃ **សីហនុ** ធ្វើជាគំរបបិទបាំងបំភន្តភ្នែកជាតិ និងអន្តរជាតិ។ ចិនសុំអោយ **សីហនុ** ជួយយួនយៀកកុង និងខ្មែរក្រហម។ យួន និងចិន សន្យាថាដណ្តើមអំណាចមកជូនព្រះអង្គវិញ តែខ្មែរជាអ្នកស្លាប់ និងមហន្តរាយ។ ថ្ងៃ

ទី ២៣ ខែមិនា ឆ្នាំ១៩៧០ **សីហនុ** បានបង្កើតរណៈសិរ្សរួបរួមកម្ពុជាមួយនៅប៉េកាំង ចូលរួមជាមួយខ្មែរក្រហម **ប៉ុល ពត** និង ជួយយួនយៀកកុង អោយរំលាយពួកសេរី **សីរមត:** និង **លន់ នល់**។ **សីហនុ** បានប្រកាសផ្សាយតាមវិទ្យុពីទីក្រុងប៉េកាំង អោយខ្មែររត់ចូលព្រៃម៉ាគី ដណ្តើមអំណាចអោយខ្លួនវិញ យ៉ាងកោលាហល និងដោយក្តីរីករាយផង ពោរពេញដោយ កំហឹង ចងអាឃាដ នឹងខ្មែរដែលជារាស្រ្តរបស់ខ្លួនឯង។ យួនបានពាក់ផ្លាករូបថត **សីហនុ** បន្លំជាកងទ័ព **សីហនុ** ដើម្បីបោកប្រាស់ខ្មែរ ធ្វើចំបាំងជាមួយកងទ័ពសាធារណរដ្ឋខ្មែរ **សីរមត:** និង**លន់ នល់**។ **សីហនុ** បានជួយយួនកុម្មុយនីស្ត(យៀកកុង) រហូត បាន ជោគជ័យលើខ្មែរសាធារណ:រដ្ឋ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយយួនបានបំពាក់ជ័យជំនះនេះ ទៅអោយពួក ខ្មែរក្រហម វិញ ដែលកាលនោះ **សីហនុ** គឺ ជាមេ ។ តែយួន បានបណ្តុះមនោគមន៍កុម្មុយនិស្ត បែបម៉្យាងដល់ខ្មែរឆ្វេងនិយម និង បញ្ចូល ចារកម្មរបស់វា ក្នុងរបបខ្មែរក្រហម ធ្វើអោយរបបនេះកាប់ សំលាប់ខ្មែរ ហើយទំលាក់កំហុសដាក់ ពួកខ្មែរក្រហម ប៉ុល ពត ។ នេះជា **ល្បិចស្វាស៊ីពាយ លាបមាត់ពពែ**។ ដូច្នេះ **សីហនុ** ជាអ្នកទទួលខុសត្រូវចំពោះ ប្រវត្តិសាស្រ្តខ្មែរ ចំពោះរបបកម្ពុជា ប្រជាធិបយតេយ្យ មិនមែន **សាឡុត សរ** (ប៉ុល ពត)ទាំងស្រុងទេ។ ១៣ ថ្ងៃក្រោយគឺ ១៧ មេសា ១៩៧៥ សង្រ្គាមយួន ខាងជើង និងយួនខាងត្បូងត្រូវបញ្ចប់ គឺ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥ដែរ។ ថ្ងៃនេះ គឺជា ថ្ងៃជ័យជំនះរបស់ កុម្មុយនិស្ត ឥណ្ឌូចិន ដឹកនាំដោយយួនខាងជើង។ កុម្មុយនីស្ត ឈ្នះពួកសេរី ហើយហុចឱកាសអោយយួន ដែលបង្កប់ខ្លួនក្នុងខ្មែរក្រហម សំលាប់ខ្មែរសាធារណ:រដ្ឋ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីរំលាយពូជសាសន៍ខ្មែរ រំលាយអ្នកចេះដឹងខ្មែរដែរ។ នេះជា ផែនការយួនរំលាយពូជសាសន៍ខ្មែរជាលើកទីពីរ ដើម្បីលេបទឹកដី។ ចារកម្មយួនបាន សំលាប់អ្នកប្រាជ្ញ បញ្ញវន្តខ្មែរទាំងអស់ ទុកតែអ្នកល្ងង់ខ្លៅ ទើបថ្ងៃទី ៧ ខែមករា ឆ្នាំ១៩៧៩ យួនចូលមកឈ្លានពានលេបយកទឹកដីខ្មែរ បន្តសំលាប់ខ្មែរ (នៅ ក៥) និងប្លន់យកទ្រព្យសម្បត្តិខ្មែរ។ តើនណាអ្នកសំលាប់ខ្មែរ? តើខ្មែរល្ងង់ណាស់ទៅ រហូតដល់ សំលាប់ បញ្ញវ័ន្តជាតិខ្លួនឯង ត្រង់ ចំណុចនេះ សូមបងប្អូនជនរួមជាតិជួយពិចារណារ ។ ចំលើយគឺ **កុម្មុយនិស្តឥណ្ឌូចិន** ដឹកនាំ និងរៀបចំដោយយួន នេះហើយ ជាអ្នក សំលាប់ខ្មែរ។ ហេតុនេះហើយ ៧ មករា ជាថ្ងៃយួន ឈ្លានពានសំលាប់ខ្មែរបន្ត មិនមែនជាថ្ងៃដឹងគុណយួននោះទេ។ ដូច្នេះ សង្រ្គាម ចាប់ពីឆ្នាំ១៩៧០ មកគឺជាសង្រ្គាមរវាង ខ្មែរ និងយួន។ តែស្តេច **សីហនុ** ធ្វើនយោបាយ ត្រឡប់ត្រឡិន ជួយយួន ពឹងយួន ធ្វើ គំរបអោយយួន បើកឱកាសអោយយួន ចូលមករំលាយពូជសាសន៍ខ្មែរ និងលេបយកទឹកដីខ្មែរ។ **សីហនុ** មានគំនុំសងសឹក នឹងខ្មែរ ជួយយួនអោយ សំលាប់ខ្មែរ **លន់ នល់** និង **សីរមត:**។ ចុងបញ្ចប់ យួនប្រើល្បិច សំលាប់ខ្មែរ ហើយទំលាក់កំហុស ដាក់ខ្មែរក្រហម រួចទុក **សីហនុ** ជាខែល។ ខ្មែរជាអ្នកបរាជ័យ និងខូចខាតផលប្រយោជន៍ គ្រប់យ៉ាង តែយួនជាអ្នកចំណេញ បានផលប្រយោជន៍យ៉ាងច្រើនសន្ធិកសន្ធាប់ទៅវិញ។

## ២_របបកុម្មុយនិស្ត ហ៊ុន សែន, ហេង សំរិន, អាយ៉ង យួន
## (Pupet Regime of Vietnam, Hun Sen and Heng Samrin)

យួនបានចូលមកឈ្លានពានទឹកដីខ្មែរ និងប្លន់យកទ្រព្យសម្បត្តិខ្មែរ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ លើកបន្ទុប ពួក អាយ៉ង **ហេង សំរិន ហ៊ុន សែន** (អតីតទាហានខ្មែរក្រហម) ដូចកាលយួនឈ្នះសាធារណរដ្ឋខ្មែ **លន់ នល់** ហើយបំពាក់ ជ័យជំនះ អោយពួកខ្មែរក្រហមដែរ។ យួនបានប្លន់យកទ្រព្យសម្បត្តិខ្មែរ ចុះកិច្ចព្រមព្រៀងសិទ្ធិសញ្ញាខុសច្បាប់ កាត់យកទឹក ដីខ្មែរ សន្ធិសញ្ញាឆ្នាំ១៩៧៩-១៩៨២-១៩៨៣ និង១៩៨៥។ យួនបន្តសំលាប់ខ្មែរទៀត ដោយចោទថាខ្មែរក្រហម បញ្ជូនខ្មែរ អោយទៅស្លាប់នៅតំបន់ ក៥។ យួនបាន បញ្ជូនអ្នកជំនាញការមកធ្វើការជាមួយ ខ្មែរអាយ៉ង។ យួនរៀនភាសាខ្មែរ យកប្រពន្ធ ឬប្តីខ្មែរ។ យួន ៥នាក់ ខ្មែរ១នាក់ នៅក្នុងទីក្រុង ចំណែកនៅតាមជនបទ យួន១នាក់ ខ្មែរ៥នាក់។ នេះជា *ផែនការយួនសំលាប់ ខ្មែរផ្តាច់ពូជ*។

សហភាពសូវៀត អ្នកនៅក្រោយខ្នងយួន បានដួលរលំនៅឆ្នាំ១៩៨៩ ចាញ់សហរដ្ឋអាមេរិច។ ពេលនោះយួនក៏ធ្លាក់ខ្សោយនៅឯកកោ ព្រោះអាស៊ាន ចិន និងសហរដ្ឋអាមេរិក បានដាក់ការគាបសង្កត់ទាំងខាងសេដ្ឋកិច្ច និងនយោបាយ ព្រោះ យួនឈ្លានពានប្រទេសខ្មែរ។ ចំណែករបបអាយ៉ង **ហេង សំរិន ហ៊ុន សែន** ដែលកំពុងត្រួតត្រាខ្មែរខុសច្បាប់ ក៏ចាប់ផ្ដើម ចរចារជាមួយចលនាតស៊ូត្រីភាគី តាមព្រំដែន គឺរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ កម្ពុជាប្រជាធិតេយ្យ និង ហ៊្វុនស៊ិនប៉ិច។ ក្រោយពីមានការចចារគ្នា ជាច្រើនលើក រវាងភាគខ្មែរទាំងបួន អង្គការសហប្រជាជាតិបានសំរេចអោយ យួនដក កងទ័ពចេញពីប្រទេសខ្មែរ។ ប្រទេសខ្មែរ នឹងរៀបចំបោះឆ្នោតមួយ ដែលមានការត្រួតពិនិត្យពីអង្គការសហប្រជាជាតិ (UNTAC)។ តែពេល ដែលយួនដកទ័ពចេញនោះ យួនបានដកទ័ពចេញទៅដោយខ្លួនឯង មុនការរៀបចំរបស់អង្គការសហប្រជាជាតិ ដោយបន្សល់ទុកនៅកងទ័ពស្លៀកពាក់ស៊ីវិលរាប់ម៉ឺននាក់ បង្កប់ខ្លួនក្នុង **គណបក្សប្រជាជនកម្ពុជា**។ **ហុក ឡងឌី** និង **បក្សពួកអាយ៉ង** មិនអនុញ្ញាតអោយអង្គការសហប្រជាជាតិត្រួតពិនិត្យឡើយ។

នៅឆ្នាំ១៩៨៩ **ហ៊ុន សែន** ខ្លួនឯងបានចេញផ្សាយថា មានជនជាតិយួនជាង១លាននាក់ មានអត្តសញ្ញាណប័ណ្ណជាតិខ្មែរ ដូចគ្នាទៅ និងអត្តសញ្ញាណប័ណ្ណដែលចេញអោយជនជាតិខ្មែរដែរ។ ដូច្នេះ ពួកយួនទាំងនោះមានសិទ្ធិពេញលេញ ក្នុងការបោះឆ្នោតជាតិជាបន្តបន្ទាប់។

សិទ្ធិសញ្ញាសន្តិភាព ទីក្រុងប៉ារីសថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៩១ ធ្វើអោយមានការបោះឆ្នោតនៅឆ្នាំ១៩៩៣។ ខ្មែរក្រហមមើលឃើញយួនបង្កប់ ដូចនេះភាគីកម្ពុជាប្រជាធិបតេយ្យមិនបានចូលរួមការបោះឆ្នោតនោះទេ។ ពេលពួកមេត្រួតត្រាខុសច្បាប់ **ហ៊ុន សែន** គណបក្សប្រជាជនចាញ់ឆ្នោត គណបក្សហ៊្វុនស៊ិនប៉ិចឆ្នាំ១៩៩៣ ដោយអាងយួនពីក្រោយខ្នង (ដែលបានបង្កប់ ទុកកងទ័ព និងជំនាញការ ក្នុងពេលកងទ័ពយួនឈ្លានពានដកចេញពីប្រទេស ខ្មែរនៅឆ្នាំ១៩៨៩) ពួក **ហ៊ុន សែន** មិនបានគោរពកិច្ចព្រមព្រៀង សិទ្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីសទេ។ ល្បិចនយោបាយ **សីហនុ** និង **ហ៊ុន សែន** បានអោយ **នរោត្តម ចក្រពង្ស** បង្កើតតំបន់អប្បគមន៍ នៅត្រើយខាងកើតទន្លេមេគង្គ ដើម្បីធ្វើសង្គ្រាម និងធ្វើអោយរាំងស្ទះ លទ្ធផលបោះឆ្នោត ដែលពេលនោះ ហ៊្វុនស៊ិនប៉ិច ជាអ្នកឈ្នះ។ **សីហនុ** បានជួបចរចារសំងាត់ជា មួយ **ហ៊ុន សែន** នៅឆ្នាំ១៩៨៧ ដើម្បីរក្សាកុម្មុយនីស្តយួន និងរាជបល្ល័ង្គបន្តទៀត។ នាពេលនោះ សីហនុ ដឹងច្បាស់ណាស់ថា សហប្រជាជាតិ បានចំណាយ ២កោដិដុល្លា មកលើប្រទេសខ្មែរ ក៏ព្រោះតែ ដើម្បីជួយប្រជាជាតិខ្មែរ អោយមានសន្តិភាព រួចចាកផុតពីទុក្ខសោករ៉ាំរ៉ៃអស់កាលជាង ៣ទសវត្សរ៍មកហើយនោះ តែមិនមែនដើម្បី មកជួយអោយមានរាជបល្ល័ងឡើងវិញទេ ។ ហើយ ស្តេចនេះ ដឹងយ៉ាងជាក់ថា បើទុកអោយ សហប្រជាជាតិ នៅគ្រប់គ្រងប្រទេសខ្មែរតទៅទៀត សីហនុ មិនអាចក្រឡុកស្ថានការណ៍អោយវិលទៅរករបបរាជានិយមបានឡើយ។ រីឯ ជនក្បត់ជាតិ ហ៊ុន សែន អាយ៉ងយួន ក៏មានការយល់ឃើញដែរថា បើសិនជាទុកអោយសហប្រជាជាតិ នៅក្នុងប្រទេសខ្មែរ វាមិនអាចពង្រឹងអំណាចឡើងវិញបានឡើយ។ ចំពោះយួន យល់ថា ដើម្បីបន្ត ផែនលេបយកទឹកដីខ្មែរ ត្រូវតែជំរុញអោយមានការដកកំលាំង សហប្រជាជាតិ ចេញពីប្រទេសខ្មែរយ៉ាងដាច់ខាត។ ស្តេច សីហនុ គិតថាខ្លួន អាចបោក ហ៊ុន សែន ដោយការបញ្ចើចបញ្ចើ អោយងារជាស្តេច ជាតេជោ ផ្សេងៗ។ ឯជនក្បត់ជាតិ ក្រោមការញុះញង់ពីយួន គិតថាខ្លួនអាចប្រើប្រាស់ស្តេច សីហនុ ដើម្បីជាប្រយោជន៍ ក្នុងការពង្រឹងអំណាចឡើងវិញបានដែរ។ ហេតុហ្នឹងហើយ ជាហេតុធ្វើអោយអ្នកទាំងពីរ ធ្វើការប្រកាសដេញ កំលាំងសហប្រជាជាតិចេញពីប្រទេសខ្មែរ នាឆ្នាំ ១៩៩៣ នោះឯង។ ហើយដោយសារតែ គំនិតស្រេកឃ្លានរាជបល្ល័ងនោះហើយ ដែលធ្វើអោយនយោបាយយួនលេបទឹកដី ខ្មែរ បន្តទៅរកការសំរេចផលធ្លោរឡើង។

អន្តរាគមន៍ពី **សីហនុ** អោយប្រទេសមាន **នាយករដ្ឋមន្ត្រី ២** ក្រោមលេសផ្សះផ្សាជាតិ បង្រួបបង្រួមជាតិ ត្រូវបានយកមកធ្វើជាខែល និងបានបង្កើតឡើង។ ពលិកម្មរបស់ អ្នកជាតិនិយមខ្មែរ ដែលប្តូរជាដោយជីវិត ដោយឈាមស្រស់ នៅតាមជាយដែនខាងលិច ដែលធ្វើឱ្យនយោបាយវាតទីរបស់យួន អាយ៉ងក្បត់ជាតិ ត្រូវដួលរលំទៅហើយនោះ ត្រឡប់ជាឥតន័យ ។ បានត្រឹមតែ ជូនដំណើរស្តេចនេះ ឱ្យបានសោយរាជ្យ វិញតែប៉ុណ្ណោះ និងត្រូវបានស្តេចនេះ យកមកជាន់ឈ្លីជាល្បែង។ មិនតែប៉ុណ្ណោះ ឧត្តមសេនីយ អ្នកតស៊ូជាច្រើន សិបនាក់ នាយទាហាន ជាច្រើនពាន់នាក់ ដែលស្មោះត្រង់ នឹងស្តេចនេះ ត្រូវបានស្តេចលីលា ប្រមូលយកមកឱ្យយួន នឹងអាយ៉ងយួន សំលាប់បង្ហើនៅថ្ងៃ ៥-៦ កក្កដា ១៩៩៧ និងបន្តសំលាប់ តាមវិធីខ្មៅងងឹតបែបភេរវកម្មផ្សេងៗ ដូចជា÷

**កលល្បិចសំលាប់អ្នកស្នេហាជាតិ**

១-នាំផឹកស៊ី បង្កជំលោះ បាញ់បោះ ហើយបាញ់សំលាប់។

២-នាំផឹកស៊ី ស្រី ញី ហើយដាក់ថ្នាំសំលាប់ ដោយពន្យាពេល។

៣-បង្ករធ្វើជាគ្រោះថ្នាក់ចរាចរ។

៤-បាញ់សំលាប់ ដោយធ្វើបែបជាចោរកម្ម ឬទំនាស់គំនុំផ្សេងៗ។

៥-បើជននោះមានការប្រុងប្រយត្ន័ មិនអាចធ្វើអ្វីកើត ពួកវាបង្កើត ឯកសារក្លែងក្លាយហើយចោទប្រកាន់ ដើម្បីចាប់ដាក់គុក និងដើម្បី បង្ខូចមុខមាត់ នយោបាយ។

**កលល្បិចយួន សំលាប់ពលរដ្ឋខ្មែរទូទៅ** (ទាំងកូនចៅ និងពួកខ្ញុំកញ្ជះយួនផងដែរ)

-សំលាប់ ដោយពង្វក់នឹងស្រា និងការដាក់ជាតិពុលក្នុងស្រា ការផលិតស្រាពីសារធាតុគីមី

-សំលាប់ តាមម្ហូបអាហារ ការផលិតអាហារដោយប្រើសារធាតុគីមី

-សំលាប់ តាមការចំលងមេរោគអេដស៍

-សំលាប់ ដោយការបំផ្លាញមច្ឆជាតិ

-សំលាប់ ដោយការបំផ្លាញ និងដណ្តើមយកតំបន់សេដ្ឋកិច្ច (បណ្តេយយកដីក្រោមលេស អភិវឌ្ឍន៍)

-សំលាប់ ដោយធ្វើឱ្យខ្មែរធ្លាក់ខ្លួនលង់ក្នុងភាពក្រតោកយ៉ាក និងការប្លន់យកការងារ ប្លន់យក តំបន់សេដ្ឋកិច្ចខ្មែរ។

-ទន្រ្ទានយកដីក្រោមផ្លាកក្រុមហ៊ុន (ដីចំការកៅស៊ូ ដីក្នុងទីក្រុង)។ ដើម្បីសំរេចផែនការលេបយកប្រទេសខ្មែរដោយមិនបាច់បង្ហូរឈាម ដែលមានពួកអាយ៉ង ហ៊ុន សែន ជាអ្នកជួយផង។ យួន បានផ្តល់លុយដ៏ច្រើនសន្ធឹកសន្ធាប់ អោយជនជាតិយួន ដែលចេះ ខ្មែរច្បាស់ ទិញដីនៅទីក្រុង ទីប្រជុំជនធំ ក្រោមផ្លាកក្រុមហ៊ុន កូរ៉េ ចិន កុងត្រារយះពេល ៩៩ឆ្នាំ។ តែតាមការពិត សុទ្ធសឹងជាជនជាតិ យួនទាំងអស់ ។ កត្តានេះ ធ្វើអោយពួកខ្មែរអ្នកមានរត់ទៅទិញដីនៅតាមជនបទ ហើយពួក អ្នកនៅតាមជនបទទៅរុករាន ទន្រ្ទាន ទៅកាប់បំផ្លាញព្រៃឈើ នៅតាមព្រៃភ្នំនានា។

**"លង្វែកប្រាក់ខ្លង ខ្មែរកាប់បំផ្លាញឬស្សី ភ្នំពេញចុល្លាថ្មី ខ្មែរកាប់បំផ្លាញព្រៃឈើរលាយភ្នំ"**

## ៣-អាណានិគមន៍យួនបែបថ្មី និងជនអន្តោប្រវេសន៍យួន

### (Neo Colonism of Vietnam and Vietnamese Immigrants)

ខ្មែរយើងកំពុងប្រឈមមុខនិងគ្រោះមហន្តរាយដ៏ធ្ងន់ធ្ងរ គឺការបាត់បង់ទឹកដី និងរលាយពូជសាសន៍ ដូច ប្រទេសចំប៉ា និងខ្មែរកម្ពុជាក្រោមដោយមិនដឹងខ្លួន។ យួនបានបន្សល់ទុកនូវជំនាញការយួនចេះភាសាខ្មែរ ដូចជា **ហ្វុក ឡុងឌី សុខ គង់, ប៊ុន សម, សុខ អាន និងចាយ សាំងយុន** ជាដើម។ ពួកយួនចេះភាសាខ្មែរទាំងនេះ កំពុងត្រួតត្រាប្រទេស ខ្មែរសព្វថ្ងៃ កំពុងបង្ហូរជនជាតិយួនអោយតាំងទីលំនៅក្នុងប្រទេសខ្មែរមានចំនួន ៤៥០០ ០០០នាក់ (បួនលានកន្លះ)។ នេះ ជានយោបាយយួនទូបនីយកម្ម តាមផែនការយួន **ហូ ជិមិញ** បញ្ចូលតាមរយៈ ពួកមេត្រួតត្រាខុសច្បាប់ "**គណបក្សប្រជាជន**" ដែល មានអាក្បត់ **ហ៊ុន សែន** ជាមេក្លោង។ ដូច្នេះ ទោះជាមានការរៀបចំឆាកល្ខោនបោះឆ្នោត បន្លំភ្នែកប្រជាជាតិខ្មែរ និងអន្តរជាតិ ក៏ដោយ ក៏លទ្ធផលនេះមិន មែនចេញ ពីឆន្ទៈប្រជាពលរដ្ឋខ្មែរពិតប្រាកដទេ។

នៅឆ្នាំ១៩៧០ ប្រជាជនខ្មែរមានចំនួនតែ ៦ ៥០០ ០០០ នាក់ប៉ុណ្ណោះ ក្នុងនោះមានជនភៀសខ្លួនយួនប្រហែលជា ២០០ ០០០ នាក់ ទៅ ៣០០ ០០០នាក់ ជាអ្នកនេសាទស្ថិតនៅតាមបឹងទន្លេសាប។ ក្រោយពីព្រឹត្តិការណ៍ផ្តួលរំលំសម្តេច **នរោត្តម សីហនុ** នៅក្នុងថ្ងៃទី១៨ មីនា ១៩៧០ ពេលនោះជនជាតិយួនមួយចំនួន ត្រូវបានឧត្តមសេនីយ៍ **លន់ នល់** បញ្ជូនអោយត្រឡប់ទៅមាតុភូមិវិញ។ យួនមួយចំនួនដែលនៅសល់ ត្រូវបានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ទៅឆ្នាំ១៩៧៨។ ដូច្នេះ នៅពេលដែលកងទ័ពយួនឈ្លានពានទឹកដីខ្មែរ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ នោះ គ្មានយួននៅសល់ លើទឹកដីខ្មែរទៀតទេ។ តាមសម្តី **ហ៊ុន សែន** ក្នុងកិច្ចសម្ភាសន៍មួយ នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៨៨ ថាប្រជាពលរដ្ឋខ្មែរ នៅចុងឆ្នាំ១៩៨៧ មានចំនួន ៧ ៩៩៥ ០០០ នាក់ ពូជសាសន៍ខ្មែរ មានពី៧៤% ទៅ៨០% ដូច្នេះមានន័យថា ចំនួនប្រជាពលរដ្ឋ ពី ១ ៦០០ ០០០ នាក់ ទៅ ២ ០០០ ០០០ នាក់ ដែលរស់នៅលើទឹកដីខ្មែរ មិនមែនជា ពូជសាសន៍ខ្មែរទេ។

នៅលើពិភពលោកគ្មានជនអន្តោប្រវេសន៍ខុសច្បាប់ណា មានអត្តសញ្ញាណប័ណ្ណ មានសិទ្ធិបោះឆ្នោតនិងធ្វើជាអ្នកដឹកនាំ សំខាន់ៗក្នុងស្ថាប័នជាតិ ដូចក្នុងប្រទេសខ្មែរសព្វថ្ងៃក្រោមការត្រួតត្រាបណ្តោះអាសន្នរបស់អាយ៉ង ហ៊ុន សែន នេះឡើយ។

នៅប្រទេសអាឡឺម៉ង់មានប្រជាពលរដ្ឋ ទួរគី ៣ ០០០ ០០០ នាក់ ទៅ ៥ ០០០ ០០០ នាក់ កំពុងរស់នៅក្នុងប្រទេសនេះ បីជំនាន់មកហើយ តែគេមិនដែលផ្តល់សិទ្ធិអោយប្រជាពលរដ្ឋ ទួរគី ទាំងនោះ មានសិទ្ធបោះឆ្នោត ដូចជនអន្តោប្រវេសន៍យួន ដែលរស់នៅប្រទេសខ្មែរឡើយ។

នៅឆ្នាំ១៩៧៩ ក្នុងទឹកដីខ្មែរ គ្មានជនជាតិយួន ម្នាក់ទេ 0% ។ តែចំនួនប្រជាជនយួន កើនឡើងរហូតដល់ ១៧.៥% នៅចុងឆ្នាំ១៩៨៧ (១.៤ លាននាក់) យួនឡើងរហូតដល់ ២៣% នៅឆ្នាំ១៩៩៥ (២.៤ លាននាក់) ឥឡូវនេះ យួនកើនឡើងដល់ ៣៣% នៅ ឆ្នាំ២០០៥ (៤.៥ លាននាក់)។ ប៉ុន្តែបច្ចុប្បន្ននេះ ប្រជាពលរដ្ឋខ្មែរ កើនឡើងយ៉ាងឆាប់រហ័ស រហូតដល់ចំនួន ១៤ ៥០០ ០០០នាក់ តើហេតុអ្វីបានជាប្រជាពលរដ្ឋខ្មែរ កើនឡើងយ៉ាងឆាប់បែបនេះ។ ការបញ្ចូលជនជាតិយួន មកតាំងទីលំនៅគ្រគ្រឹកគគ្រេងនេះ មិនខុសពីអ្វី ដែលយួនបានបញ្ចូលជនជាតិ យួន មកក្នុងប្រទេសចម្ប៉ា និងខ្មែរកម្ពុជាក្រោមពី សម័យមុននោះទេ។ (សូមអានឯកសារ យោងជាភាសាអង់គ្លេស របស់អគ្គរាជទូត សហរដ្ឋអាមេរិក ដែលចូលនិវត្តន៍)។

For publishing in your esteemed paper, in two parts.

The Editor,
The Cambodian Daily,
No. 50-B, Street 240,
PHNOM-PENH.
(Kingdom of Cambodia).

VIETNAMIZATION OF CAMBODIA

Sir,

The following report of a retired Ambassador, who was posted in Cambodia in I990, is an eye opener:-

"There is unhampered migration from Vietnam, to the point almost half of the population will be Vietnamese soon. Entire villages were no longer able to participate in the elections 2003, due to the uncontrolled advance of the Vietnamese border, these villages have become part of Vietnam. This has also been documented by the EU Election Observors, who knew these Khmer Villages, from previous election."

The population of Cambodia in I970 was 6.5 millions, out of which, it had approximately 2-300,000 Vietnamese Refugees, overspill of the Vietnam Wars, majority settled in the border districts with South Vietnam, but small majority of fishermen in Tonley Sap Lake. They were not given the right to participate in the National Elections, but were issued Identity Cards as "Vietnamese Refugees"; the intention being that when the Vietnam War is over, they will be sent back to the Republic of Vietnam (then South Vietnam). After the Coup and overthrow of Prince (now King Father) Norodom Sihanouk in March I970, when the killing of Vietnamese refugees started under Genl. Lon Nol, they were repatriated under Thiew-Lon Nol Agree ment on Repatriation of Vietnamese Refugees in I97I to the Republic of Vietnam (then South Vietnam). Once a refugee is repatriated to its country of origon, he looses his refugee status under the International Law. Latter on any left over Vietnamese Refugees were killed by the Democratic Kampuchea (Khmer Rouges) during their reign of terror (I975-78). As such when the Vietnamese troops attacked and occupied Phnom-Penh on 7th Jan. I979, there was not a single Vietnamese left in Cambodia - Khmer Rouges had even killed those Cambodians, who could speak Vietnamese language even.

The SUDOSTASIEN ACKTUEL of Nov. I989 had reported:-

"Hun Sen told Peter Schier of the Asian Affairs (Humburg FRG) in an interview of 6 Jan I988, that the population of Cambodia at the end of I987, was 7,995,000 people. According to Hun Sen, ethnic Khmers amounted to between 74% and 80% of the population."

This means that between I.6 and 2.0 million inhabitants of Cambodia are not ethnic Khmers. If we assume that the number of Hill Tribe people is now about 200,000, the number of Cham no more than 300,000, and the ethnic Chinese about I00,000, then there are between I million and I.4 million ethnic left, who cannot but be Vietnamese.

Hun Sen however, pretended that there are only about 60,000 Vietnamese living in Cambodia at present - a number which is obviously not true."

No such census giving the number of ethnic Khmers and the minorities, appear to have been conducted in Cambodia again, during the last I8 years. It is high time that it should be done now.

The VIETNAM INSIGHT ( A forum sponsored by the National United Front for the Liberation of Vietnam of Nov. I992, issued from USA), had stated in its Editorial:-

"The two million Vietnamese settlers in Cambodia, confirmed by the U.N. Peace-keeping Task Force, pose a genuine threat to the natives in the upcoming election. This is also the reason that the Khmer Rouges refuses to partici-cipate in the peace process. This fear and opposition to Vietnamese partici-pation in the polls are legitimate. ...... These two million Vietnamese vot-ers represent one-fourth of the Cambodian population.

From the perspective of the Cambodian Government, there is a deep

concern that the nation's soverignty is at stake, as one-fourth of the electorate is Vietnamese, a people whose Government invaded and occupied Cambodia for years, until being forced out by international pressure.

There are Vietnamese Communist Party Members, who have been planted in Cambodia, to continue the Party's interest on this foreign soil. ..... Its withdrawl of troops, even as accurate as it claims, is not enough. It can recall its party members and cadres, planted in Cambodia under civillian clothes."

According to Son Sann, a former Prime Minister: "Out of every four persons in Cambodia, one is a Vietnamese." He could easily distinguish, as he came from Kampuchea Krom (now in South Vietnam).

According to William Shawcross (Cambodia Deal 1994, page 69): "There are atleast 500,000 to one million illegal Vietnamese crossing to Cambodia."

According to KPLNF (under Son Sann): "A programme of mixed marriages was introduced between Vietnamese settlers and Cambodians on the pretext of national integration. All senior Cambodians officials were required to have Vietnamese wives, while Cambodian women were encouraged to have sexual relations with and bear fatherless children by Vietnamese soldiers, so that Cambodians of tomorrow, have Viernamese blood."

·II

Vietnam had done its home work properly, before withdrawing its troops from Cambodia in 1988, by issuing more than a million Vietnamese settelers with "Cambodian National Identity Cards", exactly the same type issued to the Cambodians; so that they could have a permanent say in the future elected Government. It looks Communisim is being infiltrated by the back door , in to Cambodia.

During a T.V. programme on the Immigration Law, arranged by Khmer Institute of Democracy in Phnom-Penh on 10th Sept. 1994, Kan Morn M.P. stated that S.O.C. (State of Cambodia) or former People of Kampuchea, they issued I.D. Cards to foreigners (obviously Vietnamese immigrants), which were like the same I.D. Cards issued to Cambodians, and that the ID Cards that S.O.C. issued were for only governing and identifying the holder - It means they did not grant them nationality status even the I.D. Cards that issued by UNTAC." Chen Sngoun added: "When we have the Nationality Law, we will then know the "Khmer Nationality Status".

The above clearly show that the National Identity Cards issued by the SOC to the Vietnamese Immigrants (mentioned as foreigners) were the same as those of Cambodians. As such there was no distinction between the Vietnamese and Cambodian Identity Cards, and therefore for all purposes the Vietnamess were treated as Cambodians. On the bases of these I.D. Cards, all the Vietnamese Immigrants living in Cambodia, most probably became eligible to register themselves as voters in May 1993 Elections.

After the Vietnamese troops withdrawl, the present CPP is the successor to erstwhile Khmer Peoples Revolutionary Party (subservient to Vietnamese Communist Party), revived in 1978. The CPP has only changed its name, but the Party structure, the judiciary, and other working systems are still the same as that of Peoples Republic of Kampuchea, which William Shawcross, while writing on the Guardian on 20th Nov. 1991, described:-

"When Vietnam installed its client regime, mostly Ex-Khmer Rouges, in Phnom-Penh, at the end of 1978, it declared that the Situation in Cambodia, is now "irreversible". ..... The Vietnamese were determined to impose a Communist Regime in Cambodia. That was much less brutal than the Khmer Rouges but it suppressed dissent, and its human rights record has been criticised by Amnesty and the Asia Watch. "Vietnamese Liberation" of Kampuchea in early 1979, became an illegal Occupation, rejected by the majority of the U.N.".

This is further echoed in the SUDOSTASIEN ACTUELL of Jan. 1989, page 89, where it is stated:-

"...... Don't forget that Hun Sen and Heng Samrin were Khmer Rouges uptill 1977, and upto now they continue to violate human rights. If you read carefully the annual reports of Amnesty International , you know then their violation of human rights in so called "Peoples Republic of Kampuchea" are terrible, too. There are all kinds of torture in the prisons people are being liquidated, people disappear etc.. They are not much different from the Khmer Rouges, but they are much more intelligent. In one respect this new generation of Khmer Vietminh is even worse than the Khmer Rouges, because they do not have a sense of National Independence. Heng Samrin and Khieu Samphan are both killers, but Khieu Samphan is not a traitor."

As is well known in Germany, where 3 to 5 million Turks, are living there for the last three generations, but they have not yet been given the right to vote in their national elections. Then why in Cambodia?

The UNTAC had completely forgotten that these were not normal Elections, but only the Khmers to select the type or form of Government of their choice, as they were twice forcibly placedd under the Communisim, which they had refused to accept. King Norodom Sihanouk had rightly observed that "the U.N. wasted $ 3 billions in Cambodia, by allowing Vietnamese immigrants (planted to tilt the balance) to participate in the elections - the object of the Election was defeated."

From 0 % Vietnamese in 1979, their number went upto 17.5 % of the population in end 1987 (1.4 million). It went up 23% of the total population in 1995(2.4 million), and now it has gone up to 33% in 2005 (approximately 4¼ out of the population of 13½ million) - once the Nationality Law is passed, it is hoped the majority of Vietnamese voters will not be able to participate in the National Elections.

By the increase of Vietnamese immigrants, who will soon be voters in the future elections, the CPP will be able to get the ⅔rd majority to change the Constitution, and may vote for making an alliance with the Socialist Republic of Vietnam, so as to have an Indochinese Federation, in which Vietnam will be dominant (the dying wish of Ho Chi Minh).

It is high time that all the Cambodians (inside and outside Cambodia) unite, and thwart the Vietnamese onslaught on democratic and peaceful Cambodia, and defeat the Vietnamese age old dream of "Indochinese Federation, dominated by Vietnam".

President George W. Bush is trying to bring in democracy and transparency in the Middle East. Here in Cambodia, a member of ASEAN, under his nose, Communisim is being infiltrated into it by the back door, and a democratic Kingdom, which was once an oasis of peace and tranquility, is now being swallowed by its Communist neighbour. It is high time he should look into it.

Yours Faithfully,

(K.L. Bindra)

12th Sept., 2005 — Formerly Chairman and Secretary General (1964-67), International Commission for Superfision and Control in Cambodia, set up under the Geneva Agreement on Indochina (1954).

15 Elmstead Avenue,
Wembley, Middx. U.K.
Tel: (020) 8908 4309

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ : ៣៩៤ ស.ជ.ណ

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០៣

**ជូនចំពោះ**

លោក ស៊ុម ចិ ប្រធានសមាគមខ្មែរវៀតណាមនៅព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុ** : ករណីស្តីពីការស្នើសុំបើកទីស្នាក់ការសាខា សមាគមខ្មែរវៀតណាម នៅព្រះរាជាណាចក្រកម្ពុជា នៅតាមបណ្តាខេត្ត - ក្រុង ចំនួន ១៩ និង សុំអនុញ្ញាតប្រើប្រាស់ត្រា សំរាប់ការងាររដ្ឋបាលសមាគម ។

**យោង** : លិខិតលេខ ០២ ស.វ.ណ.ក ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៣ របស់សមាគមខ្មែរវៀតណាមនៅព្រះរាជាណាចក្រកម្ពុជា ។

តបតាមកម្មវត្ថុ និងយោងខាងលើ សូមជំរាបលោកប្រធានជ្រាបថា ក្រសួងមហាផ្ទៃយល់ព្រមតាមសំណើរបស់លោកស្តីពីការស្នើសុំបើកទីស្នាក់ការសាខា សមាគមខ្មែរវៀតណាមនៅព្រះរាជាណាចក្រកម្ពុជា តាមខេត្ត-ក្រុង ទាំង ១៩ គឺ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ចាម ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តសៀមរាប ខេត្តក្រចេះ ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តតាកែវ ខេត្តកំពត ខេត្តកោះកុង ខេត្តតាកែវ ខេត្តស្ទឹងត្រែង ខេត្តរតនៈគិរី ក្រុងព្រះសីហនុ រាជធានីភ្នំពេញ និង សុំអនុញ្ញាតប្រើប្រាស់ត្រាសំរាប់ការងាររដ្ឋបាលសមាគម នោះហើយ ។

ចំពោះការអនុវត្តជាក់ស្តែង សូមលោកប្រធានធ្វើការសហការជាមួយអាជ្ញាធរមូលដ្ឋានតាមការកំណត់ ។

អាស្រ័យហេតុនេះ សូមលោកប្រធានជ្រាបជាព័ត៌មាន ។

សូមលោកប្រធាន មេត្តាទទួលនូវការគោរពដ៏ស្មោះស្ម័គ្ររបស់ខ្ញុំ ។

**ចម្លងជូន** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
- សាលាខេត្ត-ក្រុងទាំង១៩
"ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**សហរដ្ឋមន្ត្រី**

ស ខេង   យូ ហុកគ្រី

> នេះជាឯកសារដែលលោក ស ខេង និងលោក យូ ហុកគ្រី យល់ព្រមឱ្យបើកទីស្នាក់ការសាខាសមាគមវៀតណាមនៅព្រះរាជាណាចក្រកម្ពុជា

## ៤-ហ៊ុន សែន គៀបសង្កត់ជិះជាន់ ពលរដ្ឋខ្មែរអោយ ខ្សោះខ្សោយក្រីក្រ អត់ឃ្លាន ល្ងង់ខ្លៅ ភ័យខ្លាច
### (Hun Sen Makes the People Poor, Illiterated and Scared)

ដើម្បីលេបយកប្រទេសខ្មែរតាមរយៈអាណានិគមន៍បែបថ្មី (នយោបាយត្រជាក់)នេះ យួនបានសំលាប់ព្រលឹងខ្មែរ តាមការកែប្រែប្រវត្តិសាស្ត្រខ្មែរ និងមនោគមន៍ផ្សេងៗ។ តាមរយះអាយ៉ង **ហ៊ុន សែន** យួនបានបំបាក់ឆន្ទៈខ្មែរគ្រប់វិធី។ យួន ព្យាយាមប្រើគ្រប់វិធីសាស្ត្រ ដើម្បីធ្វើអោយខ្មែរមិនអាចងើបឡើងរើបំរះតស៊ូរួច។ ប្រជាពលរដ្ឋខ្មែរក្រីក្រ គ្មានការអប់រំ ល្ងិតល្ងង់ ខ្លាចពួកអ្នកមានអំណាច បក្សពួក **ហ៊ុន សែន** ។ យួនបានកាន់កាប់ស័ក្តានុពលជាតិខ្មែរសំខាន់ៗ ដូចជា ខាងយោធា ខាងសេដ្ឋកិច្ច ខាងនយោបាយ តុលាការ និងសារពតិមាន។ល។ **ហ៊ុន សែន** ធ្វើតាមបញ្ជាយួន ដែលមានចេតនា ធ្វើអោយប្រជាពលរដ្ឋខ្មែរ ខ្សោះខ្សោយក្រីក្រ អត់ឃ្លាន ល្ងង់ខ្លៅ ភ័យខ្លាច ដើម្បីអំណាចរបស់វា។ តែយួនជាអ្នកឆក់ប្លន់ យកផលប្រយោជន៍ ពីខ្មែរ ដើម្បីធ្វើអោយសំរេចមហិច្ឆតា លេបយកទឹកដីខ្មែរទាំងមូល។ យួន ធ្វើប្រើប្រាស់មធ្យោបាយគ្រប់បែបយ៉ាង ធ្វើអោយខ្មែរ វក់វង្វេងភ្លេចជាតិឯង បែកបាក់សាមគ្គី គិតតែអាត្មានិយម និងគិតតែក្រពះ។ យួនតំរូវអោយពួក **ហ៊ុន សែន** ដឹងគុណយួន ដឹងគុណ៧ មករា។

### ក-តើ យួន **ហ៊ុន សែន** ធ្វើអោយខ្មែរក្រីក្រតាមវិធីណាខ្លះ?

- យួនប្រមូលធនធានទ្រព្យសម្បត្តិធម្មជាតិរ៉ែ ក្នុងដីលើដីរបស់ខ្មែរដូចជា ត្រី ព្រៃឈើ មាស ពេជ្រ និងទ្រព្យសម្បត្តិ ផ្សេងៗទៀតយក ទៅប្រទេសយួន។
- យួនបញ្ជូនជនជាតិខ្លួន អោយមកដណ្តើមការងារ ដីធ្លី ស្រែចំការ និងផលប្រយោជន៍ខ្មែរ។
- យួនគ្រប់គ្រងប្រព័ន្ធសេដ្ឋកិច្ចខ្មែរ ដោយអោយ **សុខ គង់, ម៉ុង សម**។ល។ ធ្វើអាជីវកម្មលើ ប្រាង្គប្រាសាទ ខ្មែរ លើក្រុមហ៊ុន លើពាណិជ្ជកម្មសំខាន់នានា ។ ជនជាតិយួនតាំងទីលំនៅតាមតំបន់សេដ្ឋកិច្ច ចំណែកខ្មែរ ល្ងង់ខ្លៅរស់នៅស្រុកស្រែ ធ្វើស្រែចំការ លើដីមួយអំពក ។ នៅតាមជាយដែន យួន វាបង្ខំអោយខ្មែរ បោះបង់ចោលដីស្រែចំការ ឬបង់ថ្លៃឈ្នួលលើដីស្រែខ្លួនឯង។
- ប្រាក់ខែតិច តែទំនិញឡើងថ្លៃ ធ្វើឱយប្រាក់ចំណូលប្រជាពលរដ្ឋខ្មែរតិចជាងចំណាយ(គ្មានប្រាក់សន្សំ ធ្លាក់ខ្លួន កាន់តែក្រ)។
- កាប់ព្រៃឈើ ធ្វើអោយមានគ្រោះធម្មជាតិ ទឹកជំនន់ គ្រោះរាំងស្ងួត និងដីគ្មានជីជាតិ ជាហេតុធ្វើអោយប៉ះពាល់ពាល់ដល់ការបង្កបង្កើនផល កសិករខ្មែរ យ៉ាងធ្ងន់ធ្ងរ។
- អោយ **សុខ គង់** និងត្រកូល **ហ៊ុន សែន** លក់ប្រេងឡើងថ្លៃតាមទំនើងចិត្ត សង្កត់កខ្មែរអោយអត់ឃ្លាន។
- ខ្ចីបុលបរទេសរាប់លានដុល្លា តែយកលុយដាក់ហោប៉ៅផ្ទាល់ខ្លួន ។ ប្រព្រឹត្ត អំពើពុករលួយហួសនិស្ស័យ ធ្វើអោយ ប្រជាពលរដ្ឋខ្មែរត្រូវសងបំនុលបរទេស ជំនួសពួកវា តាមរយៈការបង់ពន្ធ។
- យួនកាន់តែច្រើន ដីកាន់តែឡើងថ្លៃ ពួកមន្ត្រីក្បត់ ដណ្តើមដីធ្លីពីប្រជាពលរដ្ឋខ្មែរ ដើម្បីលក់អោយយួន ។
- បណ្តោយអោយពួកមានអំណាច រឹបជាន់ឆក់ប្លន់យកដីធ្លីខ្មែរ លក់អោយទៅឈ្មួញយួន ដែលមានការទំនុកបំរុង និងផែនការពី រដ្ឋការយួន។
- ប្រជាពលរដ្ឋខ្មែរសព្វថ្ងៃ ត្រូវជំពាក់បំណុលបរទេស៣000 ដុល្លាក្នុងម្នាក់ទៅហើយ។

## ខ-តើ យួន ហ៊ុន សែន ធ្វើអោយខ្មែរល្ងង់ខ្លៅតាមវិធីណាខ្លះ?

- មិនអោយកូនខ្មែរសិក្សារៀនសូត្រប្រវត្តិសាស្ត្រខ្មែរពិតប្រាកដ អោយខ្មែររៀនប្រវត្តិសាស្ត្រក្លែងក្លាយ ផ្តល់ពតិមានមិនពិត ដើម្បីបំបាត់ព្រលឹងជាតិខ្មែរ បំបាក់ឆន្ទៈស្នេហាជាតិខ្មែរ ។
- ធ្វើអោយខ្មែរក្រីក្រ គិតតែអត្មានិយម និងខ្វល់តែនឹងរឿងក្រពះ នាំអោយខ្មែររៀនសូត្រមិនបានខ្ពង់ខ្ពស់ ។
- ប្រពន្ធ័ពតិមាន( គ្មានឯករាជ្យ ) ក្រោមអំណាច យួន **ហ៊ុន សែន** តែមួយ មិនផ្តល់ពតិមានពិត មានប្រយោជន៏ ដល់សង្គមជាតិ មានតែពតិមានឃោសនា ភ្លើតភ្លើន បងតូចបងធំ និងពាលាអាវ៉ាសែ ។
- ប្រព័ន្ធអប់រំគ្មានគុណភាព ( ពុករលួយ គ្មានបណ្ណាល័យ គ្មានសំភារះសិក្សាស្រាវជ្រាវ គ្មានបទដ្ឋាន ) ។
- បំបាក់ទឹកចិត្តគ្រូ ផ្តល់ប្រាក់ខែគ្រូ មិនគ្រប់គ្រាន់ បំបាក់ទឹកចិត្តអ្នកស្នេហាជាតិខ្មែរ គំរាម និងសំលាប់ វីរៈបុរស ខ្មែរ បំបាក់ស្មារតីជាតិនិយម ។
- យួនធ្វើអោយសង្គមខ្មែរ អោយតំលៃលើសំភារៈ អំណាច និងមិនអោយតំលៃខ្លួងឯង មិនអោយតំលៃអ្នកស្នេហាជាតិខ្មែរ បំភិតបំភ័យ បំបាត់ស្មារតី អ្នកគិតប្រយោជន៏ជាតិ ។

## គ-តើ យួន ហ៊ុន សែន ធ្វើអោយខ្មែរភ័យខ្លាចបាក់ស្បាតតាមវិធីណាខ្លះ?

- សំលាប់ខ្មែ តាមបែប ភេរវកម្ម អោយបាក់ស្បាត កាលពីរបបកម្ពុជាប្រជាធិបតេយ្យ និង រដ្ឋកម្ពុជា និងនៅតែ អនុវត្តន៏បន្តកាន់តែខ្លាំងឡើងរហូតដល់សព្វថ្ងៃ ។
- សំលាប់អ្នកស្នេហាជាតិ លើកអ្នកល្ងង់ខ្លៅ ពួកពាល ល្ងង់ខ្លៅ អោយមានអំណាច ដើម្បីសង្កត់សង្កិនខ្មែរ និងបន្តគាំទ្រ នយោបាយក្បត់ ជាតិ របស់ពួកវា ។ ធ្វើអោយខ្មែរសម័យក្រោយ លែងមានជំនឿ លែងអោយ តំលៃលើការចេះដឹង ការរៀនសូត្រ (ខ្មែរមានឳកាសរៀនសូត្រ តិចតួច) ។
- លុបបំបាត់ វីរះភាពអ្នកស្នេហាជាតិពិតប្រាកដ អោយតំលៃអ្នកបំផ្លាញជាតិ និងអ្នកដែលល្មោភអំណាច ស្រីទ្រព្យសម្បត្តិ លាភសក្ការៈ ។
- សំលាប់ខ្មែរតាមគ្រប់វិធី រដ្ឋប្រហារសំលាប់ ចោទប្រកាន់ ភេរវកម្ម បាញ់សំលាប់ ដាក់ថ្នាំពុល ធ្វើអោយគ្រោះថ្នាក់ ចរាចរណ៏ ចោរប្លន់ ជំងឺអេដស៏ និងជំងឺផ្សេងៗ ចាប់អោយក្រពើស៊ី ទំលាក់ជ្រោះពេជ្រនិល និងសំលាប់នៅក្នុងពេទ្យកាល់ម៉ែត្រ ដោយចាក់ថ្នាំសំលាប់ ( ពេទ្យយួនសំលាប់អ្នកស្នេហាជាតិខ្មែរ) ។ល ។



### ៥-ការសន្និដ្ឋានវាសនាអនាគតជាតិខ្មែរ (Conclusion of Future Fate of Cambodia)

សរុបមក ប្រទេសខ្មែរសព្វថ្ងៃ កំពុងតែស្ថិតនៅក្នុងអាណានិគមន៍យួនបែបថ្មី។ **ហ៊ុន សែន** កំពុងត្រួតត្រា ប្រទេសខ្មែរបំរើយួន តាមរបបកុម្មុយនិស្តផ្តាច់ការ កៀបសង្កត់ខ្មែរមិនអោយងើបរួច ធ្វើអោយប្រជាពលរដ្ឋខ្មែររងទុក្ខវេទនា ក្រីក្រល្ងង់ខ្លៅ ភ័យខ្លាច និងរស់ក្នុងភាពអយុត្តិធម៌។ វាសនាខ្មែរ នឹងបាត់បង់ទឹកដី រស់ជាជនជាតិ ភាគតិចលើទឹកដីដូនតា ខ្លួនឯងគ្មានសិទ្ធិសេរីភាព រងទុក្ខវេទនា ដូចជាប្រទេស ចម្ប៉ា និងខ្មែរកម្ពុជាក្រោម។ ប្រទេស កម្ពុជា នឹងមានតែឈ្មោះលើផែនទីប្រជាពលរដ្ឋខ្មែរនិងក្លាយជាជនជាតិភាគតិច របស់ប្រជាជន ឥណ្ឌូចិន(យួន) នាពេលអនាគតដ៏ខ្លី។

## II-គោលបំណង និងទិសដៅអ្នកដឹកនាំជាតិខ្មែរ (Goal and Objective of Khmer Leaders)

ដោយមើលឃើញគ្រោះមហន្តរាយ ចំពោះជាតិខ្មែរ ដ៏ធ្ងន់ធ្ងរនេះ ទើបមេដឹកនាំជាតិខ្មែរ បានខិតខំ ប្រមូលចងក្រង និងរិះរក មធ្យោបាយធ្វើអោយមាន ការរួបរួមប្រជាជាតិខ្មែរ អ្នកជាតិនិយម អ្នកស្នេហាជាតិខ្មែរទាំងអស់ពីគ្រប់ស្រទាប់ គ្រប់មជ្ឈដ្ឋាន ក្នុងគោលបំណងធ្វើការតស៊ូ តាមគ្រប់មធ្យោបាយ គ្រប់លទ្ធភាពដែលមាន ដើម្បី សង្គ្រោះ ជាតិ សាសនា ប្រជាជាតិខ្មែរ **អោយរួចផុតពី ½**

១-ការលេបត្របាក់ឆក់ប្លន់ទឹកដី ពីសំណាក់ចោរយួន វាតទីនិយម

២-របបត្រួតត្រា បែបកុម្មុយនិស្តផ្តាច់ការ **ហ៊ុន សែន** បំរើយួន

៣-ភាពក្រីក្រ អយុត្តិធម៌ និងអំពើពុករលួយ

### ដើម្បីនាំជាតិខ្មែរសាងអោយបាននូវ½

១-***ឯកភាពជាតិ*** យ៉ាងទូលំទូលាយ ក្នុងសង្គមខ្មែរគ្រប់មជ្ឈដ្ឋាន នៅទូទាំងទ្វីបលោក។ សាងសាមគ្គីជាតិ ការរួបរួមជាតិ ដើរឆ្ពោះទៅរកភាពរឹងបឹងគង់វង់ រួចចាកផុតពី ឧបាយកលរបស់សត្រូវជិតខាង និងចោរយួន ដែលព្យាយាម បំបែកបំបាក់ខ្មែរ រំលាយពូជសាសន៍ខ្មែរ ។

២-របប***ប្រជាធិបតេយ្យ ឯករាជ្យភាព ឥស្សរភាពជាតិ ពិតប្រាកដមួយ*** ក្នុងសង្គមខ្មែរ នាពេលអនាគត ខាងមុខ។

៣-ញ៉ាំងអោយប្រជាជាតិខ្មែរទាំងមូល រស់ក្នុង ***សុភមង្គល វិបុលភាព ប្រកបដោយថាមពលរឹងប៉ឹងជានិរន្តន៍ និងមានឧត្តមភាព ស្មើមុខនឹងប្រជាជាតិជិតខាង។*** ពោលគឺ ប្រជាជាតិខ្មែរ ត្រូវរស់ក្នុងភាពជាខ្មែរ ជាប្រទេសខ្មែរ លើទឹកដីខ្មែរ មានឥស្សរភាព មានវិបុលភាពក្នុងសង្គមជាតិ ជានិច្ចនិរន្ត មានសន្តិភាពជារៀងរហូត។ ខ្មែរមិនត្រូវរស់ ក្នុងជីវភាពមួយ ដែលមានភាពឃ្លេងឃ្លោង ដូចទឹកលើស្លឹកឈូកនោះឡើយ(សង្គ្រាមរីករវរ មិនចប់សួរពូជ)។ ខ្មែរ ត្រូវតែបញ្ចប់ភាព វឹកវរសួរពូជនៅជំនាន់នេះអោយបាន ហើយបោះជំហានទៅរក ភាពគង់វង់ មានវិបុលភាព ជារៀងរហូតតកូនតចៅ ក្នុងភាពជាខ្មែរ ម្ចាស់ស្រុក ម្ចាស់ប្រទេស។ ពោលគឺ មិនមែន កម្ពុជា ដែលមាន "ពួកខ្មែរថ្មី" (កូនយួន ដែលយួន បានរៀបចំអោយបន្លំខ្លួនជាខ្មែរ) នោះ ជាអ្នកដឹកនាំប្រទេសនោះឡើយ ។ តែគឺ ***ប្រទេសខ្មែរ ដែលមានខ្មែរ ម្ចាស់ទឹកដីពិតប្រាកដ ជាអ្នកគ្រប់គ្រង លើទឹកដីកំណើត ដ៏ពិសិដ្ឋ របស់ ដូនតារបស់ខ្មែរ***។

## III. យុទ្ធសាស្ត្រទឹក

ជាការធម្មតា កាលណាយើងចាប់ផ្តើមមានគំនិតប្រយុទ្ធ យើងតែងតែរិះរកយុទ្ធសាស្ត្រនានា ដែលនាំឱ្យមានសំនួរ និង ចំលើយ :

- បើយើងមានគ្នាច្រើន "ខ្លាំង" ជាងសត្រូវ យើងអាចវាយលុកលើសត្រូវ ។
- បើយើងមានគ្នាតិច "ខ្សោយ" ជាងសត្រូវ យើងត្រូវប្រើប្រាជ្ញា ជាដាច់ខាត ។
- តែបើយើងមានគ្នាតិច "ខ្សោយ" ហើយប្រាជ្ញាតិច ទៀតផង តើយើងធ្វើយ៉ាងណា?

ដើម្បីរកពន្លឺសំរាប់ឆ្លើយទៅនឹងសំនួរនេះ យើងគួរពិចារណា នៅលើប្រយោគមួយ របស់ទស្សនវិទូចិនដ៏ល្បីល្បាញ ម្នាក់ ឈ្មោះ "ឡាវ ស៊ឺ" ដែលគាត់និយាយថា :

*"នៅក្នុងលោកនេះ គ្មានអ្វីដែលទន់ជ្រាយ និងខ្សោយជាងទឹកទេ ។ ក៏ប៉ុន្តែ ក្នុងការវាយប្រហារ អ្នកដែលខ្លាំង និងរឹង មាំទាំងអស់ មិនដែលធ្វើបានឈ្នះទៅលើទឹក ហើយគ្មានអ្វីមកប្រៀបផ្ទឹម បាននឹងទឹកឡើយ ។ ភាពដែលខ្សោយ មានជ័យជំនះ លើភាពក្លាំងខ្លា ភាពដែលទន់ជ្រាយ មានជ័យជំនះលើភាពរឹងមាំ យើងដឹងគ្រប់ៗគ្នា តែគ្មានអ្នកណាម្នាក់យក ការចេះដឹងនេះ មក អនុវត្តឡើយ។"*

លោក ស៊ុន ស៊ឺ សង្គ្រាមវិទូចិនបានពោលថា " *ជ័យជំនះ នៃសង្គ្រាម មិនស្ថិតនៅទាំងស្រុងលើ អ្នកដែលមានកំលាំង ធំ ឬតូចឡើយ តែវាស្ថិតនៅលើការរៀបចំ ។ បើទោះជា ខ្មាំងធំប៉ុណ្ណាក្តី សុទ្ធសឹងតែមានចំណុចខ្សោយ ។ បើខ្មាំងការពារពីមុខ ខ្លាំង ខាងក្រោយខ្សោយ បើការពារពីខាងឆ្វេងខ្លាំង ខាងស្តាំខ្សោយ បើការពារជុំវិញ ជុំវិញសុទ្ធសឹងតែមានចំណុចខ្សោយ។* "

ដូច្នេះ តាមទ្រឹស្តីខាងលើ ក្នុងឋានៈយើង ជាអ្នកជាតិនិយម ជាអ្នកដឹកនាំខ្មែរ ដែលនៅក្នុងភាព កវែកកន្ទាំង ខ្វះមុខ ខ្វះក្រោយទន់ជ្រាយ "ខ្សោយ" អាចរកច្រកចេញ ដើម្បីយកជ័យជំនះទៅលើ ពួកមេក្បត់ត្រាក្បត់ជាតិ ដែលកំពុង "ខ្លាំង" និង រឹងមាំបាន បើយើង យល់ច្បាស់ ពីទ្រឹស្តីនេះ និងអាចធ្វើត្រាប់តាមលក្ខណៈសម្បត្តិរបស់ "ទឹក" បាន ។ នេះជាការមួយ ដែល យើងត្រូវតែហ៊ានប្រឈមមុខ ពិចារណា ស្រវាយកឱ្យទាល់តែបាន ។

### ១-ទឹកតាមអត្ថន័យវិទ្យាសាស្ត្រ

- គ្មានពណ៌ គ្មានក្លិន គ្មានរសជាតិ
- ជាធាតុមួយដែលគ្មានរូបរាងពិតប្រាកដ ដែលអាចសំរបសំរួលរូបរាងខាងក្រៅ ទៅតាមកន្លែងដែលវានៅ ក៏ ប៉ុន្តែ វាមិនអាចបង្រួញឱ្យតូច តាមសំពាធនានាបានឡើយ ។

**ទឹកតាមលក្ខណៈធម្មជាតិ :**

- *ទឹកហូរពីទីខ្ពស់ ទៅទីទំនាប*( កន្លែងដែលទទួលរាក់ទាក់នឹងទឹក) ។
- *ទឹកមានគោលដៅតែមួយ គឺហូរទៅរកសមុទ្រ។*
- *បើមិនទាន់ដល់គោលដៅ ទឹកស្នាក់នៅកន្លែងមួយ ដែលមានស្ថិរភាពជាទីបំផុត។*
- *ទឹកហូរចេញពីកន្លែងមួយទៅកន្លែងមួយ ទាល់តែមានជីជាវ* ( ចំណុចខ្សោយខ្មាំង) ។
- ទឹកអាចប្តូរភាពក្តៅ និងភាពត្រជាក់ ជាមួយអ្នកជិតខាង ។

- ទឹកអាចស្រោចស្រង់ ឬអាចកំទេចអ្នកជិតខាង តាមរយៈ វេលាយូរ ស្ងាត់ស្ងៀម ( *ជ្រាប* ) ឬ ឆាប់ ( *ហូរ-គ្របដណ្តប់* ) ឬ អហឹង្សា ( ជ្រាប ) ហឹង្សា ( ហូរបុកលប់លើ )
- នៅក្នុងសមុទ្រដែលជាគោលដៅធំបំផុតរបស់ទឹក ទឹកបានទទួលការស្នាក់នៅដោយសុខសាន្តត្រាណ សម្បូរ
- សប្បាយជាទីបំផុត ជាគុណបំណាច់ដែលទឹកបានទទួល តបស្នងអំពីវិរិយភាពរបស់ខ្លួនរហូតដល់អវសាន។

## ២_ទឹកប្រដូចនិងកំលាំងអ្នកស្នេហាជាតិខ្មែរ

កំលាំងអ្នកស្នេហាជាតិខ្មែរសព្វថ្ងៃ ត្រូវប្រឈមទល់មុខនឹង ចោរឈ្លានពានផង នឹងអំណាចផ្តាច់ការ ដែលជាអាយ៉ងយួនផង។ គោលដៅ ធំចុងក្រោយបំផុត របស់កំលាំងអ្នកស្នេហាជាតិ គឺត្រូវតែ រំដោះស្រុកឱ្យរួចផុត ពីកណ្តាប់ដៃ "ចោរយួន និងពួកអាយ៉ង ហ៊ុន សែន" ដែលមានមធ្យោបាយ ច្រើន លើសលប់ សំរាប់កំទេចអ្នកស្នេហាជាតិយើង។ តែអ្នកស្នេហាជាតិក៏មានភារកិច្ចជាចាំបាច់ ក្នុងពេលបច្ចុប្បន្ននេះ ដើម្បី សង្គ្រោះ ប្រទេសជាតិ ពីការស្លាប់បាត់បង់ និងការពារ ប្រជាពលរដ្ឋ ទាំងអស់ ដែលកំពុងស្ថិតនៅក្រោមការជិះជាន់របស់របបត្រួតត្រាសព្វថ្ងៃនេះ។ ដើម្បីសំរេច បេសកកម្មដ៏ពិសិដ្ឋ និងជាប្រវត្តិសាស្ត្រនេះ កំលាំង ស្នេហាជាតិ ត្រូវក្រេបជញ្ជក់យកការចេះដឹងអំពីទឹក ទឹកដែលទន់ជ្រាយ-ខ្សោយ តែអាចកំទេច សត្រូវខ្លាំង-រឹងមាំបាន។

## ៣_អត្តសញ្ញាណរបស់កំលាំងអ្នកស្នេហាជាតិខ្មែរ

- ***ទឹកគ្មានពណ៌*** ដូចជាកំលាំងអ្នកស្នេហាជាតិខ្មែរ ដែលមាន ឥស្សរៈភាព ទាំងខាងការផ្តួចផ្តើមគំនិត ការគិត ការនិយាយ ការរៀបចំកិច្ចការនយោបាយនៃការតស៊ូ និងការអនុវត្តន៍ ដោយមិនលុះតាម ការញុះញង់ ការញ្ញាក់ពី បរទេស ឬបក្សអាយ៉ងបរទេសឡើយ ហើយមិនប្រកាន់បក្សពួក ពណ៌សំបុរ តំកល់ខ្លួនយ៉ាងខ្ពស់ សំរាប់បំរើ តែ ប្រយោជន៍ជាតិ និងប្រជាជាតិខ្មែរ មិនលក់ក្បាលបំរើ ប្រយោជន៏ បក្សពួក ឬក្រុមណាមួយឡើយ។ យើងដឹង ហើយថា ដើម្បីបំផ្លាញខ្មែរ យួន បានព្យាយាមញែកបំបែកខ្មែរ ជា ខ្មែរច្រើនជនជាតិ ជាចាម ជាអនិកជន។ តែ តាមពិត ទាំងចាម ទាំងខ្មែរ សុទ្ធសឹងជាអ្នករង គ្រោះដោយសារចោរ យួនទាំង អស់គ្នា ។ ហេតុនេះ ទាំង ខ្មែរ ទាំងចាម ដែលកើតលើដីខ្មែរ ត្រូវគិតថាយើងជាខ្មែរទាំងអស់គ្នា ត្រូវរួបរួមសាមគ្គីគ្នា កំចាត់ យួន តែមួយដែល ជាសត្រូវប្រវត្តិសាស្ត្រ ទើបយើងបានសុខ។ យើងត្រូវធ្វើអោយមានការរួបរួមជុំវិញ ផលប្រយោជន៏ អាយុជីវិត ជាតិ ជាចំបងបង្អស់។ យើងត្រូវ ជួយទំនុកបំរុង តាមដែលអាចធ្វើបាន ដល់ប្រជាជាតិទាំងឡាយ ដូចជា លាវ ម៉ុង និងអ្នកប្រជាធិបតេយ្យជាតិនានា ដែលរងនូវការធ្វើទុកបុកម្នេញ ពីសំណាក់ ចោរយួន។ ការរួបរួមរបស់ ប្រជាជាតិទាំងអស់ក្នុងតំបន់ ជាយុទ្ធសាស្ត្រស្លាប់រស់ យ៉ាងសំខាន់មួយ ក្នុងការផ្តួលរំលំ មហាច្ឆិតាចោរ យួន អោយ រលត់រលាយទៅបានយ៉ាងមានប្រសិទ្ធភាព។

- ***ទឹកគ្មានក្លិន*** ក៏ដូចជាកំលាំងអ្នកស្នេហាជាតិខ្មែរ ត្រូវចេះរៀបចំ ចងក្រងកំលាំង ដោយស្ងាត់ស្ងៀម និងរក្សាការសំងាត់បំផុត មិនធ្វើឱ្យចោរយួន និងអាយ៉ង ចាប់ភ្លឹកពីសកម្មភាពរបស់យើងបានទាល់តែសោះ។ ទោះជាធ្វើការបានល្អ ឬទោះជាមានការថ្លោះធ្លោយ នៅក្នុងបេសកកម្មរំដោះជាតិ ក៏គ្មានលេចឮ សោះឡើយ។

- ***ទឹកធ្លាក់សេដាតិ*** ក៏ដូចជាកំលាំងអ្នកស្នេហាជាតិខ្មែរ ត្រូវមានបេសកកម្ម ធ្វើប្រយោជន៍ជូនជាតិ និងសង្គមជាតិ មិនធ្វើប្រយោជន៍ ទៅឱ្យក្រុមបក្សពួកបុគ្គល ឬ ផ្ទាល់ខ្លួនឡើយ ។

- ***ទឹកធ្លាក់រូបរាងពិតប្រាកដ*** ក៏ដូចជាកំលាំងអ្នកស្នេហាជាតិខ្មែរ នៅគ្រប់កន្លែងតាមក្រុមតូច តាមក្រុមធំ ដូចទឹក ថ្លុក តូចធំ នៅគ្រប់កន្លែង ហើយត្រូវចេះ បំភ្លែងរូបរាងរបស់ខ្លួន ទៅតាមកន្លែងដែលស្នាក់នៅ ។ ទោះជានៅ ក្នុងថ្លុកតូច ឬធំ ទឹកមិនអាចវៀវរួញបាក់ឆន្ទះ ដោយសារតែមានសំពាធពីលើឡើយ ក៏ដូចជា កំលាំងខ្មែរអ្នក ស្នេហាជាតិ ទោះជានៅតាមក្រុម តូច ឬតាមក្រុមធំ ក៏ " ទឹកចិត្តប្តូរផ្តាច់ " មិនអាចរួញមកតូច ឬ មិនបាត់បង់ គំនិតផ្តេចផ្តើមក្នុងការធ្វើក្នុងការរៀបចំរបស់ខ្លួន ដោយសារ ការខ្វះខាត ការលំបាកគ្រប់ប្រការ ដែលខ្លួនបាន ជួបប្រទះនោះ ឡើយ ។ ពោលគឺ នៅតែ រក្សាឥស្សរភាពគំនិត ឥស្សរះភាពខាងស្មារតីក្នុងការធ្វើ ការរៀបចំ យ៉ាងសកម្មជាប់ ជានិច្ច មិនដេកចាំមានការដាស់តឿន ឬដេកចាំតែមធ្យោបាយ ពីថ្នាក់លើឡើយ ។




## ៤.គុណសម្បត្តិ និងទឹកចិត្តរបស់កម្លាំងអ្នកស្នេហាជាតិខ្មែរ

- ***ទឹកហូរពីទីខ្ពស់ទៅទីទាប*** តាមក្បួនមួយ យ៉ាងជាក់ច្បាស់ ក៏ដូចជា កំលាំងខ្មែរអ្នកស្នេហាជាតិ ក្នុងសកម្មភាព របស់ខ្លួន ត្រូវតែគោរព "គោលមាគ៌ា ឬនយោបាយរួម យុទ្ធសាស្រ្តរួមតែមួយ និងប្រកាន់ខ្ជាប់នូវក្បួនតម្រាសឹក និងការដឹកនាំ ត្រឹមត្រូវ" ក្នុងការរៀបចំ និងការធ្វើសកម្មភាព ដូចជាសិល្បសង្គ្រាម របស់ "ស៊ុន ស៊ូ" ជា ដើម ដើម្បីឱ្យបាន លទ្ធផលល្អ ដូចទឹកហូរ ពីខ្ពស់ទៅទាប ។

- ***ទឹកហូរពីទីខ្ពស់ទៅទីទំនាប ចូលថ្លុក ចូលស្ទឹង ចូលទន្លេ ចូលសមុទ្រ*** តែថ្លុក ស្ទឹង ទន្លេ និងសមុទ្រ មិនដែល ដង្ហើយហៅទឹកឱ្យហូរចូលឡើយ ក៏ដូចជាកំលាំងខ្មែរអ្នកស្នេហាជាតិ ត្រូវតែស្វះស្វែងរាប់រកអ្នកស្នេហាជាតិ ដូចគ្នា មិនចាំបាច់ ដេកចាំគេពន្យល់អង្វរ ឬសន្យាផ្តល់រង្វាន់ ជ័យភ័ណ្ឌណាមួយឡើយ ។ ផ្ទុយទៅវិញ ថ្លុក ស្ទឹង ទន្លេ និងសមុទ្រ មិនដែលប្រកែក មិនទទួលទឹកឡើយ ។ អ្នកស្នេហាជាតិខ្មែរ តែងតែប្រកាន់យក ឧត្តមគតិ បំរើ ជាតិ ជាពិសេសប្រជាជាតិខ្មែរ ដែលកំពុងរងទុក្ខ វេទនា ត្រូវតែរិះរកវិធីជួយកែខៃ ដោយមិនដេកចាំអោយពលរដ្ឋទាំងនោះរត់មករកយើងឡើយ ។ *អ្នកដឹកនាំខ្មែរត្រូវតែស្វះស្វែងរកអ្នកជាតិនិយមនានា ប្រជាជាតិខ្មែរ ដែល រងទុក្ខទោស ប្រជាជាតិនានាដែលរងគ្រោះ* ដោយសារ យួន និងពួក អាយ៉ង

ក្បត់ជាតិ និងអ្នកទាំងឡាយ ដែលមាននិន្នាការនយោបាយដូចយើង មានសមានចិត្តទទួលយើង ដោយក្តីពេញចិត្ត ហើយអ្នកទាំងនោះហើយ ដែលជួយលាក់ ការពារយើង ផ្តល់ពតិមាន រួមកំលាំងជាមួយយើង ក្នុងការផ្តួលរំលំពួកក្បត់ ជាតិ។

- ***ទឹកមានគោលដៅតែមួយ ហូរចូលទៅក្នុងសមុទ្រ*** ។ សមុទ្រ ជាគោលដៅតែមួយ របស់ទឹក ។ យ៉ាងណាមិញ ***គោលដៅតែមួយគត់ របស់អ្នកដឹកនាំខ្មែរ គឺការរំដោះជាតិឱ្យរស់រានគង់វង់ របស់ប្រជាជាតិខ្មែរ ប្រទេសខ្មែរ ឯករាជ្យ ឥស្សរៈ ប្រកបដោយ វិបុលភាព មានថាមពល រឹងប៉ឹងស្ថិតស្ថេរ និងមានឧត្តមភាព***។ ទោះជាស្លាប់ខ្លួនក៏អ្នកដឹកនាំខ្មែរមិនរួញរាមិនលះបង់គោលដៅ នេះដាច់ខាត។

- ***បើមិនទាន់ដល់គោលដៅ ទឹកស្នាក់នៅកន្លែងមួយ ដែលមានស្ថិរភាពជាទីបំផុត*** ក៏ដូចជាកំលាំងអ្នកស្នេហាជាតិខ្មែរ បើមិនទាន់រំដោះជាតិ និងប្រជាជាតិខ្មែរបានទេ ការប្រឹងប្រែង ការរៀបចំ ការរស់នៅ និងសកម្មភាព ត្រូវធ្វើឱ្យមាន សន្តិសុខ ជាអតិបរមា។ ក្នុងកាលៈទេសៈ តស៊ូ យើងរមែងជួបនូវ ឧបសគ្គស្លាប់រស់ រាប់មិនអស់ ។ ហេតុនេះហើយ រមែងមានការបែកបាក់ ការបរាជ័យ ខ្លះដោយជៀសមិនរួច ជាហេតុធ្វើអោយដាច់ រយះទាក់ទងគ្នា រវាងខាងលើ និងខាងក្រោម នៅពេលណាមួយ។ តែក្នុងឋានៈជាអ្នកដឹកនាំខ្មែរ មិនត្រូវអស់សង្ឃឹម មិន ត្រូវចុះញ៉ូមបោះបង់ការតស៊ូ ឡើយ។ ផ្ទុយទៅវិញ ត្រូវចេះរក្សាឥស្សរភាពខាងស្មារតី គឺត្រូវចេះរស់ ចេះលាក់ខ្លួន ចេះសន្សំកំលាំង ចេះការពារកំលាំងអោយគង់វង់ ចេះរៀបចំកំលាំង រង់ចាំពេលវេលា ដែលអ្នកជាតិនិយម នានា មកធ្វើការរួបរួម ផ្គុំគ្នាឡើងវិញ ដើម្បីបន្តការតស៊ូ ឆ្ពោះទៅរកជោគជ័យ។

- ***ទឹកហូរចេញ ពីកន្លែងមួយ ទៅកន្លែងមួយ ទាល់តែមានជីជរ*** ។ បានន័យថា ទឹកតែងតែ ដើរទៅសត្រូវ ដែលមានចំណុចខ្សោយ តែ ទឹក មិនដើរទៅរកសត្រូវដែលដឹងខ្លួនប្រុងប្រយត្ន័ឡើយ។ ដូចបានពោលមកហើយថា ទោះជាខ្មាំងធំប៉ុណ្ណារមែងមានចំណុចខ្សោយ ចំណុចប្រហោងជាដាច់ខាត។ ការរស់ ការលាក់ខ្លួន មិនត្រូវដេក លាក់ខ្លួន ដោយអស់សង្ឃឹម ឬដើម្បីស្លាប់ឡើយ តែលាក់ខ្លួន ដើម្បីសិក្សារកចំនុចខ្សោយខ្មាំង ដោយប្រុងប្រយត្ន័ ហើយបន្តធ្វើ សកម្មភាពតស៊ូ ធ្វើការរៀបចំទៅមុខទៀត ដោយការភ្ញាក់រលឹក និងទទួលខុសត្រូវខ្ពស់ សមឋានៈជាអ្នកដឹកនាំខ្មែរ។ អ្នកដឹកនាំខ្មែរ ត្រូវសិក្សារកអោយឃើញចំណុច ខ្សោយរបស់ខ្មាំង ហើយធ្វើការវាយប្រហារនៅទីនោះ តាមពេលវេលាមួយសមគួរ និងមានសន្តិសុខដល់ខ្លួន និងមិត្តរួមអាវុធ។ ពោលគឺ ពេលវេលា ដែលខ្មាំង ភ្លេចខ្លួន គ្មានការប្រុងប្រយត្ន័ ដោយអនុវត្តន៍ តាមក្បួនគំរា និងកលយុទ្ធកងទព័យ៉ាងត្រឹម ត្រូវ មិនប្រមាថ។ ធ្វើបែបនេះ យើងតូចតែអាចទទួលជោគជយ័បានយ៉ាង ប្រាកដ។

- ទឹកអាចដូរភាវៈក្តៅ និងភាពត្រជាក់ ជាមួយអ្នកជិតខាង ក៏ដូចជាកំលាំងអ្នកស្នេហាជាតិខ្មែរ ត្រូវចេះវែកញែកស្គាល់ ឱ្យច្បាស់រវាងសត្រូវ និងមិត្ត។ កំលាំងអ្នកស្នេហាជាតិខ្មែរ ត្រូវចេះលាក់ខ្លួន សំរបខ្លួន បន្លំខ្លួន ទៅតាម ពេលវេលា តាមទីកន្លែង ដើម្បី ធ្វើអោយខ្លួនរស់ នៅធ្វើសកម្មភាពបាន។ ត្រូវដឹងឱ្យច្បាស់ថា ត្រូវរួបរួមជាមួយ មិត្ត អ្នកជាតិនិយមដូចគ្នា មិនវាយប្រហារគ្នា ទោះដោយសំដីក្តី ជួយគ្នាទៅវិញទៅមក មិនគិតផលប្រយោជន៍ តែត្រូវចំពោះសត្រូវត្រូវរិះរកវិធីបំផ្លិចបំផ្លាញវាតាមគ្រប់មធ្យោបាយ ដែលអាចធ្វើបាន ដោយស្ងាត់កំបាំង មិនអួតអាង មិនចេញមុខ។

- ទឹកអាចស្រោចស្រង់ ឬអាចកំទេចអ្នកជិតខាង តាមយុទ្ធសាស្ត្រ រយៈវេលា *យូរ ស្ងាត់កំបាំង* (ជ្រាប) ឬ *ឆាប់*

*វាយលុក* ( ហូរ-លិច) ឬ អហឹង្សា ( ជ្រាប) តាមភាពហឹង្សា ( ហូរ-លិច) ក៏ដូចជាកំលាំងអ្នកស្នេហាជាតិខ្មែរ ត្រូវស្គាល់ និង អនុវត្តន៍ទៅតាមដំណាក់កាលនៃការតស៊ូរបស់ខ្លួន ដោយមិនល្បើង ពោលគឺ នៅពេលដែលខ្លួន កំពុងរៀបចំ ត្រូវប្រឹងប្រែងធ្វើ អោយអស់សង្ឃឹម មិនចាំការដាស់តឿន។ ឬក៏នៅដេកចាំមើល ទាល់តែ ឬសូរ ក្នុងក្នាំង ទើបមាន ទឹកចិត្តប្រឹងធ្វើ ប្រឹងរៀបចំ នោះឡើយ។ ប្រើយុទ្ធសាស្ត្រ ប្រើកលល្បិច ប្រើការបិទបាំង នៅគ្រប់ៗជំហ៊ាន គ្រប់ពេលវេលា ដើម្បីសំងំនៅ ធ្វើការរៀបចំ អោយបាន និងត្រៀមខ្លួនប្រយុទ្ធ ពេល ឱកាស គ្រោងទុក បានមកដល់ ក្នុងការជួយស្រោចស្រង់ប្រជាជាតិ ជាតិ និង កំទេច សត្រូវអោយបានជាអតិបរមា ទាំង ខាងកំលាំង នយោបាយ ចិត្តសាស្ត្រ និងធនធាន។

### ៥-ចរិតភាពរបស់ទឹក

- នៅពេលណា ទឹកទំលាយទំនប់មួយបានហើយ វាមិនដែលនៅចាំទទួលជ័យភ័ណ្ឌណាមួយឡើយ វាតែងតែរុល តំរង់ទៅគោលដៅជានិច្ច។ អ្នកដែលទទួលជ័យភ័ណ្ឌមុនគេ គឺ មច្ឆាជាតិ ខ្យង ក្តាម ដែលគេមិនអាច឴ ឃាយ៉ាំង បានឡើយ។
- គុណបំណាច់របស់អ្នកស្នេហាជាតិ បានយ៉ាងបរិបូរណ៍ ចាប់ពីពេលណាដែលការតស៊ូបានសំរេចជោគជ័យ រហូត ដល់អវសាន នៃជាតិសាសន៍ខ្មែរ ដូចជាទឹកបានគុណបំណាច់របស់គេ នៅពេលណាដែលខ្លួនបានទៅដល់សមុទ្រ ដូច្នោះដែរ។
- គុណបំណាច់របស់អ្នកស្នេហាជាតិ មិនមែនជាសំភារ:ដែល ÷
    - បានមកអំពីការរំលោភអំណាច ប្រព្រឹត្តិអំពើពុករលួយ លួចជាតិ នោះឡើយ។
    - បានមកពីការដណ្តើម ឬលួចប្លន់ ពីប្រជាជាតិខ្មែរឡើយ។
    - បានមកពីការលក់សម្បត្តិជាតិ លក់ជាតិ ឬ លក់ក្បាល ជាកញ្ជះបរទេស នោះទេ។

- គុណបំណាច់ របស់អ្នកស្នេហាជាតិខ្មែរ មាន "សំភារ:" " កិត្តិយស " និង" ជីវិតរស់នៅប្រសើរ" បានមកពីការ ស្រឡាញ់ ការតបស្នង ពីសំណាក់ជាតិ និងជនរួមជាតិខ្មែរ ដែលមានការអបអរសាទររីករាយ និងផ្តល់ជូនជា ការតបស្នងសង គុណ សក្តិសមទៅនឹង វិរភាព គុណបំណាច់ របស់យើងជាអ្នកបំរើជាតិអស់មួយជីវិត។ កិត្តិនាម កិត្តិសព្ទ របស់អ្នកស្នេហាជាតិ ត្រូវចារ នៅលើសិលាចារឹក និងក្នុងក្រាំងមាសប្រវត្តិសាស្ត្រ និងអារ្យធម៌ខ្មែរ។ ដូចមាន សិលាចារិកនានា ជាឧទាហរណ៍ស្រាប់ ដែលចាររៀបរាប់ពី វីរភាព របស់ ជ័យវរ្ម័នទី៧ និងអស់លោក ជាមេទ័ពជាដើម។ ឬក៏ដូចជាកេរ្តិ៍ឈ្មោះ របស់វិរជន ជាច្រើន មានឧកញ៉ា ស៊ឺន គុយ, ក្រឡាហោគង់, ហែម ចៀវ, ស៊ឺង ង៉ុកថាញ់ ជាដើម។ល។ បើទោះជាត្រូវពួកមេត្រួតត្រាបង្គាបបង្អោន តែខ្មែរសម័យក្រោយនៅតែ គ្រោក ការពារលើកដំកើងជាប់រហូតមក។

### ៦-កំលាំងខ្មែរអ្នកស្នេហាជាតិពិតប្រាកដ

*ទឹកស្គាល់ ទឹកឯទៀត ដោយសារ លក្ខណ:របស់ខ្លួន ជាពិសេសវាមាន "ទំង់" ដូចគ្នា ប្រេងអណ្តែតលើទឹក ចំណែក ទឹក ធ្លាក់ចុះក្រោម* ។

អ្នកស្នេហាជាតិខ្មែរ មានអត្តសញ្ញាណរបស់ខ្លួន ជាសំគាល់។ គុណសម្បត្តិ គុណធម៌ ការព្យាយាម វិរកម្ម និង ឥរិយា បថ ទំលាប់ប្រចាំថ្ងៃ យ៉ាងស្មោះស្មើ មិនលះបង់ មិនប្រែប្រួល ជាលក្ខណ:សំគាល់របស់ជន ដែលអ្នកស្នេហាជាតិពិតប្រាកដ។ បើ ទោះជា សត្រូវជ្រៀតចូលក្នុងរង្វង់ អ្នកស្នេហាជាតិក្តី តែដោយសារវា មិនមានលក្ខណ: ពិសេសដូចខាងលើ ដែលដុះ ចេញ

ពីចិត្តគំនិត ពីស្មារតីពិត ពីខាងក្នុងទៅនោះ និងធ្វើអោយយើង សង្កេតឃើញ វាអណ្តែតធ្លោរឡើងខុសធម្មតា ដូចដុំឈើជ្រមុជក្នុងទឹក តែងតែអណ្តែតភ្លាមឡើងដែរ ឬដូចជា ដុំថ្ម ដែលតែងលិចចុះស្រឹមទៅក្នុងទឹកយ៉ាងដូច្នោះដែរ។ ដូចគ្នាដែរ បើទោះពួកសត្រូវ ទោះវាខំក្លែងខ្លួន ធ្វើឱ្យមានលក្ខណៈ ដូចអ្នកស្នេហាជាតិយ៉ាងណាក្តី ក៏ "ទំងន់ទឹកចិត្តស្នេហាជាតិ " របស់វាមិនអាចមានទំងន់ ប្រៀបស្មើ នឹងអ្នកស្នេហា ជាតិបានឡើយ។ ពេលណា វាបន្លំធ្វើជាមានការឈឺចាប់ នោះការឈឺចាប់របស់វាមានទំងន់ ស្រាលជាងការឈឺចាប់ របស់អ្នកស្នេហាជាតិខ្លាំងណាស់ ដូច្នេះ យើងនឹងអាចសង្កេតឃើញ វាលេចធ្លោមកយ៉ាង ច្បាស់ក្រឡែត ឡើងដូចប្រេង រមែងអណ្តែតលើទឹកយ៉ាងដូច្នោះដែរ។ ឬផ្ទុយទៅវិញ បើ វាបន្លំធ្វើ ជាមានការឈឺចាប់ ក៏លក្ខណៈ នៃការឈឺចាប់របស់វា មានភាព ធ្ងន់ ខ្លាំងហួសហេតុ ហើយយើងនឹងអាច សង្កេតឃើញ យ៉ាងច្បាស់ ក្រឡែត ដោយសារ វាធ្លាក់ចុះក្រោម ដូចដីនៅក្នុងទឹក។ កាលណា វាចង់ត្រាប់តាម អ្នកស្នេហាជាតិ ឱ្យដូចបេះបិតនោះ វាត្រូវតែខំប្តូរ ទំងន់ ស្នេហាជាតិ របស់វា ម្តងមាន ទំងន់ ធ្ងន់ ម្តងស្រាល ម្តងខ្លាំង ម្តងខ្សោយ ហើយម្តងធ្លាក់ទំងន់បន្តិច និងម្តងទៀតឡើងខ្ពស់បន្តិច យើងអាចនិងសង្កេត ឃើញលេចធ្លោរ ដោយមាន ហេតុមិនទៀងទាត់ មិនប្រក្រតី ខុសពីធម្មតា កើតមានឡើង ដូចជាទឹកវិលវល់ ល្អក់កករ មានពណ៌ប្លែកពីធម្មតា។

អ្នកស្នេហាជាតិពិតប្រាកដ រមែង ប្រកាន់ខ្ជាប់ការខ្វល់ខ្វាយ ចំពោះជោគវាសនា របស់ប្រទេសជាតិ ប្រជាជាតិ យ៉ាងស្មោះស្មើ តាមទិសដៅរួម ដែលបានកំណត់ ក្នុងការរំដោះជាតិ ដោយមិនប្រែប្រួល ម្តងឈប់ម្តងធ្វើ ម្តងទៅមុខម្តងទៅក្រោយ ម្តងចូល ខាងនេះ ខាងនោះ និងមិនលះលែង បោះបង់ចោល ឬក៏ដាក់ធុរៈ ដើម្បីឆក់យកប្រយោជន៍ផ្ទាល់ខ្លួន ក៏ទេដែរ មិនថា កាលៈទេសៈ ណាឡើយ។ គ្រប់ឥរិយាបថ សកម្មភាព ដេក ដើរ ឈរ អង្គុយ ស៊ីចុក ទាំងការគិត ការដើរហើរ និយាយស្តីរមែងរិះរក បង្កើតឱកាស ធ្វើការតស៊ូរំដោះជាតិ ជួយជាតិ និងប្រជាជាតិ ជានិច្ច មិនថាខ្លួននៅទីណា ត្រូវរងនូវការតាម កាប់សំលាប់ពីសំណាក់ ចោរយួន និងពួកក្បត់នោះយ៉ាងណាក្តី។ ទំងន់ ទឹកចិត្តស្នេហាជាតិ តែងមានទំងន់ ស្មើ មិនស្រកស្រុត មិនល្បៀងខុស ឬត្រូវប្រែប្រួលដោយសារ បរិយាកាសជុំវិញខ្លួន ឬកត្តាផ្សេងៗសោះឡើយ។ ដូចមានកំណាព្យខ្មែរអ្នកស្នេហាជាតិបានពោលទុកថា "

| | | |
|---|---|---|
| **-ចិត្តខ្មែរជាតិនិយម** | **ធំជាងភ្នំ រឹងជាងថ្ម** | **ទោះខ្លួននៅក្នុងឃ្នៀប** |
| **ខ្ទោះកកៀបហៀបប្រហារ** | **ចិត្តនៅរឹកដូចថ្ម** | **ប្តូរជីវិតជ្បិតស្នេហ៍ជាតិ។** |
| **-បិទភ្នែកទទួលយក** | **រាល់ទុក្ខសោកបោកបក់ចំ** | **ទោះទុក្ខធំជាងភ្នំ** |
| **ខំមាត់ទ្រាំខំពុះពារ** | **យកឈាមក្រាលប្រថពី** | **ដើម្បីខ្មែររស់គង់វង្ស។** |

## ៧_យុទ្ធសាស្ត្ររបស់ទឹកនៅក្នុងការប្រយុទ្ធ

- មុននិងចាប់ផ្តើមប្រយុទ្ធ ទឹកតែងតែប្រឹងប្រែង ហូរ ជ្រាប ដោយស្ងាត់ស្ងៀម ដោយព្យាយាម មិនឈប់មិនឈរ មិនថា យប់ថ្ងៃ ទៅផ្តុំគ្នា នៅកន្លែងមួយ ដែលមានលំហ៊ឹង ជាទីបំផុត ដែលជាកន្លែងអាចទទួលយកទឹកហូរ មក ពីគ្រប់ ទិសទីគ្រប់ច្រក ពោលគឺ ទឹក ខិតខំរៀបចំឱកាស របស់ខ្លួនដើម្បីយកប្រៀបលើសត្រូវ តែទឹកមិនដែល ដេកចាំឱកាសសោះឡើយ។ ដូចគ្នាដែរ កំលាំងអ្នកស្នេហាជាតិខ្មែរ មុននឹងមានលទ្ធភាព រំដោះជាតិបាន មិន ត្រូវដេកស្ងៀម ចាំឱកាសឡើយ។ ព្រោះថា "***ឱកាសកើតមានដោយការប្រឹងប្រែងរៀបចំ***" មិនមែនកើតឡើង ដោយការដេកចាំឡើយ។ ហេតុនេះ អ្នកដឹកនាំខ្មែរ តែត្រូវប្រឹងប្រែប្រមូលផ្តុំកំលាំងស្នេហាជាតិពីគ្រប់ទីសទី ដោយការធ្វើអោយស្មារតីជាតិនិយម ដុះដាល រីកសុះសាយ ជ្រួតជ្រាបក្នុង

ចិត្តគំនិត អារម្មណ៍ខ្មែរគ្រប់ស្រទាប់ និងទៅក្នុងថ្លុក ក្នុងស្ទឹងគំនិតរបស់ក្រុមអ្នកជាតិនិយមខ្មែរ គ្រប់ទីកន្លែងយ៉ាងសកម្មដោយ មិនឈប់មិនឈរ មិនដេកស្ងៀម ទៅតាមពេលវេលាដែលខ្លួនអាចធ្វើបាន មិនថាយប់ថ្ងៃឡើយ។

- មុននិងទឹកទំលាយទំនប់មួយបាន មុនដំបូងទឹកចូលជ្រាបបន្តិចម្តង១ នៅគ្រប់កន្លែងទាំងអស់ របស់សត្រូវ ដែលវាអាចហូរចូលទៅបាន។ ការជ្រាបនេះ ទុកជាគេមើលឃើញ ក៏គ្មាននរណាយកចិត្តទុកដាក់ដែរ ដោយសារគ្មាន គ្រោះថ្នាក់ដល់គេ។ កាលណាមានប្រភពទឹកជ្រាប មានឬសឈើ មកតាមដោយគ្មាននរណាដឹង ក្រៅពីឬសឈើ ខ្លួនឯង ពីព្រោះឬសឈើត្រូវការទឹក។ កាណាមានឬសឈើ ជ្រៀតជ្រែកខ្លាំង ទឹកជ្រាបក៏កាន់តែខ្លាំង រហូតដល់ ទឹកហូរបាន។ កាលណាទឹកហូរបាន ទឹកវារំលាយដុំដីតូចធំបានតាមកំលាំងវា ដែលនាំឱ្យមានផ្លូវទឹកហូរ កាន់តែធំ ឡើង១ ។ កាលណា ផ្លូវទឹកកាន់តែធំឡើង១ កំលាំងទឹក វារំលាយដុំដីកាន់តែធំឡើង១ រហូតដល់ទីបញ្ចប់ទឹក ទំលាយទំនប់មួយបាន។ ចូរចាំថា ប្រជាជាតិខ្មែរភាគច្រើនលើសលប់ ដេកទន្ទឹងដង្ហើយរកអ្នកស្នេហាជាតិខ្មែរ ដើម្បីជួយសង្គ្រោះ។ យើងត្រូវចាំថា យើងមិនអាចទូលផែនដីតែម្នាក់ឯងបានទេ ហេតុដូច្នេះហើយយើង ត្រូវតែស្វះស្វែង ប្រកូកប្រកាសរកខ្មែរ ដែលជាម្ចាស់ទឹកដី រួបរួមគ្នាជួយ។ ហេតុនេះ មុននឹងអាចរំដោះជាតិបាន យើងជាអ្នកដឹកនាំខ្មែរ ត្រូវតែកាត់ទៅរកព្យាយាមទៅជួបចងក្រង អ្នកទាំងនោះ ជាក្រុម ជាពួក ជាកំលាំង ជាតិ។ ព្រោះថា កំលាំងស្នេហាជាតិ បើទោះជាមានច្រើនប៉ុណ្ណា បើនៅទីទៃ មិនចងបាច់គ្នាទេ នឹងមិនអាចកើត ជាកំលាំងចលករដ៏មាន អនុភាព អាចរំលាយ ពួកខ្មាំងសត្រូវរបស់ជាតិបានឡើយ។ ដូច្នេះហើយ ការប្រើប្រាស់ កំលាំងខ្មាំងជាការសំខាន់បំផុត។ នៅក្នុងជួរខ្មាំង ក៏មានអ្នកដែលមានគំនិតជាតិនិយម ដែរ តែជាអ្នកជាតិនិយម ស្ទាក់ស្ទើ ហើយយើងជាអ្នកដឹកនាំជាតិខ្មែរ មិនអាចធ្វើបានគ្រប់ច្រកល្ហកបានឡើយ។ ក៏ប៉ុន្តែ យើងអាចប្រើ ប្រាស់ ប្រជាជាតិខ្មែរ ដែលយើង បានចងក្រង ហើយដែលជាសាច់ឈាមអោយទៅទាក់ទង បញ្ចុះបញ្ចូល ជាមួយពពួកអ្នកជាតិនិយមស្ទាក់ស្ទើទាំង នោះ ដូចទឹក ដែលប្រើឬសឈើ អោយជួយ ជ្រៀតជ្រែកហូរបុកជំនួស ជាប់ជានិច្ចដូច្នោះដែរ។

- នៅពេលណាទំនប់រឹងមាំ ទឹកទំលាយទំនប់មួយមិនបាន វាមានយុទ្ធសាស្ត្រមួយទៀតហូរកាត់ពីលើ។ កាណាទឹកហូរកាត់ពីលើបាន ទីបញ្ចប់ទឹកទំលាយទំនប់មួយបានដូចគ្នា។ យ៉ាងណាមិញ ភាពរឹងក្រៅប្រហោងក្នុងរបស់ របបត្រួតត្រា មិនអាចទប់នឹង សមុទ្រទឹកចិត្ត ជាតិ និយម ដែលដុះដាលភ្ញាក់រលឹករបស់ខ្មែរគ្រប់រូបពាសពេញ ប្រទេសបានឡើយ នៅពេលណាដែលកំលាំងស្មារតីជាតិនិយមជ្រួតជ្រាប ប្រមូលផ្តុំបានយ៉ាងមហាសាល ហើយនោះ។ របៀបនេះ ខ្មែរយើងធ្លាប់បាន ជោគជ័យពីសម័យ ទ្រៀង មិញយ៉ាង ម្តងហើយ។

- ទឹកប្រើយុទ្ធសាស្ត្រ ដែលវាយសំរុកដោយផ្តុំកំលាំង (Concentration) បាញ់ឆ្ពោះទៅលើចំណុចខ្សោយជាង គេរបស់គូសត្រូវ។ អ្នកដឹកនាំជាតិខ្មែរ ត្រូវស្វះស្វែងរកចំណុចខ្សោយខ្លាំងទាំងខាង នយោបាយ កងទ័ព សង្គមជំនឿសាសនាដែលខ្លាំង បានអនុវត្តនីសព្វថ្ងៃ ហើយប្រៀបធៀប រិះរកចំណុចខ្សោយខ្លាំងបំផុតរបស់ខ្មាំង និប្រមូលផ្តុំធនធាន ដែលមាន ផ្តោតទៅលើចំណុចខ្សោយនោះអោយបានជោគជ័យ។ មិនត្រូវជួយធ្វើអោយរបបក្បត់ ត្រឹមត្រូវ។ មិនត្រូវធ្វើអោយវាមានកំលាំង មិនត្រូវធ្វើអោយវា ស្របច្បាប់ មិនត្រូវលើកទឹកចិត្តពួកវា និងមិនត្រូវដើរតាមគន្លងយុទ្ធសាស្ត្រ វាគូសអោយយើងដើរ។ យើងដឹងហើយថា យួន វាធ្លាប់រុញច្រានអោយមហាអំណាចអាមេរិក ដែលប្រើប្រាស់ទាំង នយោបាយ កងទ័ព អោយដាច់ផ្ងាទៅវិញ ។ ហើយយើងក៏ គួរតែដឹងថាយួន ហ៊ុន សែន វាដឹងច្បាស់ថា គណបក្សប្រឆាំងទាំងអស់ សុទ្ធតែមានបំណងផ្តួលរំលំវា បើ

វាយល់ថា បក្សទាំងនោះ អាចរំលំវាបាន វានឹងអោយបក្សទាំងនេះ កើតឡើយ ។ តើមានប្រយោជន៍អ្វី ដែលអ្នកជាតិនិយមខ្លះ បោលក្បាលសំរុក ទៅសុំអនុញ្ញាតពីមេត្រួតត្រា ដើម្បីបង្កើតបក្សប្រឆាំង រាប់មិនអស់នោះ វាគ្រាន់តែជាការ បំផ្លាញ់នូវធន ធាន មានតិចតួច មិន ចំគោលដៅតែប៉ុណ្ណោះ ។

- ទឹកនៅអាចកាត់ដែក ឬ ឈើបាន នៅពេលណាទឹកមានសំពាធ នៅពីក្រោយខ្លាំង និងមានច្រកចេញតូច ។ អ្នកដឹកនាំខ្មែរ តោងយល់ច្បាស់ថា យើងប្រាកដជាផុតពូជ នៅគ្រាខាងមុខមិនយូរឡើយ បើយើងមិនហ៊ាន ក្រោកឡើងដឹកនាំ ធ្វើការតស៊ូនោះ ។ ឯការតស៊ូរបស់យើង ជាការតស៊ូដោយត្រឹមត្រូវ ស្របច្បាប់ យើងមាន បុព្វសិទ្ធពេលលេញ ក្នុងការធ្វើ ដោយមិនដេកចាំជំនួយពីណាក្រៅពីកំលាំងសាមគ្គីជាតិខ្មែរឡើយ ហើយការតស៊ូ របស់យើងប្រាកដជាឈ្នះ ។ ហេតុនេះហើយ យើងតោងធ្វើអោយអ្នកស្នេហាជាតិទាំងអស់យល់ច្បាសដូច ជាមុនថា ជំរើសរបស់យើងជាជំរើសត្រឹមត្រូវ ប្រកបដោយសីលធម៌ ដែលមនុស្ស លោកទាំងអស់នឹងគាំទ្រ យើង ។ យើងគ្មានជំរើសផ្សេងឡើយ ក្រៅពីការក្រោក ឡើងរួមធ្វើការតស៊ូដោយភាពថ្លៃថ្នូរ ក្នុងការកំចាត់ សត្រូវ ដោយប្រើគ្រប់មធ្យោបាយ ទាំងអស់ ទាំងអហិង្សា និងហិង្សានយោបាយ រួមផ្សំគ្នា ។

- ទឹកនៅក្នុងសមុទ្រ មានកំលាំងខ្លាំងខ្ទេរឡើង នៅពេលណាមាន( កត្តាក្រៅ)ខ្យល់ព្យុះ ឬមានរំជួយដីនៅក្រោមសមុទ្រ ។ តាមធម្មតា ទឹកនឹងក្លាយទៅជាកំលាំងយ៉ាងមហិមា គ្មានអ្វីមកទប់បាន នៅពេលណា មានកត្តា ក្រៅមកជាជំនួយ ។ ប្រជាជាតិ ដែលស្នេហាសន្តិភាព មនុស្សភាពក្នុងភាពថ្លៃថ្នូរ នឹងមិននៅស្ងៀមឡើយ បើខ្មែរក្រោកឡើង រួបរួមគ្នាធ្វើការតស៊ូ យ៉ាងម៉ឺងម៉ាត់ស្វិតស្វាញ ហើយដោយការជួយជ្រោមជ្រែងឈឺឆ្អាលពីអន្តរជាតិ និងអ្នក ស្នេហាសន្តិភាពជុំវិញពិភពលោក នឹងធ្វើអោយ សមុទ្រស្មារតីជាតិនិយមរបស់ខ្មែរ នឹងខ្លាំងខ្ទេរឡើងយ៉ាង ខ្លាំង មហិមា ដ៏ពិតប្រាកដ ហើយពេលនោះហើយ ដែលយើងអាច វាយរុញច្រានចោរ យួន នឹងពួកក្បត់បាន ។

## ៨-យុទ្ធសាស្ត្ររបស់ទឹកនៅក្នុងការការពារខ្លួន

- កាលណាទឹកនៅមានចំនួនតិចតួច វាតែងតែជ្រៀតខ្លួននៅក្នុងដី នៅក្នុងដើមឈើ នៅលើស្លឹកឈើ ។ នៅពេលណា វាមានចំនួនគ្រប់ល្មម វាតែងតែហូរផ្តុំគ្នាចូលទៅក្នុងថ្លុកមួយ ឬវាហូរជាផ្លូវទឹកនៅក្រោមដី ។ ពេលណាទឹកចូលក្នុង ថ្លុក ហើយ វាតែងតែចិញ្ចឹមដើមចកឱ្យដុះពាសពេញ សំរាប់ការពារខ្លួន ។ ចំណែកទឹកដែល ហូរចូលជាផ្លូវទឹក វាតែងតែហូរចូល ស្ទឹង ឬ ទន្លេ នៅក្រោមដី ។
- ទឹកនៅក្នុងថ្លុកនៅពេលណាមានអាសន្នវាបែកខ្ញែកគ្នា ( បើយើងដើរជាន់ទឹកថ្លុក ទឹកបែកខ្ចាយចេញពីថ្លុក)តែ វាហូរមកផ្តុំរកគ្នាជានិច្ចវិញ នៅពេលផុតពីអាសន្ន ។

## ៩-ទឹក និងសិល្បៈសង្គ្រាម "ស៊ុន ស៊ូ "

ស៊ុន ស៊ូ "ត្រូវធ្វើការសិក្សា និងពិនិត្យវិនិច្ឆ័យ នេះត្រូវធ្វើនៅលើកត្តាចំនួន ៥ ដែលមានឥទ្ធិពលលើទឹកចិត្ត ធាតុអាកាស ដី មេដឹកនាំ ទ្រឹស្តីនិងច្បាប់ ។

- ឥទ្ធិពលលើទឹកចិត្ត ទឹកត្រជាក់ត្រីកុម ( ទឹកជាទីសង្ឃឹម ជាជំរករបស់មច្ឆាជាតិទាំងឡាយ)
- ធាតុអាកាស ទឹកចាំកត្តាខាងក្រៅជានិច្ច ដែលសំរួលការវាយប្រហារ ( ខ្យល់-រញ្ជួយបាតសមុទ្រ)
- ដី ទឹកដក់នៅកន្លែងដែលមានសន្តិសុខសំរាប់វាជានិច្ច

- អ្នកដឹកនាំ ( ការប៉ិនប្រសប់របស់អ្នកដឹកនាំសង្គ្រាម ) ទឹកវាយប្រហារតែនៅលើចំណុចខ្សោយរបស់សត្រូវជានិច្ច
- ទ្រឹស្តី និង ច្បាប់ ទឹកតែងតែគោរពច្បាប់ធម្មជាតិជានិច្ច
    - ស៊ុន ស៊ូ " បើមានកម្លាំង ១០ ដង ច្រើនជាងសត្រូវ ត្រូវក្តោប បិទផ្លូវគ្រប់ច្រក "
    - ទឹក "មានកម្លាំងលើសលប់ ទឹកចូលលិចគ្រប់កន្លែង ទឹកគ្របពីលើ "
    - ស៊ុន ស៊ូ " បើមានកម្លាំង ៥ ដង ច្រើនជាងសត្រូវ វាយប្រហារគ្រប់ជ្រុង "
    - ទឹក " ហូរចូល ព័ទ្ធជុំវិញ "
    - ស៊ុន ស៊ូ "បើមានកម្លាំងស្មើនិងសត្រូវ ត្រូវញុះញង់ឱ្យមានការប្រយុទ្ធ "
    - ទឹក " ទឹកលលក បោកលើទំនប់ លើច្រាំង ជារៀងរាល់ពេលវេលា "
    - ស៊ុន ស៊ូ " បើមានកម្លាំងតិចជាងសត្រូវ ត្រូវមានការប្រុងប្រយ័ត្នកុំឱ្យមានការថ្លោះធ្លោយ គេចចេញពីការវាយ ប្រហាររបស់ខ្មាំង"
    - ទឹក "នៅក្នុងថ្លុក សំងំស្ងៀម អត់មានកំរើក និងមានចកគ្របពីលើ បិទបាំងថែមទៀត"

## ១០. ល្បិចដ៏ល្បីល្បាញនានានៅក្នុងសង្គ្រាម

### ក-សំលាប់សត្រូវ ដោយខ្ចីដាវគេ (ល្បិចទី៣ នៃល្បិចយុទ្ធសាស្រ្ត ទាំង ៣៦ របស់ចិនសម័យដើម)

*" ចំពោះសត្រូវ យើងជាក់ជាស្គាល់ច្បាស់អំពីបំណងរបស់វា ចំណែកឯការស្គាល់ច្បាស់អំពីបំណងរបស់ពួកសម្ព័ន្ធមិត្ត ជាការមិនប្រាកដ ។ យើងប្រើកលល្បិចឱ្យម្នាក់នេះ កំទេចម្នាក់នោះជួសយើង ដោយយើងមិនបាច់មានការប្រឡូកប្រឡាក់ជាមួយ។"*

គោលបំណងប្រឆាំងរបស់សត្រូវ ឃើញជាក់លាក់យ៉ាងប្រាកដ ។ ក៏ប៉ុន្តែ មានគូរប្រជែងមួយទៀត ចង់ចូលមកប្រឡូកជាមួយ ។ យើងត្រូវតែ " ខ្ចី " កំលាំងថ្មីនេះ ដើម្បីតទល់ប្រឆាំងនឹងសត្រូវ ។

ល្បិចដែលមានឈ្មោះថា " ខ្ចី " គឺ ជាការបង្វែរ យកកំលាំងអ្នកផ្សេងទៀត ឱ្យត្រឡប់ទៅប្រឆាំង និងសត្រូវរបស់យើង វិញ ។ ល្បិចនេះ គឺជាការសន្សំកំលាំងរបស់យើងជាអតិបរមា គឺ ជាគោលល្បិចក្នុង "សង្គ្រាមប្រជាជន" ដែល គេ ឃើញពួក "ឧទ្ទាមប្រជាជន" បំពេញសេចក្តីត្រូវការ ដោយការដណ្តើមយកអាវុធពីសត្រូវ ។

- អ្នកដែលមានកំលាំងមិនគ្រប់គ្រាន់ តែងតែ " ខ្ចី " កំលាំងសត្រូវ
- អ្នកដែលចង់សំលាប់គេ តែមិនអាចធ្វើទៅបាន តែងតែ " ខ្ចី " ដាវរបស់សត្រូវ
- អ្នកដែលខ្វះ ថវិកា តែងតែធ្វើឱ្យសត្រូវផ្តល់ឱ្យ ( វាយដណ្តើមយក ថវិការ ពីសត្រូវ ) ។
- អ្នកដែលខ្វះ សំភារៈ តែងតែទៅយកសំភារៈពីសត្រូវ( វាយដណ្តើមយក សំភារះ ពីសត្រូវ ) ។
- អ្នកដែលខ្វះ ស្បៀង តែងតែទៅយក ស្បៀង ពីសត្រូវ( វាយដណ្តើមយក ស្បៀង ពីសត្រូវ ) ។
- អ្នកដែលខ្វះ អាវុធយុទ្ធោបករណ៍ តែងតែទៅយក ពីសត្រូវ( វាយដណ្តើមយក អាវុធយុទ្ធោបករណ៍ពីសត្រូវ ) ។
- អ្នកដែលខ្វះនាយទាហ៊ាន តែងតែទៅរកពីខាងសត្រូវ ( បញ្ចុះបញ្ចូលយកទាហានសត្រូវ យកពលរដ្ឋដែលសត្រូវ គ្រប់គ្រង ) ។
- អ្នកដែលខ្វះល្បិច តែងតែលួចល្បិចពីខ្មាំង( លបសង្កេត និងត្រាប់យកល្បិចពីសត្រូវ )

## តើសេចក្តីទាំងនេះ មានន័យយ៉ាងណា?

- ការធ្វើឱ្យខ្មាំង ធ្វើអ្វីៗមួយ ដែលយើងចង់ធ្វើខ្លួនឯង នោះហើយដែលហៅថា " ខ្ចីកំលាំង " ខ្មាំង ។
- ការដែលធ្វើឱ្យ ខ្មាំង យល់ថា ត្រូវតែកំចាត់ដាច់ខាត អ្នកដែលយើងត្រូវការកំចាត់ នោះហើយជាការ " ខ្ចី ដាវ " សត្រូវ ។
- ការវាយដណ្តើមយក ថវិកា ទ្រព្យ ស្បៀង ពីខ្មាំង នោះហើយជាការដែលធ្វើឱ្យខ្មាំងផ្តល់ឱ្យ ។
- ការវាយ លួច ប្លន់ វាយយកអាវុធ សំភារៈ ពីដៃ របស់សត្រូវ ជាការ " ខ្ចី " សំភារៈរបស់ខ្មាំង ។
- ការធ្វើឱ្យវាមានការប្រេះឆាផ្ទៃក្នុង នោះហើយជាការ " ខ្ចី " នាយទាហានរបស់វា ។
- ការដែលបង្វែរយកយុទ្ធសាស្ត្ររបស់វា ប្រើជាសកម្មភាព បំផ្លាញវាវិញ នោះហើយជា ការ " លួច " យុទ្ធសាស្ត្ររបស់វា ។
- អ្វីៗដែលយើងមិនអាចអនុវត្តបាន ត្រូវតែធ្វើឱ្យនរណាម្នាក់ទៀត អនុវត្តជំនួស ។ យើងមិនមែនជាអ្នកធ្វើផ្ទាល់ដៃ ក៏គ្មានអ្វីជាសំខាន់ទេ ការសំខាន់ គឺ ការទទួលផលល្អ ពីអំពើនោះ ។
- យើងអាចធ្វើឱ្យខ្មាំងវា " ខ្ចី " អ្វីៗដែលយើងត្រូវការ ពីម្នាក់ទៀត ដើម្បីនឹងឱ្យយើងបាន " ខ្ចី " បន្ត ។
- ញ៉ាំងអោយវា ឱ្យវាទៅ " ខ្ចី " សំរាប់យើង ដោយមិនចាប់ភ្លឹក ឬបើសិនជាវាចាប់ភ្លឹក ក៏វាត្រូវតែធ្វើ ដោយសារវាគ្មានជំរើសផ្សេងក្រៅពីនេះ ។

សេចក្តីទាំងអស់នេះ ជាគោលសំខាន់ក្នុងល្បិច " ខ្ចីកំលាំងសត្រូវ " ដោយសារល្បិចនេះ " ស៊ីកុង " បានជួយស្រោចស្រង់ប្រទេស " លុយ " បានធ្វើឱ្យប្រទេស " គី " មានការលំបាក បានធ្វើឱ្យប្រទេស " វ៉ូ " ហិនហោចនិងជួយឱ្យប្រទេស " ជិន " ពង្រឹងជំហររបស់ខ្លួន ។

នៅដើមសតវត្សទី៥ ( ឆ្នាំ ៤៩០ ) មុន គ.ស. មន្ត្រី " ត្យាន ឆាង " រៀបចំធ្វើរដ្ឋប្រហារនៅក្នុងប្រទេស " គី " ។ ក៏ប៉ុន្តែ គាត់ត្រូវតែកំចាត់នាហ្មឺនប្រឆាំងមួយចំនួនជាមុនសិន ។ គាត់មានគំនិត និងកេណ្ឌកងទ័ពសំរាប់ធ្វើចំបាំងនឹង ប្រទេសជិតខាង ។ ប្រទេសដែលគាត់មើលឃើញថាមានប្រៀប និងយកជ័យជំនះបាន គឺប្រទេស " លុយ " ហើយគាត់ក៏ចាប់ ផ្តើម អុចអាល ។

ប្រទេស " លុយ " ជាប្រទេសកំណើតរបស់ " កុងហ្វុយស៊ីយុស " ដោយឃើញមហន្តរាយមកដល់ លោក " កុងហ្វុយស៊ីយុស " ក៏អំពាវនាវ សុំឱ្យកូនសិស្សរបស់លោក ធ្វើអន្តរាគមន៍ ដើម្បីស្រោចស្រង់ប្រទេស ឱ្យផុតពីមហន្តរាយនេះ ។ ក្នុងចំណោមសិស្សទាំងអស់ មាន លោក " ស៊ីកុង " ដែលមានថ្វីដៃជាងគេ ស្ម័គ្រចិត្តធ្វើអន្តរាគមន៍ ។

លោក " ស៊ី កុង " បានទៅប្រទេស " គី " សុំចូលធ្វើសវនាការជាមួយ លោក " ត្យាន ឆាង " ហើយគាត់ ក៏និយាយថា :

- *លោកមានកំហុសមួយយ៉ាងធ្ងន់ ដោយចង់វាយប្រហារលើប្រទេស " លុយ " ដោយសារប្រទេសនេះ ធ្វើអោយលោកមានការលំបាកយ៉ាងខ្លាំង ពីព្រោះទីក្រុងប្រទេស " លុយ " មិនមាំមួន មានទំហំតូច ស្តេចល្ងង់ និងកាច នាហ្មឺនពុករលួយ និងខ្វះសមត្ថភាព រាស្ត្រមិនចូលចិត្តធ្វើសង្គ្រាម លោកគួរតែវាយប្រហារប្រទេស " វ៉ូ " វិញ ។ ប្រទេស " វ៉ូ " វាជាបច្ចាមិត្តមួយសមនឹងសេចក្តីត្រូវការរបស់លោក ។ ទីក្រុងប្រទេស " វ៉ូ " មានកំផែងយ៉ាងមាំមួន មានដីធំ មានទាហានចំណានៗ មានស្បៀង និងសំភារៈគ្រប់គ្រាន់ មានអ្នកដឹកនាំ មានសមត្ថភាពសំរាប់ ការពារប្រទេសរបស់គេ ។ សង្គ្រាមជាមួយប្រទេសបែបនេះ ទើប*

*អាចសំរួលកិច្ចការ របស់លោកបាន ។*

លោក " ត្យាន ឆាង " គាត់ច្រឡោតខឹង

- *លោកមើលឃើញ ជាការងាយរបស់ដែលលំបាក ហើយលោកយកជាប្រភពនៃការលំបាក របស់ដែលភ្នែក គ្រប់ៗ គ្នា មើលឃើញថាងាយ ។ តើលោកឯងចង់និយាយប្រាប់ខ្ញុំយ៉ាងម៉េច?*

លោក " ស្ទី កុង " បានឆ្លើយតប

- *ខ្ញុំម្ចាស់ឮគេនិយាយថា បើជានយោបាយក្រៅប្រទេស របស់ប្រទេសមួយជាប្រភពនៃបញ្ហា វាជាការសមហេតុ សមផល និងបង្កសង្គ្រាមជាមួយប្រទេសខ្សោយ ។ តែបើបញ្ហា វាមកពីបញ្ហាផ្ទៃក្នុង គេគួរតែបង្កសង្គ្រាមជាមួយប្រទេសខ្លាំង ។ បើបញ្ហារបស់លោក គឺមកពីមន្ត្រីឯទៀត នៅតែបន្តប្រឆាំងនឹងលោក ។ បើលោកច្បាំងឈ្នះ ប្រទេស " លុយ " ប្រទេស " គី " ត្រូវបានពង្រីកទឹកដី ស្តេចរបស់លោក ក៏រឹតតែឡើងចាង អ្នកដែលបានទទួល កិត្តិយស គឺពួកនាយទាហានដែលជាបក្សពួក ប្រឆាំងនឹងលោក ។ ចំណែកលោក ខ្ញុំមិនឃើញថាបានចំណេញអ្វី ឡើយ ។ ផ្ទុយទៅវិញ អនុភាពរបស់លោករឹតតែចុះថយ ហេតុដូច្នេះហើយ បានជាខ្ញុំថា លោកគួរធ្វើសង្គ្រាមជា មួយ ប្រទេស " វូ " បានចំណេញ ច្រើនជាង ។*

*ប្រទេស " គី " ត្រូវចាញ់ជាការប្រាកដ ។ រាស្ត្ររបស់លោក ត្រូវស្លាប់ ក្រោមការវាយប្រហាររបស់សត្រូវ ។ ទ្រព្យ សម្បត្តិរបស់បក្សធំៗ ត្រូវហិនហោចដោយសារវៀបចំទ័ពរបស់គេ ។ លោកនឹងគ្មានអ្នកប្រឆាំងនឹងលោក នៅក្នុង ចំណោមអ្នក មានអនុភាព និងនៅក្នុងចំណោមប្រជាពលរដ្ឋ ហើយលោកនឹងក្លាយទៅជាអ្នកមានអំណាចតែម្នាក់ឯងនៅក្នុង ប្រទេស ។*

លោក"ត្យាន ឆាង " ឆ្លើយតប

- *ល្អ ! តែសង្គ្រាមជាមួយនឹងប្រទេស "លុយ " បានសំរេចចិត្តរួចហើយ ។ បញ្ជាឱ្យកងទ័ពថ្ងូរមុខព្រួញ និងនាំឱ្យ បច្ចាមិត្តដឹងខ្លួន តើត្រូវធ្វើយ៉ាងណា?*
- *ពន្យាពេលវាយប្រហារ។ "ស្ទី កុង " ឆ្លើយ ហើយសូមបញ្ជូនខ្ញុំជាការទូតទៅប្រទេស "វូ "។ ខ្ញុំនិងបង្ហាញ ហេតុផលទាល់តែគេទៅជួយសង្គ្រោះប្រទេស " លុយ " អោយមកវាយប្រហារប្រទេស " គី "។*

លោក "ត្យាន ឆាង " ទទួលយល់ព្រមតាមគំរោង ហើយលោក "ស្ទី កុង " ក៏ទៅប្រទេស "វូ " ។

ចំណែកប្រទេស "វូ " កំពុងតែរៀបចំការវាយប្រហារ ដើម្បីកំទេចជាស្ថាពរប្រទេស " យូ " នៅព្រំដែនខាងត្បូង ដោយសង្ឃឹមថា ម្តងនេះជាការសងសឹក និងភាពបរាជ័យ ដែលមានម្តងរួចមកហើយនោះ ។ ក៏ប៉ុន្តែ "ស្ទី កុង " គ្មានការពិបាក និងបង្ហាញហេតុផលដល់ស្តេចប្រទេស " វូ " ថាមានជ័យជំនះលើប្រទេស " គី " នាំឱ្យមានជំហរកាន់តែរឹង ប្រឆាំងនិងប្រទេស " ជិន " ដែលជាបច្ចាមិត្តសាហាវជាងគេ ។ ស្តេចប្រទេស " វូ " ក៏សុខចិត្តលើកងទ័ពទៅជួយសង្គ្រោះប្រទេស "លុយ " បើសិន ជាលោកមានការទុកចិត្តថា ប្រទេស "យូ " មិនវាយប្រហារប្រទេស "វូ"។ លោក "ស្ទីកុង" ក៏ទៅប្រទេស "យូ " ចចារជាមួយ ស្តេច "គួ ស្យង់" ហើយស្នើឱ្យពន្យាពេលវាយប្រហារ លើប្រទេស "វូ " ដោយចាំឱ្យប្រទេសនេះ ចុះខ្សោយនៅក្រោយ ចំបាំង ជាមួយប្រទេស "គី " ។ លោក "ស្ទី កុង " ទៅប្រទេស " ជិន " ដើម្បីប្រាប់បង្គាជាមុនថា នៅក្រោយជ័យជំនះលើប្រទេស "គី " ប្រទេស "វូ " ច្បាស់ជាបង្វែរការវាយប្រហារមកលើប្រទេសនេះមិនខាន ។

ប្រទេស "វៀ" តទល់ជាមួយប្រទេស " គី " ទុកឱ្យការប៉ុនប៉ងរបស់ "ត្យាន ឆាង " បានសំរេច។ ប្រទេស " ជិន " យកបានជ័យជំនះលើប្រទេស "វៀ " ដែលមានសង្ឃឹមថា ឆ្លៀតនៅលើជ័យជំនះទីមួយ សំរាប់កំទេចបច្ចាមិត្តទីមួយនេះចោល។ ប្រទេស "យូ " ឆក់យកឱកាសល្អនេះ សំរាប់វាយបង្ហើយដល់បច្ចាមិត្តស្លាប់រស់នេះ។

### -ទឹក និងល្បិច "សំលាប់សត្រូវ ដោយខ្ចីដាវគេ"

- ទឹក តែងតែ " ខ្ចី " កំលាំងខ្យល់ កំលាំងរញ្ជួយបាតសមុទ្រ សំរាប់វាយប្រហារ សត្រូវ។
- ដើម្បីបំបាក់ស្ពាន ទឹកតែងតែ " ខ្ចី " កំលាំងដើមឈើដែលអណ្តែតរសាត់តាមទឹក ដើម្បីបំបាក់ស្ពាន។
- ទឹកបានផ្តត់ផ្តង់ ក្តាម និង ខ្យង និងដើមឈើ ឱ្យបោះប្រហោង និងជ្រៀតទៅលើទំនប់

### -អ្នកស្នេហាជាតិខ្មែរ និងល្បិច "សំលាប់សត្រូវ ដោយខ្ចីដាវគេ"

ល្បិចនេះ ជាគោលល្បិចក្នុង " សង្គ្រាមប្រជាជាន " ដូច្នេះ យើងគួរកត់សំគាល់ថា តើគួរបដិបក្សណា ដែលត្រូវចូលប្រឡូក ក្នុងរឿងរំដោះជាតិ?

### -រឿងផ្ទៃក្នុង: សត្រូវចេញមុខ "របបខ្ញុំកញ្ជះបរទេស ពួកមេត្រួតមួយក្តាប់តូចនៃគណបក្សប្រជាជន"

ក្រុមដែលចង់ចូលប្រឡូកនៅលើឆាក

- គណបក្ស ហ្វ៊ុនស៊ិនប៉ិច
- គណបក្ស សមរង្ស៊ី
- គណបក្សរណរិទ្ធិ
- គណបក្សសិទ្ធិមនុស្ស
- ក្រុមពួកខ្មែរក្រហម
- ក្រុមឯទៀតៗ ដែលប្រកាសថា ជាអ្នកស្នេហាជាតិដែរ

### -រឿងខាងក្រៅ: សត្រូវចេញមុខ "ប្រទេសដែលលេបទឹកដីខ្មែរ យួន"

ក្រុមដែលចង់ចូលប្រឡូកនៅលើឆាក

- ប្រទេសជិតខាង
- ប្រទេសហត្ថលេខី នៃសន្និសិទ្ធទីក្រុងប៉ារីស ២៣ តុលា ១៩៩១
- ខ្មែរ កម្ពុជាក្រោម
- ខ្មែរ សុរិន
- ខ្មែរ អ៊ីស្លាម
- ជនជាតិ ម៉ុង

- ឡាវ អ្នកប្រឆាំងនឹងរដ្ឋាភិបាល
- យួន អ្នកប្រឆាំងនឹងរដ្ឋាភិបាល

យើងសូមកុំភ្លេចឱ្យសោះថា បើក្រុមខាងលើដឹងថា យើងជាអ្នកចង់ចូលប្រឡូកជាមួយគេ គេក៏អាចមានល្បិច " ខ្ចីដាវ " យើងប្រើដែរ ឬក៏ច្បាស់ជាមានអ្នកដែលមកខ្ចីដាវយើង សំរាប់ឱ្យក្រុមឯទៀតប្រើដូចគ្នាដែរ ។

## ៩- ល្បិចប្តូរស្រមោល និងភាពពិត (ល្បិចទី៧ នៃល្បិចយុទ្ធសាស្ត្រទាំង ៣៦ របស់ចិនសម័យដើម )

*" បញ្ឆោតសត្រូវ គឺដំបូងត្រូវបញ្ឆោត រួចមកទៀតលេងមែនទែន ឆ្អិនភ្នែកសត្រូវរហូតដល់វាលែងជឿ និងលែងយកចិត្តទុកដាក់ តែនៅទីបញ្ចប់ លេងមែនទែន ។ ម្តងភរ ម្តងភូត ម្តងទៀតមែន"*

ធ្វើឱ្យសត្រូវយកស្រមោលជាការពិត នេះហើយដែលហៅថា " បញ្ឆោត " តែគ្រប់ៗការបញ្ឆោត អាចធ្វើឱ្យគេជឿតែម្តងម្កាល និងតែមួយភ្លែត ដូច្នេះ កុំលេងវាយូរពេក ។

ការឆ្អិនភ្នែក មិនអាចកំទេចសត្រូវបានមែន តែការធ្វើមែនទែន នៅពេលបន្ទាប់មក អាចមានប្រសិទ្ធភាពគ្រប់គ្រាន់ក្នុង និងកំទេចសត្រូវ ។

" កាលណា ការមិនពិត ក្លាយទៅជាការពិត ការពិតខ្លួនឯងនោះ ក្លាយទៅត្រឹមតែជាស្រមោល " ។

" កាលណាភាពទទេ ក្លាយទៅជាភាពប្រាកដ ភាពប្រាកដខ្លួនឯងក្លាយទៅជាភាពទទេវិញ " ។ ន័យរបស់ល្បិច "ប្តូរស្រមោល និងភាពពិត " នេះ មិនខុសឆ្ងាយពីប្រយោគទាំងពីរនេះឡើយ ។

យុទ្ធសាស្ត្រដោយប្រើ "ល្បិចបញ្ឆោត " នេះ បានចែងនៅក្នុងជំពូកទី១ របស់ " សិល្បៈសង្គ្រាម " របស់លោក " ស៊ុន ស៊ូ " " ការបញ្ឆោតដែលល្អជាងគេ គឺ ការបញ្ឆោតលាយឡំជាមួយការពិត ឆ្លាស់វេនគ្នា ដោយគ្មានចង្វាក់ពិតប្រាកដ " ។

នៅក្នុងល្បិចនេះ សៀវភៅរបស់ " មិង " ឈ្មោះ " ស្បៀងយុទ្ធសាស្ត្រ " បានសរសេរថា " គ្មានអ្វីសំខាន់ជាងការចេះបញ្ឆោតសត្រូវ "ឡើយ ។

- បញ្ឆោត តាមរបៀប
- បញ្ឆោត តាមរបៀបរបស់សត្រូវ
- បញ្ឆោត ដោយសារសត្រូវវាស្មោះ
- បញ្ឆោត ដោយសារសត្រូវវាមានការលោភលន់
- បញ្ឆោត ដោយប្រើកំហុសរបស់សត្រូវ
- បញ្ឆោត ដោយប្រើការវិប្រសប់របស់សត្រូវ

គេអាចចាប់ផ្តើមបន្លំធ្វើជាវាយប្រហារ បន្ទាប់មកធ្វើការវាយប្រហារមែនទែន ទុកពេលឱ្យសត្រូវវាចាប់ភ្លឹកអំពី ការភ័ន្តច្រឡំរបស់វា ហើយដោយសារហេតុនេះ យើងបញ្ឆោតវាបន្តទៅទៀត ។

ដូច្នេះ មុននិងវាដឹងការពិត ការបន្លំធ្វើវាយប្រហារ អាចប្រើបានម្តងទៀត តែត្រូវធ្វើតាមរបៀបផ្ទុយទៅវិញ ។

### -ទឹក និងល្បិច "ប្តូរស្រមោល និងភាពពិត"

-" នៅក្នុងលោកនេះ គ្មានអ្វីដែលទន់ជ្រាយ និងខ្សោយ ជាងទឹកឡើយ " ។ នេះជា ភាវៈស្រមោល ដែលទឹកធ្វើឱ្យ

គេឃើញ ធ្វើឱ្យគេភ្លេចខ្លួន។ ក៏ប៉ុន្តែ តាមការពិត ទឹកចូល គៀកវាយប្រហារ។

-" ក្នុងការវាយប្រហារ អ្នកដែលខ្លាំង និងរឹងមាំទាំងអស់ មិនដែលបានឈ្នះទៅលើទី ហើយគ្មានអ្វីមកប្រៀបផ្ទឹមបាននិងទឹកឡើយ "។ រលកទឹកវាយនៅលើទំនប់ទៅម្តងៗ ម្តងខ្លាំង ម្តងតិច ទំនប់មិនអាចដឹងថា នៅពេលណា មានរលកខ្លាំងដែលត្រូវ វាយផ្តាច់វាទេ។

**ត-ល្បិចទីក្រុងគ្មានមនុស្ស** (ល្បិចទី៣២ នៃល្បិចយុទ្ធសាស្ត្រទាំង ៣៦ របស់ចិនសម័យដើម)

*" គ្មានអ្វីនៅក្នុងដៃ គ្មានអ្វីនៅក្នុងហោប៉ៅ ល្បិចក្នុងពេលមានអាសន្ន ល្បិចនៃល្បិច "។ ជាល្បិចដែលឋិត " នៅលើព្រំដែនរវាងភាពខ្លាំង និងភាពខ្សោយ "*។

ល្បិចបង្ហាញ " ***ថាមាន*** " និង " ***ថាគ្មាន*** " នាំឱ្យសត្រូវមានការមិនច្បាស់ ស្រពិចស្រពិល ជាក្បួនយុទ្ធសាស្ត្រដែលត្រូវផ្លាស់ប្តូរជានិច្ច ម្តង " ***មាន*** " ម្តង " ***គ្មាន*** "។ ល្បិចនេះ មានគេប្រើច្រើនណាស់ដែរ បន្ទាប់ពីលោក " ហ្សូហ្គឺរល្យាង " នោះមក។

ចំណុចខ្លាំង និងខ្សោយ របស់កងទ័ព ឬការការពាររបស់កងទ័ព ត្រូវធ្វើវិភាគក្នុងការប្រមាណភាព " ***គ្រប់គ្រាន់*** " ឬ " ***បន្តិចបន្តួច*** "ការបង្ហាញកត្តាទាំងពីរ អាចនាំទៅរហូតដល់ការបង្កើតជារូបភាពបញ្ឆោត ដែលនាំឱ្យបច្ចាមិត្តអស់សុភវិនិច្ឆ័យក្នុងការប្រមាណកំលាំង ដែលនៅប្រឈមមុខ។

**រូបភាពបញ្ឆោតអាចមាន ៤ យ៉ាង:**

- នៅកន្លែងណាដែល " ***មានតិច*** " ត្រូវធ្វើជារូបភាពបញ្ឆោតឱ្យឃើញ " ***មានច្រើន*** " ដើម្បីឱ្យសត្រូវខ្លាច លែងហ៊ានវាយប្រហារ។
- នៅកន្លែងដែល " ***មានច្រើន*** " ត្រូវធ្វើរូបភាពបញ្ឆោតជា " ***មានតិច*** " ដើម្បីទាញសត្រូវឱ្យចូលក្នុងអន្ទាក់។
- នៅកន្លែងដែល " ***មានតិច*** " ត្រូវធ្វើបង្ហាញរូបភាពច្បាស់ថា " ***មានតិច*** " ដើម្បីធ្វើឱ្យសត្រូវ មានការ សង្ស័យថាជាអន្ទាក់។
- នៅកន្លែងដែល " ***មានច្រើន*** " ត្រូវធ្វើបង្ហាញរូបភាពច្បាស់ថា " ***មានច្រើន*** " ដើម្បីធ្វើឱ្យសត្រូវមាន ការសង្ស័យថា ជាការបញ្ឆោត ដើម្បីឱ្យសត្រូវចេញពីរូងរបស់វា។

ក្នុងរជ្ជកាល អធិរាជ "ចិងឌិ " នៃរជ្ជកាល "ហាង្ស "ពួកចោរព្រៃ" ហ្សិយ៉ុងញូ" មកវាយប្រហារនៅ "ស្ហង់ជុន "។ អធិរាជបញ្ជូនមេទ័ពសំណប់ និងឧត្តមសេនីយ៍ " លីហ្គង់ " ឱ្យទៅធ្វើការវាយតបទៅវិញ។ ទៅដល់កន្លែងមេទ័ពសំណប់នោះ ចេញធ្វើបេសកម្ម ឈ្លបយកការណ៍ ជាមួយកងពលចំនួនម្ភៃ-សាមសិបនាក់។ ពួកគេទៅឆ្ងាយទៅៗ ស្រាប់តែជួបវ៉ាក់ ជាមួយទ័ពសេះពួកចោរព្រៃ ចំនួន ៣ នាក់។ កងពលរបស់ " ហាង្ស " ក៏ដេញ ហើយពួកចោរព្រៃរត់ដកថយ ដោយបាញ់ព្រួញជាច្រើនតបមកវិញ។ មេទ័ពសំណប់របស់អធិរាជ បានត្រូវរបួសដោយ សារព្រួញខ្លាំង ហើយកងពលមួយចំនួនត្រូវស្លាប់។ ក៏ប៉ុន្តែ មេទ័ពសំណប់នោះ បានឱ្យដំណឹងមកដល់ឧត្តមសេនីយ៍ " លី ហ្គង់ " ដែលគាត់ដេញតាមចោរព្រៃនោះ ជាមួយកងពល ចំនួន ២០០ នាក់ ជាបន្ទាន់។

គាត់បានសំលាប់ចោរព្រៃ ២នាក់ និងចាប់បានម្នាក់ទៀត ដែលកំពង់តែចងដាក់លើខ្នងសេះ ស្រាប់តែ នៅពេលនោះ ទ័ពសេះពួកចោរព្រៃចំនួនជាច្រើនពាន់នាក់បានមកដល់។ ដោយឃើញកងពលរបស់ " ហង្ស " មួយក្រុមតូចនៅ ដាច់ស្រយាល ឆ្ងាយតែឯង ពួកចោរព្រៃស្មានជានុយបញ្ឆោតសំរាប់ប្រុងព័ទ្ធពួកគេ ក៏រៀបចំទ័ព នៅចាំមើលពីចំងាយនៅលើទីខ្ពស់។ កងពលរបស់ " ហង្ស " ទាំងអស់ ឃើញដូច្នោះ ក៏ចង់ផាយបកក្រោយរត់យកតែព្រះអាយុ តែឧត្តមសេនីយ៍ " លី ហ្គង់ " និយាយថាៈ កងទ័ពរបស់យើងនៅឆ្ងាយ បើយើងរត់ វាមានពេល នឹងដេញយើងទាន់ ឬក៏យើងត្រូវស្លាប់នឹងព្រួញ របស់វា។ ការដែលល្អ យើងត្រូវនៅនឹងកន្លែង ទុកឱ្យពួកវាជឿថា គេប្រើយើងមកធ្វើជានុយ ទាក់ឱ្យពួកវាវាយប្រហារមកលើយើង។ ឧត្តមសេនីយ៍ " លី ហ្គង់ " ក៏បញ្ជាឱ្យកងពលបំផាយសេះ សំដៅទៅរកពួកចោរព្រៃ។ ទៅជិតដល់ នៅសល់ប្រហែល ២ យោជ គាត់បញ្ជាឱ្យ ឈប់ ហើយចុះពីខ្នងសេះ និងទំលាក់កែបចុះពីសេះ តែកងពល និយាយប្រឆាំងថា ទេ ! សត្រូវនៅជិតបង្កើយ !

ឧត្តម សេនីយ៍ " លី ហ្គង់ " ឆ្លើយថាៈ វាជឿថាយើងរត់ ពីព្រោះតែវាមានគ្នាច្រើនសំរាប់កំទេចយើង តែយើងបង្ហាញ ឱ្យច្បាស់ថា យើងគ្មានបំណង និងរត់ឡើយ ដែលនាំឱ្យវាជឿកាន់តែជាក់ថា គេប្រើយើងមកធ្វើជានុយ។

ពួកចោរព្រៃ នៅតែឈរចាំមើលជាបន្តទៀត។ វាបញ្ជូនគ្នាវាម្នាក់ មកឈ្លបមើលស្ថានការណ៍ ឃើញដូច្នោះ ឧត្តម សេនីយ៍ " លី ហ្គង់ " លោតឡើងលើសេះ ដេញតាមជាមួយកងពលជាង ១០ នាក់ ហើយក៏បាញ់ចោរនោះស្លាប់ទៅ។ បន្ទាប់ មក ឧត្តមសេនីយ៍ " លី ហ្គង់ " ត្រឡប់មករកគ្នាគាត់វិញ ហើយបញ្ជាឱ្យកងពលដេកសំរាក។ រហូតដល់ពេលយប់មក ដល់ ពួកចោរព្រៃលែងយល់អ្វីទាំងអស់ អំពីស្ថានការណ៍ដែលកំពុងកើតមានឡើងនោះ វានៅតែមិនហ៊ានវាយប្រហារដដែល ដល់ កណ្តាលអធ្រាត វាក៏ដកទ័ពវាចេញអស់ពីកន្លែង។

ព្រឹកឡើង ឧត្តមសេនីយ៍ " លីហ្គង់ " ក៏នាំទ័ពរបស់គាត់ត្រឡប់មកជុំវិញ។ ឧត្តមសេនីយ៍ " លី ហ្គង់ " ប្រើល្បិច គាត់ " មានគ្នាតិច " គាត់បង្ហាញភាពច្បាស់ថា គាត់ " មានគ្នាតិច " ដើម្បីធ្វើឱ្យសត្រូវមានការសង្ស័យថាជាអន្ទាក់។

### -ទឹក និងល្បិច "ទីក្រុងគ្មានមនុស្ស"

ទឹកតែងតែបញ្ចេញភាពក្រេវក្រោធ បោកគ្រាំគ្រេងបែកពពុះ តែនៅពេលដែល***ទឹកមានតិច*** (***ទឹករាក់***) " ***ខ្សោយ បង្ហាញថាខ្លាំង*** " ចំណែក***ទឹកជ្រៅមានសភាពស្ងួតបំផុត*** " ***ខ្លាំង បង្ហាញថាខ្សោយ*** " ។

### យ -ល្បិចដកថយតាមយុទ្ធសាស្ត្រ ( ល្បិចទី៣៦ នៃល្បិចយុទ្ធសាស្ត្រទាំង ៣៦ របស់ចិនសម័យដើម )

" ***រក្សាទុកកំលាំង កុំឱ្យខូចខាត ដោយគេច មិនប្រយុទ្ធ*** "

*" បើជ័យជំនះរបស់សត្រូវ និងមានជាប្រាកដ ហើយយើងមិនអាចតទល់និងវាបានទៀតឡើយ យើងមានជំរើស ៣ នៅចំពោះមុខ ចុះចូល ធ្វើការចរចារ និងដកថយ។*

- ចុះចូល មានន័យថាចុះចាញ់ ជាបរាជ័យពេញទី
- ធ្វើការចរចារ ជាបរាជ័យពាក់កណ្តាល
- ការដកថយ មិនមែនជាបរាជ័យ

ជៀសវាងបរាជ័យ ជាចំណុចដែលអាចបង្វិលនាំឱ្យមានជ័យជំនះ នៅពេលក្រោយ។

ឧត្តមសេនីយ៍ "ប៊ី យៀយូ " ក្នុងរជ្ជកាលរបស់ " សុង " នៅតទល់ពីមុខការតាំងទឹកងទ័ពរបស់ " ចិន "។ គាត់បាន បញ្ជាឱ្យទុកចោល ទង់ សញ្ញា នៅព្រោងព្រាតដដែល បន្ថែមពីនោះ គាត់ឱ្យចាប់ពពែចងព្យួរជើងខាងក្រោយ ដោយទុក ឱ្យ

ជើងមុខជាន់លើស្គរ។ ដោយពពែវាមិនអាចនៅស្ងៀម វាទទះជើងទៅលើស្គរ លាន់ឮអឺងកង ដែលធ្វើឱ្យកងទ័ព " ចិន " មិនចាប់ភ្លឹក អំពីការលើកជំរំនោះឡើយ។

នៅពេលដែលកងទ័ព " ចិន " ពិនិត្យឃើញការបញ្ឆោតនោះ កងទ័ពរបស់ឧត្តមសេនីយ៍ " ប៊ី ហៃយូ " ទៅឆ្ងាយបាត់ទៅហើយ។ នេះហើយ ជាសិល្បៈកំពូលនៃការដកថយតាមយុទ្ធសាស្ត្រ។

គេដឹងគ្រប់គ្នា អ្នកជំនាញខាងសិល្បៈដែលចំណាន គេថយក្រោយមួយជំហាន ចំណែកអ្នកល្ងង់ សំរុកចូលទៅមុខក្បាលសំយ៉ុងចុះ ហើយចាប់បញ្ចេញសំពៀងស្មៀតរបស់ខ្លួន ដែលនៅទីបញ្ចប់អ្នកដែលថយក្រោយធ្វើឱ្យអ្នកដែលសំរុកចូលដេកសន្ធឹងនៅលើដី។

## -ទឹក និងល្បិច "ដកថយតាមយុទ្ធសាស្ត្រ"

យើងសង្កេតឃើញគ្រប់ៗគ្នា នៅពេលណាមានរបស់ណាមួយសំរុកចូលក្នុងទឹក។ តែងតែដកថយ ឬគេចចេញជានិច្ច។ តែមួយពព្រិចភ្នែកប៉ុណ្ណោះ ទឹកវាយត្រឡប់មកវិញមិនដែលខានឡើយ កំលាំងវាយត្រឡប់មកវិញ មានភាពសមាមាត្រ និង កំលាំងដែលសំរុកចូលដែរ។

## -ទឹក និងអារ្យធម៌ខ្មែរ

អារ្យធមិខ្មែរ មានដើមកំណើតចេញអំពី "កោះគោកធ្លក " បានន័យថាតាំងតែពីដើមកំណើត អារ្យធមិខ្មែរ មានការរស់នៅជាប់ជាមួយនឹងទឹក។ កាលពីសតវត្សទី៥ គ.ស ទឹកជំនន់បានធ្វើឱ្យមានស្លាប់មនុស្សជាច្រើន អ្នកដែលរស់រានមាន ជីវិតនៅពេលនោះ បានទទួល ការពិសោធន៍គ្រប់គ្រាន់អំពីទឹក និងស្គាល់ទឹកជាងអ្នកនៅលើភ្នំឆ្ងាយណាស់។

នៅពេលដែលមេដឹកនាំខ្មែរ "ព្រះបាទឥន្ទ្រវរ៍្មន(៨៧៧-៨៨៩)បានជីក "បារាយណ៏" "ព្រះបាទយសោវរ៍្មន(៨៩៩-៩០០) " ជីក " បារាយណ៏ខាងលិច " ដោយព្រះអង្គបានស្គាល់អនុភាពនៃទឹកសំរាប់យកទឹកមកប្រើ ពេលនោះហើយដែលអារ្យធមិខ្មែរបានឡើងដល់កំរិតកំពូល រហូតមកដល់សម័យអង្គរ។

នៅពេលនេះខ្មែរ កំពុងតែជួបនូវមហន្តរាយយ៉ាងធ្ងន់ធ្ងរ អ្នកស្នេហាជាតិខ្មែរ ត្រូវតែរិះរកយុទ្ធសាស្ត្រជំនាញៗ សំរាប់វាយបកទៅលើសត្រូវ ដែលមានកំលាំងលើសលុប អ្នកស្នេហាជាតិខ្មែរគួរតែងាកមកធ្វើការពិនិត្យពិច័យស្រង់យកយុទ្ធសាស្ត្រដែលទឹកបានអនុវត្ត សំរាប់ការពារខ្លួន សំរាប់វាយលុក សំរាប់បំរើមនុស្សលោក យកមកប្រើជាមធ្យោបាយការពារខ្លួន យើងព្រោះអារ្យធមិខ្មែរយើង មានវាសនាលូតលាស់នៅជាប់ជាមួយទឹក តាំងតែពីដើមមក យើងច្បាស់ជាអាចយល់បាន អំពីយុទ្ធសាស្ត្រសំងាត់ៗ និងជំនាញៗ របស់ទឹកជាប្រាកដ។ អារ្យធមិខ្មែរ ដែលមាននៅក្នុងឈាមរបស់អ្នកស្នេហាជាតិខ្មែរ គ្រប់ៗគ្នាអាចផ្តល់អោយអ្នកស្នេហាជាតិខ្មែរ មានលទ្ធភាពដកស្រង់យកយុទ្ធសាស្ត្រ ដែលទឹកប្រើជារៀងរាល់ថ្ងៃ យកមកអនុវត្ត សំរាប់ការពារពូជសាសន៍ខ្មែរ ឱ្យរស់រានមានជីវិតជានិរន្តន៍ទៅទៀត។

ដើម្បីឱ្យជាតិខ្មែរ " ស្លូតត្រង់ទន់ភ្លន់ " បានស្ថិតនៅ " គង់វង្ស " នៅក្នុងចំណោមជាតិសាសន៍" កំរោលឃោរឃៅ " ដែលមានដើមកំណើតពីចោរព្រៃនៃប្រទេសចិន យើងត្រូវការរកយុទ្ធសាស្ត្រដែលឆ្លើយតបនិងស្ថានការណ៏នេះ មកប្រើជាការចាំបាច់។

### ១១-បណ្ដាំព្រលឹងមេគង្គ

*" អ្នកស្នេហាជាតិខ្មែរទាំងឡាយ អ្នកជាទីជំរក អ្នកជាទីសង្ឃឹម អ្នកមានភារៈការពារជាតិខ្មែរ ទ្រទ្រង់អារ្យធម៌ខ្មែរ ដូចជាទឹក ជាទីជំរក ជាទីសង្ឃឹម ជាអ្នកការពារមច្ឆាជាតិ ឱ្យរស់រានមានជីវិតបន្តយ៉ាងក្សេមក្សាន្ត តាំងពីដើមកំណើត នៃជីវិតនៅលើផែនដីមក។ ដោយសារអ្នកមានអារ្យធម៌លូតលាស់ជាប់ជាមួយទឹក អ្នកមានលទ្ធភាព គ្រាប់គ្រាន់ ក្នុងការដកស្រង់ គ្រែបជញ្ជក់ យកយុទ្ធសាស្ត្រដ៏ជំនាញៗពីទឹក សំរាប់ការពារអារ្យធម៌ជាតិខ្មែរ។ បើថ្ងៃណាអ្នកទាល់គំនិត នៅចំពោះមុខសត្រូវ សូមកុំអស់សង្ឃឹម អ្នកគ្រាន់តែស្ញឹងស្មាតនៅមាត់ទឹក ដើម្បីជ្រើសរើស យកយុទ្ធសាស្ត្រណាដែល សក្ដិសម ស្របតាមកាលៈទេសៈ ដែលទឹកបានយកមកប្រើរួចមកហើយ អ្នកនឹងឈ្នះសត្រូវ ពីព្រោះសត្រូវរបស់អ្នកមិនពូកែខ្លាំង ជាងទឹកឡើយ។ "*

### IV-យុទ្ធសាស្ត្រ

#### ១-គោលដៅ (Objective)

ការជ្រើសរើសគោលដៅ (Objective) បានត្រឹមត្រូវល្អ ក្នុងកិច្ចប្រតិបត្តិការ ជាកត្តាសំខាន់ក្នុងការជំរុញ ការរំដោះជាតិឱ្យបានសំរេច។ គោលដៅទាំងឡាយ ដែលជ្រើសរើស ត្រូវចាត់ឱ្យមាន *អាទិភាព ភារៈផ្ដោត* ( ***បន្ទោត*** Concentration) *ឱ្យចំចំណុច* ក្នុង*ភាពប្រាកដនិយម* ដោយ*ផ្អែកលើ ធនធាន សំភារះដែលយើងមាន*។ ការជ្រើសរើសគោលដៅមិនត្រឹមត្រូវ និងគ្មាន*បន្ទោត និងគ្មានភាពប្រាកដនិយម* (រាយមាយ មិនប្រាកដ) នាំឱ្យយើងខាតបង់ពេលវេលា ធនធាន និងការជឿទុកចិត្ត ក្នុងការដឹកនាំ។ ហេតុនេះហើយ ក្នុងពេលធ្វើការសំរេចចិត្ត ត្រូវធ្វើការថ្លឹងថ្លែងលើកត្តាខាងលើទាំងប៉ុន្មាននេះ ដោយហ្មត់ចត់ ត្រឹមត្រូវ រហ័សរហួនបំផុត។

មេដឹកនាំខ្មែរ ទាំងអស់មានភារះដឹកនាំ ប្រជាជាតិខ្មែរ ឆ្ពោះទៅជោគជ័យផ្ដាច់ព្រ័ត្រ តាមគោលដៅរួមមួយ ដែលបានកំណត់ច្បាស់លាស់។ គោលដៅរួមរបស់មេដឹកនាំជាតិខ្មែរ គឺ រំដោះជាតិខ្មែរ អោយរួចផុតពីការលេបត្របាក់ របស់ចោរយួន អណានិគមន៍បែបថ្មី និងរបបកុម្មុយនិស្ត ផ្ដាច់ការ **ហ៊ុន សែន** ខ្ញុំកញ្ជះយួន។ និងការកសាង ***ឯកភាពជាតិខ្មែរ*** យ៉ាងទូលំទូលាយមួយ សាងរបប***ប្រជាធិបតេយ្យ ឯករាជ្យ ឥស្សរភាពជាតិ វិបុលភាព ឧត្ដមភាព ពិតប្រាកដមួយ*** ក្នុងសង្គមខ្មែរ នាពេលអនាគតខាងមុខ។ ហើយញ៉ាំងអោយប្រជាជាតិខ្មែរ ទាំងមូលរស់ក្នុង ***សុភមង្គល វិបុលភាព ប្រកបដោយថាមពល រឹងប៉ឹង ស្ថិតស្ថេរ ជានិច្ចនិរន្តន៍ និង មានឧត្ដមភាព ស្មើមុខ នឹង ប្រជាជាតិជិតខាង***។ មេដឹកនាំជាតិខ្មែរ ត្រូវក្រោកឡើង ការពារជាតិ ទឹកដី ប្រជាពលរដ្ឋខ្មែរ។ កុំអោយចោរយួន និងពួកអាយ៉ង **ហ៊ុន សែន, ហេង សំរិន, ជា ស៊ីម** សំរេចតាមផែនការរបស់វា។ មេដឹកនាំជាតិខ្មែរ ត្រូវហ៊ានពុះពារ ឧបស័គ្គគ្រប់បែបយ៉ាងដោយភាពប្តូរផ្តាច់ ដើម្បីអោយបានសំរេច គោលដៅខាងលើ មិនថាយូរប៉ុណ្ណាប់ ឬក៏ត្រូវធ្វើពលីកម្មធំធេង បង់តំលៃក៏វិតណាឡើយ។ ឯកភាពជាតិខ្មែរ ប្រទេសខ្មែរឯករាជ្យ មានឥស្សរភាព មានប្រជាធិបតេយ្យ ពិតក្នុងសង្គម និងសុខសន្តិភាព វិបុលភាព ប្រកបដោយថាមពល រឹងប៉ឹង ស្ថិតស្ថេរ ជានិច្ចនិរន្ត មានឧត្តមភាព ស្មើមុខនឹងប្រជាជាតិជិតខាងជាគោលដៅតែមួយគត់ របស់យើងជាខ្មែរ ជាអ្នកដឹកនាំខ្មែរ។

ដើម្បីសំរេចគោលបំណង និងគោលដៅដ៏ពិសិដ្ឋនេះ មេដឹកនាំជាតិខ្មែរ ត្រូវតែប្រឹងប្រែង រិះរក គ្រប់មធ្យោបាយ ធ្វើអោយមានការរួបរួមអ្នកស្នេហាជាតិ អ្នកជាតិនិយម អ្នកប្រជាធិបតេយ្យ ពីគ្រប់ស្រទាប់សង្គមខ្មែរទាំងក្នុង និងក្រៅប្រទេស អោយចូលរួមជាកំលាំងខ្មែរ កំលាំងជាតិខ្មែរតែមួយ ដើម្បីបំពេញ បេសកកម្មដ៏ធំធេងនេះអោយបានជោគជ័យជាស្ថាពរ ។

ការធ្វើអោយមាន ការរួបរួមកំលាំងជាតិខ្មែរជាធ្លុងមួយ ឯកភាព សាមគ្គីជាតិទូលំទូលាយ ជាការលំបាកបំផុត សំរាប់មេដឹកនាំជាតិខ្មែរ ។ សាមគ្គីជាតិខ្មែរ ត្រូវចោរយួន ហែកហួរបែកបាក់ខ្ទេចខ្ទី ប្រៀបបានដូចជា កំទេចកែវ ដែលធ្លាក់បែក ទៅហើយ ប៉ុន្តែក៏មិនមែនមានន័យថា មេដឹកនាំជាតិខ្មែរមិនអាចធ្វើការបង្រួបបង្រួមបាននោះទេ តែដើម្បីអោយសំរេចកើតជារូបរាងឡើងបាន មេដឹកនាំជាតិខ្មែរទាំងអស់ត្រូវតែមានពិព្យាយាម អត់ធ្មត់ ស៊ូទ្រាំ នឹងឧបសគ្គ ការលំបាកផ្សេងៗយ៉ាងខ្លាំង ជាទីបំផុត ក្នុងការផ្សព្វផ្សាយ បំផុសស្មារតីប្រជាពលរដ្ឋខ្មែរ អោយមានការភ្ញាក់រលឹក រួបរួមគ្នា ពីខ្មែរគ្រប់ស្រទាប់ក្នុងសង្គមសារឡើងវិញ ។ មេដឹកនាំជាតិខ្មែរ ត្រូវមានភារះដាស់ស្មារតីខ្មែរអោយភ្ញាក់រលឹក ដោយធ្វើតាមគ្រប់វិធី តាមបង្រៀន ការបង្ហាញពន្យល់ប្រវត្តិសាស្រ្តជាតិខ្មែរពិតប្រាកដ ការបង្ហាញប្រជាពលរដ្ឋខ្មែរ អោយមើលឃើញអំពីគ្រោះថ្នាក់ប្រទេសជាតិពីសំណាក់ចោរយួន បង្រៀនខ្មែរអោយមានគំនិតដឹកនាំជាតិដោយខ្លួនឯង បង្ហាញប្រជាពលរដ្ឋខ្មែរអោយមើលឃើញអំពីមូលហេតុដែលនាំអោយ ខ្មែរ ក្រីក្រ អត់ឃ្លាន ល្ងង់ខ្លៅ ភ័យខ្លាច និងរស់ក្រោមការសង្កត់សង្កិន ជិះជាន់ យ៉ាងអយុត្តិធមិ ដូចសព្វថ្ងៃនេះ ។ បំភ្លឺប្រជាពលរដ្ឋខ្មែរអោយមើលឃើញ និងឈឺចាប់ ចង់រកយុត្តធមិ អោយជនរួមជាតិខ្មែរ ដែលរងគ្រោះស្លាប់រាប់លាននាក់ដោយសារកលល្បិច ចោរយួន សំលាប់ ដោយសារទង្វើឆ្កួតលីលាល្ងង់ខ្លៅ របស់ពួកមេគ្រួតគ្រាក្បត់ជាតិ ។ ដូចរៀបរាប់រួចមកហើយ ចោរយួន **ហ៊ុន សែន** ធ្វើអោយប្រជាពលរដ្ឋខ្មែរភ្លេចជាតិខ្លួនឯង លែងស្គាល់ខ្លួនឯង ជាអ្នកណាមកពីណា លែងអោយតំលៃខ្លួនឯងក្នុងភាពជាជាតិខ្មែរ ។ ចំណុចដែល មានប្រសិទ្ធភាពសំរាប់មេដឹកនាំជាតិខ្មែរ គឺ ត្រូវស្គាល់ អំពីតំរូវការចាំបាច់ និងចំណង់ចំណូលចិត្តពលរដ្ឋខ្មែរ តាមតំបន់នីមួយៗអោយបានច្បាស់លាស់ ។ មេដឹកនាំខ្មែរ ត្រូវផ្សព្វផ្សាយ ឃោសនា ពន្យល់នូវ អ្វីដែលប្រជាពលរដ្ឋខ្មែរចង់ស្តាប់ ចង់ឮ ចង់យល់ ចង់ដឹង ។ មេដឹកនាំជាតិខ្មែរ ត្រូវខិតខំព្យាយាមយ៉ាងសកម្មបំផុត មិនថាយប់ថ្ងៃ ដោយមិនខ្លាចនឿយហត់លំបាក ប្រើប្រាស់គ្រប់សិល្បវិធី ដើម្បីធ្វើយ៉ាងណា អោយប្រជាពលរដ្ឋខ្មែរ យល់ការពិត ភ្ញាក់រលឹក មកគាំទ្រ អ្នកជាតិនិយមខ្មែរ និងឈប់ជឿ ឈប់គាំទ្រ ចោរយួន និងអាយ៉ង **ហ៊ុន សែន** ក្បត់ជាតិ ។ *មេដឹកនាំជាតិខ្មែរ ត្រូវដាក់ខ្លួនអោយទាប ចុះជាប់ផ្ទាល់ក្នុងស្រទាប់ប្រជាពលរដ្ឋខ្មែរ ចាប់យកអ្នកមានសមត្ថភាព មានប្រសិទ្ធិភាពក្នុងឃោសនា ដូចជា ព្រះសង្ឃ គ្រូបង្រៀន តំណាងសិស្ស និសិត្ស បញ្ញវន្ត័ តំណាងកម្មករ តំណាងពាណិជ្ជករ អ្នកជំនួញ និងអ្នកមានប្រជាប្រិយ អ្នកមានឥទ្ធិពល មានស័ក្តានុពល ក្នុងការជួយបំផុសព្រលឹងខ្មែរអោយរីកដុះដាលសណ្ឋិតក្នុង ដួងព្រលឹងវិញ្ញាណខ្មែរ គ្រប់រូបបានទាប់ពេលវេលា ។*

យួន បានប្រើកលល្បិច ធ្វើអោយខ្មែរបែកបាក់គ្នា មិនទុកចិត្តគ្នា ស្អប់គ្នា លាបពណ៌គ្នា អោយខ្មែរឈ្លោះទាស់គ្នា ប្រើដៃខ្មែរអោយ សំលាប់ខ្មែរគ្នាឯង ។ យួន **ហ៊ុន សែន** បំភ័ន្តស្មារតី បំភន្ត័ភ្នែកចិត្តគំនិតខ្មែរ អោយដេកលក់នឹងការយល់ថា មានសុខសន្តិភាព និងប្រជាធិបតេយ្យ ។ យួន **ហ៊ុន សែន** កំពុងសំលាប់ស្មារតី បំបាក់ឆន្ទៈប្រយុទ្ធខ្មែរ ដោយការបន្លាចអោយភ័យខ្លាចពាក្យថា ភេរវកម្ម ។ មេដឹកនាំជាតិខ្មែរត្រូវតែហ៊ាន ផ្សព្វផ្សាយនិយាយការពិត អោយខ្មែរយល់ដឹង មើលឃើញដោយខ្លួនឯងថា សន្តិភាពសព្វថ្ងៃ ជាសន្តិភាពនៅលើគំនរភ្នក់ភ្លើង ប្រជាធិបតេយ្យសព្វថ្ងៃ ជាប្រជាធិបតេយ្យបោកប្រាស ឯអ្នកដែលប្រព្រិត្តអំពើភេរវកម្មសព្វថ្ងៃ គឺចោរយួន និងអាយ៉ង ហ៊ុន សែន នោះឯង ដែលកំពុងធ្វើមកលើប្រជាជាតិខ្មែរមិនដាច់រយះ ។ វី

ឯការដែលខ្មែរក្រោកឡើង ធ្វើការតស៊ូរំដោះជាតិ ដើម្បីឥស្សរភាពជាតិ ដើម្បីសិទ្ធសេរីភាព របស់ប្រជាជាតិ ជាទង្វើប្រកបដោយ មនសិកាដ៏ត្រឹមត្រូវ ថ្លៃថ្នូរ របស់មនុស្សជាតិទូទៅ មិនមែនជា អំពើភេរវកម្ម ដូចការចោទប្រកាន់មួលបង្កាច់របស់ អាក្បត់ ហ៊ុន សែន និងយួន ចៅហ្វាយវាឡើយ ។ លើសពីនេះ យើងត្រូវបណ្តុះជំនឿឡើងវិញ ថា "គ្មានជាតិណា ស្រឡាញ់ខ្មែរជាងខ្មែរគ្នាឯងឡើយ" និងបង្រៀនអោយកូនខ្មែរ រៀនទុកចិត្តគ្នា រៀនជឿគ្នា ដោយចិត្តទូលាយ រោះរាយរាក់ទាក់ មានអធ្យាស្រយ័ដល់គ្នាទៅវិញទៅមករវាងខ្មែរនឹងខ្មែរដូចគ្នា មានខ្សែលោកហិតតែមួយ និងដោយផ្អែកលើ ការជឿតាម របៀបសង្កេតពិនិត្យយ៉ាងល្អិតល្អន់ហ្មត់ចត់ ពីប្រវត្តិដើម ដោយ មិនខ្ជីខ្ជា មិនធ្វេសប្រហែស ។

## ក -គោលដៅ របស់ យួន និង ហ៊ុន សែន ក្បត់ជាតិ

- ក្រឡៃប្រវត្តិសាស្ត្រពិតរបស់ខ្មែរ
- រំលាយគ្រឹះ វប្បធម៌ សិក្សាអប់រំ និងអត្តសញ្ញាណខ្មែរ
- រំលាយ សាមគ្គីភាព ឯកភាពជាតិខ្មែរ
- ប្រជាពលរដ្ឋខ្មែរបាក់ស្មារតី ខ្លាចស្លាប់ អស់សង្ឃឹម និងរង់ចាំអ្នកមានបុណ្យ
- រំលាយ ព្រលឹងជាតិខ្មែរ ស្មារតីខ្មែរ ឆន្ទះប្រយុទ្ធខ្មែរ និងគំនិតស្នេហាជាតិខ្មែរ អោយសាបសូន្យ
- ធ្វើអោយប្រជាពលរដ្ឋខ្មែរវង្វេងក្នុង អំពើពាលា ល្បែង ស្រី ស្រា មិនដឹងពីភាពមហន្តរាយប្រទេសជាតិ
- ជំរុញអោយ ពួកមេត្រួត្រា លោភអំណាច មុខមាត់ ទ្រព្យសម្បត្តិ សំភារះនិយម និងអត្តានិយម
- ធ្វើអោយខ្មែរមិនទុកចិត្តគ្នា នឿយណាយស្អប់ជាតិឯង អស់ជំនឿលើខ្មែរគ្នាឯង
- បំភ្លៃការពិត ភ្លេចជាតិខ្មែរ អ្នកផ្តល់កំណើត តែដឹងគុណយួន ជាឃាដករ
- ធ្វើអោយប្រជាពលរដ្ឋខ្មែរលង់ជឿ **ហ៊ុន សែន** បោកប្រាស់
- បំផ្លាញជំនឿ សាសនា អោយខ្មែរវក់វង្វេងនឹង គ្រូទាយ និងពុទ្ធទំនាយ
- ត្រួតត្រាប្រព័ន្ធសារពរត៌មាន
- ធ្វើអោយប្រព័ន្ធអប់រំខ្សោយគ្មានគុណភាព
- បណ្តាញចារកម្ម គំរាម បំភ័យ និងផ្សាយពត៌មានមិនពិត
- ផ្តាច់ផ្នែកសេដ្ឋកិច្ច( ធ្វើអោយខ្មែរក្រីក្រ)
- កូនខ្មែរពិតប្រាកដគ្មានលទ្ធភាពសិក្សារៀនសូត្រ ( ធ្វើអោយខ្មែល្ងង់)
- សំលាប់អ្នកចេះ និងអ្នកស្នេហាជាតិខ្មែរ ( ធ្វើអោយខ្មែរខ្លាច)

## ខ -គោលដៅមេដឹកនាំជាតិខ្មែរ ប្រទេសខ្មែរឯករាជ្យ មានឥស្សរះ មានវិបុលភាព ឧត្តមភាព

- សាងឯកភាពជាតិ សាមគ្គីជាតិ ក្នុងសង្គមខ្មែរអោយបាន
- សាងប្រទេសខ្មែរ ឯករាជ្យ មានឥស្សរះភាព វិបុលភាព ឧត្តមភាព អាចប្រឈមទល់នឹងសត្រូវជិតខាង ។
- ជំរុញអោយប្រជាជាតិខ្មែរ ស្គាល់ប្រវត្តិសាស្ត្រជាតិខ្លួនពិតប្រាកដ និងគិតគូរបញ្ហាប្រទេសជាតិ ។
- បំផុសស្មារតីជាតិនិយមដល់ ប្រជាពលរដ្ឋខ្មែរ អោយភ្ញាក់រលឹក ស្រឡាញ់ប្រទេសជាតិខ្មែរ ។

- លើកដំកើងថែរក្សា អត្តសញ្ញាណជាខ្មែរ ។
- ជំរុញទឹកចិត្តប្រជាពលរដ្ឋខ្មែរ អោយក្លាហានមុះមុត ហ៊ានប្តូរជីវិត ជីពជន ដើម្បីជាតិ និងប្រជាជាតិខ្មែរ ។.
- បំផុសប្រជាពលរដ្ឋខ្មែរអោយ ឈប់ដឹងគុណយួន ៧ មករា និងពួកអាក្បត់ **ហ៊ុន សែន** ។
- ក្រោកឡើងធ្វើមេដឹកនាំជាតិខ្មែរដោយខ្លួនឯង ។
- ឈប់លង់ជឿឧបាយកល បោកប្រាស ខ្មៅក្រខ្វក់របស់ យួន **ហ៊ុន សែន** ។
- ជំរុញអោយមានស្មារតីភ្ញាក់រលឹក ក្រោកឈរឡើង សង្គ្រោះជាតិខ្មែរពី ការលេបត្របាក់របស់ យួន ។

ជាការពិតណាស់ មេដឹកនាំជាតិខ្មែរ ពុំមានសំភារះគ្រប់គ្រាន់ នឹងផ្សព្វផ្សាយ អោយជ្រួតជ្រាបដល់ស្រទាប់ប្រជាពលរដ្ឋខ្មែរទាំងមូលបានឡើយ ព្រោះយើងគ្មានប្រព័ន្ធសារពតិមាន គ្មានឧបករណ៍ផ្សព្វផ្សាយ យើងគ្មានបណ្តាញ ភ្នាក់ងារចែកចាយដំណឹង ដូចពួកយួន **ហ៊ុន សែន** ឡើយ ។ ប្រជាពលរដ្ឋខ្មែរភាគច្រើន មិនបានសិក្សារៀនសូត្រ ក៏ប៉ុន្តែដោយអំណាចទឹកចិត្តស្នេហាប្រទេសជាតិខ្មែរពិតប្រាកដ ព្រលឹងបុព្វបុរសខ្មែរ វិរះបុរសខ្មែរ បានជំរុញអោយព្រះសង្ឃ កូនខ្មែរ ប្រជាពលរដ្ឋខ្មែរអ្នកស្នេហាជាតិខ្មែរគ្រប់រូប អាចខិតខំផ្សព្វផ្សាយ រៀបចំចងក្រងគ្នាជាក្រុមមេដឹកនាំជាតិខ្មែរ តាមរយៈ½

- ការបង្រៀនប្រវត្តិសាស្ត្រខ្មែរពិតប្រាកដ ដល់ប្រជាពលរដ្ឋខ្មែរអោយដឹងព្វទូលំទូលាយគ្រប់គ្នា ។
- ការបង្កើនសមត្ថភាពមេដឹកនាំ ដល់កូនខ្មែរជំនាន់ក្រោយ ឱយចេះរៀបចំអង្គការនយោបាយជាតិដោយខ្លួនឯង ។
- ការជួបប្រជុំអប់រំគ្នាជារឿយៗ និងខិតខំនាំគ្នាផ្សព្វផ្សាយពីការគ្រោះថ្នាក់របស់ប្រទេសជាតិ ដល់គ្នាទៅវិញទៅមក ហើយចងក្រងគ្នាជាក្រុម ពួក អោយទៅជាខ្សែសម្ព័ន្ធ ស្និតរមួត ដើម្បីស្វែងរកផ្លូវដោះស្រាយអោយបានទាន់ពេល ។
- ការលះបង់ខ្ពស់ ចែកចាយឯកសារផ្សេងៗតគ្នាដល់ខ្មែរទូទៅ អោយមានចំណេះដឹងសំរាប់ចិញ្ចឹមជីវិត និង ចំណេះដឹងដឹកនាំប្រទេសជាតិ ។
- ជំរុញនិងលើកទឹកចិត្តកូនខ្មែរគ្រប់រូប អោយខិតខំរៀនសូត្រស្រាវជ្រាវដោយខ្លួនឯង រៀនអោយខ្ពង់ខ្ពស់ និងមានឯកទេសច្បាស់លាស់ ។
- ប្រមូលអ្នកជាតិនិយមខ្មែរ អ្នកស្នេហាជាតិខ្មែរ អ្នកប្រជាធិបតេយ្យ អោយខិតខំធ្វើកិច្ចការនេះយ៉ាងសកម្មបំផុត ។
- ធ្វើឱយមានការចូលរួមពីពលរដ្ឋខ្មែរ ប្រុសស្រី ទាំងអស់ ពីគ្រប់ស្រទាប់ក្នុងសង្គម ដើម្បីគោលដៅខាងលើ ។

## ២-វាយលុក (Offensive)

រាល់ការគិត ការរៀបចំផែនការ ត្រូវថ្លឹងថ្លែងអោយបានល្អិតល្អន់ និងរក្សានូវស្ថានភាពវាយលុកជានិច្ច ទាំងស្មារតី ទាំងសកម្មភាព ទាំងផែនការ ការនិយាយស្តី ការឃោសនាអូសទាញបញ្ចុះបញ្ចូល ជាដើម ។ យើងមិនត្រូវធ្វើអ្វីៗនៅក្នុងស្ថានភាព ចាំតែទប់ទល់ សត្រូវនោះឡើយ ។ ការដេកចាំតែទប់ទល់ នឹងធ្វើអោយយើងបាត់បង់ វិសាលភាពខាងគំនិត និងសកម្មភាព ។ ហេតុនេះហើយ យើងត្រូវតែផ្តួចផ្តើមគំនិត ធ្វើសកម្មភាពវាយលុកទៅលើសត្រូវ នៅគ្រប់កាលៈទេសៈ មិនត្រូវទុកឱកាសអោយសត្រូវវាយបកមកលើយើងមុនឡើយ ។ ក្នុងឋានៈជាមេដឹកនាំជាតិខ្មែរ ត្រូវបន្តគិត និងប្រមូលគំនិតផ្តួចផ្តើម ខិតខំប្រឹងប្រែងទាំងអស់គ្នា ដើម្បីឆ្ពោះទៅរកគោលបំណងរួម គឺការរំដោះជាតិ សាសនា ប្រជាជាតិខ្មែរ អោយបានយ៉ាងដាច់ខាត ។ គោលបំណងធំ របស់មេដឹកនាំជាតិខ្មែរ គឺ រំដោះ សង្គ្រោះជាតិ ខ្មែរ កាពារទឹកដីខ្មែរ និងពូជសាសន៍ខ្មែរ ។ មេដឹកនាំជាតិ

ខ្មែរទាំងអស់ ត្រូវតែរិះរកគ្រប់ វិធីវាយលុកទៅលើ ពួកចោរយួន និងពួកអាយ៉ង **ហ៊ុន សែន, ជា ស៊ីម, ហេង សំរិន** មួយក្តាប់តូចៈ តាមគាលការណ៍ នៃការវាយលុក ដូចខាងក្រោម÷

១-សកម្ម វាយលុក តាមគ្រប់រូបភាព គ្រប់មធ្យោបាយ គ្រប់ច្រកល្ហក ទាំងរូបបីយ និងអរូបីយ

២-ថែរក្សាគំនិតផ្តួចផ្តើម និងលទ្ធភាពវាយលុក

៣-បន្ត និងថែរក្សាគោលបំណងរួម ក្នុងស្ថានភាពវាយលុកជានិច្ច ។

ទោះជាពេល យើងស្ថិតនៅក្នុងស្ថានភាពខ្លួនការពារក៏ដោយ តែមេដឹកនាំជាតិខ្មែរ ត្រូវសកម្មពុះពារជានិច្ច មិន ត្រូវអស់សង្ឃឹម អសកម្ម ទ័លគំនិតនោះទេ ។ ជាទូទៅ បញ្ហាអ្វីក៏ដោយ បើយើងចូលអោយកៀក ពិនិត្យអោយបានល្អិតល្អន់ យើងនឹងត្រូវតែរកឃើញច្រកចេញយ៉ាងដាច់ខាត ។ មេដឹកនាំត្រូវមានគំនិតផ្តួចផ្តើមខ្ពស់ ឆ្លៀសវៃ ដាក់ឆន្ទៈមុតស្រួចបាញ់ឆ្ពោះទៅលើសត្រូវ ។ បង្កលទ្ធភាព និងជ្រើសរើស គោលដៅឬ កន្លែងដែលខ្លាំងមិនបានប្រុងប្រយត្ន័ មានចំណុចខ្សោយ ហើយធ្វើការវាយលុកភ្លាមៗ ទៅលើសត្រូវ តាមគ្រប់រូបភាព ។ ការជ្រើសរើសគោលដៅ ត្រូវសំលឹងទៅលើ ទីដែលសត្រូវមិនបានគិតទុកជាមុន ឬនឹកស្មានមិនដល់ ។

សកម្មភាពវាយលុក ត្រូវតែរៀបចំធ្វើព្រមគ្នានៅគ្រប់ទីកន្លែង គ្រប់ពេលវេលាទាំងអស់ កន្លែងណាដែលអាច ធ្វើបានដោយមិនរង់ចាំឱកាសល្អ ឬពេលណាមួយឡើយ ។ *កន្លែងដែលលោកអង្គុយ គឺជាកន្លែងដែលលោកអាចមើលឃើញបាន។* មេដឹកនាំជាតិខ្មែរ គឺជាអ្នកដើរនិយាយឃោសនា បំផុសស្មារតីប្រជាពលរដ្ឋខ្មែរ ។ ***ទីណាមានជនជាតិខ្មែរ ទីនោះមានអ្នកដឹកនាំជាតិខ្មែរនិយាយអំពីបញ្ហាប្រទេសជាតិខ្មែរ បណ្តុះឆន្ទៈខ្មែរឱ្យស្នេហាជាតិ ។ អ្នកដឹកនាំខ្មែរត្រូវចេះអត់អោនអាធ្យាស្រ័យ ស្រឡាញ់ខ្មែរដូចគ្នា មិនបង្ករឿងរិះគន់ ឈ្លោះប្រកែកគ្នា ស្អប់ខ្មែរគ្នាឯង លាបពណ៌តាមមនោគមន៍វិជ្ជាយនិស្តយួនឡើយ ។*** ដើម្បី ឱ្យសកម្មភាពវាយលុកមានប្រសិទ្ធិភាព អ្នកដឹកនាំខ្មែរត្រូវតែទុកផលប្រយោជន៍ជាតិជាធំ យកផលប្រយោជន៍ខ្មែរជាចំបង ជាប់ជានិច្ច ។ គ្រប់មេដឹកនាំជាតិខ្មែរ ត្រូវខិតខំធ្វើកិច្ចការនេះ យ៉ាងសកម្មបំផុត កុំភ្លេចភារៈកិច្ចនិងកាតព្វកិច្ចដ៏ចាំបាច់នេះ ចាប់ពីពេលបានទទួលសៀវភៅនេះទៅ ។ ធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋខ្មែរ ចូលរួមយ៉ាងសកម្មដូច អ្នកដឹកនាំជាតិខ្មែរដែរ ដើម្បីសំរេចជោគជ័យ ក្នុងបេសកកម្ម រំដោះ សង្គ្រោះ ការពារជាតិខ្មែរដ៏ពិសិដ្ឋនេះ ។

## សកម្មភាព និងវិធីវាយលុក

- ស្វែងរកចំណុចខ្សោយរបស់យួន **ហ៊ុន សែន** ហើយវាយលុកអោយចំចំណុចខ្សោយរបស់វា ។
- បំបែកចំណុចខ្លាំងរបស់យួន **ហ៊ុន សែន** អោយខ្សោយ ។
- ទាញអ្នកគាំទ្រយួន **ហ៊ុន សែន** អោយមកនូវអព្យាក្រិត(តែមិនអោយដឹងកិច្ចការរបស់យើង) ។
- អប់រំអ្នកដែលមានស្មារតីភ្ញាក់រលឹកនយោបាយខ្ពស់អោយចូលរួមនឹងយើង តែមិនឱយដឹងដល់ជំរៅ ។
- ហ្វឹកហ្វឺន អប់រំ ពង្រឹងស្មារតី អ្នកស្នេហាជាតិខ្មែរអោយធ្វើកិច្ចការយ៉ាងសកម្ម ក្នុងកិច្ចការតស៊ូ ។

- ធ្វើការឃោសនាអោយមានប្រសិទ្ធិភាព តាមការចុះផ្ទាល់ ការផ្សព្វផ្សាយ ចែកខិតប័ណ្ណតាម អ៊ីនធើ-ណែតអ៊ីម៉ែល តាមទូរស័ព្ទ ការបង្រៀន ការប្រជុំ ការធ្វើដំណើរ ការមានកម្មវិធីបុណ្យអប់រំផ្សេងៗ ធ្វើសង្គ្រាមចិត្តសាស្ត្រ ពន្យល់ឃោសនាអូសទាញផ្សេងៗ ( ស្គាល់តំរូវការចំណង់របស់ប្រជាពលរដ្ឋ) ។
- ទោះនៅជា ព្រះសង្ឃ សិស្ស និងនិស្សិតក្តី ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានភារះ និងកាតព្វកិច្ច ចូលរួមចំណែកជួយគ្នាផ្សព្វផ្សាយ ចងក្រងកំលាំងស្នេហាជាតិ ដើម្បីធ្វើឱ្យ **ជាតិខ្មែររស់** ។ ( ស្រីខូចយួនហ៊ានលះបង់គ្រប់បែបយ៉ាង ដើម្បីលេបយកទឹកដីខ្មែរ ចុះយើងជាខ្មែរមួយរូប មិនហ៊ានលះបង់ក្រោក ឈរឡើង ការពារជាតិ ទឹកដីរបស់ខ្លួនឬមួយយ៉ាងណា? ) ។
- រៀបចំចងក្រង សាងសាមគ្គីខ្មែរជាធ្លុងមួយ បង្កើតឱកាស ដើម្បីផ្តើមវាយលុក លើសត្រូវ របស់ជាតិដោយមានប្រសិទ្ធិភាព ។
- ពង្រីកបណ្តាញមេដឹកនាំជាតិខ្មែរអោយបានទូទាំងប្រទេស (ធ្វើដូចសត្វព្រាប ពេលត្រូវលប់ព្រានព្រៃសត្វព្រាបបានស្ទុះឡើងទាំងអស់គ្នា) ។
- បណ្តុះបណ្តាលប្រជាពលរដ្ឋខ្មែរ អោយធ្វើជាអ្នកដឹកនាំជាតិខ្មែរដោយខ្លួនឯង គ្រប់ស្រទាប់ក្នុងសង្គម
- ជោគជ័យនៃការវាយលុក អាស្រ័យលើការបំភ័ន្តមានប្រសិទ្ធភាព ។
- ប្រឆាំងគោលនយោបាយ ៧ មករា ១៩៧៩ និងមនោគមន៍គ្រប់បែបយ៉ាងរបស់ **ហេង សំរិន ហ៊ុន សែន** ( មិនមែន យួនរំដោះទេ) គឺ យួនឈ្លានពានយកទឹកដីខ្មែរ យួនប្លន់ទ្រព្យ សម្បត្តិខ្មែរ ។

## ៣_ប្រមូលផ្តុំ (Mass)

មេដឹកនាំជាតិខ្មែរត្រូវចេះប្រមូលផ្តុំប្រើប្រាស់ គ្រប់មធ្យោបាយ គ្រប់លទ្ធភាព ធនធាន សំភារៈ ស្មារតី កំលាំងចិត្តកាយ បញ្ញា របស់អ្នកស្នេហាជាតិ និង បច្ចេកទេស ដែលមាន ដើម្បីធ្វើការវាយលុកទៅលើចំណុចខ្សោយរបស់ខ្មាំង តាមគ្រប់ច្រកល្ហក មិនថា យប់ថ្ងៃ ឡើយ ។ ក្រៅពីនេះ ត្រូវយល់ច្បាស់ថា ក្នុងការតស៊ូ យើងត្រូវ ប្រើទាំង នយោបាយ ការទូត កងទព័សេដ្ឋកិច្ច ហិរញ្ញវត្ថុ និងការឃោសនា ផ្សេងៗ រួមផ្សំព្រមគ្នា ពេលតែមួយ ទើបយើងអាច ទទួលបាននូវជោគជយ័ ។ យើងមិនត្រូវដើរ តាមគន្លងយុទ្ធសាស្ត្ររបស់ខ្មាំង គូសអោយយើងឡើយ ។ សត្រូវ វាកាប់ វាសំលាប់ខ្មែរ តាមគ្រប់រូបភាព តាមបែបចំហរ បែបសំងាត់ បែបភេរវកម្ម ដោយមិនរើសមុខ ។ យើងជាខ្មែរ ជាមនុស្ស ជាម្ចាស់ទឹកដី មានបុព្វសិទ្ធពីកំណើតពេញលេញក្នុងការរស់រាននៅលើទឹកដីដូនតាខ្មែរ ជាជាតិមួយ នៅលើលោកយើងនេះ មានសិទ្ធស្របច្បាប់ ក្នុងការតបត ដើម្បីការពារអាយុ ជីវិតជាតិសាសន៍របស់យើង តាមគ្រប់រូបភាព ទាំងហឹង្សា និងអហឹង្សា ។ លើសពីនេះ យើងមិនត្រូវ ផ្តេកផ្តួលដេក ចាំទាល់តែ មានជំនួយបរទេស ទើបយើងងើបឡើងធ្វើការតស៊ូរំដោះប្រទេសជាតិនោះឡើយ ។ ផ្ទុយទៅវិញ ត្រូវចេះរិះរកប្រមូលយក ធនធានដែលមានស្រាប់ នៅក្នុងស្រុក ដែលត្រូវពួកក្បត់ ឆក់ប្លន់យកទៅ យកមកធ្វើការបំរើប្រយោជន៍អោយជាតិ និងប្រជាជាតិយើងវិញ ។ ដូចគ្នានឹង ទ្រឹស្តី របស់សង្គ្រាមវិទូចិន ពោលថា "*ក្នុងកាលៈទេសៈ សង្គ្រាម យើងតែមានការ ខ្វះខាតជាធម្មតា ហេតុនេះហើយ បើយើងអត់អាវុធ ត្រូវវាយដណ្តើមអាវុធពីខ្មាំង បើអត់ស្បៀងត្រូវដណ្តើមស្បៀងពីខ្មាំង បើអត់ហិរញ្ញវត្ថុ( លុយកាក់ថវិកាសំរាប់ការតស៊ូ) ត្រូវដណ្តើមពីខ្មាំង* "។

ការចេះប្រមូលផ្តុំធនធានក្នុងស្រុកធ្វើការតស៊ូ ដោយស្មារតីខ្លួនទីពឹងខ្លួន នេះហើយ ដែលអាចអោយយើងជៀសចាកផុតពីភាពខ្ញុំគេ ។ ការរៀបរាប់បែបនេះ មិនមែនមានន័យថា យើងមិនត្រូវការជំនួយបរទេសនោះទេ ។ តែជំនួយដែលសំរាប់

សំលាប់ខ្មែរ សំរាប់ធ្វើអោយយើងបែកបាក់គ្នា ដូចជំនួយ យួន ជួយពួកអាយ៉ង ហ៊ុន សែន នោះយើងនឹងមិនទទួលយកឡើយ។ យើងពេញចិត្តនឹងទទួលយករាល់ជំនួយដែល ជួយគ្នាទៅវិញទៅមក ក្នុងផលប្រយោជន៍រួមគ្នា ក្នុងនាមជាប្រជាជាតិដូចគ្នាក្នុងលោក។ ជំនួយបែបនេះកើតមានទៅបាន លុះណាតែយើងប្រឹងប្រែង ប្រមូលធនធានដែលមានស្រាប់ធ្វើអោយមានរូបរាងសិនទើបមានគេជួយយើង។ ចូរចាំជាក់ក្នុងចិត្តថា " ***ព្រះលោកជួយ អ្នកដែលជួយខ្លួនឯងជាមុន*** " ឬក៏ថា " ***សំណាងកើតមានដល់អ្នកដែលខិតខំប្រឹងកសាងអ្វីមួយឡើង*** *មិនមែនដោយការដេកបែបន់តែម្យ៉ាងនោះសោះឡើយ* "។

### ៤-កលល្បិច (Maneuver)

ការឃោសនា ការប្រយុទ្ធ ការវាយប្រហារលើសត្រូវ ត្រូវធ្វើការផ្លាស់ប្តូរចុះឡើង ទាំងពេលវេលា រូបភាព បែបផែន និងទំរង់នៃក្បួនប្រយុទ្ធ។ បានន័យថាម្តងដោយ **បែបភ្លឺ**(Direct Method) ម្តង**បែបងងឹត**(Indirect Method) ម្តង **ចំហរ** ម្តង **សំងាត់** ម្តង **ដោយត្រង់** ម្តង **ដោយប្រយោល** ម្តង **លេងៗ** ម្តង **មែនទែន** ម្តង**យប់** ម្តង**ថ្ងៃ** ម្តង**ព្រឹក** ម្តង**ល្ងាច**។ តើអ្នក ណាមួយ អាចទស្សន៍ទាយថា ខ្សែទ្រ តែពីរសោះ គេអាចលេងបទភ្លេងបានត្រឹមប៉ុន្មានបទ គឺពិតជាមិនអាចទស្សន៍ទាយបាន ទាល់តែសោះ។ យ៉ាងណាមិញ ការប្រើកលល្បិច ប្តូរចុះឡើងជាហេតុ ធ្វើអោយសត្រូវមិនអាច ទស្សន៍ទាយត្រូវ ប៉ាន់ស្មានបាន ឬចាត់វិធានការទប់ទល់នឹងយើងបានឡើយ។ មិនតែប៉ុណ្ណោះ វាអាចធ្វើអោយ យើង រក្សាបាននូវ **វិសាលភាពក្នុងការផ្តួចផ្តើមគំនិត** (Freedom of Initiative) និង **ប្រៀបខាងសកម្មភាព** (Freedom of Action) ទៀតផង។

#### ក-យួនយកស្រីធ្វើធ្នាក់ទាក់អ្នកដឹកនាំ

ដើម្បីវាតទីទឹកដីលើប្រទេសចម្ប៉ា យួនបានញុះញង់អោយប្រទេសចំប៉ាបែកបាក់ផ្ទៃក្នុង ដោយយួនប្រើល្បិចយកស្រីស្អាតយួនជាចារកម្មឈ្មោះ **នាងដុក** ឬ **ពាងសះ** មករៀបការជាមួយស្តេចចាម។ **នាងដុក** សុំអោយស្តេចចាម ចិញ្ចឹមបងប្អូនជនជាតិយួន ចំនួន ៧០គ្រួសារផង។ **នាងដុក** បាននាំយួនមករស់នៅក្នុងវាំង ក្រោយមកនាង **នាងដុក** បានប្រើល្បិចធ្វើជាឈឺ និយាយត្រូវគ្នាជាមួយគ្រូទាយថា នាងឈឺគឺបណ្តាលមកពីវត្ថុសាកសិទ្ធិ ដែលប្រជាពលរដ្ឋចាមគោរពបូជានោះឯង។ ស្តេចចាម ក៏បញ្ជារអោយគេយកវត្ថុ ដែលប្រជាពលរដ្ឋចាមគោរពបូជានោះចោល ជាហេតុបណ្តាលអោយក្តៅក្រហាយដល់ប្រជាពលរដ្ឋចាម។ ប្រជាពលរដ្ឋចាមឈប់គាំទ្រស្តេច បះបោរឡើង ឆ្លៀតពេលនោះ យួនបានសម្លាប់ស្តេចចាមចោលហើយបានឡើង គ្រប់គ្រងត្រួតត្រា នគរចំប៉ាចាប់ពីឆ្នាំ១៤៧១ រហូតមកដល់បច្ចុប្បន្ន។

បន្ទាប់មកយួនប្រើល្បិចយកស្រីយួនដ៏ស្អាតព្រះនាម **ភូខិន** ទៅថ្វាយស្តេចខ្មែរ គឺព្រះបាទ **ជ័យជេដ្ឋាទី២**។ យួនបានសុំទឹកដីខ្មែរ(ខេត្តព្រៃនគរ និង កោះក្របី) ពីស្តេចខ្មែរ ដើម្បីហ្វឹកហាត់កងទ័ព។ យួនសុំអោយប្រជាពលរដ្ឋយួន មករស់នៅដោយគ្មានបង់ពន្ធអាករ ដោយយកលេសថា យួនជាបងប្អូន។ ប្រជាជនយួនកាន់តែមានចំនួនកំណើនច្រើនឡើង មិនអាចដោះស្រាយបាន។ យួនបានបង្កសង្គ្រាមផ្តាវីកធ្វើគត់**ព្រះបាទជ័យជេដ្ឋាទី២**ទៅ នៅឆ្នាំ១៦២៨។ ព្រៃនគរ និងកោះ ក្របីក៏ស្ថិត នៅក្រោមការកាន់កាប់របស់យួនតាំងពីពេលនោះមក ហើយទឹកដីនោះត្រូវបានយួន ដាក់ឈ្មោះ **កូចឹនស៊ិន**(Co Chin Xin) មានន័យថា ទឹកដី " ព្រះនាងទី៩សុំ" ។ លុះអាណានិគមន៍បារាំងមកដល់ក៏ហៅតំបន់នោះថា កូសាំងស៊ីន (Cochinchine)។

យួនបានពង្រីកបណ្តាញចារកម្មចូលមកទឹកដីខ្មែរក្រោម បញ្ជូនចារនារីយួនស្អាតៗ អោយធ្វើជាប្រពន្ធបារាំងនិង ធ្វើជាអ្នកបំរើបារាំង។ ក្រោយពីបណ្តាញយួនចូលគ្រប់ក្នុងសភាហើយ យួនបានទាមទារទឹកដីកម្ពុជាក្រោម ថាជាកម្មសិទ្ធិរបស់យួន។ ក្រោយមកបារាំង បានកាត់ទឹកដីកម្ពុជាក្រោម ទៅអោយយួនពេញសិទ្ធិ ក្នុងរាជស្តេច **បាវ ដាយ** នៅថ្ងៃទី ៤មិថុនា ឆ្នាំ១៩៤៩។ នៅពេលនោះប្រទេសខ្មែរស្ថិតក្នុងរជ្ជកាលព្រះបាទ **នរោត្តម សីហនុ** ក្នុងសម័យអណានិគមនីបារាំង។ ខ្មែរក្រោមបានងើបឡើង បះបោរប្រឆាំងយួន ទាមទាងករាជ្យទឹកដីវិញ តែត្រូវអង្វាធរយួនបង្ក្រាបយ៉ាងសាហាវឃោរឃៅ បំផុត ដូចជាសំលាប់ខ្មែរក្រោម ដោយជីកដីកប់ដាំក្បាលតែអុង ដោយចាក់សោរដាក់ក្នុងជង្រុកស្រូវដុតទាំងរស់ ការអោយជីកព្រែក ហើយទំលាយទំនប់អោយលង់ស្លាប់ទាំងរស់ ទាំងម៉ឺន ទាំងសែននាក់ ។ល។ វិរបុរសខ្មែរក្រោមរាប់មិនអស់ បានធ្វើការ តស៊ូ ប្តូរបូជាជីវិត ដើម្បីការពារ ប្រជាជាតិខ្មែរ វប្បធម៌ ប្រពៃណីយរបស់ខ្មែរ នៅកម្ពុជាក្រោមនោះជាវៀងរហូតមក។







### ៩-ល្បិចក្តៅធ្វើសង្គ្រាមឈ្លានពានខ្មែរ

៣-តើមានឯកភាពផ្ទៃក្នុងឬទៅ ថ្នាក់លើ ថ្នាក់ក្រោម មានគំនិតដូចគ្នាឬទេ?
៤-យើងជាមេទ័ព ត្រូវប្រើគំនិតឈ្លៀសវៃ និងមានឥស្សរភាពក្នុងការគិតថ្លឹងថ្លែង។
៥-ត្រៀមគ្រប់យ៉ាងដើម្បីវាយបកទៅលើសត្រូវ

### ខ-ខ្នាតគំរូ

ការអនុវត្តន៍ គំរោងការមួយពេញលេញ ត្រូវមានវត្ថុ ៣ យ៉ាង ដែលត្រូវទាក់ទងគ្នា គឺ ខ្នាតគំរូ ការអនុវត្ត និង ការកែតំរូវ។ ខ្នាតគំរូ គឺជាគំរោងការ ដែលត្រូវបានបញ្ចប់ ដោយជោគជ័យតាមផែនការ។ ខ្នាតគំរូ គឺត្រូវបានរៀបចំអោយមានដូចគ្នាតាំង ពីថ្នាក់លើ ដល់ក្រោម។ ការអនុវត្តន៍ ត្រូវបានប្រតិបត្តិ ទៅតាមការកំណត់ទុក តាមលំដាប់លំដោយ និងត្រូវបញ្ចប់ទៅតាមទិសដៅ យ៉ាងត្រឹមត្រូវ។ នៅពេលប្រតិបត្តិ ខ្នាតគំរូនៃគំរោងការមួយ មេដឹកនាំ ត្រូវផ្តោតលើដំណើរការ ការអនុវត្ត និងសកម្មភាពមនុស្សតាមភារកិច្ចមួយៗ ។ បើមើលឃើញថា មានកំហុសឆ្គងកើតមានឡើងខុសពី ខ្នាតគំរូ ត្រូវធ្វើការកែតំរូវភ្លាម។

ដើម្បីធ្វើឱ្យមាន ខ្នាតគំរូ ត្រូវឆ្លងកាត់ ការអនុវត្តសាកល្បង ឬការអនុវត្តពិត ញឹកញាប់ ដោយមានការកត់ត្រាទុកដាក់ជាឯកសារត្រឹមត្រូវ ហើយនិងការកែតំរូវ ដោយយកចិត្តទុកដាក់បំផុត។ ជាងនេះទៅទៀត ត្រូវចាត់ឱ្យមានកាគ្រប់គ្រងដឹកនាំ និងត្រួតពិនិត្យតាមដានការងារនោះដោយហ្មត់ចត់ ដើម្បីធ្វើឱ្យកិច្ចការនោះប្រព្រឹត្តទៅតាម គំរោងការរបស់យើងដែលបានគ្រោងទុកមកហើយ។

### គ-ពិនិត្យបញ្ជាក់លើផែនការ (Verify)

ក្រោយពេល ធ្វើផែនការរួចស្រេចហើយ មេដឹកនាំ ត្រូវពិនិត្យពិចារណាផែនការនោះសារចុះសាឡើង ធ្វើយ៉ាងណាអោយផែនការនោះ កាន់តែមានភាពសុក្រិត និងស្របទៅនិងស្ថានការណ៍កំពុងវិវត្តន៍។ ការពិនិត្យបញ្ជាក់ ជាការប្រៀបធៀបរវាងចំណុចខ្សោយ ចំណុចខ្លាំង ឱកាស និងការគំរាមកំហែងនានា (ច្បាប់ នយោបាយ សេដ្ឋកិច្ច បរិដ្ឋាន អាកាសធាតុ បច្ចេកទេស សង្គម វប្បធម៌។ល។) ទាំងខាងខ្លួនយើង និងសត្រូវ។ ការធ្វើផែនការត្រូវធានាថា ផែនការនេះ ប្រាកដ ជាគេអាច យកទៅអនុវត្តន៍បាន និងមានធនធានល្មមសម តាមផែនការ បើមិនដូច្នោះទេ ផែនការនេះបានត្រឹមតែជា ការសុបិន្តមួយ ប៉ុណ្ណោះ។ ការសិក្សាបញ្ជាក់ គួរចាត់ឱ្យមានការចោទសួរ ដោះស្រាយក្នុងរង្វង់ សមាជិកសំខាន់ៗឱ្យបានហ្មត់ចត់បំផុត ។

### ឃ-សាកល្បង (Testing)

ក្រោយពេល ពិនិត្យច្បាស់លាស់លើផែនការនោះហើយ យើងត្រូវយកមកធ្វើការសាកល្បង ដើម្បីអោយអ្នក អនុវត្តន៍នោះ អាចយល់កាន់តែច្បាស់ អំពីស្ថានការណ៍ នៅលើតារាង ធៀបទៅនិង ភូមិសាស្ត្រពិតប្រាដក ធ្វើតាមផែនការ ដែលនិងអនុវត្ត ជាក់ស្តែងពេលខាងមុខ។ ការធ្វើសាកល្បងនោះ ត្រូវធ្វើទាល់តែ អ្នកអនុវត្តកិច្ចការនោះយល់ច្បាស់ និងអាចធ្វើបានល្អ ព្រោះថា នៅពេលអនុវត្តជាក់ស្តែងនោះ វាខុសពីការសាកល្បងទៅទៀត។ ការសាកល្បងកម្លាំងពិត ត្រូវជាមនុស្សដែលគោរពធ្វើគោលការណ៍ទាំងស្រុង និង អនុវត្តន៍តាមបទបញ្ជា របស់ស្ថាប័នណាមួយពិតប្រាកដ។

### ង-ការកែតំរូវ (Adjustment)

បើការអនុវត្តមិនធ្វើតាម ខ្នាតគំរូ យើងមានការពិបាកក្នុងការកែតំរូវ ឬធ្វើខ្នាតគំរូនោះឱ្យល្អឡើង។ តែបើយើងអនុវត្ត តាមខ្នាតគំរូ ហើយមានភាពមិនល្អ ពេលនោះការកែតំរូវ អាចត្រូវធ្វើឡើងដោយបែងចែកជាពីរ។ បណ្តុះបណ្តាលអ្នកអនុវត្តន៍បន្ថែម និងកែតំរូវខ្នាតគំរូ ដែលមានចំណុចចន្លោះប្រហោង។ ដើម្បីទទួលបានជោគជ័យ អ្នកដឹកនាំជាតិខ្មែរ ត្រូវតែគោរពតាមច្បាប់ បទបញ្ជាផ្ទៃក្នុង វិន័យ គោលការណ៍ផ្សេងៗ។ បើ អ្នក ដឹកនាំ និងសមាជិក គ្មានវិន័យក្នុងការប្រតិបត្តិមុខងារទេផែនការ នោះក៏មិនអាចទទួលបានជោគជ័យដែរ។ ហេតុដូច្នេះហើយ បើសង្កេតឃើញថា មានការប្រព្រឹត្តខុសពីគោលការណ៍ ឬមិនគោរពវិន័យ ត្រូវកែតំរូវទៅតាម ច្បាប់វិន័យ គោលការណ៍ ដែលបានកំណត់ភ្លាម។

## ៣_អនុវត្ត

នៅពេលដែលយើង បានរៀបចំផែនការ ធ្វើការសាកល្បង កែតំរូវ សារចុះឡើងបានល្អត្រឹមត្រូវ រួចស្រេចបាច់ហើយនោះ ផែនការរបស់យើង នឹងមានដំណើរការរលូនទៅបានហើយ។ តែបើសិនជាផែនការមានកំហុសឆ្គង ពេលនោះគំរោង ការរបស់យើង នឹងជួបឧបទ្ទវការលំបាកស្មុគស្មាញជាក់ជាមិនខាន ហើយអាចធ្វើឱ្យយើង ត្រូវប្រើរយះពេលវែង ដើម្បីធ្វើកិច្ចការបានសំរេច។ ម្យ៉ាងវិញទៀត បើទោះជាផែនការល្អម្តេចក្តី ក៏គង់នៅត្រូវការអ្នកដឹកនាំ អនុវត្តផែនការនោះ ប្រកបដោយភាពឆ្លាតវៃ(Intelligent) មានការពិសោធន៍ក្នុងការងារ(Good Experience) ចេះបត់បែន(Flexibility)និងមានឆន្ទៈមោះមុត (High Moral) ឱ្យស្របទៅតាមស្ថានការណ៍ និងបរិបទនៃផែនការរបស់យើង ដើម្បីធ្វើ យ៉ាងណាឱ្យផែនការរបស់ យើងទទួលបានជោគជយ័ យ៉ាងជាច់ខាត។ អ្នកដឹកនាំ ត្រូវតែមានឆន្ទៈខ្ពស់ក្នុងការធ្វើឱ្យកិច្ចការនោះបានសំរេចជោគជយ័។

## ៤_ត្រួតពិនិត្យ (Controlling)

ការអនុវត្តទៀតសោត ត្រូវរៀបចំឱ្យមាន ប្រពន្ធ័ត្រួតពិនិត្យតាមដានមួយច្បាស់លាស់ ដើម្បីធានាថា កិច្ចការទាំងអស់ត្រូវបាន អនុវត្តទៅតាមគំរោងការ និងការដឹកនាំរបស់យើងទាំងស្រុង។ តាមការពិសោធន៍ក្នុងការតស៊ូកន្លងមក បានបង្ហាញឱ្យឃើញថា ផែនការប្រយុទ្ធទាំងឡាយត្រូវ រៀបចំយ៉ាងសមរម្យ ក៏ប៉ុន្តែដោយការសិរិតសំរាំងជ្រើសរើស ក្របខណ្ឌ័អ្នកដឹកនាំមិនបានល្អ ជាហេតុធ្វើឱ្យអ្នកដឹកនាំ ខ្លះតែងភូតភរកុហាត ប្រឌិតពតិមាន។ ឧទាហរណ៍នៅក្នុងការតស៊ូប្រយុទ្ធនៅជាយដែន ដោយភាពកំសាករបស់ខ្លួន នាយទាហានខ្លះ បានភូតកុហកមកថ្នាក់លើ ថា ខ្មាំងឡើងដល់ត្រឹមនេះ ត្រឹមនោះ ឬក៏កុហកថា ខ្លួន វាយឡើង ដល់នេះដល់នោះ តែតាមការពិត ពួកនាយទាហានទាំងនោះ នៅផឹកស្រា ឱបស្រី នៅចំងាយ ១០ ឬ ២០គីឡូម៉ែត្រពី ខ្សែប្រយុទ្ធជួរមុខទៅវិញ។ ហេតុដូច្នេះ ហើយការត្រូវ ពិនិត្យត្រូវតែរៀបចំឱ្យមានបែបជាប្រពន្ធ័មួយ ដ៏មានប្រសិទ្ធភាព ដើម្បីចៀសវាង កំហុសឆ្គងដូចខាងលើនេះ។ ព្រោះ ការអនុវត្ត ដូចខាងលើនេះ ជាកត្តានាំឱ្យបរាជយ័មានមកដល់ខ្លួនយើងទាំងអស់គ្នាដោយចៀសមិនរួច ។ លើសពីនេះ ជាការសំលាប់ ឆន្ទះប្រយុទ្ធ និងជាការបំផ្លាញការជឿទុកចិត្តគ្នាថែមទៀតផង។ កំហុសឆ្គងបែបនេះ កើតមានជាញឹកញាប់ នៅក្នុងជួរអ្នកតស៊ូ ទាំងអតីតកាល និង បច្ចុប្បន្ន ហេតុនេះហើយ អ្នកដឹកនាំ មិនត្រូវធ្វេសប្រហែស ឬជឿទុកចិត្តងាយ ទៅលើទង្វើរបស់អ្នកក្រោមសោះឡើយ។ ត្រូវតែរៀបចំឱ្យមានការត្រួតពិនិត្យតាមដានការអនុវត្តការងារជាប់រហូតដល់សំរេចបានជោគជយ័ជាស្ថាពរ។

### ៥-ពិនិត្យលទ្ធផល (Result)

ចុងបញ្ចប់ មេដឹកនាំត្រូវពិនិត្យមើលលទ្ធផលរបស់ផែនការ តើទទួលបានជោគជ័យ ឬបរាជ័យ បើជោគជ័យ តើដូចផែនការ ដែលចង់បានឬទេ? ឬបានប៉ុន្មានភាគរយ? បើសិនជា បានជោគជ័យ តើត្រូវចំណាយធនធានប៉ុណ្ណា ។ បើសិនជាជោគជ័យនោះ ត្រូវច្រើនហួសប្រមាណ ខូចខាតសំភារះឧបករណ៏ ផ្សេងៗច្រើននោះ ក៏មិនមែនជាជោគជ័យពិតប្រាកដទេ។ ចូរចាំថា ផែនការល្អ ត្រូវចំណាយធនធានតិច តែមានប្រសិទ្ធភាព អាចទទួលជោគជ័យបានជាអតិបរមា ឬក៏ថា " ជោគជយ័របស់អ្នកដឹកនាំ ត្រូវចំណាយធនធានទាំងមនុស្ស សំភារះ ថវិកាតិចបំផុត និងនាំទាហានមកវិញដោយមិនមានហូរឈាមមួយចំអែតមូស មិនប៉ះពាល់ទ្រព្យសម្បត្តិ ឬទឹកចិត្តប្រជាពលរដ្ឋ តែបានផលជាអតិបរមា ទើបចាត់ទុកថាជោគជ័យ មួយរយ ភាគរយបាន " តែបើមានការខូចខាតច្រើន បើទោះជាសមរភូមិនោះ យើងដណ្តើមបានទាំងស្រុងក្តី មិនចាត់ទុកថា យើងមានជោគជយ័ ពេញលេញឡើយ ។

### ៦-សិក្សាឡើងវិញ (After Action Review)

ក្រោយពីបញ្ចប់ផែនការ ទោះជាផែនការនោះបរាជ័យ ឬ ជោគជ័យ អ្នក ដឹកនាំ ចាំបាច់ត្រូវយកមកសិក្សាសារ ឡើងវិញ អំពីរមូលហេតុដែលធ្វើអោយបរាជ័យ និង កត្តាដែលនាំអោយទទួលបានជោគជ័យ ។ ការសិក្សានេះដើម្បីទុកជាការ ពិសោធន៏សំរាប់អនុវត្តការងារបន្ត ពេលដែលការងារទទួលបានជោគជ័យ ។ បើការងារបរាជ័យ យើងសិក្សាអោយដឹងអំពីចំណុចខ្សោយ ហើយត្រូវដូរយុទ្ធសាស្ត្រថ្មី ឬផ្លាស់ប្តូររិះរកកលយុទ្ធថ្មី ដើម្បីឈានទៅរកជោគជ័យតាមផែនការ ។

ត្រូវរៀបចំធ្វើការវាយតំលៃ ទៅលើលទ្ធផលការងារ ទៅលើការអនុវត្តម្តងៗ រៀងរាល់រាល់ខែ  ឬរបាយការណ៏ពតិមាន និង លទ្ធផលការងារដែលទទួលបាន តើវាទទួលបានផលប្រយោជន៏សមតុល្យទៅនឹងការចំណាយ ធនធាន ពេលវេលា ដែលយើង បានប្រើឬទេ ខាតឬ ចំណេញ។ ត្រូវប្រៀបធៀប ចាប់តាំងពីធនធាន ពេលវេលា សំភារះ បច្ចេកទេស កំលាំង និងការចំណាយទាំងអស់ ដែលបានប្រើប្រាស់ក្នុងបេសកកម្មនេះ។ បើសិន ជាចំណាយដើមទុនតិច តែបានផលច្រើននោះ យើងត្រូវចំណាយ តែបើចំណាយទុនច្រើន យើងបានចំណេញតិច គួរកែប្រែ ឬធ្វើការសិក្សារៀបចំ កែតំរូវឡើងវិញ។

## VIII-ការជួបប្រជុំ ( Meetings)

ការជួបប្រជុំ ជាកត្តាសំខាន់ណាស់ សំរាប់អ្នកដឹកនាំជាតិខ្មែរ។ អ្នកដឹកនាំជាតិខ្មែរ ត្រូវតែជួបប្រជុំជាមួយអ្នក ក្រោមបង្គាប់ សមាជិក ឬប្រជាពលរដ្ឋខ្មែរ អោយបានញឹកញាប់បំផុត។ កាជួបជុំគ្នា កាន់តែញឹកញាប់ កាន់តែប្រសើរ ព្រោះថាការជួបជុំគ្នាអាច អោយមេដឹកនាំ ដឹងពីសុខទុក្ខ របស់អ្នកក្រោម និងមានភាពស្និតស្នាលជាមួយប្រជាពលរដ្ឋ ដឹងពី បញ្ហាកើតមានថ្មីៗ និងអាចអោយយើងមានលទ្ធភាព បង្កើតយុទ្ធសាស្ត្រថ្មីទៀតផង។ ការជួបជុំគ្នានេះ នាំអោយយើងមានគំនិតផ្តួចផ្តើមថ្មីៗទៀត និងអាចឱ្យយើងផ្សព្វផ្សាយពតិមានថ្មីៗដែលកើតមានឡើងដល់អ្នកក្រោមឱវាត ឱ្យបានដឹងទាន់ពេលវេលា ដើម្បីជាការបណ្តុះក្តីសង្ឃឹម និងជំនឿពីអ្នកក្រោមមកលើខ្លួនយើង និងអង្គការនយោបាយរបស់យើង។ មេដឹកនាំ មិនត្រឹមតែ ជាអ្នកដឹកនាំនោះទេ តែត្រូវអោយអ្នកក្រោមបង្គាប់ បានឃើញ និងអោយគេយល់ដឹងនូវអ្វី ដែលយើងបាន និងកំពុងតែធ្វើ។ ហេតុ

ដូច្នេះ យើងជាអ្នកដឹកនាំ ត្រូវបង្ហាញខ្លួនឱ្យអ្នកក្រោមបានឃើញ បានជួបទាក់ទង ដើម្បីបំបាត់ជញ្ជាំងនៃការមន្ទិលលើគ្នាទៅវិញទៅមក។ ការដែល ជួបជាមួយសមាជិក ឬ ប្រជាពលរដ្ឋផ្ទាល់ មានសារៈ សំខាន់ណាស់ អាចធ្វើអោយមេដឹកនាំ ½

- ដឹងនូវបញ្ហាដែលបាន នឹងកំពុងកើតឡើង
- ជាការលើកទឹកចិត្ត ដល់សមាជិក និងប្រជាពលរដ្ឋ
- បង្កើនប្រជាប្រិយភាព ដោយការយកចិត្តទុកដាក់ ចាត់ទុកបុគ្គលិក ឬសមាជិកជាមនុស្សសំខាន់
- កាន់តែមានភាពស្និតរមួត និងស្គាល់ចិត្តសមាជិក
- ស្គាល់ស្ថានការណ៍កាន់តែច្បាស់
- ធ្វើឱ្យអ្នកក្រោមឱវាត បានជ្រួតជ្រាបនូវពត៌មានថ្មីៗ
- កំចាត់នូវការមន្ទិលសង្ស័យផ្សេងៗ ដែលអាចនាំឱ្យមានការបែកបាក់។ ព្យាយាមធ្វើឱ្យមានការយល់ចិត្តគ្នាដូចប្តីប្រពន្ធ ឬបងប្អូន ដោយការស្និទ្ធស្នាល។ ដូចសុភាសិតខ្មែរពោលថា "*ស្នេហ៍មិនឈ្នះស្និទ្ធ ឃ្លាតឆ្ងាយណាយចិត្ត គិតសៅហ្មង*"។ តែការស្និទ្ធស្នាលហួសព្រំដែន នាំឱ្យបាត់បង់តំលៃ ទៅវិញ។

ការជួបប្រជុំនេះ យើងអាចធ្វើឡើងជាផ្លូវការ ឬក្រៅផ្លូវការក៏បានដែរ។ មុននឹងប្រជុំជាផ្លូវការ យើងអាចកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង ឬយើងត្រូវផ្តល់ដំណឹងអោយបានមុន យ៉ាងហោចណាស់មួយសប្តាហ៍ ដោយមានរបៀបវារៈអង្គប្រជុំត្រឹមត្រូវ និងកំណត់ពេលវេលាច្បាស់លាស់។ ដើម្បីទាក់ទាញ អោយអង្គប្រជុំមានការចាប់អារម្មណ៍ មេដឹកនាំត្រូវ ផ្តល់ផលប្រយោជន៍ គួរជាទីពេញចិត្តមួយដល់អ្នកចូលរួម។

### **ដំណើរការនៃការប្រជុំ**

- ត្រៀមរៀបចំអង្គប្រជុំ (ត្រូវត្រៀមបំរុងនូវ របៀបវារៈ ដែលត្រូវលើកយកទៅសិក្សាក្នុងអង្គប្រជុំនោះ)
- ត្រៀមចូលរួមអង្គប្រជុំ (ត្រូវត្រៀម នូវគំនិត ឯកសារ និងបញ្ហាផ្សេងៗដែលត្រូវដោះស្រាយ)
- កំណត់កន្លែងសំរាប់អង្គប្រជុំ
- កំណត់អ្នកចូលរួមអង្គប្រជុំ
- ចាប់ផ្តើមអង្គប្រជុំ
- ដឹកនាំប្រជុំ
- អង្គប្រជុំដំណើរការទៅមុខ
- បិទអង្គប្រជុំ
- វាយតំលៃអង្គប្រជុំ

## **IX. ការលើកទឹកចិត្តសមាជិក (Motivation)**

ការលើកទឹកចិត្តដល់សមាជិក ឬអ្នកក្រោមបង្គាប់ ជាការសំខាន់ណាស់ សំរាប់មេដឹកនាំ ដើម្បីធ្វើអោយបរិយាកាសការងារល្អ និងធ្វើអោយអ្នកក្រោមបង្គាប់ សុខចិត្តលះបង់គ្រប់បែបយ៉ាង ធ្វើការងារ ជូនជាតិ និងប្រជាជាតិ អោយបានសំរេចជោគជ័យ។ ក្នុងការលើកទឹកចិត្ត យើងជាមេដឹកនាំត្រូវស្គាល់ ពីធម្មជាតិ របស់មនុស្ស ពោល គឺ ត្រូវស្គាល់អោយច្បាស់នូវសមាជិក របស់យើង ហើយត្រូវផ្តល់ ការយកចិត្តទុកដាក់ និង ត្រូវរួមសុខរួមទុកជាមួយគ្នា។ ត្រូវចាំថា បើយើងចង់អោយ

អ្នកក្រោមស្រឡាញ់គោរពយើងយ៉ាងណា យើងត្រូវធ្វើចំពោះអ្នកក្រោមបង្គាប់ យ៉ាងនោះជាមុន។ យើងជាមេដឹកនាំ ត្រូវស្គាល់ ពីតំរូវការរបស់អ្នកក្រោម តាមទ្រឹស្តីលោក ម៉ាស្លូវ :

**ធម្មជាតិរបស់មនុស្ស មានសេចក្តីត្រូវការដូចខាងក្រោមនេះ**½

**១-សេចក្តីត្រូវការទី១:** ជំរក ម្ហូបអាហារ និងសំលៀកបំពាក់ដើម្បីរស់នៅ

**២-សេចក្តីត្រូវការទី២:** មានសុខភាពល្អ និងសុវត្ថិភាពក្នុងការរស់នៅ

**៣-សេចក្តីត្រូវការទី៣:** ចូលរួមក្នុងសង្គមដោយមានកិត្តិយស កេរ្តិ៍ឈ្មោះ ការគោរពរាប់អានពីមជ្ឈដ្ឋានក្នុងសង្គម។

**៤-សេចក្តីត្រូវការទី៤:** មានស្នាដៃ

**៥-សេចក្តីត្រូវការទី៥:** សុខសុភមង្គលគ្មានទីបញ្ចប់ គឺគ្មានទុក្ខ ស្វែងរកព្រះ ធម៌ដើម្បីចូលនិញ្វន្ត។

អ្នកដឹកនាំខ្មែរ ត្រូវស្គាល់តំរូវការរបស់មនុស្សទៅតាមកាលៈទេសៈ និងពេលវេលាផ្សេងៗគ្នា។ សេចក្តីត្រូវការ របស់មនុស្សមិនដូចគ្នាទេ អាស្រ័យតាមញាណទាំង៦ របស់ម្នាក់ៗ។ ចូរ និយាយអ្វី? ធ្វើអ្វី? ដែលអ្នកក្រោមបង្គាប់ ឬប្រជាពលរដ្ឋត្រូវការចង់ស្តាប់ ឬចង់បាន។ យើងមិនត្រូវនិយាយ ឬធ្វើអ្វីតាមអារម្មណ៍ខ្លួនឯង តាមសេចក្តីត្រូវការខ្លួនឯង ឬដែលធ្វើឱ្យប៉ះពាល់ដល់ជំនឿ អារម្មណ៍របស់អ្នកស្តាប់ អ្នកក្រោមឱវាតនោះឡើយ។ ការលើកទឹកចិត្ត សំរាប់អ្នកក្រោមបង្គាប់មានគ្រប់ពេលវេលា គ្រប់រូបបែបទាំងអស់ តាំងពី មាស ប្រាក់ ប្បើវត្សគ្រប់គ្រាន់ ការងារមាន សន្តិសុខ និងមុខមាត់ក្នុងសង្គមជាដើម។ល។

## ៦-ត្រូវបន្តផ្តល់ពត៌មានអោយសមាជិក ឬអ្នកក្រោមបង្គាប់ផ្លូតផ្ទាល់:

ដូចពោលខ្លះៗពីខាងលើមកហើយ អ្នកដឹកនាំខ្មែរ ត្រូវផ្តល់នូវដំណឹងពីការវិវត្តន៍នៃកិច្ចការ ដែលកើតឡើងជាបន្តបន្ទាប់ អោយអ្នកក្រោមបានដឹង និង ជំរុញអោយអ្នកក្រោម បង្គាប់មានការទទួលខុសត្រូវកាន់តែខ្ពស់ឡើង។ ការជំរុញ ឱ្យសមាជិក រកពត៌មានដោយខ្លួនឯង តាម ការសែត វិទ្យុ ទូរទស្សន៍ ភ្នាក់ងារពត៌មាន ឬតាមរយៈសមាជិកក្រោមបង្គាប់ របស់ខ្លួន ជាវិធី ធ្វើឱ្យសមាជិក មានការចេះដឹងកើនឡើងជាលំដាប់ ដោយស្មានមិនដល់។ ហេតុដូច្នេះហើយ អ្នកដឹកនាំខ្មែរ មិនត្រូវធ្វេសប្រហែសក្នុងការផ្សព្វផ្សាយពត៌មានដល់អ្នកក្រោមបង្គាប់សោះឡើយ។

## ៧-ការលើកទឹកចិត្តមាន

- ផ្តល់ជារង្វាន់ លុយកាក់ សំភារៈ ផ្ទះសំបែង ដីធ្លី
- តំលើងបុណ្យសក្តិ
- ស្និទ្ធស្នាល ស្និតរមួត
- សរសើរផ្ទាល់មាត់
- បំពេញតំរូវការចាំបាច់របស់សមាជិក
- ជួយអោយអ្នកក្រោមបង្គាប់បានសំរេចគោលដៅ និង ជោគជ័យ

## X. ការប្រាស្រ័យទាក់ទង (Communication)

ការប្រាស្រ័យទាក់ទង មានសារៈសំខាន់ណាស់ ដើម្បីអោយការដឹកនាំ របស់យើង អាចដំណើរការនៅក្នុងអង្គការដឹកនាំនយោបាយ ទទួលបានជោគជ័យ និងដល់គោលដៅ។ យើងត្រូវធ្វើអោយមាន ការប្រាស្រ័យគ្នា ទៅវិញទៅមក ក្នុងលក្ខណៈគោរពមុខងារ គ្នាទៅវិញទៅមក ។ យើងជាមេដឹកនាំត្រូវមាន រក្សានូវឬកពារសាមញ្ញ និងដាក់ខ្លួនអោយទាបចុះ ក្នុងស្រទាប់ប្រជាពលរដ្ឋ និងសមាជិក អោយសក្តិសមតាមកិត្តិយស។ ទំនាក់ទំនង ត្រូវមានឥរិយាបថ វិជ្ជមាន ជានិច្ច ។ ការទាក់ទង ស្និទ្ធស្នាល ជ្រុលហួសហេតុ ខុសទំនង នឹងធ្វើអោយយើង បាត់បង់នូវប្រិយភាព។ ហេតុនេះ យើងជាអ្នកដឹកនាំ ត្រូវមានការប្រុងប្រយត្ន័ គ្រប់ឥរិយាបថ របស់យើង។ ទំនាក់ទំនង ត្រូវធ្វើអោយមានភាពប្រទាក់ប្រទងគ្នា ជាខ្សែសង្វាក់។ ទំនាក់ទំនង មានលក្ខណៈពីរយ៉ាង គឺ *ទំនាក់ទំនងដោយផ្ទាល់* និង *ទំនាក់ទំនង ដោយប្រយោល*។ ត្រូវចាំថា ទំនាក់ទំនង ត្រូវធ្វើអោយស្អិត រមួតក្នុងភាពប្រុងប្រយត្ន័ គឺកុំអោយដាច់អារម្មណ៍ទាំង៦ ពីអ្នកក្រោមបង្គាប់គ្នា។ ហាមធ្វើអោយអ្នកដ៏ទៃស្អប់យើង តែក៏មិនតោងកន្ទុយអ្នកក្រោម រហូតដល់ប្រព្រឹត្តខុសគោលការណ៍ដឹកនាំដែរ។ រាល់ពេលធ្វើការទាក់ទងម្តងៗ ត្រូវមាន គោលបំណង និង គោលដៅ ច្បាស់លាស់។

**ដំហានៃការទាក់ទង**

- ដំណើរការទំនាក់ទំនង
- ទំនាក់ទំនងផ្ទាល់
- រនាំងនៃការទាក់ទង
- ការស្តាប់សកម្មភាព
- ការវាយតំលៃផលត្រឡប់
- ទំនាក់ទំនងប្រយោល




## XI. ការកំណត់មិត្ត និងសត្រូវ

ការតស៊ូត្រូវការយ៉ាងខ្លាំងនូវសាមគ្គីភាពផ្ទៃក្នុងរឹងមាំ និងមានស្ថេរភាពជានិច្ច។ បើគ្មានសាមគ្គីភាពផ្ទៃក្នុងរឹងមាំស្ថិតស្ថេរទេ យើងមិនអាចដណ្តើមយកជោគជ័យ ពីខ្មាំងសត្រូវបានឡើយ។ មានគំរូ គណបក្ស ហ្វ៊ុនស៊ិនប៉ិច ជាឧទាហរណ៍ ដោយសារគ្មានគោលនយោបាយ ក្នុងការរៀបចំ ក្នុងការដឹកនាំច្បាស់លាស់ ធ្វើអោយ អង្គការនយោបាយរាជានិយមនេះ ឈ្នះហើយ ត្រូវបែកបាក់រលំរលាយ សាបសូន្យទៅវិញ។ ប្រការដែលសំខាន់ អង្គការនយោបាយនេះ ស្គាល់សត្រូវមិនច្បាស់ គិតយល់ ច្រឡំថាពួកអាយ៉ង ហ៊ុន សែន, ជា ស៊ីម, ហេង សំរិន វាជាខ្មែរ វាមានគំនិតយោគយល់ដល់ខ្មែរ តែតាមការពិត ពួកក្បត់ជាតិ ទាំងនេះទុកខ្មែរជាសត្រូវ តែទុកយួនជាមិត្តរបស់វា ពោលគឺ វាធ្វើអ្វីៗទៅតាមការ បង្គាប់បញ្ជាពីយួនតែប៉ុណ្ណោះ។ យួន បង្គាប់អោយពួក អាយ៉ង ហ៊ុន សែន, ជា ស៊ីម, ហេង សំរិន ដើរតួរធ្វើជា អ្នករាជានិយម ដើម្បីបោកប្រាស់ស្តេច រាស្ត្រខ្មែរដែលនិយមស្តេច និងដើរតួរជា អ្នកសាធារណរដ្ឋ ដើម្បីបោកប្រាស់ប្រើពួកសាធារណរដ្ឋ និងដើម្បីគំរាមអំណាចស្តេច។ ពោលគឺ វាបោកប្រាស់ខ្មែរយើងជារៀងរហូតមក យើងមិនត្រូវល្ងង់ខ្លៅដូចកន្លងមកឡើយ។ ហេតុដូច្នេះហើយ យើងត្រូវចេះបែងចែកមិត្ត និងសត្រូវ ហើយស្គាល់សត្រូវ អោយបានច្បាស់លាស់ និងកំណត់មិត្ត សត្រូវអោយបានជាក់លាក់ថា អ្នកណាជាសត្រូវស្លាប់រស់ អ្នកណា

ជាមិត្ត។ ការដោះស្រាយទំនាស់ ឬវិប្បត្តិត្រូវផ្អែកលើគោលការណ៍នេះ។ ទំនាស់រវាងបុគ្គលនិងបុគ្គល រវាងបក្សនយោបាយនិងបក្សនយោបាយ ដែលមាននិន្នា ការដូចគ្នា ត្រូវចាត់ទុកថា ជាទំនាស់ក្រុមគ្រួសារ ដែលអាចដោះស្រាយសំរុះសំរួលគ្នាបាន។ តែទំនាស់ រវាងសត្រូវនឹងយើង ជាទំនាស់ស្លាប់រស់ មិនអាចសំរុះសំរួលយោគយល់គ្នាបានឡើយ។ ឧទាហរណ៏រួចមក ហើយពួកអ្នកជាតិនិយម ទាំងរាជានិយម ទាំងសាធារណរដ្ឋមានការយល់ច្រឡំលើបញ្ហានេះ សុខចិត្តសំរុះសំរួលនាឆ្នាំ ១៩៩៣ ឱយពួកអាយ៉ង ហ៊ុន សែន, ជា ស៊ីម, ហេង សំរិន ដែល ចាញ់ឆ្នោតនោះ មានមុខមាត់ក្នុងរដ្ឋាភិបាល។ នៅទីបំផុត ពួកអាយ៉ង ហ៊ុន សែន, ជា ស៊ីម, ហេង សំរិន ពង្រឹងអំណាចបាន ហើយកាប់ សំលាប់អ្នកជាតិនិយមស្ទើគ្មានសល់ឡើយ។ យើងមិនត្រូវមានគំនិត សន្តិភាពនិយម ឬភ្លេចខ្លួនចំពោះមេរៀនដ៏ជូរចត់នេះឡើយ។ តើ យើង កំណត់មិត្ត និង សត្រូវដូចម្តេច?

ក-**សត្រូវស្លាប់រស់ របស់ខ្មែរ** (Decisive Enemy )គឺ យួន និងបក្សពួកក្បត់លក់ជាតិ លក់ទឹកដី បំផ្លិចបំផ្លាញ់ ផលប្រយោជន៏រាស្ត្រខ្មែរ ឆក់ប្លន់ដីធ្លីស្រែចំការ ភោគផលរបស់ខ្មែរ ទៅលក់អោយ យួន និងបរទេស កាប់សំលាប់ បំបិទសិទ្ធសេរីភាពខ្មែរ យ៉ាងសាហាវយង់ឃ្នង។ សត្រូវ បែបនេះ ជាសត្រូវស្លាប់រស់ មិនអាចសំរុះសំរួលគ្នាបានឡើយ។ បើយើងអនុគ្រោះវា ថ្ងៃនេះ ថ្ងៃមុខវានឹងសំលាប់យើង។

**ខ-សត្រូវបណ្តោះអាសន្ន** (Considerable Enemy)គឺ សមាជិករបស់បក្សប្រជាជន ដែលមាននិន្នាការជាតិនិយមតែសុខចិត្តនៅស្មៀមលាក់ខ្លួនដើម្បីសេចក្តីសុខ ឬដើម្បីផលប្រយោជន៏ផ្ទាល់ខ្លួន តែមិនធ្វើអោយខូចដល់ផលប្រយោជន៏ជាតិ ឬមិនធ្វើ អោយខូចខាតដល់កិច្ចការតស៊ូរបស់យើង។ សត្រូវបែបនេះ អាចនិយាយសំរុះសំរួលបាន។ តែនៅក្នុងកាលៈទេសៈនេះយើងមិន ត្រូវអោយគេដឹងកិច្ចការ របស់យើងជ្រៅឡើយ។ យើងត្រូវព្យាយាម អូសទាញអោយគេមានការភ្ញាក់រលឹកជាតិឡើងវិញ។ អោយគេចេះ ស្រឡាញ់ខ្មែរ ស្គាល់ច្បាស់ថា អ្នកណាជាសត្រូវរបស់ខ្មែរ អ្នកណាជាមិត្ត។

**គ-មិត្តរបស់យើង** គឺ ក្រុមបក្សនយោបាយទាំងឡាយ ដែលខ្វល់ខ្វាយពី ផលប្រយោជន៏ សុខទុក្ខ អាយុជីវិត ប្រជាជាតិ និង ពូជសាសន៏ខ្មែរ ពិតប្រាកដ។ យើងត្រូវដោះស្រាយទំនាស់ រវាងមិត្តនិងមិត្ត ដោយផ្អែកលើការសំរុះសំរួលអត់អោនលើក លែងយោគយល់គ្នា ក្នុងសង្គមជាតិខ្មែរតែមួយ ជាបងប្អូនរួមឈាម រួមលោហិតតែមួយ។ គណបក្សនយោបាយទាំងនោះ មាន គណបក្ស សមរង្ស៊ី គណបក្ស សិទ្ធមនុស្ស ពួកអតីតអ្នកតស៊ូជាតិនិយមចាស់ ជាដើម។ ទោះដូច្នេះក្តី ដើម្បីសុវត្តិភាព សន្តិសុខ និងការរីកចំរើន នៅក្នុងអង្គការនយោបាយតស៊ូរបស់យើង រាល់កិច្ចការសំងាត់ ទាំងឡាយ មិនត្រូវអោយគេដឹងដល់ជំរៅទូលំទូលាយដែរ។

## XII-ការដោះស្រាយទំនាស់ ឬវិប្បត្តិ:

មេដឹកនាំខ្មែរ ត្រូវចេះប្រមើលមើលនូវ លទ្ធភាពនៃវិប្បត្តិ ឬបញ្ហាដែលអាចកើតមាន ឱយបានមុនពេលបញ្ហា នោះកើតឡើង និងត្រូវហ៊ានប្រឈមមុខ ទំលុះទំលាយដោះស្រាយបញ្ហា ដែលកើតមានឡើង ដោយការប្តេជ្ញា ឱយបានល្អជូនប្រជាពលរដ្ឋខ្មែរ។ យើងមិនត្រូវរារែក អល់អែកដោយសារការយកគំនិតគ្មានហេតុផល មកជាទីអាងឡើយ។ តែផ្ទុយទៅវិញ យើងត្រូវប្រឹងប្រែងខ្នះខ្នែង រកបច្ច័យពិត មកថ្លឹងថ្លែង និងសំរេចចិត្តដោយសមហេតុផល ចាត់ការទាន់ពេលវេលា។

### -ការដោះស្រាយទំនាស់ផ្ទៃក្នុង

-ដើម្បីដោះស្រាយទំនាស់បានល្អ យើងមិនត្រូវយករឿង បុគ្គលមកឡូកឡំនឹងរឿងជាតិ ផលប្រយោជន៍អាយុ ជីវិតជាតិឡើយ។ សូមកុំភ្លេចថា យួនមានផែនការជាក់លាក់ក្នុងការសំលាប់ខ្មែរ តាមគ្រប់រូបភាព គ្រប់មធ្យោបាយ អោយរលោះរលត់ រលាយក្នុងរយះពេល ១៥ឆ្នាំ ខាងមុខនេះ។ វិធីសំលាប់ទាំងនោះ មានការប្រើប្រាស់ម្ហូបអាហារមានជាតិគីមី ការបង្ខំអោយងប់ងល់តែនឹងគ្រឿងស្រវឹង ដែលផលិតចេញពីសារធាតុគីមី (មេស្រាដែលយកមកពីយួន)ជាដើម។ ហេតុនេះហើយ យើងមិនត្រូវជួយយួន អោយសំរេចផែនការ ក្នុងការសំលាប់ខ្មែរ សំលាប់ជាតិយើង ដូចពួកអាយ៉ង ហ៊ុន សែន, ជា ស៊ីម, ហេង សំរិន ដែលកំពុងប្រព្រឹត្តសព្វថ្ងៃនេះឡើយ។ វិធីដោះស្រាយល្អបំផុត ត្រូវយកបញ្ហាអាយុជីវិតជាតិ អាយុជីវិតពូជសាសន៍ខ្មែរ មកជាគោល ជាកត្តាក្នុងការពិចារណា។ ត្រូវ ចាំជានិច្ចថា ទំនាស់ ចំពោះការស្លាប់រស់របស់ជាតិ ជាទំនាស់មិនអាចលើកលែងបាន ។ ឯទំនាស់ រវាងបុគ្គល និងបុគ្គលជាទំនាស់ក្រុម គ្រួសារ អាចដោះស្រាយក្នុងគោលការណ៍រួបរួម ក្នុងគោលការណ៍ជាបងប្អូនរួមឈាម។

## XIII-ប្រភេទនៃការដឹកនាំ (The Styles of Leadership)

- ការដឹកនាំបែបផ្តាច់ការ
- ការដឹកនាំបែបកុម្មុយនិស្ត
- ការដឹកនាំបែបប្រជាធិបតេយ្យ
- ការដឹកនាំបែបអនាធិបតេយ្យ

### ១-ការដឹកនាំបែបផ្តាច់ការ

មេដឹកនាំ ដែលមានមនុស្សតែម្នាក់មានអំណាច គ្របដណ្តប់លើមនុស្សទូទៅ លើការសំរេចកិច្ចការទាំងអស់។ មេដឹកនាំដែលមាន ការដឹកនាំបែបនេះ មិនផ្តោតការខ្វាយខ្វល់ខ្លាំងទៅលើមនុស្សទេ តែផ្តោតខ្វល់ខ្វាយលើការងារខ្លាំងជាង។ មេដឹកនាំបែបនេះ មិនមានទំនាក់ទំនងជាមួយ មនុស្ស និងសមាជិកទេ។ ការសំរេចចិត្តនៅលើម្នាក់ឯង មិនទទួលយក មតិយោបល់ពីអ្នកផង ឯអ្នកក្រោមបង្គាប់ រង់ចាំតែអនុវត្តន៍ផែនការ ប៉ុណ្ណោះ។ មេដឹកនាំផ្តាច់ការ ប្រើអំណាចបញ្ជាផ្តាច់ការចំពោះសមាជិក ហើយ ជួយផ្តល់ប្រាក់ ឧបត្ថម្ភតិចតួច ឬគ្មាន។ ពួកគេមានកាលវិភាគមួយ កំណត់ទុក ដាក់កំហិតធ្ងន់ធ្ងរ និងរំពឹងថាអ្នកក្រោមបង្គាប់ ធ្វើអ្វីដែលគេបានប្រាប់ដោយ គ្មានសំណួរ និងការពិភាក្សា។ ពេលមានកំហុស ពួកមេដឹកនាំបែប នេះផ្តោតលើការស្តីបន្ទោស ច្រើនជាងផ្តោតលើ ការកែកំហុស ឬប្រាប់ពីរបៀបការពារកំហុស។ មេដឹកនាំផ្តាច់ការ មិនអត់អោនចំពោះអ្នកប្រឆាំងឡើយ។ ដូច្នេះ វាជាការពិបាក ចំពោះអ្នកក្រោមបង្គាប់ ក្នុងការចូលរួមចំណែកជំរុញការងារអោយជឿនលឿន។ ការដឹកនាំបែបផ្តាច់ការ ប្រជាពលរដ្ឋគ្មានសិទ្ធិសេរីភាពទេ មានតែការ ដាក់ទោសទណ្ឌកម្ម ការធ្វើទុក្ខបុកម្នេញ និងការកាប់សំលាប់។ ដូចជាការដឹកនាំរបៀបផ្តាច់ការក្នុងរបប **ម៉ូ សូលីនី, អាដុល ហ៊ីត្លែ, លេ នីន, ស្តា លីន, ម៉ៅ សេទុង, ហូ ជីមិញ, សី ហនុ, (ប៉ុល ពត) និង ហ៊ុន សែន** ជាដើម។ល។

### លក្ខណៈមេដឹកនាំផ្តាច់ការ

- បញ្ជា ( មធ្យោបាយគ្រប់បែបយ៉ាងតាមបែបបង្ខំ)
- ប្រើអំណាច ឬកំលាំងដីកាចសាហាវជាមធ្យោបាយដោះស្រាយបញ្ហាសង្គម
- បដិសេធ ឬ កំបិទសិទ្ធិសេរីភាពមនុស្សទាំងស្រុង ហើយត្រួតពិនិត្យយ៉ាងតឹងរឹងទៅលើដំណើរការរស់នៅរបស់សង្គមមនុស្សគ្រប់ជ្រុងជ្រោយទាំងអស់ ។
- ប្រជាពលរដ្ឋ ជាទាសករ គ្មានអំណាចអ្វីទាំងអស់
- មិនអនុញ្ញាតអោយមាននយោបាយប្រឆាំង ។ បោសសំអាតគូរបដិបក្ស ។
- ដាក់ទណ្ឌកម្មចំពោះការធ្វើខុស សំលាប់អ្នកហ៊ានងើបប្រឆាំង និង បង្ក្រាបតាមគ្រប់វិធី
- ការសំរេចលើរដ្ឋាភិបាលទាំងស្រុងរាល់ដំណោះស្រាយនយោបាយ គ្មានការចូលរួមពីប្រជាពលរដ្ឋ

## ២_ការដឹកនាំបែបកុម្មុយនិស្ត

ការដឹកនាំបែបកុម្មុយនិស្ត អំណាចស្ថិតនៅលើដៃមនុស្សមួយក្រុមតូច ។ មនុស្សមួយក្រុមតូច ចេញពីថ្នាក់លើ ជាអ្នកសំរេចកិច្ចការទាំងឡាយ ។ ប្រជាពលរដ្ឋគ្មានសិទ្ធិសេរីភាពអ្វីទាំងអស់ ។ អំណាចស្ថិតនៅលើ រដ្ឋជាអ្នកកំណត់ ។ ជាក់ស្តែងនៅក្នុងប្រទេសខ្មែរបច្ចុប្បន្ន បក្សពួក **ហ៊ុន សែន** មិនដែលគិតពី ផលប្រយោជន៏ជាតិ និងប្រជាជាតិខ្មែរឡើយ ពួកវាគិតតែផលប្រយោជន៏បក្សពួកមួយក្តាប់តូច កៀបសង្កត់ជិះជាន់ប្រជាពលរដ្ឋទន់ខ្សោយ ដើម្បីអំណាចផ្ទាល់ខ្លួននិង បក្សពួកវា។ សូមប្រជាពលរដ្ឋខ្មែរ កុំយល់ច្រឡំថា ប្រទេសខ្មែរមានប្រជាធិបតេយ្យពិតប្រាកដ នេះគ្រាន់តែជារបៀបសេដ្ឋកិច្ចទីផ្សារសេរី តែមិនមែនជាប្រទេសប្រជាធិបតេយ្យពិតប្រាកដឡើយ ព្រោះថាអំណាចគ្រប់គ្រងប្រទេស ស្ថិតលើ ដៃ **ហ៊ុន សែន** តែម្នាក់ ។

### លក្ខណៈដឹកនាំបែបកុម្មុយនិស្ត

- អំណាចទាំងបី និតិបញ្ញត្តិ និតិប្រតិបត្តិ និងតុលាការ គ្មានឯករាជ្យ គឺ ស្ថិតនៅលើដៃមនុស្សតែម្នាក់ ។
- សារពត៌មានលំអៀង ទៅរកអ្នកមានអំណាច គ្មានឯករាជ្យ និង ផ្សាយពត៌មានមិនពិត ។
- ប្រជាពលរដ្ឋគ្មានសិទ្ធិសេរីភាព ត្រូវពួកមានអំណាចកៀបសង្កត់ជិះជាន់ បំបិទសិទ្ធិសេរីភាព ហាមឃាត់ បិទភ្នែក ខ្ទប់ត្រចៀក ចុកមាត់ ប្រជាពលរដ្ឋមិនអោយដឹង ឮ និយាយស្តីពីបញ្ហានយោបាយជាតិ សង្គម ។
- ការបោះឆ្នោតគ្មានយុត្តិធម៌ ជាការរៀបចំឆាកល្ខោនដើម្បីផលប្រយោជន៏អ្នកមានអំណាច ។
- ផលប្រយោជន៏ មានចំពោះតែ ក្រុមអ្នកមានអំណាចមួយក្តាប់តូច ។
- ការតាក់តែងច្បាប់ ដើម្បីការពារតែផលប្រយោជន៏របស់ បក្សពួក គ្រួសារបុគ្គលមានអំណាច ។
- ប្រជាពលរដ្ឋគ្មានការអប់រំខ្ពស់ និង គ្មានគុណភាព ដើម្បីងាយស្រួលអ្នកមានអំណាចបោកប្រាស់ ។
- ប្រជាពលរដ្ឋត្រូវ ក្រជាង ទន់ខ្សោយជាង ជាទាសករ ជាល្អងធូលីក្រោមបាតជើង អ្នកមានអំណាច ។
- អ្នកមានអំណាចមិនគោរពច្បាប់ ច្បាប់មានតែលើក្រដាស ច្បាប់សំរាប់ការពារតែផលប្រយោជន៏ អ្នកមានអំណាច ។
- អ្នកមានអំណាចច្រើនប្រើច្បាប់អាជ្ញាសឹក គំរាម សំឡុត សំលាប់ បើមានការតវ៉ាប្រឆាំង

- អ្នកដឹកនាំកាន់ អំណាចមួយជីវិត គ្មានកំណត់ ។

## ៣_ការដឹកនាំបែបអនាធិបតេយ្យ

ការដឹកនាំបែបអនាធិបតេយ្យ ជាការដឹកនាំ គ្មានទិសដៅ គ្មានគោលការណ៍ច្បាស់លាស់ គ្មានច្បាប់ទំលាប់ គ្មានយករបប នយោបាយណាច្បាស់លាស់ ។ មេដឹកនាំ ធ្វើការសំរេចចិត្តតាមទំនោរអារម្មណ៍ គ្មានផ្អែកលើគោលការណ៍អ្វីឡើយ ។ មេដឹកនាំមិនគិតគូរអំពី លទ្ធផលការងារ ហើយក៏គ្មានការលើកទឹកចិត្ត សមាជិកអោយធ្វើការងារទេ ធ្វើបានប៉ុណ្ណាយកប៉ុណ្ណឹង ។

### លក្ខណៈដឹកនាំអនាធិបតេយ្យ

- **គ្មានច្បាប់**
- មេដឹកនាំ ផ្តាច់ការ ធ្វើស្រេចតែទំនើងចិត្ត ។
- សង្គម ពោរពេញដោយអំពើអនាធិបតេយ្យ គ្មានសណ្តាប់ធ្នាប់ ។
- សង្គមពោរពេញដោយអំពើអយុត្តិធម៌ ជិជាន់សង្កត់សង្កិន ហុតឈាមអ្នកក្រីក្រស្លូតត្រង់ ។
- មេដឹកនាំ មិនយកចិត្តទុកដាក់ធ្វើការងារ និងមន្ត្រីជាចោរក្នុងស្ថាបន័ជាតិ ជាឈ្លើងហុតឈាមជាតិ ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋរស់ នៅអនាធិបតេយ្យ គ្មានមេដឹកនាំ គ្រប់គ្រង គ្មានអ្នកមើលខុសត្រូវ ។

## ៤_ការដឹកនាំបែបប្រជាធិបតេយ្យ

ការដឹកនាំបែបប្រជាធិបតេយ្យ ជាការដឹកនាំ ដែលយកប្រជាពលរដ្ឋ ជាធំ ។ មានការចូលរួមយ៉ាងទូលំទូលាយ ពីប្រជាពលរដ្ឋ (ដែលមានអាយុចាប់តាំងពី ១៨ ឡើងទៅ) លើការសំរេចកិច្ចការក្នុងសង្គមជាតិ ឯមេដឹកនាំគ្រាន់តែជា តំណាងអោយប្រជាពលរដ្ឋ ប៉ុណ្ណោះ ។ ការដឹកនាំតាមបែបប្រជាធិបតេយ្យ មានគោលការណ៍មួយចំនួនដូចតទៅ½

### លក្ខណៈដឹកនាំប្រជាធិបតេយ្យ

- ប្រជាពលរដ្ឋ មានសិទ្ធិក្នុងបង្កើតអង្គការដឹកនាំផ្សេងៗ
- ប្រជាពលរដ្ឋ មានសិទ្ធិបោះឆ្នោតដោយសេរី និង យុត្តិធម៌
- ការបោះឆ្នោត ដោយសេរី និង យុត្តិធម៌
- ប្រជាពលរដ្ឋ មានសិទ្ធិក្នុងការបញ្ចេញមតិយោបល់
- អំណាចទាំង ៣ សមតុល្យគ្នា មិនចំណុះអោយអំណាចណាមួយ និតិបញ្ញត្តិ និតិប្រតិបត្តិ និងតុលាការ
- ប្រជាពលរដ្ឋ មានសិទ្ធិឈរធ្វើជាមេដឹកនាំនយោបាយអោយគេបោះឆ្នោត
- ប្រព័ន្ធសារពតិមាន ឯករាជ្យ មិនលំអៀង ហើយផ្សព្វផ្សាយទូលំទូលាយដល់ប្រជាពលរដ្ឋ
- ប្រជាពលរដ្ឋ មានសិទ្ធិអប់រំដូចគ្នាៗ
- សង្គមមានលក្ខណៈចំហរ ប្រកាន់នយោបាយបើកចំហរ
- ច្បាប់ការពារអ្នកទន់ខ្សោយ និងការពារអ្នកមានឧត្តមគតិ នយោបាយស្មោះត្រង់ ។
- និយមប្រើគោលនយោបាយផ្សះផ្សារសង្គម




## វដ្តចក្រនៃមេដឹកនាំល្អ




## វដ្តចក្រនៃមេដឹកនាំមិនល្អ



ដូច វដ្តចក្រទាំងពីខាងលើនេះ យើងជាអ្នកដឹកនាំ មិនត្រូវយល់ច្រឡំ ប្រជាធិបតេយ្យ និងអនាធិបតេយ្យឡើយ ។ ត្រូវស្គាល់នូវអ្វីជាធាតុ ប្រជាធិបតេយ្យ និងអនាធិបតេយ្យ ។ របបត្រួតត្រាសព្វថ្ងៃជារបបផ្តាច់ការ អនាធិបតេយ្យ ដែលនឹង ធ្វើខ្មែរសង្គមជាតិខ្មែរ ត្រូវរលាយសាបសូន្យក្នុងពេលមិនយូរ ។

## XIV. កត្តាសំខាន់ៗដើម្បីធ្វើអោយការដឹកនាំមានប្រសិទ្ធភាព

### (The Key Elements of Effective Leadership)

ដើម្បីអោយការដឹកនាំមានប្រសិទ្ធភាព មេដឹកនាំ ត្រូវផ្អែកលើ កត្តាសំខាន់ៗ ជាច្រើនដូចជា ½

- ផ្តល់នូវការដឹកនាំមួយដែលមានរយៈពេលយូរ ធ្វើអោយច្បាស់លាស់ មានការចូលរួម និងគាំទ្រយ៉ាងស្ថិតស្ថេរ ទាំងបេសកកម្ម និងចក្ខុវិស័យពីអ្នកក្រោមបង្គាប់ ។
- អាទិភាពនៃការតែងតាំង និងតំឡើងមុខងារសមាជិក ដើម្បីអោយការងារមានប្រសិទ្ធភាពខ្ពស់½
  - O អ្នក***ស្មោះត្រង់បំផុត ចំពោះសង្គមជាតិ ប្រជាជាតិខ្មែរ*** នឹងអង្គការនយោបាយយើង
  - O អ្នក***សកម្មប្រយុទ្ធ***បំផុតក្នុងការងារ
  - O អ្នកមាន***វិន័យ គោរពបញ្ជាខ្ពស់***
  - O អ្នកមានស្មារតី***ក្លាហានមោះមុតស្រួច***ហ៊ាននិយាយ ហ៊ានធ្វើ
  - O អ្នកមានការ***លះបង់ដាច់ខាត***មិនគិតប្រយោជន៍ផ្ទាល់ខ្លួន មិនគិតមុខមាត់ខ្លួន ។
- គាំទ្រដល់សមាជិកទាំងអស់នៃអង្គការដឹកនាំ ដើម្បីអោយពួកគេអាចធ្វើការដោយមោទនភាព អប់រំ បណ្តុះបណ្តាល ធ្វើអោយមានអំណាច និងផ្តល់រង្វាន់ដល់អ្នកទាំងនោះ ។
- អោយតំលៃ ដោយការសហប្រតិបត្តិការ ការគិតជាប្រព័ន្ធ ជាការប្រសើរបំផុត
- បង្កើតបរិយាកាសនៅកន្លែងធ្វើការ ជាកន្លែងដែលមនុស្សចូលចិត្តការងារ
- ផ្តោតលើស្មារតី ស្នេហាជាតិពិត ផ្តល់តំលៃលើអ្នកក្រោមឱវាទ អោយតំលៃ លើគុណភាពការងារ និងលើគុណភាពសេវាកម្ម ដែលផុសចេញពីទស្សនៈរបស់ពួកគេ ។
- បង្កើតការទុកចិត្ត ហើយបំបាត់ការភ័យខ្លាច ។
- អាចបញ្ចេញនូវការយល់ឃើញ និងអាចចូលរួមក្នុងអង្គការដឹកនាំ ។
- ស្តាប់យ៉ាងប្រុងប្រយ័ត្ន និងពិចារណារឿងដទៃទៀត( កុំឆាប់ជឿពាក្យញុះញង់ ឬរិះគន់ផ្សេងៗ ) ។
- បន្តកសាងខ្លួនឯង អោយប្រសើរឡើង ទាំងខាងរាងកាយ ខាងប្រាជ្ញា ស្មារតី ។
- ដាក់ខ្លួនយ៉ាងសាមញ្ញ និងធ្វើអោយសមាជិកទាំងអស់នៃអង្គការដឹកនាំ ទទួលចំណែកលើផលនៃជោគជ័យ ។
- កាត់បន្ថយចំណាយផ្សេងៗ ជាផ្លូវសំរាប់អភិវឌ្ឍន៍គុណភាពការងារអោយប្រសើរឡើង ។

## XV. កត្តាដែលនាំអោយបរាជ័យ

កត្តាដែលនាំអោយបរាជ័យមាន :

- មេដឹកនាំមិនធ្វើជាគំរូនាំមុខ  កំសាក អាត្មានិយម គ្មានការទទួលខុសត្រូវ ត្រឡប់ត្រឡិន ស្នាក់ស្ទើ
- ខ្វះការប្តេជ្ញាចិត្ត ពីសមាជិកម្នាក់ៗ
- តែងតាំងមនុស្សគ្មានសមត្ថភាព គ្មានគោលការណ៍ក្នុងការតែងតាំង ។
- គ្មានទំនុកចិត្តគ្នាទៅវិញទៅមក
- គ្មានផែនការគ្រប់គ្រាន់ដើម្បីជោគជ័យ
- គិតតែកិច្ចការ ១ថ្ងៃ ទៅ ១ ថ្ងៃ មិនគិតពីកិច្ចការអនាគត
- គិតតែកិច្ចការអនាគត តែមិនគិតពីកិច្ចការពី ១ ថ្ងៃ ទៅ ១ ថ្ងៃ
- គ្មានការត្រៀមទុក ហ្វឹកហ្វឺន និង ធ្វើចលនាអោយរហ័ស
- គ្មានយុទ្ធសាស្រ្តដឹកនាំ គ្មានការដឹកនាំបែបប្រពន្ធ័
- មិនផ្តល់ពត៌មានទាន់ពេល នូវអ្វីដែលកើតឡើង និងមូលហេតុ ដល់សមាជិកនៃអង្គការដឹកនាំ
- បរាជ័យក្នុងការស្តាប់ និងធ្វើការជាមួយ មេដឹកនាំដែលមិនជឿក្នុងដំណើរការនេះ
- មិនហ៊ាននិយាយ **ខ្ញុំខុស  លោកត្រូវ**
- មិនទុកចិត្តគ្នា មិនហ៊ានប្រថុយប្រថាន
- បរាជ័យក្នុងការផ្លាស់ប្តូរសកម្មភាព និងគោលនយោបាយ
- មិនមានលទ្ធភាពបំបាត់ភាពភ័យខ្លាច
- បញ្ឈប់ការងារកណ្តាលទី

## XVI. អំពើអាក្រក់ ២២ ប្រការ ដែលមេដឹកនាំជាតិខ្មែរត្រូវចៀសវាង

**(Leaders should avoid 22 sins)**

### ១-ភូតកុហក  ប្រឌិតពត៌មាន

ការពិសោធន៏ក្នុងអតីតកាល ជាពិសេស ក្នុងរបបទាំង ៤ " សង្គមរាស្ត្រនិយម សាធារណរដ្ឋខ្មែរ របបកម្ពុជា ប្រជាធិបតេយ្យ ក្រុមអ្នកតស៊ូសេរី ទាំង២ក្រុម" បានបង្ហាញអោយឃើញថា ការបរាជ័យទាំងអស់ កើតចេញពីបច្ច័យមួយដ៏អាក្រក់ គឺ ការភូតភរកុហក ការប្រឌិតពត៌មានមិនពិត ការបំភ្លើសលទ្ធផលការងារ ។ បច្ច័យដ៏អាក្រក់នេះ បានធ្វើអោយការតស៊ូគ្រប់ជំនាន់ ត្រូវរងនូវការខូចខាតយ៉ាងធ្ងន់ធ្ងរ ។ ព្រោះថា នៅពេលដែល ថ្នាក់លើទទួលបាននូវរបាយការណ៏ ដែលមាន ការភូតភរកុហក ការប្រឌិតពត៌មានមិនពិត ការបំភ្លើសលទ្ធផលការងារ នាំឱ្យថ្នាក់លើធ្វើការវិភាគថ្លឹងថ្លែង និងសំរេចតាម របាយការណ៏មិនពិតទាំងនោះ ជាហេតុនាំឱ្យការសំរេចចិត្តនោះ ជាការសំរេចចិត្តខុស នាំឱ្យដល់នូវការបរាជ័យទាំងស្រុងដល់អង្គការនយោបាយទាំងមូល ។

ដូចរៀបរាប់ត្រួសៗមកខាងលើនេះ អ្នកដឹកនាំខ្មែរ មិនត្រូវឱ្យមាន ការភូតភរកុហក ការប្រឌិតពត៌មានមិនពិត ការបំភ្លើសលទ្ធផលការងារនេះទេ ។ ត្រូវធ្វើការដោយសេចក្តីស្មោះត្រង់ ហ៊ានទទួលខុសត្រូវចំពោះការបរាជ័យរបស់ខ្លួនដោយសុទ្ធចិត្ត ។ ជាធម្មតា គ្រប់គ្នាតែងតែជួបការបរាជ័យដោយចៀសមិនរួច ហើយអ្នកណាក៏មិនចង់ជួបការបរាជ័យឡើយ បើមិនច្រើន

ក៏តិច ។ ការហ៊ានទទួលយកនូវការបរាជ័យ មកដាក់ខ្លួនដោយមិនគេចវេស នឹងនាំមកឱ្យខ្លួនយើង ក្រុមរបស់យើងទទួលបាននូវការពិសោធន៍ និងអាចជាវិធានការន៍ដ៏ល្អមួយ ដើម្បីកុំឱ្យយើងជួបនូវកំហុសដ៏ដែល១នេះទៀត ។ ការលាក់បាំងនូវការបរាជ័យនេះហើយ ដែលញ៉ាំងឱ្យខ្មែរវេរ្វវញមកដូចសព្វថ្ងៃនេះ ព្រោះថា ស្តេចតែងលាក់បាំងបំភ្លៃការពិត ដោយខ្លាចគ្រួសាររបស់ខ្លួនអព្ភ័រអោន ជាហេតុធ្វើឱ្យខ្មែរសម័យក្រោយដើរជាន់កំហុសដដែល១នេះ ។

ក្នុងការជ្រើសរើសសមាជិក ការតំលើងឋានៈ យើងមិនត្រូវរើសយក មនុស្សដែលភូតភរកុហក ក្រឡេកក្រឡុក មកធ្វើការ ឬឱ្យមានតំនែងនាទីខ្ពង់ខ្ពស់ឡើយ ។

## ២-ខូះវិន័យខ្លួនឯង

មេដឹកនាំជាតិខ្មែរ ត្រូវជៀសវាងប្រការនេះអោយបាន ។ ចូរចាំថា ប្រជាពលរដ្ឋខ្មែរក្តី អ្នកស្នេហាជាតិខ្មែរដទៃទៀតក្តី តែងចាប់អារម្មណ៍លើ ទង្វើរបស់យើងជាមេដឹកនាំ ។ យើងត្រូវប្រុងប្រយត្ន័ លើឥរិយាបថទាំងអស់របស់យើង ដូចព្រះសង្ឃត្រូវប្រុងប្រយត្ន័លើឥរិយាបថប្រចាំថ្ងៃរបស់ព្រះអង្គដែរ ។ ឥរិយាបថទាំងនោះមាន½ ដេកដើរ ឈរ អង្គុយ ស៊ីចុក និយាយស្តី លេង សើច ស្លៀកពាក់ ។ល ។ អ្នកក្រោម បង្គាប់សង្កេតមើលចាប់តាំង ពីការស្លៀកពាក់របស់មេដឹកនាំ មានសណ្តាប់ ឬអត់ ។ មេដឹកនាំជាតិខ្មែរត្រូវធ្វើគំរូល្អ នាំមុខគេគ្រប់យ៉ាង ជាពិសេស ការប្រកាន់នូវ វិន័យផ្ទាល់ខ្លួន ។ វិន័យផ្ទាល់ខ្លួនទីនេះ សំដៅលើ ឥរិយាបថប្រចាំថ្ងៃរបស់យើងជាមេដឹកនាំជាតិខ្មែរ គឺ ការដេក ដើរ ឈរ អង្គុយ ស៊ីចុក និយាយស្តី លេង សើច ស្លៀកពាក់ និង ការប្រតិបត្តិមុខងាររបស់ខ្លួន ។ ជាពិសេសការនិយាយស្តី ត្រូវមានការទទួលខុសត្រូវ ប្រកបដោយភាពវិជ្ជមាន ជានិច្ច ពោល គឺ ត្រូវគិតគូរបញ្ហាប្រទេសជាតិគ្រប់វិនាទី គ្រប់កន្លែង ។ ព្យាយាមបណ្តុះឆន្ទៈប្រយុទ្ធ ឆន្ទះជាតិនិយម ដល់ប្រជាពលរដ្ឋខ្មែរទាំងអស់ អោយស្រឡាញ់ប្រទេសជាតិ ទឹកដី និងផលប្រយោជន៍ សង្គម ជនរួមជាតិខ្មែរ ។ ការគោរព ទៀងទាត់ពេលវេលា និងពាក្យពិតទៀងត្រង់ ក៏មានសារសំខាន់ យ៉ាងខ្លាំងផងដែរ សំរាប់យើងជាមេដឹកនាំជាតិខ្មែរ ។

## ៣-ប្រើការវិនិច្ឆ័យខ្សោយ

មេដឹកនាំមួយចំនួន បាត់បង់លទ្ធភាពដឹកនាំ ដោយសារតែការភ្លាត់ភ្លាំងនៅក្នុងការវិនិច្ឆ័យ អោយបានត្រឹមត្រូវ និងយុត្តិធម៌ ។ មុននឹងនិយាយអ្វីមួយ ត្រូវគិតពីផលប្រយោជន៍ជាតិខ្មែរជាធំ មិនត្រូវនិយាយញុះញង់ បង្អាក់ឆន្ទៈ ឬវាយប្រហារ ចំពោះ អ្នកស្នេហាជាតិដូចគ្នា ។ ប៉ុន្តែ មេដឹកនាំជាតិខ្មែរ មានតួរនាទីក្នុងការបង្រៀន បង្វឹក អប់រំ បណ្តុះបណ្តាល តាមគ្រប់មធ្យោយ ធ្វើយ៉ាងណា អោយខ្មែរចេះស្រឡាញ់គ្នា ឯកភាពគ្នា សាមគ្គីគ្នា ជាធ្លុងមួយ ជួយគ្នាទៅវិញទៅមក ដើម្បីជាតិខ្មែររស់ ។ មេដឹកនាំជាតិខ្មែរ មិនត្រូវសំរេចចិត្ត តាមអារម្មណ៍ឡើយ តែត្រូវសំរេចចិត្ត ផ្អែកតាមហេតុ ផល ពិត ។ មេដឹកនាំជាតិខ្មែរ ត្រូវគ្រប់គ្រង អារម្មណ៍ ខ្លួនឯងអោយបាន តែមិនត្រូវ បណ្តោយទុកអោយ អារម្មណ៍គ្រប់គ្រងសកម្មភាពខ្លួនឯងឡើយ ។

## ៤-តឹងរឹងពេក និងធូរលុងពេក

ការដឹកនាំ មិនត្រូវតឹងពេក ធូរពេក នោះឡើយ ។ ការដឹកនាំ ដែលធូរពេក តឹងពេក នឹងធ្វើឱ្យបញ្ហារបស់យើង គ្មានប្រសិទ្ធិភាព គ្មានការគោរព ប្រណិបត្តន៍តាមសោះឡើយ ។ ការដឹកនាំត្រូវធ្វើទៅ ក្នុង*ភាពស្មោះស្មើរលូន* (Consistency &

Smoothness) ។ ដូចនេះអ្នកដឹកនាំជាតិខ្មែរ ត្រូវយក វិន័យ ច្បាប់ ឬ បទបញ្ជាផ្ទៃក្នុង ជាគោលការណ៍ក្នុងការអនុវត្តនី ការងារ ។ ឯការរៀបចំចងក្រង វិន័យ ច្បាប់ ឬបទបញ្ជាផ្ទៃក្នុង ទៀតសោត ត្រូវប្រមើលថា តើ តឹងពេក ឬក៏ធូរពេក តើសមាជិកទាំងអស់អាច អនុវត្តបានទូរទៅឬទេ?

### ៥-មិនរួសរាយ មិនសេពគប់និងអ្នកដទៃ វាយឫកក្រអើតក្រទមរួតរាង

អ្នកដឹកនាំជាតិខ្មែរ មិនត្រូវឆ្មើងកន្ទ្រើង វាយឫកក្រអើតក្រទម ខ្វះការ រួសរាយរាក់ទាក់ ដាក់ខ្មែរទូទៅដូចគ្នាសោះឡើយ ។ អ្នកដឹកនាំជាតិខ្មែរ ត្រូវទទួលរាប់រកអ្នកផងជាជនរួមជាតិ ដោយការញញឹម ប្រើសំដីផ្អែមល្ហែម និងមាន ការយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមក ។ អ្នកដឹកនាំខ្មែរ ត្រូវបំផុសគំនិត រំលឹកជជែកគ្នាពីបញ្ហាជាតិ ដែលកំពុងប្រឈមមុខនឹងមហន្តរាយ ដោយសារចោរ **យួន** និងអាក្បត់ **ហ៊ុន សែន** ។

### ៦-ធ្វើច្រើន និងដឹកនាំតិចតួច

អ្នកដឹកនាំជាតិខ្មែរ ត្រូវចាំថា ជោគជ័យនៃការងារ អាស្រ័យដោយកំលាំងចូលរួមពីមនុស្សទូរទៅ យ៉ាងសកម្ម ក្លៀវក្លា ។ ហេតុនេះ ត្រូវដឹងថា ភារៈជាអ្នកដឹកនាំ មិនមែនចេះតែធ្វើការតែម្នាក់ឯង ដោយខ្វះការដឹកនាំនោះឡើយ ។ តែត្រូវចេះដឹកនាំ ឱ្យអ្នកក្រោម ឱ្យវាតចូលរួមធ្វើការងារ យ៉ាងសកម្មជាមួយខ្លួន ។ ម្យ៉ាងទៀត មិនត្រូវធ្វើការ ដើម្បីតែធ្វើ ឱ្យរវល់មិនឈប់ តែផលតិចតួច នោះឡើយ ។ ពួកកុម្មុយនិស្ត ដឹកនាំដោយពួកអាក្បត់ ហ៊ុន សែន សព្វថ្ងៃ វាច្រើនតែធ្វើតាមបែបល្ខោនកិច្ចការប៉ុនក្រចក តែពង្រីកបំប៉ោង ប៉ុនភ្នំ ហើយលទ្ធផលសឹងតែគ្មានប្រយោជន៍ទាល់តែសោះ ។

### ៧-ធ្វើឱ្យមានភាពអវិជ្ជមាន

អ្នកដឹកនាំខ្មែរ មិនត្រូវនិយាយអ្វី ធ្វើអ្វីក្នុងភាពអវិជ្ជមានសោះឡើយ ។ ដូចពោលរៀបរាប់ ខាងលើរួចមកហើយថា " *ទង្វើ ពាក្យសំដី ឥរិយាបថប្រចាំថ្ងៃ របស់យើងជាអ្នកដឹកនាំ ជះឥទ្ធិពលយ៉ាងខ្លាំងទៅលើ ការគិត ការនិយាយ ការអនុវត្ត និងឥរិយាបថប្រចាំថ្ងៃរបស់អ្នកក្រោមឱវាត*" ។ ហេតុនេះ មិនត្រូវលើកតំកើងអ្វីដែល នាំឱ្យ បាត់បង់លក្ខណៈ អត្តសញ្ញាជាខ្មែរ ឡើយ ។ ផ្ទុយទៅវិញ ត្រូវលើកតំកើងអត្តសញ្ញាណជាខ្មែរ អ្នកស្នេហាជាតិខ្មែរ បុព្វបុរសស្នេហាជាតិ វីរៈ បុរសស្នេហាជាតិ និង អ្នកប្រាជ្ញ ឬបណ្ឌិតខ្មែរ ។ ការសរសេរ ការនិយាយអ្វីៗដែលមានការទាក់ទឹងពាក្យថាខ្មែរ ទាំងបុព្វបទ ឬបច្ច័យ យើងត្រូវនិយាយថា ខ្មែរ ជានិច្ច ។ ឧទាហរណ៍ ប្រទេសខ្មែរ ទឹកដីខ្មែរ ប្រជាជាតិខ្មែរ ពលរដ្ឋខ្មែរ សញ្ជាតិខ្មែរ ជាតិខ្មែរ ជាដើម ។ល ។

ក្រៅពីនេះ មិនត្រូវនិយាយអ្វីដែលខ្វះការទទួលខុសត្រូវ ដែលនាំដល់ ការបាក់ទឹកចិត្ត ការបែកបាក់ និងការអស់សង្ឃឹម នៅក្នុងជួរអ្នកតស៊ូជាតិ ប្រជាជាតិ និងជនជាតិទាំងឡាយដែលកំពុងធ្វើការតស៊ូរំដោះពីក្រញ៉ាំដៃយួន ។

### ៨-ក្បត់ការសន្យា

អ្នកដឹកនាំខ្មែរ កុំធ្វើការសន្យាអ្វីដែលយើងមិនអាចធ្វើបាន ។ បើយើងដឹងថា យើងមិនអាចបំពេញការសន្យានោះបានទេ យើងមិនត្រូវសន្យាឡើយ ។ ផ្ទុយទៅវិញបើយើបបានជាសន្យាហើយ ត្រូវព្យាយាមធ្វើឱ្យបាន ។ បើបានជាសន្យាហួស ទៅ

ហើយ តែធ្វើមិនបាន មិនត្រូវខ្មាសសេចក្តីក្លាហាន ក្នុងការពោលពាក្យថា " *ខ្ញុំសុំទោស ខ្ញុំបានខំប្រឹងប្រែងធ្វើអស់ពីសមត្ថភាព ហើយ តែធ្វើមិនបាន* " ។ ការធ្វើដូចនេះនឹងធ្វើឱ្យយើងរក្សាភាពជឿជាក់ និងទំនុកចិត្តពីអ្នកក្រោម បង្គាប់បាន ។

### ៩ -មិនត្រូវដោះសារយករួចខ្លួន

បញ្ហាដែលយើងដាក់ឱ្យអ្នកក្រោមធ្វើហើយ បើជួបនូវការបរាជ័យ ត្រូវហ៊ានទទួលថា នោះជាកំហុសរបស់យើងខ្លួនឯង មិនត្រូវឆ្លើយដោះសារយករួចខ្លួនឡើយ ។ ឬបើយើងប្រាប់នរណាម្នាក់ អោយធ្វើអ្វីមួយ យើងត្រូវរក្សាគោលបំណងរបស់យើងអោយនៅក្នុងអាទិភាពខ្ពស់ ដើម្បីជា ទំនុក ចិត្តរវាងយើង និងអ្នកក្រោមឱវាត ។ មិនត្រូវផ្លាស់ប្តូរត្រឡប់ត្រឡិនសោះឡើយ ។

### ១០ -គុំគួន ច្រណែន និងឈ្នានីស

យើងជាអ្នកដឹកនាំ មិនត្រូវច្រណែននឹងការរីកចំរើនរបស់អ្នកផង សោះឡើយ ។ ផ្ទុយទៅវិញ ត្រូវអបអរសាទរដោយភាពស្មោះសរ នឹងជោគជ័យរបស់អ្នកផង ។ លើសពីនេះទៅទៀត មិនត្រូវគុំគួនដោយ សារតែការទាស់ទែងបន្តិចបន្តួច ឬដោយសារ ការឈ្លោះប្រកែកគ្នាព្រោះតែរឿងតូចតាច ដូចជារឿងផ្ទាល់ខ្លួន ស្រី ស្រា ជាដើមនោះឡើយ ។ ផ្ទុយទៅវិញ ត្រូវចេះអត់អោនលើកលែងទោសចំពោះកំហុសឆ្គងរបស់អ្នកក្រោមឱវាត ដែលបានប្រព្រឹត្តខុស ។ បើយើងមានបញ្ហា ត្រូវនាំគ្នាអង្គុយជជែក ដោះស្រាយបញ្ហាដោយសន្តិវិធី ។ អ្នកដឹកនាំខ្មែរ មិនត្រូវគុំគួន ច្រណែននិន្ទា ឈ្នានិះ ឡើយ ។

### ១១ -កិច្ចការកំប៉ិកកំប៉ុក

យើងជាអ្នកដឹកនាំ មិនត្រូវគិតគូរបញ្ហាតូចតាច ជាបញ្ហាធំ ដោយសារចិត្តចង្អៀត អាត្មានិយម ឬគិតគូរក្រុម គ្រួសារនោះឡើយ ។ ត្រូវតំកល់ផលប្រយោជន៍ជាតិ ផលប្រយោជន៍ខ្មែរ ជាធំ ជាចំបងខ្ពង់ ។ មិនត្រូវមានចរិត រញ៉េរញ៉ៃ សន្សំរឿងដោយសារតែរឿងកំប៉ិកកំប៉ុកសោះឡើយ ។

### ១២ -បរាជ័យក្នុងការជ្រើសរើសបុគ្គលិកដែលមានប្រសិទ្ធភាព

អ្នកដឹកនាំជាតិខ្មែរ ត្រូវដឹងថា មនុស្សដែលនៅជុំវិញមានសារៈសំខាន់ណាស់ ក្នុងការជំរុញការងារឱ្យរីកចំរើនឆ្ពោះទៅរកជោគជ័យ ។ ហេតុនេះហើយ ការជ្រើសរើស តែងតាំងមនុស្ស ត្រូវរើសមនុស្សដែលមានលក្ខណៈសម្បត្តិត្រឹមត្រូវតាមគោលការណ៍រួមដែលបានកំណត់ ។ ជាពិសេស ត្រូវជ្រើសតែងតាំង ជនទាំងឡាយជាខ្មែរអ្នកស្នេហាជាតិពិតប្រាកដ មានសមត្ថភាពខ្ពង់ខ្ពស់ មានភាពស្មោះត្រង់ចំពោះជាតិ ប្រជាជាតិខ្មែរ មិនប្រែប្រួលផ្លាស់ប្តូរ និងប្តេជ្ញាចិត្ត ធ្វើកិច្ចការឱ្យបានជោគ ជ័យ ។

### ១៣ -គ្មានលទ្ធភាពគិតជាយុទ្ធសាស្ត្រ

ការវាយឫកពារខ្ពស់ គិតតែប្រយោជន៍ផ្ទាល់ខ្លួនហួសហេតុ នឹងធ្វើអោយយើងជាអ្នកដឹកនាំ គ្មានលទ្ធភាពដឹកនាំគេបានឡើយ ។ ព្រោះ ភាពត្រអើតក្រទម កំណាញ់ស្វិត លើការលះបង់ ទ្រព្យធន ពេលវេលា លើការជួយជ្រោមជ្រែងជួយអ្នកដទៃ មិនអាចធ្វើអោយយើងមានទំនាក់ទំនងល្អប្រសើរជាមួយមជ្ឍដ្ឋានខាងក្រៅបានឡើយ ។ ជាពិសេស បើគេគ្មានការគោរពស្រឡាញ់ រាប់អានមកលើយើងទេនោះ គេនឹងមិនស្តាប់យើងឡើយ ។ ត្រូវចាំថា បើយើងគ្មានអ្នកជុំវិញខ្លួនជួយជ្រោមជ្រែងដើរតាមយើងទេ យើងមិនអាចរៀបចំ យុទ្ធសាស្ត្រសំខាន់ក្នុងការងារធំដុំបានឡើយ ។

ហេតុនេះហើយ យើងជាមេដឹកនាំត្រូវមានគោលការណ៍ សំរាប់ទាក់ទង ជាមួយអ្នកស្នេហាជាតិខ្មែរដទៃទៀត ដើម្បីអោយគេអនុវត្តតាម។ អ្នកដឹកនាំខ្មែរ ជាអ្នកដើរបង្រៀន ជាគ្រូបង្វឹក ជាអ្នកបណ្តុះបណ្តាល ដល់ប្រជាជាតិខ្មែរ អោយស្គាល់ប្រវត្តិសាស្ត្រខ្មែរពិត ប្រាកដ  អោយចេះរបៀបដឹកនាំ និងចេះយុទ្ធសាស្ត្រផ្សេងៗ ចេះបណ្តុះឆន្ទៈស្នេហាជាតិ និងជាដឹកនាំប្រយុទ្ធ តាមគ្រប់រូបភាព។

### ១៤-គ្មានឆន្ទៈ និងសម្របតាមមនុស្សដែលមានឥរិយាបថផ្សេងៗ

អ្នកដឹកនាំជាតិខ្មែរ ត្រូវតែមានឥរិយាបថវិជ្ជមាន ជានិច្ច និងត្រូវចេះបត់បែនទៅតាមកាលទេសៈពេលវេលា នៅចំពោះមុខជំពូកជនផ្សេងៗ ដែលមានឥរិយាបថផ្សេងពីយើង។ មិនត្រូវធ្វើអ្វីឱ្យមានការទាស់អធ្យាស្រ័យចំពោះអ្នកដែលយើងធ្វើការប្រាស្រយ័ទាក់ទង។ បើពុំនោះទេ យើងនឹងមិនអាចអូសទាញ បញ្ចុះបញ្ចូលឱ្យគេដើរតាមយើងបានឡើយ។ ភាព ទន់ភ្លន់បត់បែន មិនមែនបានន័យថា យើងត្រូវអូសគេអូសទាញបានឡើយ។ តែចាំបាច់យើងនៅចងចាំប្រកាន់គោលការណ៍របស់យើងជាប់ជានិច្ច ថាជាអ្វី ហើយយើងធ្វើនោះ ដើម្បីអ្វី។

### ១៥-ការឆ្លុះបញ្ចាំងឥរិយាបថ អ្នកដឹកនាំ ចំពោះគោលនយោបាយ និង និតិវិធី

គោលការណ៍ទាំងឡាយ ដែលអ្នកដឹកនាំ បានកំណត់ហើយ អ្នកដឹកនាំ ត្រូវប្រណិតន៏មុនគេ។ ការដឹកនាំ នាំមុខ ធ្វើនឹងធ្វើឱ្យអ្នកក្រោម ប្រណិបត្តន៏តាម។ គេអាចមើលឃើញថា ឥរិយាបថ និងអាកប្បកិរិយា របស់អ្នកនៅក្រោមបង្គាប់ យ៉ាងណា នឹងអាចជាកញ្ចក់ឆ្លុះបញ្ចាំងពី ឥរិយាបថ និងអាកប្បកិរិយា របស់អ្នកដឹកនាំបានយ៉ាងប្រាកដ។ បើអ្នកដឹកនាំ ចូលចិត្ត ផឹកស្រា ក្រុមនោះនឹងមានសមាជិកចូលចិត្តផឹកស្រា បើអ្នកដឹកនាំ ជាអ្នកពុករលួយ ក្រុមនោះមានសមាជិក ច្រើនជាអ្នកពុករលួយ ខ្វះភាពស្មោះត្រង់។ ហេតុដូច្នេះហើយ ដើម្បីឱ្យគោលការណ៍ដឹកនាំទាំងឡាយ ត្រូវបានអនុវត្តយ៉ាងទូលំទូលាយខ្ជាប់ខ្ជួន អ្នកដឹកនាំ ត្រូវប្រុងប្រយត្ន័ មិនត្រូវធ្វើឱ្យខុសពីគោលការណ៍រួមឡើយ។ ឧទាហរណ៍ បើគោលការណ៍រួមបានកំណត់ដោយពេញចិត្តគ្រប់គ្នាថា ត្រូវតែលើកដំកើងអត្តសញ្ញាណខ្មែរ ហេតុនេះអ្នកដឹកនាំ មិនត្រូវនិយាយសំដៅលើពាក្យ *សូន្យ* ថាជា*ហ្សេរ៉ូ* (Zero) ឡើយ ក្នុងការនិយាយទាក់ទងទូទៅ។ ម្យ៉ាងទៀត ការសរសេរលេខ ក្តីគួរប្រើលេខ ខ្មែរ ជាផ្លូវការ យើងមិនគួរប្រើ លេខឡាតាំង ជំនួសលេខខ្មែរឡើយ។ ព្រោះថា ការនិយាយ ការសរសេរដូចបានរៀបរាប់មកនេះ ជាការព្យាយាមលប់អត្តសញ្ញាណខ្មែរដោយខ្លួនឯង ហើយបើយើងនៅតែអនុវត្តបែបនេះ តទៅមុខកូនខ្មែរជំនាន់ក្រោយនឹងលែងស្គាល់អ្វីជាខ្មែរឡើយ។ លើសពីនេះ សៀម វានឹងដណ្តើមថា លេខនេះជាលេខរបស់វាយ៉ាងប្រាកដ (ព្រោះសៀម ក៏ប្រើលេខនេះជា លេខ សៀមដែរ)។

### ១៦-បង្កើតព្រំដែនមិនច្បាស់លាស់

អ្នកដឹកនាំ ត្រូវបែងចែកតួនាទី និងភារះកិច្ចអោយច្បាស់លាស់ ត្រូវដឹងថា តើមេដឹកនាំត្រូវធ្វើអ្វីខ្លះ ហើយតើអ្នកក្រោមបង្គាប់ ត្រូវមានតួនាទី និងភារះធ្វើអ្វីខ្លះ។ ពោល គឺត្រូវមាន ដែនកំណត់នៃការសំរេចចិត្ត និងការបញ្ជាឱ្យបាន ជាក់លាក់។ ការគំណត់ព្រំដែនមិនច្បាស់លាស់ នាំឱ្យមានការបំពានលើមុខងារគ្នា ជាហេតុនាំឱ្យមានទំនាស់ផ្ទៃក្នុង។

## ១៧-ឧកខានធ្វើកិច្ចការចាំបាច់

មេដឹកនាំ ត្រូវចេះចាត់អោយមានអទិភាពក្នុងការងារ ហើយជ្រើសយកការងារដែលមាន អទិភាពខ្ពស់ជាងគេ ដែលចាំបាច់សំរាប់ជាតិខ្មែរទាំងមូលមកដោះស្រាយមុនគេ។ ដូចជា ការស្លាប់រស់ របស់ពូជសាសន៍ខ្មែរ ការបាត់បង់ទឹកដីទាំងមូល ជនអន្តោប្រវេសន្តយួន ប្រទេសខ្មែរក្រោមអណានិគមន៍យួនបែបថ្មី ប្រជាពលរដ្ឋក្រីក្រ អំពើពុករលួយ អយុត្តិធមិ ជា ដើម។

## ១៨-ផ្តល់ជំបូន្មានផ្ទាល់ខ្លួន

ចូរកុំផ្តល់ដំបូន្មានផ្ទាល់ខ្លួន ដែលប្រាសចាកពីគោលការណ៏រួម ដល់សមាជិក ទូទៅ។ បើសិនជាចាំបាច់ អ្នកដឹកនាំ ត្រូវលើកទឹកចិត្ត សសើរ និងកែតំរូវ ដល់អ្នកក្រោមបង្គាប់ ពេលដែលអ្នកក្រោមបង្គាប់ធ្វើខុស។ ប៉ុន្តែអ្នកដឹកនាំជាតិខ្មែរ គួរតែទុកដំបូន្មាន ផ្តល់អោយអ្នកស្រឡាញ់វិញ។ លើសពីនេះ ត្រូវទុកឱកាសឱ្យអ្នកក្រោមឱវាតមានលទ្ធភាពបញ្ចេញយោបល់ ឬបកស្រាយការពិតផង។ មិនត្រូវចាត់ទុកគំនិតយោបល់អ្នកក្រោម ជាគំនិតមិនបានការឱ្យសោះ។ មិនត្រូវ សំដែងការបដិសេធចំពោះគំនិតយោបល់របស់អ្នកក្រោមឡើយ តែត្រូវយកគំនិតយោបល់នោះ មកពិចារណារកផលចំណេញយ៉ាងហោច ត្រូវរក្សាការស្ងៀមស្ងាត់ទុកក្នុងចិត្ត ដើម្បីជាការលើកទឹកចិត្ត អោយអ្នក ក្រោមមាន ទឹកចិត្ត ក្នុងការបញ្ចេញគំនិត ឬការរក្សាការផ្តួចផ្តើមគំនិត។

## ១៩-ការយល់ច្រឡំន័យ នៃពាក្យប្រជាធិបតេយ្យ និងអនាធិបតេយ្យ

ត្រូវចងចាំថា សិទ្ធិក្នុងការបញ្ចេញយោបល់ និងគោលការណ៏ មានព្រំដែនខុសគ្នា។ ក្នុងគោលការណ៏ប្រជាធិបតេយ្យ សមាជិកទាំងអស់ មានសិទ្ធបញ្ចេញគំនិតយោបល់ ។ ឯគំនិតម្នាក់ៗ ត្រូវបានយកមកត្រេះរិះពិចារណាថ្លឹងថ្លែងពិភាក្សា នៅពេល ដែលកិច្ចការ មួយទើប បានចាប់ផ្តើមរៀបចំពិភាក្សាឡើង។ នៅពេលដែល គំនិតទូទៅ ត្រូវបានចំរាញ់ផ្តុំឱ្យទៅជាគោលការណ៏ហើយនោះ គោលការណ៏នោះនឹងក្លាយទៅជាគោលគំនិតរួម គោលការណ៏រួម ដែលសមាជិកទាំងអស់ ត្រូវគោរពប្រតិបត្តិតាមទាំងអស់គ្នា។ ពេលមកដល់ត្រឹមនេះ គំនិត មនុស្សម្នាក់ មិនអាចយកមកធ្វើជាគោល អាចបង្វិលបង្វែរ គោលការណ៏រួមបានឡើយ។

ហេតុនេះ ក្នុងឋានៈជាអ្នកដឹកនាំ មិនត្រូវយកគំនិតបុគ្គលមកបង្វិលគោលការណ៏រួមបានឡើយ។ ឯគោលការណ៏រួមទៀតសោត បើត្រូវបុគ្គលម្នាក់បង្វិលបាន ពេលនោះ ស្ថាបន័ទាំងមូលនឹងក្លាយទៅជាអនាធិបតេយ្យ ធ្វើឱ្យមានភាពច្របូកច្របល់ក្នុងក្រុមជាក់ជាមិនខាន។ ហេតុនេះមិនគួរ ឱ្យមានហេតុបែបនេះកើតមានឡើយ។

## ២០-មហិច្ឆតា

អ្នកដឹកនាំខ្មែរ មិនត្រូវមានចិត្តលោភលន់ អំណាច យសសក្តិ ទ្រព្យសំភារះ ស្រី ស្រា ព្រោះតែតណ្ហាផ្ទាល់ខ្លួននោះឡើយ។ តែមេដឹកនាំជាតិខ្មែរ ត្រូវតែមានមហិច្ឆិតាខ្ពស់ ក្នុងការធ្វើកិច្ចការ ធ្វើប្រយោជន៏ជូនជាតិ និងប្រជាជាតិខ្មែរពិតៗ។ ឧទាហរណ៏ អ្នកល្មោភស៊ី និងល្មោភ សង្គ្រាម ។ អ្នកល្មោភស៊ី ជាទូរទៅរមែង តែងតែមានសាច់ឈាម ធាត់ធំ។ ឯអ្នកល្មោភសង្គ្រាមវិញ រមែងមានទឹកដីធំល្វឹង ល្វើយ។

សម័យចក្រភពខ្មែរមហានគរ អ្នកដឹកនាំខ្មែរតែង មានមហិច្ឆិតាធំធេង ដោយការសាងឧត្តមភាពជាតិ មិនដែលយល់ព្រម ឬធ្វើព្រងើយកន្តើយឱ្យបរទេសរំលោភឈ្លានពាន ទោះក្នុងរូបភាពបែបណាឡើយ។ ឯពួកមេត្រួតត្រាដែលបន្ទុបដោយបរទេស នាសម័យក្រោយអង្គរ តែងតែបន្ទុះគំនិតកំសាក ដោយអប់រំយុវជន ជំនាន់ក្រោយថា " *មិនបាច់គិតទេ ទឹកដីដែលបាត់បង់* " ឬក៏ថា " *ទឹកដីទាំងនោះ ស្តេចកាត់អោយគេទេ មិនមែនជាកំហុសរបស់យើងឡើយ យើងមិនបាច់គិតគូរឈឺចាប់ទេ នាំអោយប៉ះពាល់ដល់មិត្តភាព* "។ ទាំងនេះជាគំនិតអាយ៉ង គំនិតកំសាកលក់ជាតិ គ្មានមនសិការជាមនុស្សសោះឡើយ។ បើទោះបីជាយើងមិនអាចទាមទារវិញក៏ដោយ ក៏គង់យើងត្រូវបង្រៀនកូនចៅជំនាន់ក្រោយកុំអោយដើរជាន់ដាន ចាស់ ទៀត។ យ៉ាងណាក៏ដោយយើងគួរខ្មាស់ខ្លួនឯងថា "***យួន សៀម ជាចោរជាយដែនចិនសោះ គង់ចិញ្ចឹមចិត្តយកដីខ្មែរ ចំប៉ា អស់គ្មានសល់ ចុះយើងជាខ្មែរ ជាពូជដើមរបស់មនុស្ស មានអាយុជាង ១0000ម៉ឺនឆ្នាំហើយនោះ សុខចិត្តអោយបាត់បង់ ពូជសាសន៍ខ្មែរ នាសម័យនេះឬ ?*** " ។

### ២១-ទុកអោយតំណែង ជាអ្នកដឹកនាំមនុស្ស

ការដឹកនាំ មិនលំបាកពេកនោះទេ បើយើងហ្វឹកហាត់ធ្វើ អោយបានសំរេចតាមមេរៀន។ ប៉ុន្តែសំរាប់ឥឡូវនេះ ការទទួលខុសត្រូវចំពោះមហន្តរាយចំពោះខ្មែរ ត្រូវធ្លាក់មកលើ យើងជាអ្នកស្នេហាជាតិទាំងអស់គ្នា និងជាក្តីសង្ឃឹមនៃពលរដ្ឋខ្មែរទូទៅ។ មេដឹកនាំជាតិខ្មែរទាំងអស់ មិនត្រូវធ្វើអោយខ្មែរទាំងអស់ អស់សង្ឃឹមទេ តែត្រូវដឹកនាំអោយរីកចំរើន ល្អជាងមុនមានស្ថិតស្ថេរ សន្តិភាព ឯករាជ្យភាព ឥស្សរភាព និងមានប្រជាធិបតេយ្យពិតប្រាកដ។ មិនមែនយកតែអំណាច តំណែង ហើយគ្មានលទ្ធផលការងារល្អ រីកចំរើនជូនជាតិខ្មែរនោះទេ។

### ២២-មានសុភវិនិច្ឆ័យចំពោះតំរូវការអ្នកដទៃ

ត្រូវយល់អោយច្បាស់អំពីតំរូវការរបស់ប្រជាពលរដ្ឋ ឬតំរូវការអ្នកក្រោមឱវាត។ មេដឹកនាំជាតិខ្មែរ ត្រូវមានយុត្តិធម៌ ត្រូវមានការខ្នះខ្នែង ស្វះស្វែងរកមក បំពេញតំរូវការប្រជាពលរដ្ឋខ្មែរ និងផ្តល់ឱកាស អោយខ្មែរ ចូលរួម ចំណែកដើម្បីកិច្ចការដ៏ចំបងក្នុងការរំដោះ នេះ។

## " កើតជាខ្មែរ ស៊ូរស់ដើម្បីខ្មែរ ពេញចិត្តស្លាប់ដើម្បីខ្មែរ"

**"របបវាលពិឃាត ប៉ុល ពត និង ៧មករា កើតឡើងដោយសារយួនជាអ្នករៀបចំបង្កើតឯអង្គការនយោបាយនិងកងទ័ពរបប ប៉ុល ពត ត្រូវបានយួនរំលាយឱ្យរលាយទៅហើយមិនអាចកើតឡើងទៀតទេ តែសេចក្តីស្លាប់ចំពោះមុខរបស់ ខ្មែរ គឺ នយោបាយត្រជាក់របស់យួន មិនមែនរបប ប៉ុល ពត ទៀតឡើយ"។**

# ឯកសារយោង


១- ព្រះបាទធម្មិក (ធម្មបណ្ឌិត ហេង មន្ទីចិន្តា)

២- យុទ្ធសាស្ត្រទឹក អ្នកស្នេហាជាតិខ្មែរ បណ្ឌិត ស ធម្មរង្សី

៣- វិទ្យាសាស្ត្រនយោបាយ (បណ្ឌិត ឈុន ណារ៉េត )

៤- ទស្សនៈវិជ្ជានយោបាយ (សាស្ត្រាចារ្យ ទៀត ណារិទ្ធ)

៥- ប្រវត្តិសាស្ត្រនយោបាយ (បណ្ឌិត ណារ៉ាញ់ គីរីទិត្យ)

៦- នណាជាឃាតករ (ហ៊ុន ស៊ីថាន)

៧- ជំងឺកម្ពុជា (ប្រែសម្រួលដោយ ទីឃាយុ)

៨- ប្រវត្តិសាស្ត្រខ្មែរ (ដេវិឌ឴ ឆាណ្ឌល័រ)

៩- វិបត្តិកម្ពុជា (សៅ ឆាត)

១០-វចនានុក្រមខ្មែរ សម្តេចសង្ឃ ជួន ណាត

១០- Headquarters, Department of the army. (June 1987). *Leadership and Command at Senior Levels.*

១១- Donald G. Krause. (1995). *Sun Tzu : The Art of War for Executives*.

១២- The art of Leadership

១៣- The Sun Sue strategy

*១៤-* Harry G.Summers Jr. *Colonel of Infantry On Strategies, a critical analysis of the Vietnam War.*

១៥- The Film of Sam Kok story

16- Bass, Bernard (1989). *Stogdill's Handbook of Leadership: A Survey of Theory and Research*. New York: Free Press.

17-Bass, Bernard (1990). *From transactional to transformational leadership: learning to share the vision*. *Organizational Dynamics*, Vol. 18, Issue 3, Winter, 1990, 19-31.

18-Blake, Robert R. and Mouton, Janse S. (1985). *The Managerial Grid III: The Key to Leadership Excellence.* Houston: Gulf Publishing Co.

19-Bolman, L. and Deal, T. (1991). *Reframing Organizations*. San Francisco: Jossey-Bass.

20-Kouzes, James M. & Posner, Barry Z. (1987). *The Leadership Challenge*. San Francisco: Jossey-Bass.

21-U.S. Army Handbook (1973). *Military Leadership.*

22- Dr.Philip Kotler. (1993). *Marketing Management.*

23- Edurado M. Arroya & Associates. *Making the leader*

24- Cometitive in new millionium, By Eduadro M.Arroyo